# វិបស្សនាន័យ

## ភាគទី ២

ព្រះសោភណមហាថេរ ( មហាស៊ីស្យាដវ ) រចនា

## "អគ្គមហាបណ្ឌិត"

ប្រមូលរៀបរៀងដោយ

## សមាគមសមណាវាសី

ពុទ្ធសករាជ ២៥៥២

# វិបស្សនាន័យ

## ភាគទី២

យោ ធម្មំ បស្សតិ សោ មំ បស្សតិ



បុគ្គលណាឃើញធម៌ បុគ្គលនោះឃើញតថាគត

ប្រមូលរៀបរៀងដោយ

សមាគមសមណវាសី

សម្រាប់ចែកជាធម្មទាន

# មាតិកាធម៌

## " ក្នុងសៀវភៅវិបស្សនាន័យភាគ ទី ២ "

លេខរៀង ទំព័រ

អារម្ភកថា ... ... ... .... ... ... .... .... .... ..... ..... ..... .... ......(៧)

អក្សរសង្ខេបឈ្មោះគម្ពីរ ... .... .... ... ... ... ... .... ... ..(១១)

អនុមោទនាជោតិកថា ... ... ... ... ... ... ... ... ... .... ....(១៧)

រតនប្បណាមគាថា .... ... ... ... .... ... .... .... .... ... ....(១៩)

## I. បរិច្ឆេទទី ៥

ក្រសែផ្លូវសោឡសញាណ .... .... .... .... .... .... .... .... ...១

ការកំណត់ដឹងថ្នាក់មូលដ្ឋាន .... .... .... .... .... .... .... ...... ៧

វិធីផ្តើមរយៈពេលនៃការកំណត់ដឹង .... .... .... .... .... ......២៧

សរុបវិធីបដិបត្តិ .... .... .... .... .... .... .... .... .... .... .....៣២

វិធីកំណត់ដឹងយ៉ាងបន្តបន្ទាប់ .... .... .... .... .... .... ... ....៣៣

វិធីផ្តើមអារម្មណ៍នៃការកំណត់ដឹង .... .... .... .... .... .... ..៥៩

ការពន្លុះព្រះនិព្វាន ... .... .... .... .... .... ... .... .... .... ....៧៥

ការចូលផលសមាបត្តិ.... .... .... .... .... .... .... .... .... ..៨១
ការសារឡើងវិញនូវលំដាប់ញាណ.... .... .... .... .... ... .៨៥
ការបដិបត្តិដើម្បីពន្ទុះមគ្គផលជាន់ខ្ពស់....... .... .... .... ....៨៨
គន្លងផ្លូវបដិបត្តិ និងការឃើញប្រចក្សច្បាស់ដោយបញ្ញា-
ក្នុងសកទាគាមិផល.... .... .... .... .... .... .... .... .... .....៩០
គន្លងផ្លូវបដិបត្តិ និងការឃើញប្រចក្សច្បាស់ដោយបញ្ញា-
ក្នុងអនាគាមិផល.... .... .... .... .... .... .... .... .... ..... ..៩១
គន្លងផ្លូវបដិបត្តិ និងការឃើញប្រចក្សច្បាស់ដោយបញ្ញា-
ក្នុងអរហត្តផល.... .... .... .... .... .... .... .... .... ..... ....៩២
ពាក្យណែនាំ.... .... .... .... .... .... .... .... .... .... .... ..១០៥

## II. បរិច្ឆេទទី ៦

បរិច្ឆេទទី ៦ សោឡសញាណ.... .... .... .... .... .... ....១០៨
ញាណទី១ នាមរូបបរិច្ឆេទញាណ.... .... .... .... .... .....១០៩
លំដាប់វិបស្សនាញាណ.... .... .... .... .... .... ..... .... .១១០
នាមរូបបរិច្ឆេទញាណ និង ទិដ្ឋិវិសុទ្ធិ.... .... .... .... .... .១១០

ញាណទី ២ បច្ចយបរិគ្គហញាណ.... .... .... .... .... .....១២៧
បច្ចយបរិគ្គហញាណ និងកង្ខាវិតរណវិសុទ្ធិ.... .... .... ..១២៨
ការឃើញហេតុបច្ច័យតាមន័យទី ១.... .... .... .... .... ..១៣០
ការអនុមានដឹងហេតុបច្ច័យដែលជាអតីត និងអនាគត.....១៣៧
ការដឹងហេតុបច្ច័យតាមន័យទី ២.... .... .... .... .... ... ..១៤៣
ការដឹងហេតុបច្ច័យតាមន័យទី ៣.... .... .... .... .... ... ..១៤៥
ការដឹងហេតុបច្ច័យតាមន័យទី ៤... .... .... .... .... .... ..១៤៨
ការដឹងហេតុបច្ច័យតាមន័យទី ៥.... .... .... .... .... ... ..១៤៨
វិបាកវដ្តដែលជាផលក្នុង បច្ចុប្បន្ន ៥.... .... .... .... ... .១៥២
វិបាកវដ្តដែលជាផលក្នុង អនាគត ៥.... .... .... .... .. ..១៥៦
ព្រះចូឡសោតាបន្ន.... .... .... .... .... .... .... .... .... ...១៧១
កថារបស់ព្រះចូឡសោតាបន្ន.... .... .... .... .... .... ... ..១៧៥
ញាណទី ៣ សម្មសនញាណ.... .... .... .... .... .... .. ..១៧៨
សម្មសនញាណ និងមគ្គាមគ្គញាណទស្សនវិសុទ្ធិ... .. ..១៧៩
អនិច្ចសម្មសន ( ការពិចារណាថា មិនទៀង )... ... .. ..១៨៧
ទុក្ខសម្មសន ( ការពិចារណាថា ជាទុក្ខ )... ... ... ... ...១៩២

អនត្តសម្មសន ( ការពិចារណាថាមិនមែនខ្លួន )... ... ...១៩៤
សេចក្តីប្រាកដរបស់អនត្តា... ... ... ... ... ... ... .... ......២០១
អដ្ឋកថាន័យ ដែលក្រៅអំពីព្រះបាលី... ... ... .... ... ....២១២
វិធីប្រាប់ ( កែតម្រូវ ) ឥន្ទ្រីយ៍ ៩ ប្រការ... .... ... .. ...២១៣
ការកំណត់ដឹងរូបផ្លូវរូបសត្តក:.... ... ... ... ... ... ... ....២១៧
១ ការពិចារណាសេចក្តីប្រកាន់មាំ និងការប្រលែងចោល-
( អាទាននិក្ខេបន័យ )... ... ... ... ... ... ... ... ... ... ..២១៩
ការលើកនូវត្រៃលក្ខណ៍ចូលក្នុងរូបនាម... ... ... ... .. ..២២១
២ការពិចារណាសេចក្តីបែកធ្លាយរបស់រូបដែលធំធាត់-
ឡើងតាមវ័យ ( វយោវុឌ្ឍត្ថង្គមន័យ )... ... ... ... ... ..២២៦
៣ ការពិចារណារូបដែលកើតអំពីអាហារ(អាហារជរូប)...២៣៥
៤ ការពិចារណារូបដែលកើតអំពីឧតុ( ឧតុជរូប )... .. ..២៣៧
៥ ការពិចារណារូបដែលកើតអំពីកម្ម( កម្មជរូប)... .. ...២៣៨
៦ ការពិចារណារូបដែលកើតអំពីចិត្ត( ចិត្តជរូប)... ... ..២៤៦
៧ ការពិចារណារូបធម្មតា( ធម្មតារូប )... ... .... ... .. ..២៥៤
ការកំណត់ដឹងនាមផ្លូវនាមសត្តក:... .... ... ... ... ... .. .២៥៥

ញាណទី ៤ ឧទយព្វយញាណ... ... ... ... ... ... ... ....២៦៧
ឧទយព្វយញាណ និងមគ្គាមគ្គញាណទស្សនវិសុទ្ធិ... ....២៦៨
ខណៈបច្ចុប្បន្ន និងសន្តតិបច្ចុប្បន្ន... ... ... ... ... ... ... ២៧៥
ការអនុមានដឹងលក្ខណៈកើតឡើង ២៥ និងលក្ខណៈរលត់-
ទៅ ២៥ ដោយហេតុបច្ច័យ... ... ... ... ... ... ... .. .. ..២៨៤
វិបស្សនូបក្កិលេស ១០យ៉ាង... ... ... ... ... ... ... ...២៩៩
១ ឱភាស ( ឱភាស )... ... ... ... ... ... ... ... ... ... ... ...៣០២
២ ញាណ... ... ... ... ... ... ... .... ... ... ... ... ... .. ..៣០៩
៣ បីតិ... ... ... ... ... ... ... .... ... ... ... ... ... ... .. ..៣១០
៤ បស្សទ្ធិ... ... ... ... ... ... ... .... ... ... ... ... ... .. ..៣១៦
៥ សុខ... ... ... ... ... ... ... .... ... ... ... ... ... ... ... ៣១៩
៦ អធិមោក្ខ... ... ... ... ... ... .... ... ... ... ... ... ... ...៣២០
៧ បគ្គហៈ... ... ... ... ... ... ... .... ... ... ... ... ... ... .. ..៣២១
៨ ឧបដ្ឋាន... ... ... ... ... ... ... .... ... ... ... ... ... ... .៣២១
៩ ឧបេក្ខា... ... ... ... ... ... ... .... ... ... ... ... ... ... .. ..៣២២
១០ និកន្តិ... ... ... ... ... ... ... .... ... ... ... ... ... .. ..៣២៤

មគ្គាមគ្គញាណទស្សនវិសុទ្ធិ... ... ... ..... ... ... ... .. ...៣២៩
-ញាណ ទី ៥ ភង្គញាណ... ... ... ... ... ... ... ... .. ...៣៣០
ភង្គញាណ និងបដិបទាញាណទស្សនវិសុទ្ធិ... ... ... .. ..៣៣១
**-ញាណទី ៦-៨ ភយញាណ អាទីនវញាណ-និព្វិទាញាណ**... ... ... ... ... ... ... ... ... ... .... ... .. ..៣៥១
ភយញាណ អាទីនវញាណ និព្វិទាញាណនិង-បដិបទាញាណទស្សនវិសុទ្ធិ... ... ... ... ... ... ... ... ....៣៥២

“សមាគមសមណាភាសី”

# គន្ថារម្ភកថា

ព្រះពុទ្ធវចនៈទាំងអស់ មាន ៨៤០០០ ព្រះធម្មក្ខន្ធ បែកជាព្រះវិន័យមាន ២១០០០ ព្រះធម្មក្ខន្ធ បែកជាព្រះសូត្រមាន ២១០០០ព្រះធម្មក្ខន្ធ និងព្រះអភិធម្មមាន ៤២០០០ ព្រះធម្មក្ខន្ធ ។ បើពោលដោយសិក្ខាមាន ៣ យ៉ាង គឺអធិសីលសិក្ខា អធិចិត្តសិក្ខា និងអធិបញ្ញាសិក្ខា តែដែលអាចចូលដល់សីល សមាធិ និងបញ្ញាបាន អាស្រ័យធុរៈ ២ យ៉ាងទៀត គឺគន្ថធុរៈ និងវិបស្សនាធុរៈ ។ ក្នុងសម័យមួយព្រះចក្ខុបាលត្ថេរ ( នាមដើម **មហាបាល** ) ក្រោយពីបានឧបសម្បទាហើយ មិនយូរប៉ុន្មានក៏ចូលទៅរកព្រះបរមសាស្តា ហើយទូលសួរអំពីធុរៈក្នុងព្រះពុទ្ធសាសនា ។

បន្ទាប់មកព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងឆ្លើយតបបញ្ហារបស់ចក្ខុបាលត្ថេរថា

គន្ថធុរំ វិបស្សនាធុរន្តិ ទ្វេយេវ ធុរានិ ភិក្ខុ ។

“ម្នាលភិក្ខុ ( ក្នុងសាសនានេះ ) ធុរៈមាន ២ យ៉ាងប៉ុណ្ណោះ

គឺគន្ថធុរៈ និងវិបស្សនាធុរៈ” ។

ការរៀនយកនិកាយមួយក្តី និកាយពីរក្តី ឬក៏ចេះចាំព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដកទាំងអស់ក្តី តាមសមគួរដល់បញ្ញារបស់ខ្លួន ហើយទ្រទ្រង់ទុក សម្តែង ឆ្លើយ ព្រះពុទ្ធវចនៈនេះឯង ឈ្មោះថា “គន្ថធុរៈ” ។

ចំណែកឯការចាប់ផ្តើមប្រារព្ធសេចក្តីព្យាយាម កំណត់ដឹងរូបធម៌នាមធម៌ក្នុងអត្តភាពនេះ ញុំាងវិបស្សនាឲ្យកើតឡើងដោយអំណាចនៃការធ្វើឲ្យជាប់តគ្នានូវសីល សមាធិ និងបញ្ញាប្រចក្សច្បាស់នូវត្រៃលក្ខណ៍ ហើយកាន់យកនូវវិវេកធម៌ជាអារម្មណ៍ មានចិត្តបង្អោនទៅកាន់ព្រះនិព្វានរឿយៗ នេះឈ្មោះថា “**វិបស្សនាធុរៈ**” ។ ( ខុ. ធ. យមកវគ្គ )

ពេលនេះ យើងខ្ញុំព្រះករុណាបានរៀបចំប្រែនូវគម្ពីរមួយដែលមានឈ្មោះថា **វិបស្សនាន័យ** ដែលមានការរចនាដ៏វិចិត្ររបស់ព្រះថេរៈ ព្រះនាម**សោភណមហាថេរៈ** ជនជាតិភូមា ( មហាស៊ីសយាដ័រ ) នៅក្នុងសម័យសង្គាយនាលើកទី ៦ **[ឆដ្ឋសង្គាយនា]** ។ ព្រះពុទ្ធវចនៈមានតម្លៃកាត់ថ្លៃមិនបាន

ដែលព្រះបរមសាស្តា កសាងអភិនីហារបារមីអស់ចំនួន ២០ អសង្ខេយ្យ និងកម្រៃមួយសែនមហាកប្ប ( **គិតក្នុងចិត្ត ៧ អសង្ខេយ្យ,បញ្ចេញវាចា ៩ អសង្ខេយ្យ និងចាប់ផ្តើមអំពីការបានទទួលព្រះពុទ្ធព្យាករណ៍ ៤ អសង្ខេយ្យ** ) ដើម្បីឲ្យបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ដោយគោលបំណងរបស់ព្រះអង្គ គឺចង់ឲ្យសព្វសត្វរួចផុតអំពីសេចក្តីទុក្ខក្នុងសង្សារវដ្ត ។

ក្រោយអំពីការត្រាស់ដឹង ទ្រង់បានប្រកាសសម្តែងនូវព្រះធម៌ ដែលជាមាគ៌ាទៅកាន់ព្រះនិព្វាន ជា**វិមុត្តដ្ឋាន** ។

ខ្ញុំព្រះករុណា បានរៀបចំប្រែ គម្ពីរ**វិបស្សនាន័យ**នេះមកជា**ខេមរភាសា** ក្នុងវង្សាទី ៧ របស់ខ្ញុំដោយមានការរួមសហការជាមួយសព្រហ្មចារីដ៏ច្រើនរូបទៀត ដូចជា : **ភិក្ខុលី សារាឌី ភិក្ខុវិត ថេន ភិក្ខុណុប ណេង ភិក្ខុរី សារ៉ែន** និងក្រុម**សមណាភាសី** ទាំងអស់ដែលជាសុវចបុគ្គលដ៏ឆ្នើមក្នុងព្រះសាសនានេះ ។

ម្យ៉ាងវិញទៀត ខ្ញុំព្រះករុណាសង្ឃឹមរំពៃថា ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងពុទ្ធបរិសទ្យ នឹងជួយកែតម្រូវនូវសេចក្តីខុស

ឆ្គាំឆ្គងនូវអក្ខរៈ ព្យញ្ជនៈទាំងអស់ដែលភ្លាំងភ្លាត់ ដោយការត្រួតជម្រះមិនសព្វ ចេះមិនដល់ យល់មិនជ្រះ ។ សូមវិញ្ញូជនទាំងឡាយ បានទទួលនូវសុខសន្តិភាព ដើម្បីជាម្លប់ដល់សព្វសត្វ ហើយដោយបុញ្ញានុភាពនេះ ក៏សូមឲ្យពួកជនដែលនៅក្នុងដែនកម្ពុជរដ្ឋ បានទទួលនូវសេចក្តីសុខជានិរន្តរ៍រៀងទៅ.........។

ឆាយមញ្ញស្ស កុព្វន្តិ    ទិដ្ឋន្តិ សយមាតបេ
ផលានិបិ បរស្សេវ    រុក្ខា សប្បុរិសា ឥវ ។

មហាព្រឹក្សាជាម្លប់ឲ្យដល់អ្នកដទៃ តែខ្លួនឯងវិញនោះត្រូវអត់ធន់ចំពោះកំដៅថ្ងៃដ៏ខ្លាំងក្លា ឯដើមឈើនោះវិញ រមែងញ៉ាំងផលដើម្បីអ្នកដទៃដោយពិត សប្បុរសទាំងឡាយ រមែងប្រព្រឹត្តខ្លួនដូចដើមឈើ ។    សូមអនុមោទនា........!!!

៨ កើត ខែ ផល្គុណ ឆ្នាំ ជូត ឯកស័កពុទ្ធសករាជ ២៥៥២

“សមាគមសមណាភាសី”

# អក្សរសង្ខេបឈ្មោះគម្ពីរ

( ព្រះត្រៃបិដក=ភាគ, វគ្គ, ទំព័រ, អដ្ឋកថានិងដីកា= ភាគ,ទំព័រ )

## ព្រះវិនយបិដក

| | |
|---|---|
| វិ. មហាវិ. | វិនយបិដក មហាវិភង្គ |
| វិ. ភិក្ខុនី. | វិនយបិដក ភិក្ខុនីវិភង្គ |
| វិ. មហា. | វិនយបិដក មហាវគ្គ |
| វិ. ចុល្ល. | វិនយបិដក ចុល្លវគ្គ |
| វិ. ប. | វិន័យបិដក បរិវារវគ្គ |

## ព្រះសុត្តន្តបិដក

| | |
|---|---|
| ទី. សី. | ទីឃនិកាយ សីលក្ខន្ធវគ្គ |
| ទី. មហា. | ទីឃនិកាយ មហាវគ្គ |
| ទី. បា. | ទីឃនិកាយ បាដិកវគ្គ |
| ម. មូ. | មជ្ឈិមនិកាយ មូលបណ្ណាសក |
| ម. ម. | មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក |
| ម. ឧ. | មជ្ឈិមនិកាយ ឧបរិបណ្ណាសក |
| សំ. ស. | សំយុត្តនិកាយ សគាថវគ្គ |
| សំ. និ. | សំយុត្តនិកាយ និទានវគ្គ |

| | |
|---|---|
| សំ. ខ. | សំយុត្តនិកាយ ខន្ធវគ្គ |
| សំ. សឡា. | សំយុត្តនិកាយ សឡាយតនវគ្គ |
| សំ. មហា. | សំយុត្តនិកាយ មហាវគ្គ |
| អំ. ឯក. | អង្គុត្តរនិកាយ ឯកនិបាត |
| អំ. ទុក. | អង្គុត្តរនិកាយ ទុកនិបាត |
| អំ. តិក. | អង្គុត្តរនិកាយ តិកនិបាត |
| អំ. ចតុក្ក. | អង្គុត្តរនិកាយ ចតុនិបាត |
| អំ. បញ្ចក. | អង្គុត្តរនិកាយ បញ្ចកនិបាត |
| អំ. ឆក្ក. | អង្គុត្តរនិកាយ ឆក្កនិបាត |
| អំ. សត្តក. | អង្គុត្តរនិកាយ សត្តកនិបាត |
| អំ. អដ្ឋក. | អង្គុត្តរនិកាយ អដ្ឋកនិបាត |
| អំ. នវក. | អង្គុត្តរនិកាយ នវកនិបាត |
| អំ. ទសក. | អង្គុត្តរនិកាយ ទសកនិបាត |
| អំ. ឯកាទក. | អង្គុត្តរនិកាយ ឯកាទសកនិបាត |
| ខុ. ខុ. | ខុទ្ទកនិកាយ ខុទ្ទកនិបាត |
| ខុ. ធ. | ខុទ្ទកនិកាយ ធម្មបទ |
| ខុ. ឧ. | ខុទ្ទកនិកាយ ឧទាន |
| ខុ. ឥតិ. | ខុទ្ទកនិកាយ ឥតិវុត្តកៈ |
| ខុ. សុ. | ខុទ្ទកនិកាយ សុត្តនិបាត |

| | |
|---|---|
| ខុ. វិ. | ខុទ្ទកនិកាយ វិមានវត្ថុ |
| ខុ. បេ. | ខុទ្ទកនិកាយ បេតវត្ថុ |
| ខុ. ថេរ. | ខុទ្ទកនិកាយ ថេរគាថា |
| ខុ. ថេរី. | ខុទ្ទកនិកាយ ថេរីគាថា |
| ខុ. ជា. | ខុទ្ទកនិកាយ ជាតក |
| ខុ. មហា. | ខុទ្ទកនិកាយ មហានិទ្ទេស |
| ខុ. ចូឡ. | ខុទ្ទកនិកាយ ចូឡនិទ្ទេស |
| ខុ. បដិ. | ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ |
| ខុ. អប. | ខុទ្ទកនិកាយ អបទាន |
| ខុ. ពុទ្ធ. | ខុទ្ទកនិកាយ ពុទ្ធវង្ស |
| ខុ. ចរិយា. | ខុទ្ទកនិកាយ ចរិយាបិដក |
| នេត្តិ. | នេត្តិបករណ៍ |
| មិលិន្ទ. | មិលិន្ទបញ្ហា |

## ព្រះអភិធម្មបិដក

| | |
|---|---|
| អភិ. ធ. | អភិធម្មបិដក ធម្មសង្គណី |
| អភិ. វិ. | អភិធម្មបិដក វិភង្គ |
| អភិ. ធា. | អភិធម្មបិដក ធាតុកថា |
| អភិ. បុ. | អភិធម្មបិដក បុគ្គលប្បញ្ញត្តិ |
| អភិ. ក. | អភិធម្មបិដក កថាវត្ថុ |

| | |
|---|---|
| អភិ. យ. | អភិធម្មបិដក យមកៈ |
| អភិ. ប. | អភិធម្មបិដក បដ្ឋាន |

## គម្ពីរអដ្ឋកថា

| | |
|---|---|
| វិ. អ. | វិនយបិដក អដ្ឋកថា |
| ទី. អ. | ទីឃនិកាយ អដ្ឋកថា |
| ម. អ. | មជ្ឈិមនិកាយ អដ្ឋកថា |
| សំ. អ. | សំយុត្តនិកាយ អដ្ឋកថា |
| អំ. អ. | អង្គុត្តរនិកាយ អដ្ឋកថា |
| ខុ. អ. | ខុទ្ទកនិកាយ អដ្ឋកថា |
| ធម្ម. អ. | ធម្មបទ អដ្ឋកថា |
| ឧទាន. អ. | ឧទាន អដ្ឋកថា |
| ឥតិវុត្ត. អ. | ឥតិវុត្តក អដ្ឋកថា |
| សុត្តនិ. អ. | សុត្តនិបាត អដ្ឋកថា |
| វិមាន. អ. | វិមានវត្ថុ អដ្ឋកថា |
| បេត្ត. អ. | បេត្តវត្ថុ អដ្ឋកថា |
| ថេរ. អ. | ថេរគាថា អដ្ឋកថា |
| ថេរី. អ. | ថេរីគាថា អដ្ឋកថា |
| ជា. អ. | ជាតក អដ្ឋកថា |
| មហានិ. អ. | មហានិទ្ទេស អដ្ឋកថា |

| | |
|---|---|
| ចូឡនិ. អ. | ចូឡនិទ្ទេស អដ្ឋកថា |
| បដិសំ. អ. | បដិសម្ភិទា អដ្ឋកថា |
| អប. អ. | អបទាន អដ្ឋកថា |
| ពុទ្ធវំ. អ. | ពុទ្ធវំស អដ្ឋកថា |
| ចរិយា. អ. | ចរិយាបិដក អដ្ឋកថា |
| នេត្តិ. អ. | នេត្តិ អដ្ឋកថា |
| វិសុទ្ធិ. | វិសុទ្ធិមគ្គ |
| អភិ. អ. | អភិធម្មបិដក អដ្ឋកថា |
| សង្គហ. | អភិធម្មត្ថសង្គហៈ |

## គម្ពីរដីកា

| | |
|---|---|
| វជិរ. ដី | វជិរពុទ្ធិដីកា |
| សារត្ថ. ដី | សារត្ថទីបនីដីកា |
| វិមតិ. ដី | វិមតិវិនោទនីដីកា |
| កង្ខា. ដី. | កង្ខាវិតរណីដីកា |
| កង្ខា. នវដី. | កង្ខាវិតរណីអភិនវដីកា |
| ទី. ដី. | ទីឃនិកាយដីកា |
| សី. ដី. | សីលក្ខន្ធវគ្គ អភិនវដីកា |
| ម. ដី. | មជ្ឈិមនិកាយ ដីកា |
| សំ. ដី | សំយុត្តនិកាយ ដីកា |

អំ. ដី. អង្គុត្តរនិកាយ ដីកា

វិសុទ្ធិ. ដី. វិសុទ្ធិមហាដីកា

មណិមញ្ជូ. មណិសារមញ្ជូសា , ខុទ្ទ. ដី. ខុទ្ទសិក្ខាដីកា

ប្រមូលរូបរួមចងក្រងដោយ **សមាគមសមណវាសី**

# "អនុមោទនាជោតិកថា"

ខ្ញុំព្រះករុណា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ ការឧបត្ថម្ភនូវថវិកា ដើម្បីបោះពុម្ពសៀវភៅនេះឡើង ដោយការយកចិត្តទុកដាក់ជាទីបំផុត ទាំងកម្លាំងកាយ និងកម្លាំងចិត្តដើម្បីជ្រោមជ្រែងនូវក្រុម**សមណវាសី** ឲ្យដំណើរការទៅយ៉ាងរលូន និងវិវឌ្ឍនភាពទៅរកសេចក្តីសុខសន្តិភាព នៃពុទ្ធសាសនមណ្ឌល ហើយនៅក្នុងចំណោមពុទ្ធបរិស័ទដែលធ្វើឲ្យសាសនារុងរឿងចំរើន មានសុពលភាព និងឧត្តមភាពទៅបាន អាស្រ័យលើពុទ្ធបរិស័ទទាំង ៤ ចំណែកឯការវិនាសទៅវិញ ឬសាបសូន្យ នោះអាស្រ័យលើពុទ្ធស័ទ ។

ពិតមែនហើយ ការចងក្រងនូវសៀវភៅមួយៗ វាជាការលំបាក តែចំពោះទស្សនៈរបស់ខ្ញុំវិញ ក៏នៅតែគិត ថា ការចងចាំទេ ទើបជាការលំបាក, ការបដិបត្តិតាមទេ ទើបជាការលំបាក, ហើយវិសេសជាងនេះ ទៅទៀត ខ្ញុំគិតទៀតថា បុគ្គលដែលបានរួចផុតបាកទុក្ខទេ ទើបជាការលំបាក ( **បដិវេធកោ** ) ។

ការព្យាយាមរបស់ខ្ញុំបានសម្រេចជាស្ថាពរ ក្នុងឱកាសនេះ ខ្ញុំព្រះករុណា សូមអនុមោទនាត្រេកអរ ចំពោះកិច្ចការជាកុសលនៃ**សុទស្សនជន**ទាំងឡាយ ដែលកំពុងតែព្យាយាមអាន និងសិក្សា គម្ពីរវិបស្សនាន័យនេះ ក្នុងនោះទៀតសោតខ្ញុំព្រះករុណា សូមថ្លែងអំណរគុណចំពោះ **ករុណាទិសម្បន្ន-បុគ្គល** ជាអ្នកឲ្យនូវចំណេះដឹង និងបទពិសោធន៍ ដល់ខ្ញុំគឺអ្នកគ្រូ **អ៊ុំ ជា** និងអ្នកគ្រូ **ប៉ោរ សុម៉ាលី** ជាអ្នកបង្ហាត់បង្រៀននូវគម្ពីរព្រះអភិធម្មដល់រូបព្រះករុណា និងលោកគ្រូ**អមតានន្ទៈ** សោម វណ្ណៈ ជាអ្នកបង្ហាត់រៀនគម្ពីរព្រះបាលី ហើយនិងឲ្យនូវអនុសាសន៍ជាច្រើនដល់ខ្ញុំព្រះករុណា ។

សូមកុសលបុញ្ញរាសី ដែលកើតឡើងពីការព្យាយាមចងក្រងនូវសំណៅនេះ សូមឲ្យអ្នកគ្រូនិងលោកគ្រូបានទទួលសម្បត្តិ គឺបញ្ញាប្រចក្សច្បាស់នូវព្រះនិព្វានក្នុងកាលដ៏ខ្លីចុះ ។

សូមឲ្យសព្វសត្វទាំងឡាយបាននូវសេចក្តីសុខជានិរន្តរ៍រៀងទៅ ។ សូមអនុមោទនា...!!!

អមរាភិវសៈ **ថោន សីលា**

# រតនប្បណាម

ពុទ្ធោ សុសុទ្ធោ ករុណាមហណ្ណវោ
យោច្ចន្តសុទ្ធព្វរញ្ញាណលោចនោ
លោកស្ស បាបូបកិលេសឃាតកោ
វន្ទាមិ ពុទ្ធំ អហមាទរេន តំ ;

ធម្មោ បទីបោ វិយ តស្ស សត្ថុនោ
យោ មគ្គបាកាមតភេទភិន្នកោ
លោកុត្តរោ យោ ច តទត្ថទីបនោ
វន្ទាមិ ធម្មំ អហមាទរេន តំ ;

សង្ឃោ សុខេត្តាព្យតិខេត្តសញ្ញិតោ
យោ ទិដ្ឋសន្តោ សុគតានុពោធកោ
លោលប្បហីនោ អរិយោ សុមេធសោ
វន្ទាមិ សង្ឃំ អហមាទរេន តំ ;

ឥច្ចេវមេកន្តភិបូជនេយ្យកំ

វត្ថុត្តយំ វន្ទយតាភិសង្ខតំ
បុញ្ញំ មយា យំ មម សព្វុបទ្ទវា
មា ហោន្តុវេ តស្ស បភាវសិទ្ធិយា ។(ប្រែ ឃ្លោងពាក្យ ៧)

ព្រះសម្ពុទ្ធម្ចាស់អង្គឯណា ទ្រង់គុណថ្លៃថ្លាល្អម៉ត់ហ្មង គឺវិសុទ្ធិគុណស្អាតកន្លង ករុណាគុណផង ជ្រៅទូលាយ ។ ដូចកល់អន្លង់ជារជំឯក លេងល្ហើយអនេកផុតអធិប្បាយ ទាំង-បញ្ញាគុណរុងរឿងឆ្ងាយ ប្រសើរស្រុសសាយសព្វលើសលប់ ។ ទ្រង់សម្លាប់ចោលគ្រឿងសៅហ្មង បាបកម្មចាំចងសត្វក្នុងភព ដោយការព្យាយាមមិនឈរឈប់ រាល់ថ្ងៃរាល់យប់សព្វវេលា ។ យើងខ្ញុំបង្គំព្រះពុទ្ធនោះ ល្បីកេរ្តិ៍ឈ្មោះផុតភពកា ដោយការគោរពដ៏ថ្លៃថ្លា ចិត្តកាយវាចាទាំងបីពិត ។

ព្រះធម៌នៃអង្គព្រះសាស្តា រុងរឿងភ្លឺថ្លាល្អវិចិត្រ ដូចកល់ប្រទីបខ្វាត់ងងឹតទ្រោលបំភ្លឺផុតឆ្ងាយក្តីណា ។ ជាធម៌ផ្ទេកផ្សេងដោយប្រភេទមគ្គផលទាំងប៉ែតប្រាំបីឃ្លា ជាលោកុត្តរច្នេងលោកាបំភ្លឺប្រាជ្ញាណែប្រយោជន៍ ។ ធម៌ណាដែលខ្ញុំថ្លែងអធិប្បាយបន្ទៃប្រែស្រាយជ្រៅលន្ទោច ខ្ញុំសូមបង្គំផ្គងចិត្តស្រោច មិនរួញ

ភាញោចចាកធម៌នោះ ។

ព្រះសង្ឃអង្គណាជាស្រែបុណ្យ ល្អល្អះលើសលន់ច្រើន ជាន់ស្មោះ សញ្ញាជាប្រែឥតចន្លោះ ប្រសើរចំពោះរបស់ជន ។ មានការយល់ត្រូវសន្តានស្ងប់ ជ្រាបធម៌ផងសព្វមិនមោហន្ធ តាមផ្លូវព្រះសុគតម្ចាស់ទិព្វគន់ លះការទាបទន់ក្តីឡេះឡោះ ។ ជាអរិយសង្ឃទ្រង់ប្រាជ្ញា គឺស្វាងជ្រះថ្លាថ្កុះសាយសុស ទម្លាយកិលេសឥតមានមោះ មន្ទិលពព្រុះក្នុងសន្តាន ។ ខ្ញុំសូមវន្ទាព្រះសង្ឃនោះ ទ្វារបីចំពោះក្រាបប្រញ្ញប្រាណ គោរពកោតក្រែងសង្ឃប៉ុន្មាន ដែលបាននិព្វានផុតទុក្ខភ័យ ។

បុណ្យដែលយើងខ្ញុំបានតាក់តែង វន្ទាចាំបែងវត្ថុត្រ័យ ដែលគួរបូជាពល់សម័យ ជាឯកឥតន័យណាដូចនេះ ។ អន្តរាយទាំងពួងរបស់ខ្ញុំ សូមឲ្យជោរទុំជ្រះរបេះ កុំមានដល់ខ្ញុំ-អ្នកសំណេះ- សំណាលពោលគុណទាំងបីឡើយ ។ សូមសម្រេចដោយកម្លាំង ដែលយើងខ្ញុំតាំងយ៉ាងនេះហើយ ចំពោះត្រ័យរ័ត្នម្ចាស់ត្រាណត្រើយ សូមបានសះស្បើយគ្រោ-នេះឯង ។ ( បុរាណភាសិត )......

# អ្នកជួយពិនិត្យអក្ខរាវិរុទ្ធ

-ក្រុមសមណវាសី -អមរាភិសេក ថោន សីលា

-ភិក្ខុ រ៉ុត ថេន -ភិក្ខុ ហ៊ាង សំអឿយ

-ភិក្ខុ សាន់ ឈុនលី -លោកគ្រូ ស្វាយ ផន

- ឃិត ឃីម -សាមណេរ សាក វុឌ្ឍី

-ភិក្ខុសាមណេរ វត្តអូរញេរ និងក្រុមធម្មាចារ្យជាច្រើនរូបទៀត ។

# អ្នកមានឧបការៈក្នុងកិច្ចការធម្មទាន

| | |
|---|---|
| -ក្រុមសមណាភាសី | -ភិក្ខុ លី សាភឌី |
| -ភិក្ខុ វ៉ិត ថេន | -ភិក្ខុ ហ៊ាង សំអឿយ |
| -សាមណេរ ញឹម គា | -សាមណេរ ធឹម ធា |
| -វីសារ៉ែន | -ណុប ណេង |
| -សុខ សាន្ត | -សាន់ ភ៉ត |
| - ឃិត ឃីម | -សាមណេរ សាភ វុឌ្ឍ |
| -លោកគ្រូស្វាយ ផន | -ឧបាសិកា សន ម៉ាលី |
| -ឧបាសិកាទិត្យ ដាវី | -ឧបាសិកា ប៉ូ យ៉ុន |
| -ឧបាសិកា លឹម ចន្ទន | -ឧបាសិកា លី យ៉ុង |
| -ឧបាសិកា ស វន | -ឧបាសិកា ព្រាប បុប្ផា |
| -ឧបាសក អ៊ុយ ខុង | -ឧបាសក ធុន មាឃ |
| -ឧបាសិកា ចាប សាផន | -ឧបាសិកា គា |

និងពុទ្ធបរិសទ្យ វត្ត អូរញេរ

# បរិច្ឆេទទី ៥

## ក្រសិណផ្លូវសោឡសញ្ញាណ

ឯកាយនំ ជាតិខយន្តទស្សី
មគ្គំ បជានាតិ ហិតានុកម្បី
ឯតេន មគ្គេន តរឹសុ បុព្វេ
តរិស្សន្តិ យេ ច តរន្តិ ឱឃំ ។

“ព្រះមានព្រះភាគទ្រង់ឃើញទីបំផុត គឺការអស់ទៅនៃជាតិ ទ្រង់អនុគ្រោះដោយប្រយោជន៍ ទ្រង់ជ្រាបផ្លូវមួលតែមួយ ជនទាំងឡាយក្នុងកាលមុនឆ្លងអន្លង់ [សង្សារវដ្ត] ដោយផ្លូវនេះ ក្នុងអនាគត ក៏នឹងឆ្លងដោយក្រសែផ្លូវនេះ សូម្បីក្នុងកាលឥឡូវនេះ ក៏នឹងឆ្លង [ អន្លង់សង្សារវដ្តដោយ] ក្រសែផ្លូវនេះដូចគ្នា” ។

“សំ.មហា. ១៩. ៣៨៤. ១៨៦”

❦

# វិបស្សនាន័យ

# ( ភាគទី ២)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## បរិច្ឆេទទី ៥

### ក្រសែផ្លូវសោឡសញាណ

អ្នកបដិបត្តិធម៌ដែលប្រាថ្នានឹងសម្រេចមគ្គផលនិព្វានក្នុងបច្ចុប្បន្នជាតិ គួរកាត់សេចក្តីកង្វល់រឿងផ្សេងៗ ដូចជា អាវាស ត្រកូលឧបដ្ឋាក ( អ្នកឧបត្ថម្ភបច្ច័យ ៤ ) ការបានវត្ថុរបស់របរ ដែលជាហេតុឲ្យកើតសេចក្តីលោភជាដើម ។

គួរជម្រះសីលឲ្យហ្មត់ចត់ជាមុនសិនមុននឹងចូលទៅបដិបត្តិធម៌ ដូចពោលទុកក្នុងបរិច្ឆេទទី ១ (ទំព័រ ៣ ) និងគួរបង្អោនចិត្តគិតថា សូមឲ្យសីលនេះបានជាបច្ច័យ ដើម្បីការសម្រេចនូវមគ្គញាណ ។ ប្រសិនបើអ្នកបដិបត្តិធម៌សង្ស័យថា ខ្លួនធ្លាប់បាននិយាយតិះដៀល ព្រះអរិយបុគ្គល ក៏គួរត្រូវសូមខមាទោស

លោក តែបើទៅជួបលោកមិនបាន ក៏ឲ្យពោលសូមខមាទោស ចំពោះ វិបស្សនាចារ្យ ។

[ ការសូមខមាទោសរាប់ថាជាធម្មទំនៀមម្យ៉ាងនៃពុទ្ធបរិស័ទ មានប្រយោជន៍ដើម្បីឲ្យសង្រួមរវាងក្នុងឱកាសតទៅ ឬដើម្បីកើតសេចក្ដីសប្បាយចិត្ត ដូចជាព្រះបាទអជាសត្តុ បានសូមខមាទោសចំពោះព្រះពុទ្ធជាម្ចាស់ ក្នុងរឿងនៃការផ្ដាច់បង់ព្រះជន្មព្រះរាជបិតា ការនិយាយតិះដៀលព្រះអរិយបុគ្គលហៅថា **អរិយូបវាទ** ញុំាងមិនឲ្យសម្រេចធម៌បានក្នុងជាតិនេះ ។

កាលបុគ្គលបានសូមខមាទោសព្រះអរិយបុគ្គល ហើយនឹងជួយឲ្យវចីកម្មមិនជាអរិយូបវាទ តែនឹងត្រូវបានទទួលផលកម្មអំពីការនិយាយមិនល្អពិតប្រាកដ ព្រោះវចីកម្មបានសម្រេចរួចហើយ ទោសនោះមិនបានវិនាសទៅដោយការសូមខមាទោស ត្រឹមតែស្រាលចុះ ខ្លះព្រោះប្រាសចាកអបរចេតនា គឺចេតនាក្រោយអំពីការធ្វើកម្ម] ។

ការកាត់សេចក្ដីអាល័យក្នុងរាងកាយនិងជីវិត ធ្វើឲ្យមិនកើតសេចក្ដីភ័យខ្លាច ពេលមានអារម្មណ៍ដែលគួរខ្លាចប្រាកដឡើងខណៈបដិបត្តិធម៌ និងគួរបូជាថ្វាយរាងកាយនេះចំពោះ

វិបស្សនាចារ្យដើម្បីឲ្យលោកអប់រំទូន្មានបាន ពេញលេញដោយមិនក្រេងចិត្ត បើបដិបត្តិតាមពាក្យណែនាំរបស់អាចារ្យយ៉ាងតឹងរឹង សូម្បីនឹងមិនបូជាថ្វាយរាងកាយ ក៏អាចនឹងជួបជាមួយការឈានទៅមុខក្នុងការបដិបត្តិបានដូចគ្នា ។

[ ការបូជាថ្វាយរាងកាយរបស់ខ្លួនចំពោះព្រះសម្មាសម្ពុទ្ធ និងវិបស្សនាចារ្យ ពោលទុកក្នុង គម្ពីរវិសុទ្ធិមគ្គ ជាលំដាប់ថា៖

ឥមាហំ ភគវា អត្តភាវំ តុម្ហាកំ បរិច្ចជាមិ ។

“បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គម្ចាស់សូមបូជាថ្វាយរាងកាយនេះ ចំពោះព្រះអង្គ” ។

ឥមាហំ ភន្តេ អត្តភាវំ តុម្ហាកំ បរិច្ចជាមិ ។

“បពិត្រលោកអាចារ្យដ៏ចំរើន ខ្ញុំព្រះអង្គម្ចាស់សូមបូជាថ្វាយរាងកាយនេះ ចំពោះលោក]” ។

ម្យ៉ាងទៀតអ្នកបដិបត្តិធម៌ គួរអប់រំចិត្តឲ្យជឿតាមពាក្យពិតដែលពោលថា “ព្រះនិព្វានជាសភាវៈរលត់ទុក្ខទាំងពួង ( គឺរូបនាម ឬខន្ធ ៥ ) ជាសភាវៈប្រសើរ មគ្គអាចលះបង់កិលេសបានជាសមុច្ឆេទ នឹងទទួលដឹងព្រះនិព្វានជាអារម្មណ៍ ក៏ជាសភាវៈ

ប្រសើរ និងបុគ្គល រមែងសម្រេចមគ្គផលនិងនិព្វាន ដូចពោល ពិតប្រាកដដោយផ្លូវ គឺវិបស្សនានេះ” និងគួរពិចារណាតទៅ ដើម្បីឲ្យកើតកម្លាំងចិត្តថា វិបស្សនាជាផ្លូវដែលសប្បុរសគឺព្រះពុទ្ធជាម្ចាស់ ព្រះអរហន្ត និងព្រះអរិយបុគ្គលទាំងឡាយបានដើរទៅហើយទាំងអស់ ។

ក្រោយអំពីនោះ គួរក្រាបសំពះដោយរឭកដល់ព្រះពុទ្ធគុណ គួរផ្សាយមេត្តាចិត្ត ឲ្យសព្វសត្វតាំងអំពីទេវតារក្សាវត្តជាដើម ទៅថាសូមឲ្យលោកទាំងនោះចូលរស់នៅជាសុខចុះ កុំគប្បីមានពៀរដល់គ្នានឹងគ្នាឡើយ.....ជាដើម ។

បើអាចធ្វើបានក៏គួរពិចារណាសេចក្តីមិនស្អាតថារាងកាយនេះ មិនស្អាតប្រកបដោយសក់ រោម ក្រចក ធ្មេញ ស្បែក ។ល។ ទាំងគួរពិចារណាទៀតដល់សេចក្តីស្លាប់ថា យើងនិងត្រូវស្លាប់ជាធម្មតា ។

[ក្នុងខណៈដែលចំរើនវិបស្សនា គួរចំរើនសមថភាវនារួមគ្នាផង ដើម្បីឃុំគ្រងអ្នកបដិបត្តិធម៌ឲ្យបដិបត្តិបានរៀបរយ សមថភាវនាដូច

ពោលមកនេះ ឈ្មោះថា **អារក្ខកម្មដ្ឋាន** គឺកម្មដ្ឋាន យាំគ្រងអ្នកបដិបត្តិធម៌មាន ៤ ប្រការ គឺ ៖

១. **ពុទ្ធានុស្សតិ** ការរឭកដល់ព្រះពុទ្ធគុណជារឿយៗ មានប្រយោជន៍ ដើម្បីឲ្យកើតបីតិបាមោជ្ជៈ ។

២. **មេត្តាភាវនា** ការចំរើនមេត្តា មានប្រយោជន៍ ដើម្បីឲ្យមនុស្សដែលរស់នៅរួមគ្នា មិនបៀតបៀនគ្នា ។

៣. **អសុភភាវនា** ការពិចារណាថារាងកាយមិនស្អាត មានប្រយោជន៍ដើម្បីឲ្យដកចេញនូវសេចក្តីជាប់ជំពាក់ក្នុងរាងកាយ ។

៤. **មរណានុស្សតិ** ការរឭកដល់សេចក្តីស្លាប់ មានប្រយោជន៍ដើម្បីឲ្យកើតសេចក្តីសង្វេគមិនប្រមាទក្នុងជីវិតរស់នៅ ។

កាលអ្នកបដិបត្តិធម៌បានពិចារណាដូចនេះហើយ គប្បីអង្គុយដុះខាត់សមាធិ ឬអង្គុយឲ្យស្រួល ដោយអង្គុយបែបណានីមួយ ហើយរឭកដឹងសភាវធម៌បច្ចុប្បន្ន ដូចគ្រាដែលនឹងពោលតទៅ ប្រសិនបើអង្គុយចម្រើនកម្មដ្ឋាន បែបសម្របជើង (អង្គុយបត់ជើង) ដោយជើងមិនគងគ្នា ក៏នឹងធ្វើឲ្យអង្គុយបានងាយស្រួលឡើងថែមទៀត ។

# ការកំណត់ដឹងថ្នាក់ជាមូលដ្ឋាន

អ្នកបដិបត្តិធម៌ គួរចាប់ផ្តើមតាំងចិត្តផ្តោតអារម្មណ៍ឆ្ពោះមុខទៅរកពោះរបស់ខ្លួនទឹងរឭកដឹងថា ពោះប៉ោងឡើងនិងផតចុះ បើនៅមិនទាន់ទទួលដឹងអាការៈនេះ បានជាក់ច្បាស់ក៏គួរដាក់ដៃទុកត្រង់ពោះត្រឹមមួយសន្ទុះ សភាវៈប៉ោងផតក៏នឹងតឹងឡើងនៃពោះថា ( ប៉ោងហ្ន៎ ) ក្នុងខណៈដែលដកដង្ហើមចូលនិងដកដង្ហើមចេញ ។

ការកំណត់ដឹង គឺការតាំងចិត្តផ្តោតអារម្មណ៍ ដើម្បីទទួលដឹងសភាវធម៌បច្ចុប្បន្ន ដោយល្អិតសុខុមក្នុងខណៈខ្លះ មិនចាំបាច់បរិកម្មក៏បាន ឬអាចបរិកម្មខ្លះៗ ត្រឹមតែ១ វិនាទី ក្នុងខណៈដើរចង្រ្កម និងអង្គុយកម្មដ្ឋាន ការបរិកម្មវែងយូរពេក អាចធ្វើឲ្យចិត្តទទួលដឹងតែពាក្យបញ្ញត្តិ គ្រប់ពេលដែលបរិកម្មនូវនិម្មិត្តអាចទទួលដឹងសភាវធម៌បាន ពីព្រោះតែមួយខណៈចិត្ត អាចទទួលដឹងបានត្រឹមតែអារម្មណ៍មួយប៉ុណ្ណោះ ។

ក្នុងពេលផ្តើមការបដិបត្តិ មិនគួរដាក់ចិត្ត ចំពោះរូបរាងសណ្ឋានរបស់រាងកាយទាំងអស់ ឬចំណែកណាមួយ គួរយក

ចិត្តទុកដាក់ក្នុងការរឭកដឹង ដែលមិនមានតួរខ្លួន ទទួលដឹងត្រឹមតែសភាវធម៌បច្ចុប្បន្ន សភាវធម៌នោះសូម្បីនឹងកើតរួមជាមួយបញ្ញត្តិ ក៏មិនមែនបញ្ញត្តិ ។ ដូចម្លប់ឈើកើតរួមជាមួយដើមតែមិនមែនដើមឈើ កាលយើងទៅសម្រាកនៅក្រោមម្លប់ឈើ យើងក៏នឹងត្រូវនៅក្រោមដើមឈើនោះ ក្នុងករណីដូចគ្នានេះ គ្រាយើងទទួលដឹងសភាវធម៌ធូន់ស្រាល តឹងធូរ ឬសម្ផស្សក៏ឲ្យដឹងត្រឹមតែជាសភាវធម៌ប៉ុណ្ណោះ ។ កុំធ្វើទុកក្នុងចិត្តចំពោះសម្មតិបញ្ញត្តិ សភាវធម៌ទាំងនេះ កើតរួមជាមួយបញ្ញត្តិក៏ពិតតែមិនមែនជាបញ្ញត្តិ បើយើងព្យាយាមមិនធ្វើទុកក្នុងចិត្តចំពោះអារម្មណ៍នោះៗ តមកវាក៏នឹងបាត់ទៅបន្តិចម្តងៗ នោះគឺពេលដែលចិត្តរបស់យើងទទួលដឹងសភាវធម៌ ជារូបនាមបានរហូតគ្រប់ពេលវេលា ។

សូម្បីក្នុងខណៈខ្លះ ក៏អាចនឹងដឹងចំពោះរូបរាងសណ្ឋានផ្សេងនៃបញ្ញត្តិ ដែលទទួលដឹងរួមជាមួយនឹងសភាវៈតឹង ធូរ ដែលកើតព្រមគ្នា ព្រោះនៅមិនទាន់អាចលះបញ្ញត្តិ ឲ្យអស់ក្នុងខណៈនោះបាន ក្រៅអំពី សតិ សមាធិ និងបញ្ញាដែលនៅមិនទាន់ចាស់ក្លា

នាកាលពេលដែលធម៌ចាស់ក្លា ហើយបញ្ញត្តិក៏នឹងអន្តរធានទៅ បញ្ញារមែងកើតឡើងទទួលដឹងសភាវៈតឹង ធូរប៉ុណ្ណោះ ដោយប្រាសចាករូបរាងសណ្ឋាននៃផ្ទៃពោះ]។

ក្រោយអំពីនោះ អ្នកបដិបត្តិអាចនឹងកំណត់ដឹងសភាវធម៌ គឺរូបនាម ដែលប្រាកដក្នុងទ្វារទាំង ៦ បាន រឿងនេះជាធម្មជាតិរបស់វិបស្សនា តែក្នុងគ្រាដំបូងនៃការបដិបត្តិត្រូវកំណត់អារម្មណ៍ជាគោលក្នុងខណៈអង្គុយ ដូចសភាវៈប៉ោង ផត បានប្រាកដច្បាស់ដល់បុគ្គលទូទៅ គួរកំណត់ធ្វើទុកក្នុងចិត្តថា "ប៉ោងហ្ន៎" "ផតហ្ន៎" យ៉ាងបន្តបន្ទាប់ដោយមិនផ្លាស់ប្តូរបរិកម្ម ទាំងមិនគួរដកដង្ហើមខ្លាំងៗ ទៀតផង ដើម្បីឲ្យសភាវៈប៉ោងផតប្រាកដ មិនគួរដកដង្ហើមយូរ ឬរហ័សពេកទេ គួរដកដង្ហើមតាមប្រក្រតី ។

បើមានសេចក្តីរាយមាយក្នុងខណៈនោះ គួរកំណត់ដឹងនូវសេចក្តីរាយមាយថា "គិតហ្ន៎" "រវើរវាយហ្ន៎" ឬ "ត្រិះរិះហ្ន៎" ។

ពាក្យបរិកម្មថា "គិតហ្ន៎" គួរប្រើក្នុងខណៈដែលទទួលដឹងរឿងរ៉ាវដែលកំពុងនឹកគិត ដូចជាពេលកំពុងនឹកគិតដល់នរណាម្នាក់ ឬ នឹកគិតដល់រឿងអ្វីមួយ ។

ពាក្យបរិកម្មថា "រវើរវាយហ្ន៎" គួរប្រើក្នុងខណៈដែលចិត្តទទួលសេចក្តីរាយមាយ ដែលកើតឡើងយ៉ាងលឿនរហ័ស រហូតដល់មិនដឹងថា គិតដល់រឿងអ្វី? ។

ពាក្យបរិកម្ម គួរប្រើពាក្យត្រឹមតែ ២ ព្យាង្គ ជាគោល នឹងជួយឲ្យឈានទៅមុខបានយ៉ាងរហ័សឡើង ព្រោះការកំណត់សេចក្តីរវើរវាយ ជាការទទួលដឹងសភាវៈ ដែលទើបតែរលត់ទៅឈ្មោះថា **សន្តតិបច្ចុប្បន្ន** គឺ បច្ចុប្បន្ន តជាប់អំពីអតីតដែលទើបតែនឹងរលត់ទៅថ្មីៗ ទើបគួរប្រើពាក្យបរិកម្មខ្លីៗ នឹងធ្វើឲ្យចាប់កំណត់ដឹងនូវសភាវៈរាយមាយបានរហ័ស] ។

បើរឭកដឹងថា បានជួបនឹងបុគ្គលណាមួយ ក្នុងការគិតឲ្យកំណត់ថា "ជួបហ្ន៎" ។

បើឃើញវត្ថុណាប្រាកដក្នុងចិត្ត ឲ្យកំណត់ថា "ឃើញហ្ន៎" នឹងកំណត់ដឹងរហូតទាល់តែសភាវធម៌ឃើញនោះ នឹងបាត់រលត់សូន្យទៅវិញ ។

បើរឭកដឹងថា និយាយនឹងបុគ្គលណា ក្នុងការគិតឲ្យកំណត់ថា "និយាយហ្ន៎" កាលសេចក្តីរាយមាយ ដូចពោលនោះ បានបាត់ទៅ

ហើយ ទើបត្រឡប់មកកំណត់អារម្មណ៍ជាគោល ដូចគ្រាដើម គឺសភាវៈប៉ោង-ផត ដូចដើម ។

[ អ្នកដែលបដិបត្តិធម៌អស់កាលយូរ រហូតសតិមានកម្លាំងច្រើន ក្នុងខណៈនោះ អាចកំណត់ដឹងការគិតបាន ពេលដែលមិនទទួលដឹងរឿងរ៉ាវ ឬបុគ្គលណាដែលកំពុងគិត ក្នុងខណៈនោះ គួរកំណត់ថា“គិតហ្ន៎” ប៉ុណ្ណោះ]។

បើបំណងនឹងស្ទោះទឹកមាត់ ឲ្យកំណត់ថា “ចង់ស្ទោះហ្ន៎” “ស្ទោះហ្ន៎” ហើយទើបត្រឡប់មកកំណត់ដឹងអារម្មណ៍ដើមតាមប្រក្រតីវិញ ។

បើត្រូវការនឹងឱនសីសៈចុះ ឲ្យកំណត់ថា “ចង់ឱនហ្ន៎” ហើយកំណត់ថា “ឱនហ្ន៎” ក្នុងខណៈដែលឱនយូរ កុំឱនចុះលឿនរហ័សពេក ។

បើត្រូវការនឹងងើបក្បាលឡើង ឲ្យកំណត់ថា “ចង់ងើបហ្ន៎” ហើយកំណត់ថា “ងើបហ្ន៎ៗ” ក្នុងពេលដែលងើបសីសៈឡើងក្រោយពីនោះ ទើបត្រឡប់មកកំណត់សភាវៈប៉ោង-ផត ដូចគ្រាដើម ។ [ចិត្តដែលត្រូវការនឹងធ្វើនូវអាកប្បកិរិយាយ៉ាងណាទីមួយ

ឈ្មោះថា ចិត្តបញ្ញា គឺ ចិត្តដែលប្រកបដោយ ចេតនា និង ឆន្ទៈ ដែលត្រូវនឹងធ្វើ អ្នកបដិបត្តិគួរកំណត់ចិត្តបញ្ញា ដូចពោលមកនេះ ការប្រាប់ក្បួនច្បាស់នូវសភាវធម៌របស់រូបនាម យ៉ាងជាក់ច្បាស់ហើយ ទើបនឹងអាចកំណត់ចិត្តបញ្ញាបាន មិនគួរប្រញាប់ប្រញាល់កំណត់ដឹងចិត្តបញ្ញា ក្នុងពេលចាប់ផ្តើមបដិបត្តិធម៌ទេ ព្រោះត្រឹមតែជាការបរិកម្ម ដោយមិនទទួលដឹងនូវសភាវៈចិត្តបញ្ញាយ៉ាងពិតប្រាកដ]។

ប្រសិនបើឈឺចុកចាប់ ប្រាកដក្នុងរាងកាយ ចំណែកណាទីមួយឲ្យផ្តោតអារម្មណ៍ត្រង់កន្លែងឈឺ និងកំណត់ដឹងថា“ឈឺហ្ន៎” ដោយបរិកម្មមិនយូរពេក មិនលឿនពេក ការឈឺចុកចាប់នោះអាចថយចុះ ធូរស្បើយឡើង ហើយក៏បាត់ទៅ ឬអាចធ្ងន់ឡើងៗ រហូតអត់ទ្រាំមិនកំរើក ប្រសិនបើដូច្នោះ ក៏ឲ្យកំណត់ចិត្តដែលត្រូវការផ្លាស់ប្តូរថា “ចង់ផ្លាស់ប្តូរហ្ន៎” ហើយកំណត់ដឹងអាកប្បកិរិយាផ្នែករាងកាយដែលប្រែប្រួលឥរិយាបថអង្គុយ ដូច្នោះ ។

-បើលើកដៃ ឬជើង ឲ្យកំណត់ថា “លើកហ្ន៎ៗ” ព្រមទាំងលើកឡើងយូរៗ ។

-បើសណ្ដូកឲ្យកំណត់ថា "សណ្ដូកហ្ន៎ៗ" ព្រមនឹងសណ្ដូកយូរៗ ។

-បើកោងឲ្យកំណត់ថា "កោងហ្ន៎ៗ" ព្រមនឹងកោងយូរ ។

-បើដាក់ឲ្យកំណត់ថា "ដាក់ហ្ន៎ៗ" គួរធ្វើយូរកំធ្វើលឿន ។

-បើពាល់ត្រូវអវយវៈរាងកាយផ្នែកណាមួយ គប្បីកំណត់ថា "ពាល់ត្រូវហ្ន៎" ។

កាលអ្នកបដិបត្តិធម៌ បានប្ដូរទូវឥរិយាបថយ៉ាងនេះហើយ ការឈឺចុកចាប់អាចបាត់ទៅវិញ ក្នុងខណៈខ្លះ គួរត្រឡប់មកកំណត់ដឹងសភាវធម៌ ប៉ោង-ផត យ៉ាងបន្តបន្ទាប់ ។

បើការរព្វកដឹងផ្សាក្ដៅប្រាកដឡើង ក្នុងរាងកាយចំណែកណាទីមួយ ឲ្យកំណត់ថា "ក្ដៅហ្ន៎" កាលបើរព្វកដឹងផ្សាក្ដៅរលត់បាត់ទៅ ក៏ត្រឡប់មកកំណត់សភាវៈប៉ោង-ផត ដូចគ្រាដើម ។

បើត្រូវការនឹងផ្លាស់ប្ដូរឥរិយាបថ ព្រោះរព្វកដឹង ដូចពោលមកនេះចាស់ក្ដា គួរកំណត់ចិត្តត្រូវការនឹងប្ដូរថា "ចង់ប្ដូរហ្ន៎" ហើយកំណត់ដឹងអាកប្បកិរិយា ខាងផ្នែករាងកាយដែលប្ដូរថា "ឡើងហ្ន៎" ជាដើមតាមជួរវារៈ ដែលពោលរួចមកហើយ ក្នុងកាលជាទីបំផុត

ឲ្យត្រឡប់មកកំណត់ដឹងសភាវៈពោង-ផត ដើម្បីមិនឲ្យដាច់រយៈក្នុងការចម្រើនសតិ កុំឲ្យមានរយៈពេលទំនេរ ដែលខ្វះសតិកំណត់ដឹង ។

បើសភាវៈរមាស់ប្រាកដក្នុងរាងកាយ ចំណែកណាទីមួយ ឲ្យកំណត់ដឹងសភាវៈដូចកំណត់ថា "រមាស់ហ្ន៎ៗ" បើសភាវធម៌បាត់ទៅវិញ ហើយក្នុងខណៈកំណត់ដឹងនោះ ក៏ត្រឡប់កំណត់ដឹងសភាវៈពោង-ផត ដូចគ្រាដើម ។

ពេលដែលរឭកដឹងថា អត់ទ្រាំចំពោះសភាវៈរមាស់មិនបាន ត្រូវការនឹងផ្លាស់ប្តូរឥរិយាបថ ក៏កំណត់ថា "ចង់ប្តូរហ្ន៎" ឬ "ចង់អេះហ្ន៎" ។

កាលត្រូវការនឹងលើកដៃឡើងឲ្យកំណត់ថា "ចង់លើកហ្ន៎" "លើកហ្ន៎ៗ" ឬ "ចង់លើកឡើងហ្ន៎" "លើកឡើងហ្ន៎ៗ" ។

កាលយកដៃប៉ះខ្ទប់ជុំវិញបរិវេណកន្លែងរមាស់ឲ្យកំណត់ថា "ពាល់ត្រូវហ្ន៎" និងកំណត់ថា "អេះហ្ន៎ៗ" ក្នុងខណៈកំពុងអេះ ។

កាលត្រូវការនឹងដាក់ដៃចុះ ឲ្យកំណត់ថា "ចុះហ្ន៎ៗ" ។

កាលត្រូវការនឹងយកដៃប៉ះសម្ទស្សកន្លែងណាទីមួយ ក៏ឲ្យ

កំណត់ថា "ពាល់ត្រូវហ្ន៎" ហើយត្រឡប់មកកំណត់សភាវៈប៉ោង ផតដដែលវិញថា "ប៉ោងហ្ន៎" "ផតហ្ន៎" ។

បើកើតការឈឺចាប់ជាដើមក្នុងរាងកាយ គប្បីកំណត់តាមសភាវៈថា "ឈឺហ្ន៎" "ចុកហ្ន៎" "ស្ពឹកហ្ន៎" "ប៉ឹតហ្ន៎" "ទៀយហ្ន៎" "វិលហ្ន៎" គួរកំណត់ឲ្យទាន់ពេលក្នុងខណៈបច្ចុប្បន្ន មិនឲ្យលឿន ឬ យូរពេកទេ ។

ក្នុងខណៈដែលកំណត់ដឹងការឈឺចុកចាប់ គ្រាខ្លះ ការឈឺចុកចាប់ ក៏បាត់ទៅ គ្រាខ្លះក៏អាចធ្ងន់ធ្ងរឡើង រហូតអត់ធន់មិនបាន ឬអត់ធន់ក្តីរញាព្រោះសភាវធម៌ កាលបើកើតឡើងហើយរមែងរលត់ទៅវិញ បើអត់ធន់មិនបាន ក៏ឲ្យប្តូរឥរិយាបថអង្គុយជាថ្មី ហើយត្រឡប់មកកំណត់ថា "ប៉ោងហ្ន៎""ផតហ្ន៎"តាមប្រក្រតី ដោយមានសតិមិនដាច់រយៈ ។

អ្នកបដិបត្តិខ្លះ មានកម្លាំងសមាធិល្អ ទើងកំណត់បានទាន់សភាវបច្ចុប្បន្ន អាចរឭកដឹងថា ការឈឺចុកចាប់ ខ្លាំងឡើងៗ រហូតស្ទើតែទ្រាំមិនបាន ដូចមានរបស់អ្វីមួយធ្វើឲ្យស្ទះដើមទ្រូង នឹងធ្វើឲ្យដកដង្ហើមមិនស្រួល ខ្លះក៏ដឹងថាឈឺ ដូចត្រូវបន្លាមុត

ឬកាំបិតមុត ខ្លះក្តៅដូចត្រូវទឹកក្តៅរលាក់ ឬឈឺដូចត្រូវម្ជុលមុត ឬឈឺញ៉ឹកញ៉ាប់ៗ ដូចមានសត្វល្អិតវារតាមខ្លួនប្រាណ ខ្លះក៏កើតអាការរមាស់ ឬឈឺចុកចាប់រហូតអត់ទ្រាំមិនកំរើក នឹងធ្វើឲ្យអ្នកខ្លះខ្លាចក្នុងការអង្គុយកម្មដ្ឋានតទៅទៀត ។ ប្រសិនបើមិនកំណត់តាមសភាវៈ សូម្បីការឈឺចុកចាប់នោះ នឹងបាត់ទៅក៏អាចត្រឡប់មកប្រាកដជាថ្មីទៀត កាលមានសមាធិល្អ ចូរកុំខ្លាចព្រោះមិនមែនជារោគដ៏អាក្រក់នោះទេ ហើយក៏មិនមែនធ្ងន់ធ្ងរណាស់ណាទេ ត្រឹមតែជាវេទនាសាមញ្ញដែលធ្លាប់ប្រាកដដល់យើងកន្លងមកហើយ តែកាលគ្រាមុននោះ មិនប្រាកដច្បាស់ព្រោះមានអារម្មណ៍ដទៃប្រាកដច្បាស់ជាង កាលបើសមាធិល្អឡើង វេទនាទាំងនេះក៏នឹងប្រាកដច្បាស់តាមសភាវធម៌ពិត ចូរកំណត់ដឹងវេទនានោះ រហូតទាល់តែបាត់ទៅ នឹងមិនអាចកើតអន្តរាយណាទីមួយដល់ជីវិតឡើយ កាលកំណត់ដឹងរហូតបានហើយវេទនាដូចពោលមកនេះ នឹងមិនអាចប្រាកដឡើងទៀតបានឡើយ ។

ប្រសិនចង់ទម្រេតកាយ គប្បីកំណត់ថា "ចង់ទម្រេតហ្ន៎"

ក្នុងខណៈដែលកំពុងទម្រេតកាយ ឲ្យកំណត់ថា "ទម្រេតហ្ន៎ៗ" ។

ប្រសិនបើរាងកាយកើតអាការទ្រេតទៅទ្រេតមក កុំខ្លាច ចូរតាំងសតិដោយមានការមុតមាំក្នុងចិត្តថា ការទ្រេតនឹងបាត់ទៅ ខណៈទ្រេតឲ្យកំណត់ថា "ទ្រេតហ្ន៎ៗ" កុំឲ្យលឿនពេក ឬយូរពេកទេ ។ បើមានអាការខ្លាំងក្លាឡើងរហូតស្ទើរតែតម្រង់កាយមិនហ្នឹង ឲ្យផ្អែកនឹងជញ្ជាំង ឬសសរក៏បាន ឬនឹងទម្រេតកាយដេកចុះក៏បាន ព្រមគ្នាជាមួយការកំណត់ថា អាការនោះនឹងបាត់ទៅឯងក្នុងពេលមិនយូរឡើយ ។

បើមានអាការញ័រ ឬអង្រួន គប្បីកំណត់ដឹងដូចពោលមកនេះហើយ ។

បើមានសភាវៈឡើងសម្បុរគឺឆ្អក់ សម្លេងឈ្ងួចរ ឬសភាវៈត្រជាក់ស្រួលត្រង់ខ្នង ឬក៏ទូទៅពេញសព្វសព៌ាង្កាយ ចូរកុំខ្លាចនេះត្រឹមតែជាសភាវៈរបស់បីតិដែលកើតឡើងប៉ុណ្ណោះ ។

គ្រាខ្លះអាចកើតអាការតក់ស្លុត កាលបានឮសម្លេងក៏កុំខ្លាចសេចក្ដីតក់ស្លុតរន្ធត់នៃចិត្តនេះ ជាការប្រាកដរបស់អារម្មណ៍ដែលមកប៉ះខ្ទប់យ៉ាងជាក់ច្បាស់ ព្រោះសមាធិមានកម្លាំងជាងមុនៗ

កាលត្រូវការផ្លាស់ប្តូរឥរិយាបថសម្រួលដៃជើង ឬអវយវៈ ចំណែកណាទីមួយ ឲ្យកំណត់ចិត្តបញ្ញាជាមុន ហើយទើបកម្រើក ឥរិយាបថផ្សេងៗ តាមសភាវៈពិត ឲ្យទាន់បច្ចុប្បន្នខណៈ គួរធ្វើ ឲ្យយូរៗ ដូចអ្នកគ្មានកម្លាំង កុំកម្រើកលឿន ។

បើចង់ផឹកទឹក ឲ្យកំណត់ថា "ចង់ផឹកហ្ន៎" ។

បើចង់ទឹងក្រោកឈរឡើង ឲ្យកំណត់ថា "ចង់ក្រោកហ្ន៎" ក្នុងខណៈដែលក្រោកឡើង ឲ្យកំណត់ថា "ក្រោកហ្ន៎" កាលបើ ឈរត្រង់ហើយ ឲ្យកំណត់ថា " ឈរហ្ន៎ " ។

ខណៈដើរ និងមើលឃើញ ឲ្យកំណត់ថា "ឃើញហ្ន៎" ។

ប្រសិនបើគិតថា ចង់ទឹងដើរ ឲ្យកំណត់ថា "ចង់ដើរហ្ន៎" និង"ឈានហ្ន៎" ឬ"ឈានជើងស្តាំហ្ន៎" "ឈានជើងឆ្វេងហ្ន៎"ក៏បាន ។

អ្នកបដិបត្តិធម៌គួរកំណត់ដឹង ចាប់តាំងអំពីខណៈលើកជើង ឡើងរហូតដល់ខណៈដាក់ចុះ និងឈានយឺតៗ ក្នុងពេលដើរចង្ក្រម គ្រប់ជំហាន គួរកំណត់ថា "លើកហ្ន៎" "ដាក់ហ្ន៎" ។

ក្រោយអំពីការកំណត់ដឹង ២ រយៈបានស្ទាត់ជំនាញហើយ

ឲ្យកំណត់យ៉ាងឧក្រិដ្ឋជាលើកទី ៣ ថា "លើកហ្ន៎" "ឈានហ្ន៎" "ដាក់ហ្ន៎" តទៅរឿយៗ រហូតទាល់តែនឹងដើរដល់កន្លែងតម្កល់ទឹកផឹកនោះ ។

ខណៈខ្លះ ដែលមើលឃើញទីតម្កល់ទឹកផឹក ឲ្យកំណត់ថា "ឃើញហ្ន៎" ។

-ក្នុងខណៈដែលកំពុងឈរ ឲ្យកំណត់ថា " ឈរហ្ន៎" ។

-កាលនឹងលូកដៃទៅចាប់កែវ ឲ្យកំណត់ថា "លូកហ្ន៎" ។

-កាលដៃប៉ះខ្ទប់និងកែវទឹក ឲ្យកំណត់ថា"ពាល់ត្រូវហ្ន៎"។

-ក្នុងខណៈចាប់កែវទឹក ឲ្យកំណត់ថា " ចាប់ហ្ន៎" ។

-ក្នុងខណៈដងទឹក ឲ្យកំណត់ថា " ដងទឹកហ្ន៎" ។

-ក្នុងខណៈលើកកែវទឹកលើកឡើងផឹក ឲ្យកំណត់ថា "លើកហ្ន៎"។

-ក្នុងខណៈកែវទឹកប៉ះខ្ទប់នឹងមាត់ ឲ្យកំណត់ថា "ពាល់ត្រូវហ្ន៎"។

-បើដឹងត្រជាក់ ឲ្យកំណត់ថា " ត្រជាក់ហ្ន៎" ។

-ក្នុងខណៈកំពុងផឹក ឲ្យកំណត់ថា " ផឹកហ្ន៎" " លេបហ្ន៎ " ។

ប្រសិនបើដឹងត្រជាក់ត្រង់បំពង់ក ឬក្នុងពោះ ឲ្យកំណត់ថា "ត្រជាក់ហ្ន៎" ។

-ក្នុងខណៈដាក់កែវទឹក ឲ្យកំណត់ថា " ដាក់ហ្ន៎ " ។
-ក្នុងខណៈដាក់ដៃចុះ ឲ្យកំណត់ថា " ចុះហ្ន៎ " ។
-បើដៃប៉ះខ្ទប់រាងកាយ ឲ្យកំណត់ថា " ពាល់ត្រូវហ្ន៎" ។
-បើត្រូវការនឹងបែរខ្លួន ឲ្យកំណត់ថា " ចង់បែរហ្ន៎" ។
-ក្នុងខណៈបែរខ្លួន ឲ្យកំណត់ថា " បែរហ្ន៎" ។

បើដើរទៅ ឲ្យកំណត់ដឹងតាមគោល ដូចដែលពោលមកហើយនេះឯង ។

កាលបើត្រូវការនឹងឈរ ឲ្យកំណត់ថា "ចង់ឈរហ្ន៎" ក្នុងខណៈដែលឈរ ឲ្យកំណត់ថា " ឈរហ្ន៎" ។

បើត្រូវការឈរយូរ ដូចរង់ចាំដាក់អាហារ, ទឹកផឹក, បាន: ...ជាដើម ហើយប្រាកដសភាវៈប៉ោង-ផត ក៏កំណត់ថា "ឈរហ្ន៎" "ប៉ោងហ្ន៎" "ផតហ្ន៎" ។

បើត្រូវការនឹងអង្គុយ ឲ្យកំណត់ថា "ចង់អង្គុយហ្ន៎" កាលដើរទៅកាន់បរិវេណទីអង្គុយ ក៏កំណត់តាមប្រក្រតី ដូចដែលបានពោលរួចមកហើយនោះឯងដូចគ្នា ។

កាលបែរខ្លួន ដើម្បីនឹងអង្គុយ ឲ្យកំណត់ថា "ចង់អង្គុយហ្ន៎" ។

ក្នុងខណៈដាក់ខ្លួនអង្គុយចុះ ឲ្យកំណត់ថា "ចុះហ្ន៎" ដោយទទួល ដឹងសភាវៈធ្ងន់ស្រោល បន្ទាបចុះក្នុងខណៈដាក់ខ្លួនអង្គុយ ។

ក្នុងខណៈដែលអង្គុយដំបូង ឲ្យកំណត់ការប្តូរឥរិយាបថ ដៃ និង ជើងដោយហ្មត់ចត់ បើមានសភាវបច្ចុប្បន្នយ៉ាងដទៃ ដែលជាក់ច្បាស់សភាវៈប៉ោង-ផត គប្បីកំណត់ថា "ប៉ោងហ្ន៎" "ផតហ្ន៎" តាម គ្រាដើម ដូចពោលហើយ ។

បើត្រូវការនឹងដេក ឲ្យកំណត់ថា "ចង់ដេកហ្ន៎" គប្បីកំណត់សភាវៈកម្រើករបស់ដៃជើង និងរាងកាយ ក្នុងខណៈទម្រេតខ្លួនចុះ ដូចជា "លើកហ្ន៎" "សណ្តូកហ្ន៎" "ផ្អៀងហ្ន៎"... ជាដើម ។

ក្នុងខណៈទម្រេតដេកភ្លាមៗ ឲ្យកំណត់អាការកម្រើករបស់ដៃជើង និងរាងកាយយ៉ាងសន្សឹមៗ ហើយទើបនឹងកំណត់ថា " ប៉ោងហ្ន៎" " ផតហ្ន៎" ដូចគ្រាដើមវិញ ។

ក្នុងខណៈកំពុងដេក កាលកើតវេទនា ដូចជា ចុករោយ ក្តៅ ឈឺផ្សា ឈឺពើត រមាស់ ឲ្យកំណត់វេទនានោះទាន់ពេល ។

បើចង់លេបទឹកមាត់, ស្តោះទឹកមាត់ ឬ ការគិតរាយមាយ ក៏គប្បីកំណត់សភាវៈនោះៗ ។

កាលបើចង់នឹងផ្ទៀងកាយទៅផ្អែកខាងស្តាំ ឬឆ្វេង ឬត្រូវការនឹងសណ្តូកដៃជើងទាំងគូ ឲ្យកំណត់ថា ចិត្តបញ្ញាមុននឹងធ្វើអាកប្បកិរិយានោះៗបើមិនមានសភាវៈជទៃមកប្រាកដច្បាស់ក៏គប្បីកំណត់ថា“ប៉ោងហ្ន៎”“ផតហ្ន៎” ដូចគ្រាដើមវិញ ។

បើចង់នឹងដេក ឲ្យកំណត់ថា “ចង់ដេកហ្ន៎” ។

កាលបើងងុយដេក ឲ្យកំណត់ថា “ងងុយហ្ន៎” ។

កាលបើសមាធិមានកម្លាំងច្រើនឡើងហើយ បើកំណត់បានទាន់សភាវបច្ចុប្បន្ន យ៉ាងល្អិតល្អន់ អាការងងុយដេកនឹងបាត់ទៅឯង នឹងស្វាងស្រឡះតាមប្រក្រតី បើកើតអាការស្វាងស្រឡះ ឲ្យកំណត់ថា “ស្វាងហ្ន៎” ហើយទើបត្រឡប់មកកំណត់ សភាវៈ “ប៉ោងហ្ន៎” “ផតហ្ន៎” ដូចគ្រាដើម ។

សូម្បីការងងុយដេក នឹងមិនបាត់ទៅ ក៏មិនគួរឈប់កំណត់ដឹង គួរកំណត់ថា “ប៉ោងហ្ន៎” “ផតហ្ន៎”ជាដើម ។ ដោយគិតថា នឹងកំណត់រហូតទាល់តែដេកលក់ទៅ បើរាងកាយទន់ខ្សោយខ្លាំង អ្នកបដិបត្តិនឹងដេកលក់ទៅ ក្នុងខណៈដែលកំពុងកំណត់នោះឯង ។

ការដេកលក់ស៊ប់ គឺការកើតឡើងនៃភវង្គចិត្ត ( ចិត្តដែលរួចអំពីការដឹង ) កើតជាប់បន្តគ្នាយូរច្រើនម៉ោង ដោយមិនមានវិថីចិត្តកើតឡើង ភវង្គចិត្តជាចិត្តប្រភេទតែមួយ នឹងបដិសន្ធិចិត្ត ( ចិត្តដំបូងក្នុងភពថ្មី ) ក្នុងខណៈដេកលក់ស៊ប់គ្រប់ៗ មនុស្សនឹងមិនដឹងអារម្មណ៍ណាៗ ឡើយ ក្នុងពេលប្រក្រតីដែលភ្ញាក់ឡើងមក ភវង្គចិត្តរមែងកើតឡើងរវាងចន្លោះវិថីចិត្ត ( ចិត្តដែលដឹងអារម្មណ៍ផ្សេងៗ ក្នុងរវាងចន្លោះនៃការឃើញ, បានឮ, នឹកគិតជាដើម ) តែមិនកើតយូរ ដូចពេលដេកលក់ស៊ប់ទេ ទើបមិនអាចកំណត់ដឹងភវង្គចិត្តបាន ក្នុងពេលភ្ញាក់ ឲ្យកំណត់ថា "ភ្ញាក់ហ្ន៎" ក្នុងរយៈពេលនៃការផ្ដើមបដិបត្តិជាដំបូងៗ ជាការលំបាកដែលនឹងកំណត់ដឹងចិត្តភ្ញាក់គ្រាដំបូងបាន សូម្បីនឹងកំណត់ដឹង ការរឭកបានទាន់ប៉ុណ្ណោះ ។

កាលបើកើតការគិតក្រោយភ្ញាក់ពីដេក ឲ្យកំណត់ថា "គិតហ្ន៎" រហូតទាល់តែបាត់ទៅវិញ ហើយទើបត្រឡប់មកកំណត់ "ប៉ោងហ្ន៎" "ផតហ្ន៎" តាមប្រក្រតីដូចគ្រាដើម ។

ក្នុងខណៈដេក កាលបើភ្ញាក់ឡើងក្នុងខណៈបានឮសម្លេង

ឲ្យកំណត់ថា "បានឮហ្ន៎" ហើយកំណត់ថា " ប៉ោងហ្ន៎" "ផតហ្ន៎" កាលបើមិនមានអារម្មណ៍ដទៃ ដែលប្រាកដច្បាស់ជាងសភាវៈ ប៉ោង-ផត ។

គប្បីកំណត់សភាវៈបង្វែរខ្លួន រង្កិលខ្លួន បន្ទាប ឬសណ្ដូក តាមសភាវៈនោះៗ ដោយកម្រើកឃើញៗ ។

បើអ្នកបដិបត្តិធម៌ត្រូវការទឹងដឹងពេលវេលា ឲ្យកំណត់ថា " គិតហ្ន៎" ។

កាលចង់ក្រោកឡើង ឲ្យកំណត់ថា "ចង់ក្រោកហ្ន៎" និង ឲ្យកំណត់អាការកម្រើករបស់កាយ ដែលកំពុងត្រៀមទឹងក្រោក ដូចជាក្នុងខណៈកំពុងក្រោក ឲ្យកំណត់អាកប្បកិរិយាផ្លូវកាយ ដែលបំរុងទឹងក្រោកឡើងថា "ក្រោកហ្ន៎" កាលបើអង្គុយហើយ ត្រូវកំណត់ថា "អង្គុយហ្ន៎" ក្រោយអំពីនោះ ទើបត្រឡប់មក កំណត់សភាវៈប៉ោង-ផត តាមប្រក្រតីដូចគ្រាដើមវិញ ។

ក្នុងខណៈដែលលុបលាងមុខ ឬងូតទឹក ឲ្យកំណត់តាម លំដាប់សភាវៈការឃើញ, ការបានឮ, ការចាប់, ការទាញ, ការទេរ, ភាពត្រជាក់, ការប៉ះខ្លួប់ ជាដើម ។

សូម្បីក្នុងខណៈដែលផ្លាស់សំពត់ រៀបចំទីដេក បើកទ្វារ ឬ បិតទ្វារ និងធ្វើការចាប់កាន់វត្ថុណាទីមួយជាដើម ក៏គួរកំណត់ យ៉ាងបន្តបន្ទាប់ ។

ក្នុងខណៈប្រើដៃទទួលការប្រគេនអាហារ [បែបកូមា] ឲ្យ កំណត់ដឹងដូច្នេះ គឺ៖

-កាលក្រឡេកមើលឃើញចានបាយ ឲ្យកំណត់ថា“ឃើញហ្ន៎”។

-ក្នុងខណៈចាប់ពុំនូតបាយ ឲ្យកំណត់ថា “ពូតហ្ន៎” ។

-ក្នុងខណៈឱនសីសៈចុះ ឲ្យកំណត់ថា “ឱនហ្ន៎” ។

-ក្នុងខណៈដែលដុំបាយប៉ះគ្នាជាមួយមាត់ ឲ្យកំណត់ថា “ប៉ះខ្ទប់-ហ្ន៎” ។

-ក្នុងខណៈដែលហារមាត់ ឲ្យកំណត់ថា “ ហារហ្ន៎” ។

-ក្នុងខណៈដែលទំពារដុំបាយ ឲ្យកំណត់ថា “ ទំពារហ្ន៎” ។

-ក្នុងខណៈដែលបិតមាត់ ឲ្យកំណត់ថា “ បិតហ្ន៎” ។

-ក្នុងខណៈដែលដាក់ដៃចុះ ឲ្យកំណត់ថា “ ដាក់ហ្ន៎” ។

-ក្នុងខណៈដែលដៃប៉ះខ្ទប់ជាមួយចានបាយ ឲ្យកំណត់ថា “ពាល់-ត្រូវហ្ន៎” ។

-ក្នុងខណៈដែលងើបសីសៈឡើង ឲ្យកំណត់ថា " ងើបហ្ន៎ " ។

-ក្នុងខណៈដែលទំពារ ឲ្យកំណត់ថា "ទំពារហ្ន៎" ។

-ក្នុងខណៈដែលដឹងរស ឲ្យកំណត់ថា " ដឹងរសហ្ន៎" ។

-ក្នុងខណៈដែលលេប ឲ្យកំណត់ថា " លេបហ្ន៎" ។

-ក្នុងខណៈដែលអាហារធ្លាក់ចុះទៅប៉ះខ្ទប់ជាមួយបំពង់ក ឬពោះវៀន ឲ្យកំណត់ថា "ប៉ះខ្ទប់ហ្ន៎" ។

អ្នកបដិបត្តិគួរកំណត់ដឹងដោយល្អិតល្អន់ តាមន័យដូចដែលពោលមកនេះគ្រប់ៗ ខណៈក្នុងពេលដែលទំពារបាយនិងហុតទឹកសម្ល ។

អ្នកដែលចាប់ផ្តើមបដិបត្តិធម៌ រមែងមិនអាចកំណត់ដឹងដោយល្អិតល្អន់យ៉ាងបន្តបន្ទាប់ និងមិនអាចកំណត់ដឹងចិត្តដែលត្រូវការនឹងធ្វើអាកប្បកិរិយានោះៗ យ៉ាងណាក៏ដោយចូរកុំរាថយ ។ បើតាំងចិត្តថា យើងនឹងកំណត់ដោយល្អិតល្អន់ហើយ ក៏នឹងអាចកំណត់បានច្រើនឡើងរឿយៗ កាលបើបញ្ញាចាស់ក្លាឡើង ក៏អាចកំណត់បានល្អិតជាងអាកប្បកិរិយាដូចដែលពោលមកនេះទៀត ។

## វិធីផ្ដើមរយៈពេលនៃការកំណត់ដឹង

កាលបើកន្លងទៅច្រើនថ្ងៃ អ្នកបដិបត្តិដឹងច្បាស់ថាអាចកំណត់សភាវៈប៉ោងផត ទាំង ២ បានងាយ នឹងមានរវាងចន្លោះសភាវៈប៉ោងនិងផត ប្រសិនបើនៅក្នុងឥរិយាបថអង្គុយឲ្យបំពេញបន្ថែមនូវសភាវៈអង្គុយតទៅទៀត ដោយកំណត់ថា "ប៉ោងហ្ន៎" "ផតហ្ន៎" "អង្គុយហ្ន៎" មាន ៣ គ្រា និងក្នុងពេលដែលកំណត់ថា "អង្គុយហ្ន៎" គប្បីទទួលដឹងសភាវៈផ្លូវកាយដែលអង្គុយ ។

ប្រសិនបើនៅក្នុងឥរិយាបថដេក ឲ្យកំណត់បន្តទៀតជា ៣ ដងថា "ប៉ោងហ្ន៎" " ផតហ្ន៎" "ដេកហ្ន៎" ។

បើកំណត់ ៣ ដងហើយ នៅដឹងថាមានចន្លោះ ការកំណត់ ( ដាច់រវាងចន្លោះមិនតជាប់គ្នា ) ក៏គួរបន្ថែមនូវការកំណត់ជាលើក ទី ៤ ថា "ប៉ោងហ្ន៎" "ផតហ្ន៎" "អង្គុយហ្ន៎" "ពាល់ត្រូវហ្ន៎" ដោយផ្ដើមសភាវៈប៉ះខ្ទប់ដែលប្រាកដច្បាស់ ។

បើកំណត់ច្រើនដង ហើយនៅតែមិនច្បាស់ ឲ្យផ្លាស់មកកំណត់ដឹងសភាវៈអង្គុយត្រឹម ៣ គ្រា ដោយកាន់យក "ពាល់-ត្រូវហ្ន៎"

ចេញត្រឹមតែកំណត់ថា " ប៉ោងហ្ន៎" " ផតហ្ន៎"" អង្គុយហ្ន៎" ។

សូម្បីក្នុងខណៈដេកក៏កំណត់ថា " ប៉ោងហ្ន៎" " ផតហ្ន៎" "ដេកហ្ន៎" "ពាល់ត្រូវហ្ន៎" ឬ "ប៉ោងហ្ន៎" "ដេកហ្ន៎" "ផតហ្ន៎" "ដេកហ្ន៎" ។

[ការកំណត់សភាវៈដែលប៉ះខ្ទប់សម្ផស្ស ដែលហៅថា ផោដ្ឋព្វារម្មណ៍ នៅជាមួយក្នុងជម្មានុបស្សនា គួរកំណត់ក្នុងបរិវេណដែលកាយបសាទប៉ះខ្ទប់គ្នា ដូចជាបបូរមាត់ អណ្តាតដែលទុលទល់អញ្ចាញខាងលើ ឬកណ្តាលម្រាម ដៃដែលប៉ះខ្ទប់គ្នា ដៃដែលប៉ះខ្ទប់ការដាក់ត្រួតលើគ្នា នឹងធ្វើឲ្យសមាធិកពូនលឿនជាងការកំណត់ដីងក្នុងបរិវេណ ដែលរាងកាយប៉ះខ្ទប់ជាមួយវត្ថុខាងក្រៅ ដូចជាការជូតក្បាល ឬភ្នែក ជើងដែលប៉ះខ្ទប់ជាមួយសម្ផស្សជាដើម]។

ខណៈដែលកំណត់សភាវៈប៉ោង-ផត ជាដើម ដោយការផ្តោតអារម្មណ៍ និងមានអារម្មណ៍ដទៃ ដែលមិនច្បាស់មកប្រាកដក៏មិនចាំបាច់ត្រូវការកំណត់សភាវៈហើយ ឬបានឮជាដើម តែបើបើកភ្នែកមើល ឲ្យកំណត់ថា "ឃើញហ្ន៎" ហើយទើបតាម

កំណត់សភាវៈពោង-ផត ជាដើមតទៅ ។

បើឃើញអារម្មណ៍ ដែលមកប្រាកដផ្លូវចិត្តក្នុងលក្ខណៈរបស់រូបដូចជា បុរស ស្ត្រី គប្បីកំណត់ថា "ឃើញហ្ន៎" ២ ឬ ៣ ដង ។

បើតាំងចិត្តស្តាប់សម្លេង ឲ្យកំណត់ថា "ស្តាប់ហ្ន៎" ឬ "បានឮហ្ន៎" ។

បើបានឮសម្លេងនិយាយ សម្លេងស្ត្រី ឬសម្លេងឆ្កែព្រុសសត្វយំ មាន់រងាវដែលច្បាស់ ឲ្យកំណត់ថា"បានឮហ្ន៎" ២ ឬ ៣ លើក ហើយត្រឡប់មកកំណត់សភាវៈពោង-ផត តាមប្រក្រតីដូចគ្រាដើមវិញ ។

បើអ្នកបដិបត្តិមិនអាចកំណត់ដឹងទាន់សភាវៈឃើញ ឬបានឮ ដែលមកប្រាកដច្បាស់បាន អាចញ៉ាំងផលឲ្យសភាវៈពោងផតជាដើមមិនប្រាកដច្បាស់ ។

សេចក្តីរវើរវាយ អាចកើតឡើងក្នុងវេលាបដិបត្តិធម៌ខ្លះឲ្យកំណត់ថា "គិតហ្ន៎" ហើយត្រឡប់ទៅកំណត់ដឹងអារម្មណ៍ដូចគ្រាដើម ។

បើភ្លេចសភាវៈកម្រើកផ្លូវកាយ ឬការរវើរវាយ កាលដឹងខ្លួនហើយឲ្យកំណត់ថា “ភ្លេសប្រហែសហ្ន៎” ហើយត្រឡប់ទៅកំណត់អារម្មណ៍ដើម ។

បើខ្យល់ដកដង្ហើមចេញចូលល្អិតឡើងៗ អាចធ្វើសភាវៈប៉ោងផតមិនច្បាស់ទើបគួរផ្លាស់ប្តូរទៅកំណត់សភាវៈអង្គុយ ដេក ឬប៉ះខ្លួនសម្ផស្ស ដោយផ្លាស់ប្តូរកន្លែងទៅតាមចំណុច ដែលសម្ផស្សបានប្រហែល ៤, ៥, ៦ ចំណុចតាមសមគួរ ។

គ្រាខ្លះកាលអង្គុយយូរ អាចគិតថា ខ្លួនមិនឈានទៅមុខ និងសេចក្តីខ្ជិលច្រអូសប្រាកដ គប្បីកំណត់ថា “ខ្ជិលច្រ-អូសហ្ន៎” ។

កាលបើសតិ សមាធិនិងវិបស្សនាញាណដែលនៅមិនទាន់ចាស់ក្លាអាចសម្គាល់ថា ការបដិបត្តិរបស់ខ្លួននៅមិនទាន់ឈានទៅមុខ ហើយកើតសេចក្តីសង្ស័យរារែចិត្ត គប្បីកំណត់សេចក្តីសង្ស័យនោះថា “ សង្ស័យហ្ន៎” ។

ក្នុងខណៈខ្លះ អ្នកបដិបត្តិធម៌អាចបង់ប្រាថ្នាការឈានទៅមុខ និងប្រាថ្នាឲ្យគុណធម៌វិសេសមកប្រាកដ គប្បីកំណត់

ការប្រាថ្នានោះថា "ប្រាថ្នាហ្ន៎" ឬ"ចង់ហ្ន៎" ។

ក្នុងខណៈខ្លះ អាចគិតដល់ការបដិបត្តិ ឬវត្ថុដែលធ្លាប់ធ្វើមកមុន ឲ្យកំណត់ថា "នរណាជួរហ្ន៎" ឬពិចារណាថា វត្ថុដែលកំណត់ដឹងជារូប ឬនាម ឲ្យកំណត់ថា "ពិចារណាហ្ន៎" ។

ខណៈអាចកំណត់បានមិនល្អ ទើបគិតការខូចចិត្ត គប្បីកំណត់ថា "ខូចចិត្តហ្ន៎" ។

បើកំណត់បានល្អ រមែងដឹងថា សប្បាយចិត្ត ឲ្យកំណត់ថា "សប្បាយចិត្តហ្ន៎" ។

តាមន័យនេះ អ្នកបដិបត្តិធម៌ គប្បីកំណត់ដឹងសភាវៈក្នុងផ្លូវចិត្តគ្រប់ៗខណៈ ដែលប្រាកដឡើងហើយ គួរត្រឡប់មកកំណត់ដឹងសភាវៈប៉ោង-ផត តទៅទៀត ។

ការកំណត់ក្នុងរវាងនៃការបដិបត្តិធម៌នោះ ត្រូវកំណត់ឲ្យបន្តបន្ទាប់គ្នា តាំងតែអំពីភ្ញាក់ឡើង, រហូតដល់ដេកលក់ស៊ប់ កាលចាប់ផ្តើមបដិបត្តិធម៌ សូមឲ្យអ្នកប្រារព្ធសេចក្តីព្យាយាមតាំងចិត្តថា យើងកំណត់ដឹងយ៉ាងបន្តបន្ទាប់រឿយៗ កាលវិបស្សនាញាណមានកម្លាំងចាស់ក្លាហើយ អ្នកខ្លះអាចរឮកដឹង

សភាពក្តីស្វាងជានិច្ច ដោយមិនត្រូវការដេកទៅវិញឡើយ ។

# "សរុបវិធីបដិបត្តិ"

អ្នកចំរើនវិបស្សនាគប្បីកំណត់ដឹងអាកប្បកិរិយាផ្លូវកាយ ដែលកម្រើកមិនថាតិច ឬច្រើន ( កាយានុបស្សនា ) នឹងកំណត់ដឹងការរំញោកគ្រប់យ៉ាង ដែលជាសុខ ឬទុក្ខ ដែលប្រាកដផ្លូវកាយនិងចិត្ត ( វេទនានុបស្សនា ) គប្បីកំណត់ដឹងសភាវៈផ្លូវចិត្ត ដែលគិតរាយមាយក្នុងរឿងល្អ ឬមិនល្អ ( ចិត្តានុបស្សនា ) និង គប្បីកំណត់សភាវៈគ្រប់យ៉ាង ដែលប្រាកដផ្លូវចិត្ត ដូចជា នីវរណៈជាដើម ( ធម្មានុបស្សនា ) ។

កាលមិនមានអារម្មណ៍ដទៃណានីមួយប្រាកដក្នុងខណៈអង្គុយ ឲ្យកំណត់សភាវៈ ប៉ោង-ផត ឬអង្គុយជាដើម តាមប្រក្រតីក្នុងខណៈដើរក៏គួរកំណត់សភាវៈលើក ឈាន និង ជាន់យ៉ាងបន្តបន្ទាប់ ។

អ្នកដែលខិតខំព្យាយាម កំណត់ដឹងតាមន័យ ដែលពោលមកហើយនេះ ទាំងថ្ងៃទាំងយប់មិនដាច់ វៀរលែងតែពេលដេកលក់ មិនយូរប៉ុន្មាន ក៏រមែងប្រចក្សច្បាស់នូវរូបនាម

ទាំងអស់ដែលកើតរលត់បានទាន់សភាវបច្ចុប្បន្ន ហើយសម្រេចវិបស្សនាញាណជាន់ខ្ពស់ផ្សេងៗ មានឧទយព្វយញាណជាដើមតាមលំដាប់ ។

# "វិធីកំណត់ដឹងយ៉ាងបន្តបន្ទាប់"

កាលសតិ សមាធិ និងបញ្ញាចាស់ក្លាឡើងអំពីវិធីបដិបត្តិដូចដែលពោលមកហើយ អ្នកបដិបត្តិធម៌និងជួបប្រទះថាអារម្មណ៍បច្ចុប្បន្នជាមួយកំណត់ដឹងមានទៅព្រមជាមួយគ្នា ឬសម្ពន្ធចូលគ្នាដូច្នេះ គឺ ៖

-រូបដែលប៉ោងព្រមជាមួយចិត្ត ដែលកំណត់ថា "ប៉ោងហ្ន៎" ។

-រូបដែលផតព្រមជាមួយចិត្ត ដែលកំណត់ថា "ផតហ្ន៎" ។

-រូបដែលអង្គុយព្រមជាមួយចិត្ត ដែលកំណត់ដឹង ។

-រូបដែលកោងព្រមជាមួយចិត្ត ដែលកំណត់ដឹង ។

-រូបដែលសណ្ដូកព្រមជាមួយចិត្ត ដែលកំណត់ដឹង ។

-រូបដែលលើកព្រមជាមួយចិត្ត ដែលកំណត់ដឹង ។

-រូបដែលឈានព្រមជាមួយចិត្ត ដែលកំណត់ដឹង ។

-រូបដែលជាន់ព្រមជាមួយចិត្ត ដែលកំណត់ដឹង ។

ក្រៅពីនោះ អ្នកបដិបត្តិធម៌ក៏អាចញែករូបនាមចេញអំពីគ្នាបានច្បាស់ថា សភាវៈប៉ោង ១ ( រូប ) ចិត្តដែលកំណត់ដឹង ១ ទៀត ( នាម ) សភាវៈផត ១ ចំណែកចិត្ត ដែលកំណត់ដឹង ១ ជាដើម ។

ការប្រាកដរបស់ចិត្ត ដូចជាការរត់ទៅរកអារម្មណ៍ផ្សេងៗមានសភាវៈប៉ោង-ផតជាដើម ចាត់ថាជាលក្ខណៈ របស់នាមដែលបង្អោនទៅរកអារម្មណ៍ ( **នមនលក្ខណំ** ) វត្ថុដែលកំណត់ដឹងរូបធម៌បានជាក់ច្បាស់ត្រឹមណា នាមធម៌ក៏ប្រាកដច្បាស់ត្រឹមនោះ ។ ដូចក្នុងគម្ពីរវិសុទ្ធិមគ្គពោលថា៖

**យថា យថា ហិស្ស រូបំ សុវិក្ខាលិតំ ហោតិ និជ្ជដំ សុបរិសុទ្ធំ; តថា តថា តទារម្មណា អរូបធម្មា សយមេវ បាកដា ហោន្តិ ។**

“ ពិតមែនហើយ នាមដែលមានរូបនោះ ជាអារម្មណ៍រមែងប្រាកដឯង កាលរូបបានប្រេចក្រច្បាស់ស្អាតបរិសុទ្ធល្អដល់អ្នកហើយ”

អ្នកបដិបត្តិដែលមិនបានសិក្សាគោលធម៌ កាលបែករូបនាមបានយ៉ាងនេះ រមែងយល់ថា មិនមានវត្ថុដទៃក្រៅពីរូបនិងនាម គឺមានត្រឹមតែសភាវៈប៉ោងនិងចិត្តដែលកំណត់ថា "ប៉ោង" សភាវៈផត និងចិត្តដែលកំណត់ថា "ផត" សភាវៈអង្គុយ និងចិត្តដែលកំណត់ថា " អង្គុយ" ។

មនុស្សយើងនេះ មានត្រឹមតែរូបនាម ២ យ៉ាងប៉ុណ្ណោះ ទោះបីជា ស្រី ឬប្រុសក៏មានត្រឹមតែរូបនាម មិនមានសត្វ បុគ្គល យើង គេ របស់យើង បុរស ឬស្ត្រី ជាដើមដែលក្រៅ អំពីរូបនាមនោះទេ ។

ចំណែកអ្នកដែលស្ដាប់មកច្រើន នឹងឃើញបានច្បាស់ជាងនេះ គឺនឹងយល់បានថា ក្នុងពេលដែលកំណត់ដឹង ឬមិនបានកំណត់ដឹង ក៏មានត្រឹមតែរូបនិងនាម ដទៃក្រៅអំពីរូបនេះ មិនមានបុគ្គល បុរស ស្ត្រី មានត្រឹមតែរូបនាមដែលកំណត់ដឹងនិងចិត្ត ( នាម ) ដែលជាតួកំណត់ដឹង ឬមានត្រឹមតែរូបដែលដែលជាទីតាំងរបស់នាម និងចិត្តដែលពិចារណាជាដើម ។ សត្វផ្សេងសន្មតិរូបនាមនេះថាជា បុគ្គល បុរស ឬស្ត្រី មានត្រឹម

តែវត្ថុដែលត្រូវបញ្ញត្តិប៉ុណ្ណោះ មិនមានបុគ្គល បុរស ឬស្ត្រីជាតួខ្លួនឡើយ ។ សូម្បីត្រឹមតែបន្តិចបន្តួចក៏មិនមាន បើពិចារណាបានយ៉ាងនេះ ក្នុងខណៈដែលកំពុងតែបដិបត្តិ គប្បីកំណត់ថា "ពិចារណាហ្ន៎" ហើយត្រឡប់មកកំណត់ដឹងសភាវៈប៉ោង-ផត ដូចគ្រាដើមវិញ ។

កាលការនាចាស់ក្លា ចិត្តដែលត្រូវការធ្វើអាកប្បកិរិយាយ៉ាងណានីមួយ នឹងប្រាកដច្បាស់ឡើងឯង ពោលគឺអ្នកបដិបត្តិអាចនឹងកំណត់ដឹងចិត្តបានទាន់ពេល មុននឹងកម្រើករាងកាយ ផ្សេងគ្នាពីការហ្វឹកហាត់បដិបត្តិធម៌ថ្មីៗ ពេលនោះសូម្បីនឹងកំណត់ថា "ចង់កោងហ្ន៎" ក៏មិនអាចទទួលដឹងចិត្តដែលចង់នឹងកោងបានជាក់ច្បាស់ធ្វើឲ្យដឹង ដូចជារូបដែលកំរើកយឺតជាងចិត្ត និងចិត្តកើតឡើងលឿនជារូប តែកាលការនាមានកម្លាំងច្រើនឡើង ក៏អាចនឹងកំណត់ចិត្តបាន លឿនជាក់ច្បាស់ដូចជាមួយការរង់ចាំទទួលសភាវៈកំរើកដែលនឹងកើតឡើងតទៅ និងមិនលាយឡំជាមួយអាកប្បកិរិយាផ្លូវកាយ ក្នុងខណៈនោះ គួរកំណត់ដឹងចិត្តមុនដែលត្រូវការនឹងសណ្តូក បត់ អង្គុយ

ឈរ ដើរ ជាដើម ។

សភាពត្រជាក់ ឬក្តៅច្រើនប៉ះខ្ទប់គ្នាហើយ អ្នកបដិបត្តិធម៌ កំណត់ថា "ត្រជាក់ហ្ន៎" ឬ "ក្តៅហ្ន៎" អាចទទួលដឹងសភាព ត្រជាក់ ឬក្តៅតិចៗ ដែលចាប់ផ្តើមឡើងក្នុងខណៈទទួលនូវ អាហារក៏អាចដឹងថា មានផល មានកម្លាំងផ្តើមឡើងជាលំដាប់ ខណៈដែលកំណត់សភាវៈប៉ោង-ផត នៅអាចប្រាកដអារម្មណ៍ ដទៃដែលប្រាកដច្បាស់ជាង ក៏គួរតាមកំណត់ដឹងអារម្មណ៍ ដែល ជាក់ច្បាស់ជាងនេះ ។

ខណៈខ្លះអាចឃើញរូបព្រះពុទ្ធ ឬព្រះអរហន្ត ឬខណៈខ្លះដែល កំណត់ទុក្ខវេទនា ( មានការឈឺជាដើម ) ក៏អាចមានអារម្មណ៍ ដទៃដែលច្បាស់ជាងមកប្រាកដ អ្នកបដិបត្តិត្រូវការប្តូរទៅកំណត់ អារម្មណ៍ជាក់ច្បាស់នោះ ការផ្លាស់ប្តូរទៅកំណត់សភាវៈដែល ប្រាកដច្បាស់ជាងនេះ នឹងជួយឲ្យយល់ចូលចិត្តថា ការកំណត់ ដឹងរមែងមានបាន ដោយអាស្រ័យអារម្មណ៍ដែលប្រាកដច្បាស់ ។

[ការកំណត់ដឹងត្រូវអាស្រ័យអារម្មណ៍ជានិច្ច ប្រៀបដូច ជាមនុស្សចាស់ ដែលត្រូវការអាស្រ័យឈើច្រត់ ឲ្យដើរទៅបាន

ចិត្តប្រៀបដូចជាមនុស្សចាស់ និងអារម្មណ៍ប្រៀបដូចជា ឈើ-ច្រត់ ដូច្នោះអារម្មណ៍ដែលជាទីពោងរបស់ចិត្តទើបបាន ឈ្មោះថា **អារម្មណបច្ច័យ** គឺ បច្ច័យដែលជាអារម្មណ៍ ] ។

ម្យ៉ាងទៀត ក្នុងខណៈដែលសភាវៈប៉ុន្មានតមិនប្រាកដច្បាស់ធ្វើឲ្យកំណត់បាន អ្នកបដិបត្តិធម៌ លំបាកនឹងយល់ចូលចិត្តថា ការកំណត់ដឹងរមែងមានមិនបាន កាលមានអារម្មណ៍កាលនោះគួរកំណត់ថា "អង្គុយហ្ន៎" "ពាល់ត្រូវហ្ន៎" "ដេកហ្ន៎" "ពាល់ត្រូវហ្ន៎" និងគួរកំណត់សភាវៈប៉ះខ្លួនសម្លស្សប្រមាណ ៤ ឬ ៥ ចំណុចផ្លាស់គ្នាដូចជាកាលកំណត់ថា "អង្គុយហ្ន៎" ហើយឲ្យកំណត់ថា "ពាល់ត្រូវហ្ន៎" កន្លែងជើងស្តាំជាដើម ។

ក្រោពីនេះ ក្នុងការកំណត់សភាវៈហើយ ឬបានឮក៏អាចយល់ចូលចិត្តបានងាយថា ការឃើញកើតអំពីដូងភ្នែក ( ចក្ខុ-បសាទ ) និងរូប ( រូបារម្មណ៍ ) ការបានឮកើតអំពីត្រចៀក និង សម្លេង ដូច្នេះជាដើម ។

[ការយល់ចូលចិត្តថា ឃើញកើតអំពីដូងភ្នែកនិងរូប រាប់ថាជាការឃើញហេតុបច្ច័យ គឺដូងភ្នែក និងរូបជាហេតុបច្ច័យឲ្យ

កើតផល គឺសភាវៈឃើញ ចំណែកហេតុបច្ច័យជារូបញ៉ាំងឲ្យកើតនាម គឺការឃើញ ចំណែកឯចិត្តដែលពោលមកមុននោះជានាមធម៌ដែលញ៉ាំងឲ្យកើតរូបគឺអាកប្បកិរិយាផ្លូវរាងកាយ] ។

ម្យ៉ាងទៀត អ្នកប្រាជ្ញសេចក្ដីព្យាយាមរមែងយល់ចូលចិត្តហេតុបច្ច័យ ដូចតទៅនេះថា :

-អាកប្បកិរិយាផ្លូវរាងកាយផ្សេងៗ បានព្រោះមានចិត្តដែលគិតនិងសណ្ដូក ឬបត់ជាដើម ។

-រាងកាយត្រជាក់ក្ដៅ ព្រោះមានធាតុត្រជាក់ និងធាតុក្ដៅ ។

-រាងកាយនេះតាំងនៅបាន ព្រោះមានអាហារបរិភោគ ។

-ការកំណត់ថាប៉ោង-ផតបាន ព្រោះមានសភាវៈប៉ោង-ផត។

-ការឃើញ និងបានឮមានបាន ព្រោះមានអារម្មណ៍ គឺរូប សម្លេង ក្លិន ឬព្រោះមានទីអាស្រ័យកើតនៃភ្នែក ត្រចៀកជាដើម។

-ការកំណត់ដឹងក្នុងខណៈពេលក្រោយកើតឡើងបាន ព្រោះមានការកំណត់ដឹងក្នុងគ្រាដំបូង ។

-វេទនាក្នុងបច្ចុប្បន្នមានទៅបាន ក៏ព្រោះមានកម្មក្នុងជាតិមុន ។

-រូបនាមក្នុងបច្ចុប្បន្ន មានតាំងតែអំពីបដិសន្ធិជាដើមមក ក៏ព្រោះមានកម្មក្នុងភពមុន ។

អ្នកបដិបត្តិទើបអាចយល់ចូលចិត្តបានថា រូបនាមសុទ្ធៗ កើតអំពីហេតុបច្ច័យ ដែលអាស្រ័យគ្នាប្រាសចាកអំណាចពីធម្មជាតិ ដែលបណ្ដាលឲ្យកើតឡើង ការយល់ចូលចិត្តដូច្នេះនឹងនើបឡើងបាន និងកើតឡើងច្បាស់ត្រឹមមួយជួខណៈ ទើបគួរកំណត់សភាវៈពិចារណានេះថា "ពិចារណាហ្ន៎" ឬ "យល់ចូលចិត្តហ្ន៎" ឬ "ដឹងហ្ន៎" ហើយត្រឡប់មកកំណត់នូវអារម្មណ៍ដូចគ្រាដើម ។

កាលអ្នកបដិបត្តិធម៌យល់ចូលចិត្តហើយថា រូបនាមដែលកំពុងកំណត់ដឹង កើតអំពីរូបនាមដែលជាហេតុបច្ច័យ រមែងយល់ចូលចិត្តតទៅថា រូបនាមក្នុងអតីតកើតឡើង ព្រោះហេតុនេះ សូម្បីរូបនាមក្នុងកាលអនាគតក៏កើតឡើង ព្រោះហេតុនេះ មិនមានបុគ្គល យើង របស់យើង មិនមានអ្នកនិម្មិតរូបនាម កាលនោះ គួរកំណត់សភាវៈពិចារណាយ៉ាងនេះ ហើយត្រឡប់មកកំណត់ដឹងអារម្មណ៍ ដូចគ្រាដើមវិញ ។

អ្នកសិក្សាធម៌មកតិច អាចពិចារណាបានមិនយូរ ផ្សេងគ្នាពីអ្នកដែលសិក្សាធម៌មកច្រើន ពិចារណាយូរ និងតទៅឆ្ងាយផង ក្នុងពេលបដិបត្តិមិនគួរពិចារណាច្រើន នឹងគួរកំណត់ដឹងសភាវធម៌បច្ចុប្បន្នជាគោល នឹងធ្វើឲ្យឈានទៅមុខបានលឿនជាងការពិចារណា ដោយការយល់ចូលចិត្តត្រឹមតែ បន្តិចបន្តួចក៏ល្អមណាស់ហើយ ។

ខណៈដែលសមាធិមានកម្លាំងច្រើនឡើង ទុក្ខវេទនាផ្លូវកាយដូចជាការរមាស់, ឈឺ, ពើត, ផ្សា, ក្រហល់ក្រហាយ...អាចប្រាកដដល់អ្នកបដិបត្តិ ហើយនិងអត់ទ្រាំបានដោយលំបាក ។ និងកាលមិនបានអត់ធន់កំណត់ដឹង ( គឺធ្វើទុកក្នុងចិត្តចំពោះការឈឺ ) វេទនាក៏នឹងបាត់ទៅឯង តែគួរចាប់ផ្តើមកំណត់ដឹងរហូតទាល់តែ មានសតិ សមាធិចាស់ក្លាឡើង វេទនាពួកនេះក៏នឹងប្រាកដឡើងទៀត ។ ជាការពិតហើយ វេទនានេះ មិនមែនរោគសាហាវខ្លាំងក្លានោះទេ តែនឹងប្រាកដតាមសភាវធម៌ ដែលអ្នកបដិបត្តិអាចឃើញលក្ខណៈវិសេសរបស់ទុក្ខវេទនា គឺសភាវៈដែលអត់ទ្រាំបានដោយលំបាក ចង់ឃ្លាតចេញអំពីទុក្ខវេទនា

ឲ្យព្យាយាមកំណត់វេទនានោះ ឲ្យបានល្អ ព្រោះមិនយូរឡើយ នឹងថយចុះ តិចឡើងៗ រហូតបាត់ទៅបាន ។

ក្រៅអំពីនោះ ក្នុងខណៈឃើញវត្ថុផ្សេងៗ ដូចជាការឃើញ ប្រចក្សដោយភ្នែក ដូចជា :

-ព្រះពុទ្ធ ដែលមានរស្មីផ្សាយចេញ ។

-ព្រះសង្ឃ ហោះឰដ៏អាកាស ។

-ព្រះចេតីយ៍ ។

-អ្នកដែលខ្លួនគោរពបូជា ។

-ដើមឈើ ព្រៃភ្នំ ឧទ្យាន ពពក ។

-សាកសពឡើងហើមប៉ោង ។

-គំនរឆ្អឹង ។

-សាកសព ដែលអាភាត់អាភាយនៅពាស់ពេញបន្ទប់ឬផ្ទះ ។ ខ្លួនឯងជាសាកសពឡើងហើមប៉ោង មានខ្ទុះហូរចេញ រហែក ជាកំណាត់ៗ ជាគំនរឆ្អឹង ឬផ្លាស់ប្តូរទៅជាប្រការដទៃ ។

-ឆ្អឹង សាច់ សរសៃ ពោះវៀន ថ្លើម ឬខ្ទុះដែលមានក្នុងខ្លួន ។

-នរក សួគ៌ សត្វនរក ប្រេត ទេវតា ព្រះឥន្ទ្រ ព្រះព្រហ្ម...។

ដែលមានប្រាកដទាំងអស់នេះ ត្រឹមតែជាបញ្ញត្តិ ដែលកើតឡើងអំពីកម្លាំងសមាធិ មិនមែនជាវត្ថុដែលគួរប្រាថ្នា ឬពេញចិត្ត ប្រៀបដូចជាយល់សប្តិប៉ុណ្ណោះ ។ តែមនោវិញ្ញាណដែលដឹងច្បាស់ ដូចដែលពោលមកនេះ គឺជាបរមត្ថ ដែលមានពិត អ្នកបដិបត្តិធម៌គួរកំណត់ដឹងសភាវៈឃើញថា "ឃើញហ្ន៎" រហូតដល់បាត់ទៅវិញ ព្រោះអារម្មណ៍ដែលប្រាកដក្នុងចិត្ត កំពុងតែកំណត់ដឹងនូវអារម្មណ៍ ។

ក្នុងខណៈខ្លះអារម្មណ៍ដែលប្រាកដច្បាស់ផ្លូវចិត្ត អាចផ្លាស់ប្តូរជាអារម្មណ៍ដទៃខ្លះ, តិចខ្លះ, បាត់ទៅខ្លះ, ខណៈខ្លះអាចកើតការកំណត់ដឹង ៤ ឬ៥ គ្រា កាលបើសមាធិមានកម្លាំងហើយកំណត់ដឹងត្រឹមតែ ១ ឬ២ គ្រាហើយក៏បាត់ទៅបាន ។ បើអ្នកបដិបត្តិធម៌ត្រូវការឃើញ ឬ ឮកដឹងហើយខ្លាចវត្ថុដែលប្រាកដ អារម្មណ៍នោះនឹងប្រាកដនៅយូរ និងជាអារម្មណ៍ដែលអ្នកគិតរវើរវាយរាយមាយ ពេញចិត្ត នឹងកើតយូរឡើង ដូច្នោះទើបគួរវាងប្រុងប្រយ័ត្ន កុំគិតរវើរវាយ ក្នុងកម្លុងពេល ដែលសមាធិមានកម្លាំងច្រើនឡើង កាលដឹងខ្លួនថាគិតរវើរវាយឲ្យ

ប្រញាប់កំណត់ដឹងនូវសភាវៈរវើរវាយនោះទាន់ពេល ។

អ្នកខ្លះរញ្ជួកដឹងហើយធុញទ្រាន់ ( ខ្ជិល ) ព្រោះចាំមើលតាមសភាវធម៌ដដែលៗ ទៅមកដោយមិនមានអ្វីប្លែកថ្មីសោះ ឬមិនប្រាកដវេទនាប្លែកៗ មកប្រាកដគួរប្រញាប់កំណត់ដឹងសភាវៈធុញទ្រាន់នោះ រហូតទាល់តែបាត់ទៅថា "ធុញទ្រាន់ហ្ន៎" ក្នុងរយៈពេលនោះមិនថា នឹងទទួលអារម្មណ៍ប្លែកៗ ឬថ្មី មិនមែនជារឿងសំខាន់ទេ វត្ថុសំខាន់ គឺត្រូវកំណត់ដឹងទៅរហូតតាំងតែពីចាប់ផ្តើមពីដើមរហូតដល់ចុងទីបំផុតនៃសភាវៈ ដែលកំពុងកំណត់ដឹង ។ ក្រៅពីនោះក្នុងពេលចាប់បដិបត្តិ រមែងត្រូវផ្លាស់ប្តូរកំណត់ដឹងអារម្មណ៍ដទៃ ដែលមកប្រាកដខណៈកំពុងកំណត់ដឹងអារម្មណ៍ដទៃតែម្យ៉ាង ។

តែក្នុងរយៈពេលនេះនឹងទទួលដឹងបានថាអារម្មណ៍ចាស់រលត់ទៅ ហើយប្រាកដអារម្មណ៍ថ្មី ទើបអាចដឹង ឬប្រចក្សច្បាស់ដល់ការចាប់ផ្តើមគ្រាដំបូង ទៅរហូតដល់ទីបំផុតរបស់អារម្មណ៍ដែលកំពុងកំណត់ដឹងបាន ។

ពេលនោះអ្នកបដិបត្តិ រមែងអាចប្រចក្សច្បាស់នូវការកើត

ឡើងនិងការរលត់ទៅរបស់សភាវធម៌បច្ចុប្បន្ន ដែលទទួលដឹងបានយ៉ាងជាក់ច្បាស់ ធ្វើឲ្យយល់ចូលចិត្តថា រូបនាមគ្រប់យ៉ាងមិនទៀងកើតឡើង ហើយរលត់រទៅវិញគ្រប់ៗ ខណៈ ។

ដូចសេចក្តីក្នុងព្រះបាលី និងអដ្ឋកថាពោលថា៖

**អនិច្ចំ ខយដ្ឋេន ។**

" មិនទៀង ព្រោះមានសភាពអស់ទៅ " ។

**ហុត្វា អភាវតោ អនិច្ចា ។**

"មិនទៀង ព្រោះកើតឡើងហើយរលត់ទៅ" ។

ក្រោយពីនោះ គេរមែងយល់ចូលចិត្តថា រូបនាមដែលកំពុងកើតរលត់នោះជាទុក្ខ យើងភ្លើតភ្លើនត្រេកអរក្នុងរូបនាមនោះ ដោយសភាពវង្វេង មិនដឹងសេចក្តីពិតវត្ថុពួកនោះ មិនគួរភ្លើតភ្លើនត្រេកអរ សូម្បីត្រឹមតែបន្តិចបន្តួច កាលកើតឡើងហើយ ក៏រលត់ទៅជានិច្ច ត្រូវគៀបសង្កត់ដោយការកើតឡើង ហើយរលត់ទៅ និងជារបស់គួរខ្លាច ដូចសេចក្តីក្នុងព្រះបាលីនិង អដ្ឋកថាថា៖

**យទនិច្ចំ តំ ទុក្ខំ ។**

"របស់ណាមិនទៀង របស់នោះជាទុក្ខ" ។

**ទុក្ខំ ភយដ្ឋេន ។**

“ជាទុក្ខ ព្រោះសភាពគួរខ្លាច” ។

**ឧទយព្វយបដិប្បីឡនតោ ទុក្ខា ។**

“ជាទុក្ខ ព្រោះលាយឡំដោយការកើតរលត់ ” ។

ក្រៅពីនោះ កាលជួបជាមួយទុក្ខវេទនាដែលអត់ទ្រាំបាន ដោយលំបាក ក៏អាចពិចារណាថា រូបនាមមិនមែនជារបស់ល្អ ជាទុក្ខ ដូចសេចក្តីក្នុងព្រះបាលី និងអដ្ឋកថា៖

**ទុក្ខមទក្ខិ សស្លតោ ។**

“ឃើញទុក្ខថា ដូចជាកូនសរ ” ។

**ទុក្ខវត្ថុតាយ ច ទុក្ខតោ ។**

“ឃើញទុក្ខ ដោយសភាពជារបស់តាំងនៅនៃទុក្ខ ” ។

**រោគតោ គណ្ឌតោ សស្លតោ ។**

“ឃើញថា ជារោគ ជាបូស ជាកូនសរ ” ។

[ ទុក្ខគឺជាវត្ថុដែលមិនគួរប្រាថ្នា ដូចជារោគបូស ឬកូនសរ ដែលគួរប្រាថ្នានោះទេ ធ្វើឲ្យជាទុក្ខក្តៅក្រហល់ក្រហាយ ] ។

ក្រៅអំពីនោះ គេអាចពិចារណាថា "រូបនាមកើតឡើង ហើយរលត់ទៅ ដូចជាកងទុក្ខសុទ្ធៗ មិននៅក្នុងអំណាចរបស់ ខ្លួន ប្រាសចាកខ្លឹមទៀង និងជាទុក្ខមិនមែនតួខ្លួន ដែលយើង មិនអាចបង្គាប់បញ្ជាឲ្យកើតឡើង ឬកុំឲ្យរលត់ទៅ ដូចសេចក្តី ក្នុងព្រះបាលី និងអដ្ឋកថា ពោលថា៖

**យំ ទុក្ខំ តទនត្តា ។**

"របស់ណាដែលជាទុក្ខ របស់នោះមិនមែនជាតួខ្លួន" ។

**អនត្តា អសារដ្ឋេន ។**

"ជាអនត្តាព្រោះ មានសភាពប្រាសចាកខ្លឹម" ។

**អវសវត្តនតោ អនត្តា ។**

"ជាអនត្តា ព្រោះមិនប្រព្រឹត្តទៅតាមអំណាចខ្លួន " ។

ការពិចារណាត្រៃលក្ខណ៍ដូច្នេះហើយ គប្បីកំណត់តាម ន័យដែលពិចារណាថា "ពិចារណាហ្ន៎" ហើយត្រឡប់ទៅ កំណត់អារម្មណ៍ដូចគ្រាដើម ។

តាមអ្នកបដិបត្តិដឹងជាក់ច្បាស់ ឃើញប្រចក្សអារម្មណ៍បច្ចុប្បន្ន ជាមិនទៀង ជាទុក្ខ ជាអនត្តា ក៏រមែងពិចារណាដល់សភាវ-

ធម៌គ្រប់យ៉ាង ដែលមិនឃើញប្រចក្សថា មានសភាពមិនទៀង ជាទុក្ខ ជាអនត្តា តែមួយដូចគ្នា កាលបើពិចារណាយ៉ាងនោះ ចាត់ជា**អនុលោមញាណ** គឺបញ្ញា ដែលអនុមានដឹងបន្តអំពី **បច្ចក្ខញាណ** គឺបញ្ញាឃើញប្រចក្ស ។

អ្នកដែលសិក្សាគោលធម៌មកតិច រមែងកំណត់ដឹងបានយ៉ាងបន្តបន្ទាប់ដោយមិនបានពិចារណា អ្នកខ្លះកំពុងគិត ជាមួយការគិតពិចារណាក្នុងញាណលំដាប់នោះ ញ៉ាំងផលឲ្យកើតការឈានទៅមុន ឈប់ចុះ រហូតកាលចម្រើនសមាធិសម្រេចវិបស្សនាញាណជាន់ខ្ពស់ ហើយក៏ឃើញរូបនាមបានជាក់ច្បាស់ ដូច្នេះ អ្នកបដិបត្តិទើបមិនគួរពិចារណាដដែលៗ តែគួរពិចារណាការកំណត់សភាវធម៌បច្ចុប្បន្នយ៉ាងបន្តបន្ទាប់រឿយៗ មិនដាច់រវាងចន្លោះ ។

បុគ្គលអ្នកដែលឃើញការមិនទៀង ជាទុក្ខ និងមិនមែនតួខ្លួន ដែលជំនាញក្នុងការបដិបត្តិ ហើយរមែងតាមដឹងសភាវធម៌ដែលប្រាកដក្នុងខណៈនោះ ដោយមិនបាច់ត្រិះរិះពិចារណា ក្នុងខណៈនោះ ឥន្ទ្រិយ៍ ៥ គឺសទ្ធា វិរិយ សតិ សមាធិ និងបញ្ញា

រមែងស្មើគ្នា មិនក្រលែងជាងគ្នានិងគ្នា ចិត្តបានទទួលការបាស់ក្លា ដោយឥន្ទ្រិយ៍ពួកនោះ ញុំាងផលឲ្យទទួលដឹងរូបនាម បានរហ័សទាន់សភាវបច្ចុប្បន្ន ។

ក្នុងខណៈដែលដកដង្ហើមចូលសភាវៈប៉ោង អាចប្រាកដច្រើនលំដាប់ខ្ពស់ ឬក្នុងខណៈដែលដកដង្ហើមចេញសភាវៈផតក៏ប្រាកដជាច្រើនដង សូម្បីក្នុងពេលធ្វើឥរិយាបថតូចធំ ដែលសណ្តូក បត់ ។ល។ សភាវៈកម្រើកកើតរលត់ជាខណៈៗ រមែងប្រាកដ អ្នកខ្លះអាចប្រាសចាកសេចក្តីតក់ស្លុតបន្តិចបន្តួច ក្នុងសរីរៈរាងកាយ ឬទទួលដឹងសភាវៈប៉ះខ្ទប់សម្ផស្ស ដែលប្លែកៗនៃរាងកាយ, ពេលខ្លះអាចរឭកដឹងដល់សភាវៈរមាស់ពេញខ្លួន ឬមានសភាវៈ ឈឺចុកចាប់បន្តិចបន្តួច កើតឡើងម្តងទៀត យ៉ាងលឿនរហ័សបាន ភាគច្រើន សភាវៈដូចដែលបានពោលមកនេះមិនមែនជាការរមាស់ ឬការឈឺចុកចាប់ណាស់ណានោះទេ ។

កាលនោះ អ្នកបដិបត្តិធម៌ មិនអាចនឹងកំណត់ដឹងដោយបរិកម្មតាមសភាវៈដែលប្រាកដយ៉ាងលឿនរហ័សបាន តែអាចប្រើសតិតាមដឹងបានទាន់ពេលយ៉ាងជាក់ច្បាស់ ទើបគួរប្រើសតិ

តាមដឹងប៉ុណ្ណោះ ។ មិនគួរបរិកម្មតាមសភាវៈ ដែលប្រាកដ បើធ្វើទុកក្នុងចិត្តនូវបរិកម្ម ក៏អាចធ្វើឲ្យនឿយណាយបានងាយ ក្នុងគ្រាខ្លះ អាចបរិកម្មត្រឹមតែ ២ ដង តែនឹងឃើញច្បាស់នូវសភាវធម៌ដែលប្រាកដបានរហូត ៤០ ឬ៥០ គ្រា ។ ខណៈនោះ ទើបមិនគួរតាមដឹងអារម្មណ៍តែមួយ គួរកំណត់ដឹងសភាវៈ ដែលប្រាកដច្បាស់តាមទ្វារ ៦ តែបើកំណត់ដូច្នេះហើយ បែរជាដឹងមិនល្អ ក៏គួរត្រឡប់មកកំណត់អារម្មណ៍ដើមវិញ ។

រូបនាម ដែលមានការកើតរលត់រហ័សជាងការប៉ព្រិចភ្នែក ឬផ្លេកបន្ទោរ កាលបើអ្នកចំរើនវិបស្សនាអាចប្រចក្សច្បាស់នូវការកើតរលត់យ៉ាងលឿនរហ័សបានហើយ សតិរបស់អ្នកនោះនឹងមានកម្លាំងច្រើនជាងមុន អាចបង្អោនទៅរកអារម្មណ៍បច្ចុប្បន្នទាន់ពេល អារម្មណ៍ក៏ប្រាកដច្បាស់ដូចជាមួយសតិ ( ទន្ទឹមគ្នា )។ ម្យ៉ាងទៀតទាំងបញ្ញា ក៏ប្រចក្សច្បាស់នូវសភាវធម៌ដែលប្រាកដច្បាស់តែម្យ៉ាងមិនលាយឡំគ្នា បុគ្គលនោះ រមែងត្រិះរិះថា រូបនាមកើតរលត់យ៉ាងលឿនរហ័សដូចគ្រឿងចក្រ ដែលធ្វើការងារតាមឋានៈរបស់ខ្លួន សូម្បីរូបនាមដែលនឹងកើតរលត់លឿន

យ៉ាងនេះ ក៏អាចដឹងបានច្បាស់ វត្ថុដែលគួរដឹងគង់នឹងមានត្រឹមតែប៉ុណ្ណោះ មិនមានវត្ថុដទៃក្រៅអំពីនេះឡើយ ។ ការត្រិះរិះដូចដែលបានពោលមកនេះ ជាកាគិតឃើញដែលកើតអំពីបទពិសោធន៍ ពិតមែនហើយ ការកើតរលត់ដែលមិនធ្លាប់ជួបប្រទះ សូម្បីក្នុងខណៈដែលយល់សប្តិ ។

បទពិសោធន៍របៀបខ្លះ [ **វិបស្សនូបក្កិលេស ១០យ៉ាង** ] ដែលអាចដឹងបានដោយអំណាចរបស់វិបស្សនា ដូចជា :

**១. ឱភាស** ពន្លឺ ដោយអំណាចពន្លឺដែលកើតយូរ ឬមួយគ្រា ។

**២. បីតិ** សេចក្តីឆ្អែតកាយ ឆ្អែតចិត្ត, ដោយរឭកដឹងថា សប្បាយចិត្ត ដែលជ្រួតជ្រាបពេញរាងកាយ ទឹកភ្នែកហូរ... អណ្តែតខ្លួនដូចជិះលើដី ឬត្រជាក់ពាសពេញរាងកាយ ។

**៣. បស្សទ្ធិ** សេចក្តីស្ងប់ ដោយរឭកដឹងថាស្ងប់កាយ ស្ងប់ចិត្តក្នុងខណៈកំពុងដើរ អង្គុយ ដេក និងឥរិយាបថផ្សេងៗ ក្នុងគ្រាខ្លះអាចកើតសេចក្តីស្រាលកាយស្រួល ( កាយលហុតា ) ដែលធ្វើឲ្យអង្គុយ ឬដេកកំណត់បានយ៉ាងបន្តបន្ទាប់គ្នា អស់ពេលយូរប្រាសចាកការឈឺចុកចាប់ផ្លូវកាយ ។

**៤. អធិមោក្ខ:** ការចុះស៊ប់ក្នុងអារម្មណ៍ ដោយរឭកដឹងដល់ការផូរផង់នៃចិត្តដែលមិនមានកិលេសបៀតបៀន ខណៈខ្លះអាចកើតសេចក្តីជ្រះថ្លា ព្រោះយល់ជ្រាប់ក្នុងគុណព្រះពុទ្ធថា ព្រះអង្គជាសព្វញ្ញុពុទ្ធទ្រង់ជ្រាបច្បាស់នូវធម៌ទាំងពួង ពាក្យប្រៀនប្រដៅដែលព្រះអង្គត្រាស់សម្តែង មានត្រឹមតែរូបនាមដែលមិនទៀងជាទុក្ខ និងមិនមែនខ្លួនយ៉ាងពិតប្រាកដ ។

**៥. បគ្គហ:** សេចក្តីព្យាយាម ដោយរឭកដឹងថា តស៊ូព្យាយាមចង់បដិបត្តិធម៌ ដើម្បីប្រាកដសេចក្តីទម្រន់ ឬការខ្ជិលប្រអូសក្នុងខណៈ ត្រូវការនឹងសម្តែងធម៌ឲ្យអ្នកដទៃបានយល់ ដោយខ្លួនឯង ។

**៦. សុខ:** សេចក្តីសុខ ដោយរឭកដឹងសេចក្តីសុខកាយ និងសុខចិត្ត ។

**៧. ញាណ:** វិបស្សនាញាណដែលប្រាកដច្បាស់ ។

**៨. ឧបដ្ឋាន:** សតិដែលប្រាកដច្បាស់ ។

**៩. ឧបេក្ខា** ការដាក់ចិត្តជាកណ្តាល ដែលកើតរួមជាមួយនឹងវិបស្សនាញាណ ដែលមិនត្រូវដាក់ចុះនូវវីរិយ និងសមាធិឲ្យ

ស្មើគ្នា ក្រៅអំពីធម៌ ២ ប្រការ ដែលមានការថ្លឹងថ្លែងស្មើគ្នាទាំងអស់ ។

**១០. និកន្តិ** ការកើតភ្ញើនត្រេកត្រអាលក្នុងសភាវៈ ៩ ចំណុចខាងដើម បន្តបន្ទាប់អំពីការបដិបត្តិធម៌ បណ្តាលឲ្យបដិបត្តិធម៌អស់ពេលយូរ ដោយមិននឿយណាយ ។

អ្នកបដិបត្តិធម៌ដាក់ចិត្តចំពោះពន្លឺ ឬ ជួបហេតុដទៃដែលធ្លាប់បានទទួលច្រើនហើយ គួរកំណត់ថា "ឃើញហ្ន៎ៗ" ឬ "ស្អែតហ្ន៎ៗ" "ពិចារណាហ្ន៎ៗ" "ជ្រះថ្លាហ្ន៎ៗ" "ចិត្តល្អហ្ន៎ៗ" ឬ "ស្អែតចិត្តហ្ន៎ៗ" តាមសភាវៈនោះៗ ក្នុងខាងដើមអាចរញ្ញកដឹងសេចក្តីពេញចិត្តត្រង់ពន្លឺ សូម្បីនឹងកំណត់សភាវៈឃើញ ពន្លឺក៏មិនបានបាត់ទៅ ព្រោះអ្នកបដិបត្តិមានសេចក្តីពេញចិត្ត ( និកន្តិ ) តមកការជួបប្រទះ ដែលធ្លាប់ឃើញ ក៏អាចនឹងយកឈ្នះបានហើយកំណត់រហូតដល់ទៅបុគ្គលខ្វះឆាយជួបប្រទះ នឹងពន្លឺអស់ពេលយូរ សូម្បីតែនឹងកំណត់ដឹងក៏មិនបាត់ទៅ ក្នុងពេលនោះទើបមិនគួរដាក់ចិត្តចំពោះពន្លឺ ឲ្យចាប់យកជា ខាងក្រោយនៃការបដិបត្តិតែគួរផ្តោះមុខ ( ផ្លូវស្មារតី ) កំណត់ដឹងសភាវធម៌

ផ្លូវកាយ និងចិត្តដែលប្រាកដច្បាស់ជាគោល និងមិនគួរពិចារណាថា ពន្លឺនៅប្រាកដដែរឬហ្ន៎? ព្រោះបើបាន ពិចារណាយ៉ាងនោះហើយអាចធ្វើឲ្យពន្លឺប្រាកដរឿយៗ ។

បុគលខ្លះមានសមាធិផ្ដើមឡើងហើយបានបង្អោនចិត្តគិតទៅដល់វត្ថុផ្សេងៗ ធ្វើឲ្យមានពន្លឺនិងអារម្មណ៍ដទៃៗ ប្រាកដឡើងក្នុងចិត្ត ដូច្នេះ ទើបមិនគួរបង្អោនចិត្តគិតទៅ ហើយក៏ឲ្យលះបង់សេចក្ដីភយមាយនោះដោយការកំណត់ដឹង ។

បុគ្គលខ្លះសូម្បីនឹង មិនបានបង្អោនចិត្តគិតដល់ ក៏អាចឃើញវត្ថុផ្សេងៗ ដែលមិនច្បាស់មកប្រាកដយ៉ាងលឿនរហ័សហើយនឹងដូចរថភ្លើង ដែលរត់ទៅដោយរហ័ស ក្នុងខណៈនោះគួរកំណត់ថា "ឃើញហ្ន៎ៗ" អារម្មណ៍ប្រាកដផ្លូវចិត្តនឹងបាត់ទៅកន្លែងមួយដោយកំណត់ដឹង ក្នុងគ្រាតែមួយជាមួយគ្នា តែកាលបើសមាធិថយចុះ វត្ថុដែលបានជួបប្រទះ តាមផ្លូវចិត្តអាចប្រាកដច្បាស់ កាលកំណត់ថា "ឃើញហ្ន៎ៗ"អារម្មណ៍ទាំងនោះ រមែងអន្តរធានទៅ ក្នុងទីបំផុតសេចក្ដីភយមាយរមែងស្ងប់រម្ងាប់ ។

តអំពីនោះអ្នកបដិបត្តិធម៌គួរយល់ថា ការដាក់ចិត្តចំពោះ

ពន្ធជាដើម មិនត្រឹមត្រូវ ឯខបដិបត្តិដែលត្រឹមត្រូវនោះគឺ ការកំណត់ដឹងទាន់សភាវធម៌បច្ចុប្បន្ន គឺរូបនាម ដែលប្រាកដផ្លូវកាយនិងផ្លូវចិត្ត តាមសេចក្ដីពិត ហើយកំណត់ដឹងយ៉ាងបន្ត-បន្ទាប់ជានិច្ច វិបស្សនាញាណ រមែងប្រាកដច្បាស់ឡើងតាមលំដាប់ហើយ នឹងកើតបញ្ញាប្រចក្សច្បាស់ ឃើញការកើតនិងការរលត់ទៅភ្លាមយ៉ាងលឿនរហ័ស សភាវធម៌ដែលកើតឡើងមុន បានជាប់តាមសភាវៈដែលកើតខាងក្រោយ អ្នកបដិបត្តិធម៌រមែងយល់យ៉ាងច្បាស់ថា រូបមិនទៀង ជាទុក្ខ និងជាអនត្តា ។

បុគ្គលខ្លះ យល់យ៉ាងនេះហើយ អាចរឭកដឹងសេចក្ដីពេញចិត្តចំពោះហេតុការណ៍ ដែលកើតឡើង ហើយឈប់ធ្វើការបដិបត្តិដោយគិតថា មិនមានវត្ថុណាប្រសើរជាងវត្ថុនេះទៀតទេ គប្បីឈប់កំណត់ដឹង គួរបដិបត្តិទៅកុំឲ្យដាច់គ្នា ក៏នឹងឃើញបានថា សេចក្ដីចម្រើនទៅមុខមានទៅជាលំដាប់ ។

កាលបើវិបស្សនាញាណ ដល់នូវភាពចាស់ក្លាឡើងតាមលំដាប់ អ្នកបដិបត្តិធម៌នឹងមិនទទួលដឹងសភាវៈផ្ដើមកើតឡើងរបស់អារម្មណ៍បច្ចុប្បន្ន តែរមែងដឹងដល់សភាវៈរលត់ទៅ តែ

ម្យ៉ាងធ្វើឲ្យរឭកដឹងថា មានតែការរលត់ទៅ ដែលកំពុងប្រាកដ ក្នុងខណៈខ្លះ អាចដឹងច្បាស់នូវការរលត់ទៅរបស់ចិត្ត ដែលកំណត់ដឹងបានទៀតផង ពោលគឺ ក្នុងខណៈកំណត់ថា "ប៉ោងហ្ន៎" អាចរឭកដឹងថា សភាវៈប៉ោងបានរលត់ទៅយ៉ាងលឿនរហ័ស នឹងរឭកដឹងថាចិត្ត ដែលកំណត់ដឹងសភាវៈ ដូចបានពោលមកនេះ រលត់ទៅជាមួយគ្នា បុគ្គលនោះ រមែងដឹងថា សភាវៈប៉ោងនិងចិត្ត ដែលកំណត់ដឹង ក៏រលត់ទៅតាមគ្នា ប្រព្រឹត្តទៅជាលំដាប់ ។

សូម្បីក្នុងខណៈ ដែលកំណត់ថា "ផតហ្ន៎" "អង្គុយហ្ន៎" "កោងហ្ន៎" "សណ្តូកហ្ន៎" "ចុកហ្ន៎" ជាដើម ។ ក៏អាចឃើញច្បាស់ក្នុងការរលត់ទៅនៃសភាវធម៌ និងចិត្ត ដែលកំណត់ដឹងបាន តាមលំដាប់ បុគ្គលខ្លះ អាចឃើញច្បាស់ ការរលត់ទៅរបស់សភាវធម៌ ។ ចិត្តដែលកំណត់ដឹង និងសតិដែលកំណត់ដឹងចិត្ត ដែលពោលមកនេះ ជាបីផ្នែក រលត់ទៅតាមលំដាប់យ៉ាងណាក៏ដោយ បើអាចឃើញច្បាស់ក្នុងការរលត់ទៅរបស់សភាវធម៌ និងចិត្តដែលកំណត់ដឹងបាន ពីរយ៉ាង ក៏ដឹងថាគ្រប់

គ្រាន់ហើយ ។

កាលអ្នកបដិបត្តិធម៌បានឃើញច្បាស់នូវការរលត់ទៅនៃសភាវធម៌បច្ចុប្បន្ន ដែលកំណត់ដឹងយ៉ាងនេះ ហើយរូបរាងសណ្ឋាន ដែលហៅថា **ឃនបញ្ញត្តិ** មាន រូបរាងកាយ ក្បាល ដៃជើង ជាដើមរមែងអន្តរធានទៅឯង ហើយទឹងដឹងដល់ការរលត់ទៅយ៉ាងលឿនរហ័ស ប្រាកដឡើងក្នុងរាងកាយនេះ ដោយប្រាសចាកសម្មតិបញ្ញត្តិទាំងអស់ក្នុងខណៈនោះ អ្នកខ្លះ អាចរឭកដឹងថា ការបដិបត្តិធម៌មិនឈានទៅមុខ និងការកំណត់ដឹងមិនមាំទាំ ព្រោះសេចក្តីភយមាយ រមែងកើតឡើងបានងាយការយល់ដូច្នេះ មិនទាន់ត្រឹមត្រូវឡើយ ព្រោះចិត្តរបស់មនុស្សទូទៅរមែងត្រេកត្រអាលក្នុងរូបរាងសណ្ឋាន ដែលជាសម្មតិបញ្ញត្តិ កាលបើបានទទួលអារម្មណ៍បញ្ញត្តិ ដែលជាទីស្រឡាញ់ ដូចមុនរមែងរឭកដឹង ហើយមិនត្រេកត្រអាល ។

ពិតមែនហើយ ការរឭកដឹងដូច្នេះ ជាការឈានទៅមុខមួយកម្រិតទៀត ព្រោះការតាំងចិត្តពិចារណា ក្នុងខណៈខ្លះ ដែលវិបស្សនាញាណ នៅមិនទាន់ចាស់ក្លា អារម្មណ៍បញ្ញត្តិ រមែង

ប្រាកដមកមុន ក្នុងពេលដែលឃើញ, បានឮ និងការប៉ះខ្ទប់សម្ផស្សជាដើម តែកាលវិបស្សនាញាណចម្រើនឡើង ហើយសភាវៈរលត់ទៅ រមែងប្រាកដច្បាស់ក្នុងខណៈនោះ នឹងអាចឃើញច្បាស់នូវសភាវធម៌យ៉ាងប្រចក្ស ដោយកន្លងបង់នូវបញ្ញត្តិគ្រប់បែបយ៉ាង គេរមែងប្រចក្សច្បាស់បាន ។ សមពិតដូចពាក្យរបស់បោរាណាចារ្យ ដែលពោលថា :

"កាលបញ្ញត្តិប្រាកដ បរមត្ថរមែងបាត់ទៅ, កាលបរមត្ថប្រាកដ បញ្ញត្តិរមែងបាត់ទៅ " ។

ក្នុងខណៈដែលកំណត់ដឹងប្រាកដច្បាស់ អ្នកបដិបត្តិអាចឮកដឹងថា មានការចន្លោះរវាងនៃការកំណត់ដឹង មុននិងក្រោយការឮកដឹងដូចពោលមកនេះ ជាការទទួលដឹងរយៈ ពេលនៃការកើតឡើងរបស់ភវង្គចិត្ត គឺចិត្តដែលផុតការដឹង ដែលកើតឡើងរវាងនៃវិថីចិត្តក្នុងពេលជាប្រក្រតី ព្រោះជាបញ្ញា ដែលទទួលដឹងបានលឿនរហ័សជាងមុន ។ បុគ្គលខ្លះកំណត់ដឹងចិត្ត ដែលត្រូវការនឹងសណ្តូក ឬបត់ ធ្វើឲ្យចិត្តនោះបាត់ទៅ ទើបមិនអាចសណ្តូក ឬបត់បានទាន់ពេលក្នុងខណៈនោះ អ្នកបដិបត្តិធម៌

មិនគួរប្រញាប់ប្រញាល់កំណត់ដឹងអារម្មណ៍ ដែលប្រាកដតាមផ្លូវទ្វារទាំង ៦ ទេ ។

## "វិធីចាប់ផ្តើមអារម្មណ៍នៃការកំណត់ដឹង"

អ្នកបដិបត្តិធម៌ ដែលកំណត់ដឹងសភាវបច្ចុប្បន្ន ដោយន័យថា "ប៉ោងហ្ន៎" "ផតហ្ន៎" "អង្គុយហ្ន៎"ជាដើម បានល្អ ហើយនឹងមានសមាធិចាស់ក្លាឡើង ក៏គួរកំណត់ដឹងសភាវៈប៉ះខ្ទប់ច្រើនកន្លែង ដែលប្រាកដផ្លូវកាយ ព្រមទៅដោយការឃើញ ឬបានឮជាដើម ដែលប្រាកដយ៉ាងជាក់ច្បាស់ កាលបើបដិបត្តិដូច្នេះហើយកំណត់ដឹងបានមិនល្អវិញ មានការរវើរវាយប្រាកដឡើង ឬរឭកដឹងការអស់កម្លាំងចិត្ត ក៏គួរបន្ថយសេចក្តីព្យាយាម ដោយកំណត់ដឹងសភាវៈប៉ោង-ផត និងសភាវៈអង្គុយជាដើម ។ តមកកាលបើកំណត់ដឹងល្អហើយ ទាំងសមាធិក៏មានកម្លាំងច្រើន ទើបផ្តើមការកំណត់ឲ្យក្រៃលែងជាងមុន ។

ក្នុងខណៈដែលអ្នកបដិបត្តិផ្ចង់សតិកំណត់ដឹងសភាវធម៌ ដែលប្រាកដច្បាស់ក្នុងរាងកាយ សូម្បីនឹងបានតាំងចិត្តកំណត់ដឹងច្រើនលើក ច្រើនគ្រា ក៏អាចប្រែចក្សុនូវសភាវធម៌ ដែល

បានឮ ជាសភាវៈរលត់ទៅយ៉ាងលឿនរហ័ស ដែលមិនជាប់តគ្នា ក្នុងគ្រាខ្លះ អាចជួបប្រទះថា វត្ថុដែលបានឃើញនោះ បានរលត់យ៉ាងលឿនរហ័ស អ្នកខ្លះ សូម្បីទឹងតាំងចិត្តមើល ក៏សម្លឹងមើលមិនឃើញច្បាស់ ព្រោះឃើញការរលត់ទៅយ៉ាងលឿនរហ័ស ធ្វើឲ្យរលឹកដឹងថា សម្លឹងឃើញមិនបានច្បាស់ [ដូចគ្នាជាមួយការមើលភាពយន្ត ដែលមានរូបដាច់ទៅជាចន្លោះៗ] ឬស្រវាំងភ្នែកវិលមុខ ដូចដែលពោលមកនេះជា សភាវៈដែលកើតពីការមិនបានទទួលដឹងនូវសម្មតិបញ្ញត្តិ យ៉ាងពិតប្រាកដ ។ ព្រោះបានប្រចក្សសភាវៈឃើញ ដែលរលត់ទៅជាលំដាប់លំដោយ ។ រហូតទាល់តែមើលមិនឃើញសម្មតិបញ្ញត្តិ តែបើឈប់កំណត់ដឹង ក៏នឹងជួបនូវសម្មតិបញ្ញត្តិ ដែលប្រាកដប្រក្រតី ។

អ្នករឭកដឹងថា សតិរបស់ខ្លួនអាចតាមកំណត់ដឹងរូបនាមបច្ចុប្បន្នបានរហូតគ្រប់កាល សូម្បីនឹងដេកលក់ ក៏មិនសូវមានសភាពស្វាងស្វៃទាំងពេលយប់ពេលថ្ងៃ ក៏មិនគប្បីកង្វល់ជាមួយការដេកលក់ ព្រោះមិនមែនជាអន្តរាយដល់សុខភាពយ៉ាងណា-នីមួយ ។ គួរព្យាយាមកំណត់ដឹងយ៉ាងបន្តបន្ទាប់ តទៅកាលបើ

វិបស្សនាញាណមានកម្លាំងផ្ដើមឡើង សតិរបស់អ្នកបដិបត្តិធម៌រមែងប្រាកដច្បាស់ដូចធ្លាក់ចូលទៅរកអារម្មណ៍បច្ចុប្បន្ន ។

កាលអ្នកបដិបត្តិធម៌ឃើញច្បាស់នូវការរលត់ទៅរបស់ធម៌បច្ចុប្បន្ន និងចិត្តដែលកំណត់ដឹងយ៉ាងនេះហើយ ទើបរមែងពិចារណាថា "សភាវៈគ្រប់យ៉ាង មិនបានតាំងនៅក្នុងខណៈដែលប៉ព្រិចភ្នែក ឬដូចក្រសែផ្លេកបន្ទោរ មានសភាពមិនទៀងសូម្បីសភាវធម៌ ដែលកើតឡើងហើយ ឬដែលនឹងកើតឡើងតទៅ មានសភាពមិនទៀង ត្រូវរលត់ទៅយ៉ាងលឿនរហ័ស" ក្នុងខណៈនោះ គួរកំណត់ដឹងចិត្ត ដែលគិតពិចារណានោះផង ។

ក្រោយពីនោះ ក្នុងខណៈខ្លះដែលកំពុងកំណត់ដឹង កំពុងតែពិចារណាដល់សេចក្ដី ដែលគួរឲ្យខ្លាចបានច្រើនលក្ខណៈដូចជា៖

-កាលមុននេះ យើងខ្វះបញ្ញាកំណត់ដឹង ទើបកើតសេចក្ដីត្រេកត្រអាល កាលបានជួបនូវការរលត់ទៅរបស់រូបនាមហើយយល់ចូលចិត្តថា រូបនាមគួរឲ្យខ្លាចពិតៗ ។

-គ្រប់ពេលសិតសឹងតែជាខណៈនៃការស្លាប់ ដែលរូបនាមត្រូវទៅតាមធម្មជាតិ ដែលគួរឲ្យខ្លាចពិតៗ ។

-ការកើតឡើងក្នុងភពនេះ គួរឲ្យខ្លាច សូម្បីការកើតក្នុងភពតទៅៗ ក៏គួរឲ្យខ្លាចដូចគ្នា ។

-រូបកាយនេះ មិនមានទ្រង់ទ្រាយសណ្ឋាន តែការប្រាកដជារូបកាយ ដែលមិនទៀងយ៉ាងពិត គួរឲ្យខ្លាច ។

-ការកើត ក៏គួរឲ្យខ្លាចពិត ។

-ការចាស់ ការឈឺ ការស្លាប់ សេចក្តីសោក និង សេចក្តីខ្សឹកខ្សួល ទុក្ខទោមនស្ស ក៏គួរឲ្យខ្លាចពិត ។

អ្នកបដិបត្តិធម៌ ដែលពិចារណាដូច្នេះហើយ គួរកំណត់ដឹងកន្លែងពិចារណានោះផង ក្រៅពីនោះ ក្នុងខណៈខ្លះ ក៏អាចពិចារណាដល់រូបនាម ដែលត្រូវដឹង និងចិត្តដែលកំណត់ថា៖

-មានសភាពគ្រោតគ្រាតមិនល្អិត ។

-មានសភាពចោកថយ ។

-មានសភាវគ្មានតម្លៃ ។

-មានសភាវគួរឆ្ងាស់ កាលបើកើតឡើងហើយ រមែងរលត់ទៅវិញ មិនតាំងនៅរហូត អស់កាលយូរនោះទេ ។

ម្យ៉ាងទៀតក្នុងខណៈខ្លះ អាចព្រួកដឹងថាកាយទាំងអស់

ស្មោកគ្រោគ ឬដូចពពុះទឹកដែលបែកធ្លាយ កាលយល់ដឹងយ៉ាងនេះប្រាកដឡើង សម្បីទឹងតាមរព្ទកដឹងរូបនាម ដែលប្រាកដច្បាស់ផ្លូវទ្វារ ៦ ក៏អាចប្រាសចាកសេចក្ដីភ្លើតភ្លើនក្នុងរូបនាមពួកនោះ សម្បីទឹងឃើញការរលត់ទៅរបស់រូបនាមយ៉ាងជាក់ច្បាស់ ក៏រព្ទកដឹងសេចក្ដីពេញចិត្ត ការបដិបត្តិធម៌ ដូចក្នុងវិបស្សនាញាណខាងដើមៗ នឹងរមែងរព្ទកដឹងសេចក្ដីនឿយណាយធុញទ្រាន់ មិនសប្បាយក្នុងការបដិបត្តិ តែមិនអាចវៀរលែងការបដិបត្តិបានឡើយ ដូចមុនស្សដែលដើរទៅខាងលើផ្លូវដែលប្រឡាក់លាមក សម្បីទឹងរង្គាស់ក៏ត្រូវដើរជាន់លើផ្លូវទៅតាមលំដាប់ ។

គេរមែងយល់ចូលចិត្តថា មនុស្សលោកមិនអាចរួចផុតទៅអំពីរូបនាមដែលរលត់ទៅយ៉ាងលឿនរហ័សទេ សម្បីទឹងកើតជាមនុស្ស បុរស ស្ត្រី ព្រះរាជា ឬ សេដ្ឋី ក៏មិនគួរភ្លើតភ្លើនមានតែការគួរឲ្យនឿយណាយ ឬកាលពិចារណាដល់ទេវលោកនិងព្រហ្មលោក ក៏កើតសេចក្ដីនឿយណាយ តាមន័យ ដូចដែលពោលនេះ ។

អ្នកដែលនឿយណាយពីរូបនាមហើយ រមែងរឭកដឹងថា ត្រូវការនឹងរួចផុតទៅអំពីលោក ដែលកំណត់ដឹងដោយពាក្យថា

-សភាវៈទាំងអស់ត្រឹមតែជាការឃើញ ការរឭក ការប៉ះខ្ទប់ អន្ទុយ ឈរ សណ្ដូក លាត ជាដើម បើមិនប្រាកដទាំងអស់ទេ ក៏ជាការល្អ ។

-បើអាចនឹងលះបង់ចោលទាំងអស់ទៅក្នុងការរួចផុតបាន ក៏នឹងជាការល្អ ។

-យើងប្រាថ្នាចង់នឹងបន្ទុះសភាវៈរលត់ទុក្ខដែលរួចផុតទៅអំពីរូបនាមទាំងអ្នកបដិបត្តិ គួរកំណត់ដឹងការត្រិះរិះដូចពោលទៀតផង ក្នុងខណៈខ្លះអាចត្រិះរិះថា ធ្វើយ៉ាងណា ទើបធ្វើឲ្យរូប-នាមរលត់សូន្យទៅ ការកំណត់ដឹងក្នុងពេលឥឡូវនេះបានជួបតែភាពមិនគួរភ្ញើតភ្ញើន បើមិនបានកំណត់ សភាវៈពួកនោះទេ ក៏នឹងជាកាល្អ សេចក្ដីត្រិះរិះនេះគួរត្រូវកំណត់ដឹងដូចគ្នា ។ បុគ្គលអាចឈប់កំណត់ដឹងទៅតាមពាក្យត្រិះរិះ ដែលនឿយណាយ សូម្បីនឹងឈប់កំណត់ដឹងទៅមួយគ្រាៗ រូបនាមមានការឃើញ និងការឮ ក៏នៅប្រាកដយ៉ាងបន្តបន្ទាប់ ព្រោះរូប-

នាមទាំងនោះប្រាកដច្បាស់ដោយកម្លាំងវិបស្សនាញាណ និង បដិបត្តិធម៌ ក៏អាចទទួលដឹងនូវរូបនាមបានយ៉ាងជាក់ច្បាស់ បុគ្គលនោះរមែងយល់ថា“រូបនាមរមែងប្រាកដដូចដើម និង សតិក៏អាចតាមកំណត់ដឹងជាបន្តបន្ទាប់ ដូច្នោះ សូម្បីនឹងមិន បានកំណត់ដឹងក្នុងពេលឥឡូវនេះ ក៏មិនអាចលះបង់ឲ្យរួចផុត ទៅអំពីរូបនាមបានទេ នឹងត្រូវប្រាប់ច្បាស់នូវត្រៃលក្ខណ៍ គឺការមិនទៀង ជាទុក្ខ និងមិនមែនតួខ្លួន ទើបព្រងើយកន្ដើយ ក្នុងរូបនាម នឹងពន្លះនូវការរលត់ទុក្ខ គឺព្រះនិព្វាន ដែលរលត់ រូបនាមទាំងអស់ ពេលនោះរូបនាមទើបនឹងរលត់ទៅដោយមិន មានសេសសល់” ប្រសិនបើអ្នកបដិបត្តិធម៌មិនអាចពិចារណា បាន ក៏គួរធ្វើការយល់តាមពាក្យណែនាំរបស់វិបស្សនាចារ្យ ហើយនឹងបដិបត្តិតទៅ ។

បុគ្គលខ្លះ កាលត្រឡប់មកកំណត់ម្ដងទៀត រហូតដល់ វិបស្សនាញាណចាស់ក្លាឡើង អាចជួបនឹងទុក្ខវេទនាដ៏ខ្លាំងក្លា ក៏ចូរកុំរួញរា ព្រោះសភាវៈនោះជាលក្ខណៈរបស់ទុក្ខដែលមក ប្រាកដ ដូចកងទុក្ខ ឬជាសម្បុកនៃរោគ តាមព្រះបាលីថា

ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ ។

រមែងប្រចក្ស ( នូវបញ្ចក្ខន្ធ ) ថាជាទុក្ខ ជារោគ ជាបូស ជាកូនសរ ជាឫស្សគល់នៃសេចក្ដីទុក្ខ និងជាទីប្រមូលមកនូវអាពាធ ។

គេគួរអត់ធន់កំណាត់ដឹងឲ្យធ្ងន់ផុតអំពីទុក្ខវេទនាទៅ អ្នកខ្លះមិនធ្លាប់ជួបទុក្ខវេទនាដ៏ខ្លាំងក្លា តែបើជួបនឹងលក្ខណៈយ៉ាងណានីមួយក្នុងលក្ខណៈ ៤០ យ៉ាងរបស់ការមិនទៀង ជាទុក្ខ និងមិនមែនតួខ្លួន ដូចដែលនឹងពោលតទៅក្នុងបដិសង្ខាញាណ គេរមែងរឭកដឹងថា សូម្បីនឹងកំណាត់បានល្អដោយប្រាសចាកសេចក្ដីភយមាយ ក៏រឭកដឹងសតិមិនអាចផ្ដោះទៅកាន់សភាវ-ធម៌បច្ចុប្បន្នយ៉ាងជាក់ច្បាស់ ការរឭកដឹងដូចដែលពោលមកនេះ ជាការមិនភ្លើតភ្លើនក្នុងការបដិបត្តិធម៌ ព្រោះបានឃើញត្រៃលក្ខណ៍ដោយប្រចក្ស ។

អ្នកខ្លះមិនធ្វេសប្រហែលជាមួយការបដិបត្តិ អាចផ្លាស់ឥរិយាបថច្រើនគ្រា ដូចជា កាលកំពុងអង្គុយ ក៏សម្គាល់ថា

កំណត់ដឹងបានមិនល្អ ទើបផ្លាស់ទៅដើរចង្ក្រម ឬកាលកំពុងដើរចង្ក្រម ក៏សម្គាល់ថា កំណត់ដឹងបានមិនល្អ ទើបផ្លាស់ទៅអង្គុយកម្មដ្ឋាន ឬកាលកំពុងអង្គុយ ក៏សម្គាល់ថា កំណត់ដឹងបានមិនល្អ ទើបផ្លាស់ទៅធ្វើឥរិយាបថតូចធំដែលសណ្ដូក ឬលាតជាដើម ឬផ្លាស់ប្ដូរកន្លែងបដិបត្តិធម៌ ឬត្រូវការនឹងដេកកំណត់ដឹង ដើម្បីឲ្យរឭកដឹងបានល្អឡើងៗ ។ សូម្បីនឹងផ្លាស់ប្ដូរឥរិយាបថច្រើនគ្រាយ៉ាងនេះ ក៏មិនអាចនៅដោយឥរិយាបថនោះបានយូរ នឹងស្ថិននៅត្រូវការនឹងផ្លាស់ប្ដូរឥរិយាបថទៀតប្រសិនបើដូច្នោះ មិនគួរវេញរា ។ ការរឭកដឹងដូច្នោះ ជាការយល់ចូលចិត្តក្នុងរូបនាមថាមិនគួរត្រេកអរក្ដៅក្ដៅរ៉ិន និងដោយហេតុដែលនៅមិនទាន់អាចព្រងើយកន្ដើយក្នុងខណៈ ពន្ធះនូវសង្ខារុបេក្ខាញាណ ទើបធ្វើឲ្យរឭកដឹងថា សូម្បីសតិនឹងរឭកដឹងបានយ៉ាងជាក់ច្បាស់ ក៏មិនគួរក្ដៅក្ដៅរ៉ិនក្នុងការបដិបត្តិធម៌នៅក្នុងខណៈនោះ ទើបគួរអត់ធន់កំណត់ដឹងក្នុងឥរិយាបថតែមួយឲ្យយូរ ក៏នឹងរឭកដឹងថា កំណត់ដឹងបានប្រភេទណា គួរក្ដៅក្ដៅរ៉ិនមានសេចក្ដីសុខ ចិត្តនឹងក្រៀកចេញ ហើយស្ងប់ នឹង

ត្រូវការនៅតែក្នុងឥរិយាបថតែមួយប៉ុណ្ណោះ ។

កាលវិបស្សនាញាណចាស់ក្លា រហូតដល់អាចព្រងើយកន្តើយមិនត្រូវការសម្ងឹងរូបនាមដូចមុន ចិត្តដែលកំណត់ដឹងមានសេចក្តីផូរផង់ល្អិតសុខុម អ្នកបដិបត្តិធម៌រមែងរឭកដឹងថាអាចកំណត់ដឹងបានតាមធម្មជាតិសូម្បីទឹងផ្តោតអារម្មណ៍ ក៏ឃើញប្រចក្សរូបនាមដែលល្អិតសុខុមបាន នឹងឃើញត្រៃលក្ខណ៍យ៉ាងប្រចក្សដោយមិនត្រូវការពិចារណារិះគិតយ៉ាងខ្លាំងទេ ។ បទពិសោធន៍ ដែលនឹងបានទទួលមានដូចតទៅនេះ គឺ៖

-សភាវៈប៉ះខ្ទប់ប្រាកដច្បាស់ដោយរាងកាយបាត់ទៅ ។

-សភាវៈប៉ះខ្ទប់ល្អិតសុខុមស្តួចស្តើង ដូចប៉ះខ្ទប់ជាមួយស្រទាប់សំឡីគរ ។

-សភាវៈប៉ះខ្ទប់ប្រាកដច្បាស់ទូទាំងរាងកាយនិងសតិ ក៏តាមដឹងបានយ៉ាងលឿនរហ័ស ដូចទឹកវិលទូទាំងរាងកាយ ។

-កាយនិងចិត្តដូចអណ្តែតរសាត់ឡើងខ្ពស់ទៅខាងលើ ។

-សភាវបច្ចុប្បន្នមិនប្រាកដតែអាចទទួលដឹងស្ងប់កាយ និងចិត្តបានអស់កាលយូរ ។

-រាងកាយនិងសភាវៈពោង-ផត អង្គុយជាដើម បាត់ទៅសល់ត្រឹមតែចិត្តដែលឃើញការកើតរលត់ប៉ុណ្ណោះ ។

-បីតិដែលដូចជាការប្រោះទឹក ផ្សព្វផ្សាយទូទៅទាំងរាងកាយប្រាកដឡើង ។

-បស្សទ្ធិ គឺការស្ងប់កាយនិងចិត្តប្រាកដឡើង ។

-ពន្លឺដែលប្រាកដច្បាស់ ដូចផ្ទៃមេឃស្រឡះប្រាកដឡើង ។

ការសប្បាយចិត្តដែលកើតអំពីការបានជួបប្រទះជាមួយការប្រតិបត្តិពួកនេះ រមែងមិនមានកម្លាំងច្រើនឡើយ ដូចក្នុងវិបស្សនាញាណជាន់ខ្ពស់តែអ្នកបដិបត្តិ ក៏គួរកំណត់ដឹង និងគួរកំណត់ដឹងបីតិ បស្សទ្ធិ ព្រមដោយពន្លឺទៀតផង ។ ប្រសិនបើកំណត់ដឹងហើយសភាវៈពួកនោះមិនបាត់ទៅ ក៏គួរបោះបង់ចិត្ត ដោយប្រកាន់ថា ពេលក្រោយ ក៏គួរកំណត់ដឹងសភាវបច្ចុប្បន្ននេះយ៉ាងបន្តបន្ទាប់ទៅ ។

ក្នុងញាណលំដាប់នេះ អ្នកបដិបត្តិធម៌រមែងយល់ចូលចិត្តយ៉ាងជាក់ច្បាស់ថា មានត្រឹមតែសភាវធម៌ គឺរូបនាមសង្ខារដែលកើតឡើងតាមហេតុបច្ច័យមិនមានតួខ្លួនយើង របស់យើង

អ្នកដទៃ របស់អ្នកដទៃ គេរមែងរឭកដឹងការត្រេកត្រអាលក្នុងការបដិបត្តិយ៉ាងខ្លាំងក្លា អាចតម្រង់ឲ្យតាំងនៅក្នុងឥរិយាបថតែមួយបានយូរ ដោយប្រាសចាកទុក្ខវេទនា មានការឈឺចុកចាប់ ការនឿយហត់ ការស្រពន់ និងស្ពឹក ជាដើម សូម្បីទឹងអង្គុយ ឬដេកអស់កាលយូរ ២ ឬ ៣ ម៉ោង ក៏គិតថា មិនយូរ ប្រាសចាកការឈឺ ស្ពឹកស្រពន់ ក្នុងកាលមុន និងរាងកាយ សីសៈ ដៃ ជើង ក៏ស្ងប់ស្ងៀមមិនផ្លាស់ប្តូរចេញទៅអំពីកន្លែងដើម ។

ក្នុងខណៈខ្លះ ការកំណត់ដឹងប្រព្រឹត្តទៅល្អច្រើនដោយសតិប្រព្រឹត្តទៅយ៉ាងរហ័សរហួន អាចធ្វើឲ្យអ្នកបដិបត្តិធម៌កន្ទ្រល់ចិត្ត គួរកំណត់ដឹងថា "កន្ទ្រល់ហ្ន៎" ។

អ្នកខ្លះអាចពិចារណាវិបស្សនា កំពុងតែចំរើនទៅមុខគួរកំណត់ថា "ពិចារណាហ្ន៎" អ្នកខ្លះអាចតាំងសេចក្ដីសង្ឃឹមថា វិបស្សនានឹងចំរើនទៅមុខ គួរកំណត់ថា "សង្ឃឹមហ្ន៎" កាលកំណត់ដូច្នេះហើយគួរតាមដឹង សភាវធម៌តទៅ កុំរួញរា ឬបន្ថយការផ្ដោតអារម្មណ៍នោះឡើង ។ អ្នកខ្លះមិនអាចកំណត់

ដឹងសភាវៈកន្លល់បាន ការពិចារណាការសប្បាយចិត្ត ឬការសង្ឃឹមធ្វើឲ្យការកំណត់ដឹងមិនជាប់តគ្នា ហើយក៏ថយកម្លាំងចុះ អ្នកខ្លះផ្គងសេចក្តីព្យាយាម ដោយត្រិះរិះថា យើងកំពុងតែនឹងសម្រេចធម៌ ទើបធ្វើឲ្យការកំណត់ដឹងមិនជាប់តគ្នា ។ ពិតមែនហើយ ការគិតរាយមាយដែលជាសេចក្តីកន្លល់ ការពិចារណាការសប្បាយចិត្ត ឬការតាំងសេចក្តីសង្ឃឹម ក៏ធ្វើឲ្យការចំរើននោះថយចុះ ព្រោះរាំងវិបស្សនាវិថី ទុកមិនឲ្យជាប់តគ្នា ដូច្នោះអ្នកបដិបត្តិធម៌ ទើបគួរកំណត់តទៅតាមប្រក្រតី កាលបើសតិមានកម្លាំងរហ័សរហួនឡើង មិនគួរបង្កើន ឬបន្ថយសេចក្តីព្យាយាមក្នុងការកំណត់ដឹង បើអ្នកបដិបត្តិធ្វើតាមនេះ ក៏នឹងអាចបាក់ជុះនូវការរលត់ទុក្ខបានជាទីបំផុត ។

អ្នកខ្លះបានសម្រេចវិបស្សនាលំដាប់នេះហើយ អាចបន្ថយកម្លាំងសមាធិក្នុងខណៈខ្លះ សូម្បីនឹងធ្វើបានច្រើនៗ ឬតិចបុះៗយ៉ាងនេះច្រើនគ្រា ក៏កុំធុញទ្រាន់ គួរពង្រីកការកំណត់ដឹងទូទៅពេញរាងកាយ ដោយទទួលដឹងសភាវធម៌ដែលប្រាកដច្បាស់ផ្លូវទ្វារទាំង ៦ មុននឹងទទួលដឹងដល់សេចក្តីស្ងប់ស្ងាត់ ដែលល្អិត

សុខុមក្នុងចំណុចណាទីមួយ ដើម្បីឲ្យវិបស្សនាញាណមានកម្លាំងខ្លាំងឡើង កាលបើរឭកដឹងដល់សេចក្ដីស្ងប់ល្អិតសុខុមនោះបានក៏ឈប់ពង្រីកការកំណត់ដឹងទូទៅក្នុងទ្វារទាំង ៦ ។

កាលកំណត់ដឹងទាន់សភាវធម៌បច្ចុប្បន្ន ដោយចាប់ផ្ដើមអំពីការតាមដឹងសភាវៈប៉ោង-ផត សភាវៈអង្គុយ ឬដើមអំពីការតាមដឹងសភាវៈផ្សេងៗក្នុងកាយនិងចិត្តយ៉ាងនោះ សតិរមែងប្រាកដច្បាស់យ៉ាងបន្តបន្ទាប់ សូម្បីមិនបានផ្ដោតអារម្មណ៍ច្រើនពេកទេក៏អាចកំណត់ដឹងទាន់យ៉ាងស្ងប់មិនរាយមាយ ដូចជាការឃ្លាំមើលសភាវធម៌ដែលបែកទៅឯងយ៉ាងលឿនរហ័ស ក្នុងខណៈនោះចិត្តនឹងមិនកាន់យកនូវអារម្មណ៍ ដែលនាំឲ្យកើតកិលេស គឺសូម្បីនឹងជួបនូវអារម្មណ៍ ដែលគួរពេញចិត្ត ក៏មិននឹកគិតថាគួរពេញចិត្ត សូម្បីនឹងជួបអារម្មណ៍ដែលគួរស្អប់ ក៏មិននឹកគិតថាគួរស្អប់ ចិត្តតាំងនៅក្នុងសភាវៈឃើញ បានឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វៈ ឬនឹកគិតប៉ុណ្ណោះ ។ ឧបេក្ខាដែលមានអង្គ ៦ ( ឆឡង្គុបេក្ខា ) តាមដែលពោល ទុកហើយក្នុងបរិច្ឆេទទី ៤ រមែងប្រាកដច្បាស់ ។

[ ឆឡង្គុបេក្ខា គឺឧបេក្ខាដែលមានអង្គ ៦ មានន័យថា ការព្រងើយកន្តើយ មិនត្រេកអរ មិនប្រទូសរាយ ក្នុងអារម្មណ៍ ៦ ដែលមកប្រាកដក្នុងផ្លូវទ្វារទាំង ៦ ដោយអង្គធម៌ បានដល់ តត្រមជ្ឈត្តតាចេតសិក] ។

ពេលនោះ រមែងប្រាសចាកការគិតរាយមាយដោយមិនសេសសល់ មិនមានសូម្បីប្រទះការគិតថា ខ្លួនកំពុងអង្គុយយូរប៉ុណ្ណា ឬពេលកន្លងទៅយូរប៉ុណ្ណា, យ៉ាងណាក៏ដោយ បើវិបស្សនាញាណរបស់គេនៅមិនទាន់ចាស់ក្លា រហូតអាចសម្រេចមគ្គញាណបាន ។ កាលអង្គុយកម្មដ្ឋានយូរ ១ ឬ ២, ៣ ម៉ោងហើយ ការផ្តោតអារម្មណ៍ថយចុះម្តងបន្តិចៗ ញាំងផលឲ្យកំណត់ដឹងមិនជាប់គ្នា ឬកើតការរាយមាយបានក្នុងខណៈខ្លះ អាចរឭកដឹង សតិមានការរហ័សរហួនជាងពេលមុន ធ្វើឲ្យចិត្តភ្លើតភ្លើនរាយមាយថា យើងកំពុងតែនឹងចម្រើនទៅមុខ គេគួរកំណត់ដឹងសភាវៈគតិរាយមាយ សេចក្តីសង្ឃឹមការរីករាយដូចដែលពោលមក កាលតាំងចិត្តកំណត់ដឹងទាន់ហើយ ក៏ជួបប្រទះការចំរើនតទៅ តែបើវិបស្សនាញាណនៅមិនទាន់ចាស់ក្លា

សមាធិទៀតសោត ក៏នឹងធ្លាក់ចុះទៅវិញ ។

អ្នកខ្លះ បដិបត្តិបានច្រើនឡើងៗ តិចចុះៗ តាមន័យនេះ ច្រើនជង អ្នកដែលយល់លំដាប់ញាណ រមែងប្រាកដសភាវៈយ៉ាងនេះ ច្រើនជាងមនុស្សទូទៅ ដូច្នោះ អ្នកដែលបដិបត្តិធម៌ជាមួយនឹងវិបស្សនាចារ្យ ទើបមិនគួរយល់លំដាប់ញាណជាមុនសិន ដើម្បីចម្រើនទៅមុខលឿនរហ័ស សូម្បីគេក៏នឹងជួបប្រសព្វ ដូចដែលពោលនេះ មិនគួររួញរា គួរយល់ថា ខ្លួននៅក្បែរនឹងមគ្គផលហើយ ប្រសិនបើឥន្ទ្រិយ៍ ៥ គឺ សទ្ធា វិរិយ សតិ សមាធិ និងបញ្ញា មានការចាស់ក្លាស្មើគ្នា ក៏នឹងឃើញច្បាស់នូវមគ្គផល និព្វាន ដោយប្រចក្សបានត្រឹមតែក្នុងមួយខណៈប៉ុណ្ណោះ ។

[ អ្នកខ្លះដែលយល់លំដាប់ញាណហើយ អាចធ្វើឲ្យក្ដីសង្ឃឹម ឬការរៀបចំតាក់តែងឲ្យកើតលំដាប់ញាណ ញ៉ាំងផលឲ្យចំរើនឡើង តើអ្នកដែលមិនមានក្ដីសង្ឃឹម នឹងតាំងចិត្តបដិបត្តិតាមការយល់ក្នុងលំដាប់ញាណ រមែងចំរើនទៅយ៉ាងលឿនរហ័ស ដូចការដឹងផែនទីដើរផ្លូវយ៉ាង ត្រឹមត្រូវរមែងធ្វើឲ្យមុតមាំក្នុងការ

ដើររបស់ខ្លួនទើងមិនខុសផ្លូវ ] ។

## "ការចាក់ផ្លុះទ្វារព្រះនិព្វាន"

វិបស្សនាញាណ ដែលប្រព្រឹត្តទៅចំរើនឡើងៗ ថយចុះៗ យ៉ាងនេះ ដូចគ្នាជាមួយនឹងបក្សីដែលត្រូវគេដោះលែងចេញពីទូកសមុទ្រ ដើម្បីហើរស្វែងប្រាំង ក្នុងសម័យមុនអ្នកចុះទូករមែងប្រលេងសត្វបក្សីដើម្បីហើរស្វែងរកប្រាំង ក្នុងពេលដែលវង្វេងផ្លូវសត្វបក្សីនោះ នឹងហើរទៅសម្លឹងរកប្រាំង ហើយឆ្ពោះទៅកាន់ទិសទាំង ៤ ។

ប្រសិនបើនៅមិនទាន់ជួបនូវត្រើយទេ ក៏នឹងហើរត្រឡប់មកកាន់ទូកវិញ តែបើជួបនូវត្រើយ ក៏នឹងហើរតម្រង់ទៅរកប្រាំង ។ ការវិនាសទៅរបស់វិបស្សនាញាណ ដែលមិនទាន់ចាស់ក្លា ដូចបក្សីហើរទៅត្រឡប់មកកាន់ទូកវិញ ចំណែកវិបស្សនាដែលចាស់ក្លាដោយកម្លាំងឥន្ទ្រិយ៍ ៥ ដូចសត្វបក្សីដែលហើរឆ្ពោះចូលទៅរកប្រាំង វិបស្សនាញាណ ដូចពោលមកនេះ រមែងប្រាកដយ៉ាងលឿនត្រឹម ៣, ៤ ខណៈចិត្តហើយ អាចឃើញការកើតរលត់របស់សង្ខារ ៦ យ៉ាង គឺការប៉ះខ្ទប់, ការទទួល

ដឹង, ការបានឮ, ការឃើញ, ការដឹងក្លិន, ការដឹងរស ( ក្នុងទីនេះរៀងលំដាប់តាមសភាវៈដែលប្រាកដបានងាយ រកបានដោយលំបាក ) អ្នកបដិបត្តិ រមែងឃើញប្រចក្សច្បាស់ ការរលត់ទៅនៃអារម្មណ៍ ដែលខ្លួនកំណត់ដឹងជាមួយវិបស្សនាចិត្ត ហើយទើបបានសម្រេចនូវមគ្គផលក្នុងខណៈនោះ ។

ក្នុងខណៈដែលជិតនឹងសម្រេចនូវព្រះនិព្វាន សតិដែលកំណត់ដឹងរមែងប្រាកដច្បាស់ឡើងរឿយៗ ក្នុងទីបំផុតនឹងលះបង់នូវអារម្មណ៍ ដែលជាសង្ខារ ហើយចូលទៅកាន់ព្រះនិព្វានដែលរលត់សង្ខារ ដោយមិនមានសេសសល់ អ្នកដែលសម្រេចធម៌ហើយ រមែងនិយាយដល់អារម្មណ៍បច្ចុប្បន្ន នឹងការកំណត់ដឹងដែលប្រាកដក្នុងខណៈនោះថា៖

-រលត់ទៅដោយឆាប់រហ័ស ។

-ដាច់ទៅភ្លាម ដូចប្រើកាំបិតកាត់វល្លិ៍ ។

-ធ្លាក់ទៅភ្លាម ដូចបោលរបស់ធ្ងន់ដែលធ្លាក់ចុះទៅ ។

-របូតចេញទៅភ្លាម ដូចរបស់ជ្រុះចេញទៅអំពីដៃ ។

-ផុតទៅភ្លាមអំពីគ្រឿងពន្ធនាគារ ។

-រលត់ទៅយ៉ាងលឿនរហ័ស ដូចព្រោយភ្លើង ( ភ្លើងកើតអំពីការគួតឈើ ) ។

-ចេញពីទីងងឹតភ្លាម ចូលទៅកាន់ទីភ្លឺស្វាង ។

-ចេញពីទីព្រៃស្អុកភ្លាម ហើយទៅទីវាលស្រឡះ ។

-ឈប់ធ្មឹងភ្លាម ដូចជាការចាប់ទុកនូវមនុស្សដែលកំពុងរត់យ៉ាងលឿនរហ័សឲ្យឈប់ភ្លាំផ្ទាល់ ។

-បាត់ទៅដោយមិនមានអ្វីសល់ ។

ខណៈដែលអ្នកបដិបត្តិធម៌ សម្រេចការរំលត់សង្ខារនោះថយចុះ កើតឡើងត្រឹមតែមួយជួខណៈចិត្ត តពីនោះ ទើបបានពិចារណាថា ការរំលត់ដូចជាការសម្រេចធម៌ ឬមគ្គផល និព្វាន ។ អ្នកដែលមានករដើងក្នុងការបដិបត្តិ រមែងយល់ថា សភាវៈដែលរំលត់សង្ខារជាព្រះនិព្វាន សភាវៈដែលឃើញការរលត់ដោយប្រចក្សច្បាស់ជាមគ្គផល យើងបានឃើញនូវព្រះនិព្វានហើយបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផល ហើយអ្នកដែលមានការដើងដូច្នោះ រមែងអាចពិចារណាបានយ៉ាងបរិបូណ៌ ទឹងញុំាងការពិចារណាបានទៀតថា កិលេសដែលត្រូវលះបង់

បានហើយ មានប៉ុន្មាន? កិលេសដែលនៅសល់មានប៉ុន្មាន?

ការពិចារណាដូច្នេះហើយ អ្នកដែលបដិបត្តិធម៌ ត្រឡប់ទៅកំណត់សភាវធម៌ផ្លូវកាយ និងចិត្ត ដូចដើមវិញ ក្នុងខណៈនោះរូបនាមរមែងប្រាកដឲ្យឃើញថា កើតឡើង និងរលត់ទៅយ៉ាងជាក់ច្បាស់ ធ្វើឲ្យយល់ថា ការកំណត់មិនចំរើនទៅមុខដូចខណៈមុនដែលឃើញចំពោះតែការរលត់ទៅ ជាការពិតហើយ ការត្រឡប់ទៅ ពន្ធុះញាណដែលឃើញការកើតរលត់ ( **ឧទយ-ព្វញាណ** )ម្យ៉ាងទៀត ។

[ព្រះអរិយបុគ្គលតាំងអំពីព្រះសោតាបន្ន ជាដើមទៅនឹងកើតនូវឧទយព្វញាណ ជាញាណដំបូង ចំណុចនេះ ផ្សេងគ្នាពីបុថុជ្ជនទូទៅ ដែលកើតនាមរូបបរិច្ឆេទញាណមុន ដូចគម្ពីរវិសុទ្ធិមគ្គពោលថា :

**ផលសមាបត្តិកេន ហិ អរិយសាវកេន រហោគតេន បដិសល្លីនេន ឧទយព្វយាទិវសេន សង្ខារា បស្សិតព្វា ។**

"ដោយពិតប្រាកដហើយ អរិយសាវក អ្នកត្រូវការនឹងចូលផលសមាបត្តិ ត្រូវគេចខ្លួនទៅសម្ងំនៅក្នុងទីស្ងាត់ កំណត់

ឃើញសង្ខារ ដោយវិបស្សនាញាណ មានឧទយព្វញាណជាដើម"] ។

ដោយហេតុដូចដែលឧទយព្វញាណប្រាកដ អ្នកបដិបត្តធម៌ទើបឃើញពន្លឺ ឬនិមិត្តអារម្មណ៍ផ្សេងៗ អ្នកខ្លះកាលកំណត់ដឹងបានថា សតិមិនអាចដឹងទាន់អារម្មណ៍បច្ចុប្បន្នបានទេ អ្នកខ្លះកើតទុក្ខវេទនាតិចតួច ត្រឹមតែមួយខណៈ តែបើចំណែកជំចិត្តដែលផូរផង់រមែងប្រាកដយ៉ាងបន្តបន្ទាប់ នឹងរឭកដឹង ជាសុខយ៉ាងក្រៃលែង ដូចជាកាយ និងចិត្ត ដែលនៅចំកណ្ដាលផ្ទៃមេឃ សូម្បីនឹងតាំងចិត្ត កំណត់ចិត្តដូចពោល ក៏កំណត់ដឹងមិនបាន ឬសូម្បីនឹងកំណត់ដឹងបាន ក៏មិនអាចដឹងច្បាស់ឡើយមួយទៀតទាំងនៅប្រាសចាកការគិតរវើរវាយ ដោយគ្មានសេសសល់ គឺមានត្រឹមតែសេចក្ដីសុខស្ងប់ ដែលប្រាកដច្បាស់កាលបើចិត្តផូរផង់នោះ ថយកម្លាំងចុះ អ្នកពន្លុះធម៌នោះ រមែងឃើញការកើតរលត់បានតទៅ ។

កាលអ្នកបដិបត្តធម៌តទៅ គេរមែងពន្លុះដល់សតិ ដែលល្អិតសុខុម និងកាលបើបញ្ញាចាស់ក្លាឡើង ក៏នឹងពន្លុះសភាវៈ

រលត់សង្ខារបាន ដូចគ្រាមុន ។

អ្នកខ្លះ ដែលមានកម្លាំងសមាធិ និងបញ្ញាចាស់ក្លា ល្មមអាចចាក់ធ្លុះសភាវៈដែលរលត់ទៅនៃសង្ខារបានរឿយៗ តាមន័យ ដូចពោលមកនេះ ចំណុកនេះជាការចូលផលសមាបត្តិរបស់ព្រះសោតាបន្ន ដែលនៅក្នុងការចាប់ចិត្ត របស់មនុស្សក្នុងសម័យនេះ ដែលប្រាថ្នានឹងសម្រេចជាព្រះសោតាបត្តិផលជាគោល ។

អ្នកដែលសម្រេចមគ្គផលហើយ រមែងមានសភាពនៃចិត្តបែកផ្សេងទៅអំពីភាពដើម ដូចជាកើតថ្មី សទ្ធាដែលជាការជ្រះថ្លា និងការផូរផង់នៃចិត្ត នឹងមានកម្លាំងចាស់ក្លាមាំទាំ បីតិនិងបស្សទ្ធិ ក៏មានកម្លាំងចាស់ក្លា ដោយអំណាចនៃកម្លាំងសទ្ធាម្យ៉ាងទៀត ទាំងសេចក្តីសុខ នឹងប្រាកដតាមធម្មជាតិ អ្នកដែលបានសម្រេចធម៌ នឹងមិនអាចកំណត់ដឹងសទ្ធា បីតិ បស្សទ្ធិ និងសុខបានយ៉ាងជាក់ច្បាស់ ក្នុងពេលដែលផ្តើមសម្រេចធម៌ ព្រោះធម៌ពួកនោះ មានកម្លាំងចាស់ក្លា ដូចពេលកន្លងទៅច្រើនម៉ោង ឬ ច្រើនថ្ងៃ ធម៌ដូចពោលនឹងតិចទៅៗ ថយកម្លាំងចុះ គេរមែង

អាច កំណត់ដឹងបានយ៉ាងជាក់ច្បាស់ អ្នកខ្លះរឭកដឹង ដូចជាការសុខស្រួលរហូតដល់មិនចង់កំណត់ដឹង ឬរឭកដឹងថា ត្រឹមត្រូវហើយការដឹងនេះ ជាសេចក្ដីសន្ដោសរបស់អ្នកដែលប្រាថ្នាត្រឹមតែសម្រេចមគ្គផលថ្នាក់ដំបូងប៉ុណ្ណោះ ។

## "ការចូលផលសមាបត្តិ"

អ្នកដែលត្រូវការនឹងចូលផលសមាបត្តិ ដើម្បីសោយផលនិព្វានសុខក្នុងបច្ចុប្បន្នជាតិ គប្បីកំណត់ដឹងដូចគ្រាដើម ដោយអំណាចវិបស្សនាញាណគ្រាដំបូង គឺនាមរូបបរិច្ឆេទញាណ ( ញាណដែលចែកនាម និងរូបឲ្យដាច់ពីគ្នា ) រមែងប្រាកដដល់បុថុជ្ជនជាគ្រាដំបូង តែសម្រាប់ព្រះសោតាបន្នឧទយព្វញាណយ៉ាងចាស់ក្លា នឹងប្រាកដមុន កាលពន្ធុះញាណ ដូចពោលនេះដោយឃើញការកើត នឹងការរលត់ទាំងពីរយ៉ាង ហើយនឹងកន្លងនូវកម្លាំងញាណតាមលំដាប់តទៅ មិនយូរប៉ុន្មាន ក៏នឹងសម្រេចដល់សង្ខារុបេក្ខាញាណ ( ញាណដែលព្រងើយកន្ដើយចំពោះសង្ខារ ) កន្លែងដែលមាការកំណត់ដឹងល្អិតស្អួចស្ដើង កាលបើញាណដែលពន្ធុះ មានកម្លាំងចាស់ក្លាហើយ នឹងអាចឈានកន្លង

ទៅកាន់អារម្មណ៍ថ្មី គឺព្រះនិព្វាន ដែលរលត់សង្ខារ ដោយកើតផលចិត្តយ៉ាងបន្តបន្ទាប់រឿយៗ ។

អ្នកដែលមិនបានអធិដ្ឋានចិត្ត ដើម្បីចូលផលសមាបត្តិ អាចកើតផលចិត្តត្រឹមតែមួយខណៈចិត្ត ខ្លះអាចកើតយូរ ៥ នាទី ១០ នាទី ១៥ នាទី កន្លះម៉ោង ឬអាចយូរដល់ ១ ម៉ោង ក្នុងគម្ពីរអដ្ឋកថា ពោលថា "ផលសមាបត្តិ អាចកើតបានរហូត ១ ថ្ងៃ និង ១ យប់ ឬកើតបានរហូតដែលបានអធិដ្ឋានទុក" ក្នុងបច្ចុប្បន្នធ្លាប់ឃើញថា អ្នកខ្លះ ដែលមានកម្លាំងសមាធិ និងបញ្ញាចាស់ក្លា អាចចូលផលសមាបត្តិបានយូរ ១-៣ ម៉ោងខ្លះជាដើមតាមពេលដែលបានអធិដ្ឋានទុក កាលគ្រប់ហើយ ទើបចេញអំពីផលសមាបត្តិ ។ យ៉ាងណាក៏ដោយ ក្នុងពេលដែលកំពុងចូលផលសមាបត្តិ កាលវេលាដែលកន្លងទៅ ១-២ ម៉ោង ចិត្តដែលពិចារណា អាចប្រាកដឡើងបាន ៤ ឬ ៥ខណៈ គប្បីកំណត់ដឹងចិត្តនោះហើយ ក៏ចូលផលសមាបត្តិតទៅបាន ។

តាមន័យនេះអ្នកសម្រេចធម៌ នឹងឃើញថា ផលចិត្តអាចតាំងនៅបានច្រើនម៉ោង និងក្នុងខណៈនោះ នឹងមិនទទួលដឹងនូវ

អារម្មណ៍ណាមួយឡើយ ពិតហើយ ព្រះនិព្វានជាសភាវៈដែលរួចផុតពីសង្ខារ គឺរូបនាម និងបញ្ញត្តិ ដែលលោកនេះ និងលោកដទៃ ដូច្នោះ ក្នុងខណៈដែលចូលផលសមាបត្តិ នឹងទទួលយកនូវព្រះនិព្វានជាអារម្មណ៍ ចិត្តទើបមិនដឹងរឿងរ៉ាវនៃលោកនេះ និងលោកដទៃ ។

ម្យ៉ាងទៀតទាំងប្រាសចាក សេចក្តីរវើរវាយរាយមាយ សូម្បីអារម្មណ៍ដទៃ ចូលមកតាមទ្វារ ដូចជារូប សម្លេង ក្លិនរស និងផោដ្ឋព្វៈ ជាដើម ក៏មិនប្រាកដដល់គេ សូម្បីឥរិយាបថអង្គុយក្នុងខណៈចូលផលសមាបត្តិ ក៏តាំងនៅមិនកំរើក ឬផ្លាស់ប្តូរឥរិយាបថទៅយ៉ាងដទៃ ដូចព្រះអដ្ឋកថាពោលថា ៖

**តត្ថ អប្បនាជវនំ ឥរិយាបថម្បិ សន្នាមេតិ ។**

“ ក្នុងបណ្តាចិត្ត ៧៥ ដួងនោះ អប្បនាជវន រមែងញុំាងរាងកាយឲ្យតាំងនៅបាន” ។

កាលក្រសែផលចិត្តរលត់បាត់ទៅហើយ អ្នកសម្រេចធម៌អាចពិចារណាដល់សភាវៈ នៃការរលត់ទៅរបស់សង្ខារ ឬសភាវៈដែលចាក់ធ្លុះការរលត់សង្ខារ ឬអាចឃើញនូវនិមិត្តអារម្មណ៍

ផ្សេងៗមុន ក្រោយអំពីនោះ ចិត្តដែលប្រកបដោយសតិតាមដឹង ចិត្តផ្សេងៗ ឬចិត្តដែលពិចារណា រមែងកើតឡើង តាមសមគួរ កាលចាប់ផ្តើមកំណត់ រមែងជួបប្រទះការរលត់យ៉ាងគ្រោតគ្រាត ក្រោយអំពីវិបស្សនាញាណ ដែលចាស់ក្លាឡើង ទើបនឹងកំណត់ដឹងយ៉ាងបន្តបន្ទាប់ដ៏ឧក្រិដ្ឋ ក្នុងខណៈនោះ គួរតាំងចិត្តអធិដ្ឋាន ដើម្បីឲ្យសម្រេចផលសមាបត្តិបានលឿន នឹងតាំងនៅបានយូរ តែក្នុងការកំណត់រយៈពេលតទៅ មិនគួរកង្វល់ ឬសង្ស័យ ការអធិដ្ឋានរបស់ខ្លួនឡើយ ។

អ្នកខ្លះ យល់ថា បើកម្លាំងវិបស្សនានៅមិនទាន់ចាស់ក្លា ដល់ពេលចូលផលសមាបត្តិ ក៏អាចមានការព្រឺរោមឡើង ក្នុងខណៈដែលសមាធិមានកម្លាំងខ្លាំង ក្រោយពីនោះ អាចមិនតជាប់គ្នាដូចមុន ។

អ្នកខ្លះ ក៏សង្ស័យថាកំពុងតែនឹងចូលផលសមាបត្តិ ត្រឡប់ធ្វើឲ្យខ្វះសតិ មិនអាចបានសម្រេចនូវសមាបត្តិនោះទេ ក្នុងករណីដូចគ្នានេះ បើការសង្ស័យកើតឡើង ក៏គួរកំណត់ដឹងកន្លែងសង្ស័យនោះផង ។

អ្នកខ្លះ យល់ថា សតិនឹងមិនជាប់តគ្នា នៅអស់កាលយូរ កាលមុននឹងអាចពន្ទុះផលសមាបត្តិបាន នោះពិតហើយ កម្លាំងរបស់សមាធិ និងបញ្ញាជាគោលការណ៍នៃការចូលកាន់ផលសមាបត្តិ បើកម្លាំងរបស់ធម៌ទាំងពីរ មានមិនទាន់ច្រើន ក៏នឹងធ្វើឲ្យសម្រេចផលសមាបត្តិបានតិច ឬតាំងនៅមិនបានយូរ ។

## "ការសោរឡើងវិញនូវលំដាប់ញាណ"

អ្នកខ្លះ មិនបានជួបជាមួយភយញាណ អាទីនវញាណ និព្វិទាញាណ និងមុញ្ចិតុកម្យតាញាណ អស់កាលយូរទេ ទើបយល់ចូលចិត្តពួកនោះមិនបានច្បាស់ ដូច្នោះ បើត្រូវការនឹងឃើញយ៉ាងប្រចក្ស ក៏គួរអធិដ្ឋានឲ្យកើតញាណមួយគ្រា ដូច្នេះ បើអធិដ្ឋានថា យើងនឹងកំណត់ដឹងការកើតរលត់ប៉ុណ្ណោះ ក្នុងកម្លុងពេលកន្លះម៉ោង ឬ ១ម៉ោងនេះ សូមឲ្យឧទយព្វញាណចូរប្រាកដ កាលបើដូច្នេះ **ឧទយព្វញាណ** នឹងកើតឡើងត្រឹមតែមួយគ្រា ដោយមិនសម្រេចញាណជាន់ខ្ពស់ជាងនេះ ក្នុងកម្លុងពេលដែលបានអធិដ្ឋានទុកទេ កាលបើគ្រប់ពេលដែលអធិដ្ឋាន

ហើយនោះ **ភយញ្ញាណ** ដែលឃើញការកើតរលត់តែម្យ៉ាង ប៉ុណ្ណោះ ។

សូមឲ្យ**ភង្គញ្ញាណ** ចូរប្រាកដ **ភង្គញ្ញាណ** ក៏ប្រាកដតាមដែលអធិដ្ឋានទុក កាលគ្រប់កំណត់ហើយ វិបស្សនាញ្ញាណជាន់ខ្ពស់នេះ រមែងប្រាកដតទៅ គប្បីជ្រាបន័យនេះ សូម្បីក្នុងវិបស្សនាញ្ញាណបន្ទាប់តទៅ ។

ទោះបីយ៉ាងណាក៏ដោយ បើវិបស្សនាញ្ញាណជាន់ខ្ពស់មិនប្រាកដ កាលបើ**ភង្គញ្ញាណ**ចាស់ក្លាហើយ ក៏គួរបង្អោនចិត្តទៅថា សូមឲ្យ**ភយញ្ញាណ** ដែលឃើញការគួរខ្លាច ចូរប្រាកដ **ភយញ្ញាណ** ក៏រមែងប្រាកដក្នុងពេលនោះ, កាល**ភយញ្ញាណ**មានកម្លាំងចាស់ក្លាហើយ ក៏គួរបង្អោនចិត្តថា **អាទីនវញ្ញាណ** ដែលឃើញទោសចូរប្រាកដ **អាទីនវញ្ញាណ** រមែងប្រាកដដោយ ការឲ្យឃើញទោស ក្នុងខណៈនៃការកំណត់ដឹង កាលបើ **អាទីនវញ្ញាណ** មានកម្លាំងចាស់ក្លាហើយ ក៏គួរបង្អោនចិត្តថា សូមឲ្យ**និព្វិទាញ្ញាណ** ដែលឃើញការនឿយណាយ ចូរប្រាកដ **និព្វិទាញ្ញាណ** រមែងប្រាកដក្នុងពេលនោះ, កាលបើ**និព្វិទាញ្ញាណ**

មានកម្លាំងចាស់ក្លាហើយ ក៏គួរបង្អោនចិត្តថា សូមឲ្យ**មុញ្ចិតុ-កម្យតាញាណ** ដែលត្រូវការនឹងរួចផុតទៅអំពីសង្ខារ ចូរប្រាកដ **មុញ្ចិតុកម្យតាញាណ** រមែងមកប្រាកដក្នុងពេលនោះ, កាលបើ **មុញ្ចិតុកម្យតាញាណ** មានកម្លាំងចាស់ក្លាហើយ ក៏គួរបង្អោន ចិត្តថា សូមឲ្យ**បដិសង្ខាញាណ** ដែលឃើញទោស ចូរប្រាកដ **បដិសង្ខាញាណ** ក៏រមែងប្រាកដព្រមជាមួយទុក្ខវេទនា ដែលទ្រាំបានដោយលំបាក កើតចំណង់ដើម្បីនឹងផ្លាស់ប្តូរ ឬការបដិបត្តិ ដែលមិនបានដូចបំណង ការតាំងចិត្ត កាលបើ**បដិសង្ខាញាណ** មានកម្លាំងចាស់ក្លាហើយ ក៏គួរបង្អោនចិត្តថា សូមឲ្យ**សង្ខារុ-បេក្ខាញាណ** ដែលព្រងើយកន្តើយក្នុងសង្ខារ ដោយលក្ខណៈ ដែលល្អិត ចូរប្រាកដ**សង្ខារុបេក្ខាញាណ** រមែងប្រាកដក្នុងពេល នោះឯង ។

ដោយប្រការដូច្នេះ វិបស្សនាញាណជាន់ខ្ពស់ៗ រមែងប្រាកដក្នុងកម្លុងពេលនៃការកំណត់ ដែលបានអធិដ្ឋានទុក ឬ ប្រាកដតាមសេចក្តីត្រូវការ ក្នុងពេលដែលវិបស្សនាញាណ កើតមុនមានកម្លាំងចាស់ក្លាឡើង បើអ្នកសម្រេចធម៌សាកល្បង

វិធីមួយ ក្នុងចំណោមពីរវិធីនេះ ហើយនៅមិនទាន់ឃើញផល ឲ្យព្យាយាមច្រើនគ្រា ក៏នឹងឃើញផលឯង ។ ចំណែកអ្នកដែលមិនបានអធិដ្ឋាន គ្រប់គ្រាន់តាមលំដាប់ញាណ តែមានសមាធិចាស់ក្លាអាចសម្រេចនូវ**សង្ខារុបេក្ខាញាណ** កាលបើកំណត់ដឹងត្រឹម ៤, ៥ គ្រា ឬ ១០ គ្រា ហើយអាចចូលផលសមាបត្តិបានទាន់ពេល អ្នកខ្លះ ដែលមានសមាធិច្រើន អាចចូលនូវសមាបត្តិបានយ៉ាងលឿនរហ័ស សូម្បីក្នុងពេលកំពុងដើរ ឬទទួលទានអាហារបានទៀតផង ។

## “ការបដិបត្តិដើម្បីបានសម្រេចមគ្គផលជាន់ខ្ពស់”

កាលបើអ្នកបដិបត្តិ សម្រេចធម៌អាចចូលផលសមាបត្តិបានលឿនរហ័ស នឹងតាំងនៅបានយូរ ហើយត្រូវការនឹងសម្រេចមគ្គផលជាន់ខ្ពស់ គប្បីបដិបត្តិតទៅដោយកំណត់ដឹងរយៈពេលត្រូវនឹងបដិបត្តិ ហើយអធិដ្ឋានថា ក្នុងកម្លុងពេលនេះ យើងនឹងមិនចូលផលសមាបត្តិ សូមឲ្យផលសមាបត្តិចូរកុំមកប្រាកដ និងសូមឲ្យយើងបានចាក់ធ្លុះមគ្គផលជាន់ខ្ពស់ ហើយនឹងកំណត់ដឹងសភាវធម៌ផ្លូវកាយ និងចិត្តតទៅ ។

ការកំណត់ដឹងរយៈពេលមានប្រយោជន៍ ដើម្បីឲ្យអាចចូលផលសមាបត្តិបាន កាលកន្លងហួសរយៈពេលនោះ ក៏មិនអាចសម្រេចធម៌ជាន់ខ្ពស់បានឡើយ ។ អ្នកសម្រេចធម៌អាចអធិដ្ឋានថា ចាប់ពីថ្ងៃនេះតទៅ សូមឲ្យការបដិបត្តិ ដើម្បីសម្រេចមគ្គផលជាន់ខ្ពស់ប៉ុណ្ណោះ តែក៏អាចនឹងមិនបានសម្រេចផងដែរ ការដែលតាំងចិត្តទុក ទាំងនៅមិនទាន់អាចចូលផលសមាបត្តិបាន ធ្វើឲ្យមិនពេញចិត្តក្នុងផលដែលខ្លួនកំពុងបដិបត្តិ ។

ការកាត់សេចក្តីអាល័យក្នុងផលសមាបត្តិនោះ ដោយតាំងចិត្តថា នឹងមិនចូលផលសមាបត្តិនេះទេ ប្រព្រឹត្តទៅដើម្បីមិនឲ្យបានសម្រេចផលសមាបត្តិ ក្នុងកម្លុងពេលដែលកំណត់ដឹង ព្រោះបើនៅមានសេចក្តីអាល័យក្នុងផលសមាបត្តិ ក៏អាចធ្វើឲ្យចូលផលសមាបត្តិបានទៀតផង នឹងមិនអាចសម្រេចមគ្គផលជាន់ខ្ពស់ដូច្នោះ អ្នកដែលត្រូវការនឹងសម្រេចមគ្គផលជាន់ខ្ពស់ ទើបគួរកាត់សេចក្តីអាល័យក្នុងផលសមាបត្តិ ក្នុងកម្លុងពេលដែលកំពុងកំណត់ទុក ហើយប្រារព្ធនូវសេចក្តីព្យាយាមតទៅ ។

## "គន្លងផ្លូវបដិបត្តិ និងការឃើញច្បាស់ដោយបញ្ញា ក្នុងសកទាគាមិផល"

ក្នុងខណៈបដិបត្តិធម៌ វិបស្សនាញាណរមែងប្រាកដតាមលំដាប់ដូចគ្រាដើម តាំងអំពី **ឧទយព្វញាណ** ជាដើមទៅ ដោយលំដាប់ញាណកើតឡើង ដូចក្នុងពេលមុន ដែលបដិបត្តិដើម្បីសម្រេចមគ្គ ព្រោះបដិបត្តិដើម្បីចូលផលសមាបត្តិ ក៏រមែងពន្លះនូវសង្ខារុបេក្ខាញាណបាន ហើយចូលផលសមាបត្តិ តែក្នុងខណៈដែលបដិបត្តិដើម្បីសម្រេចមគ្គ ត្រូវប្រព្រឹត្តតាមលំដាប់ **ឧទយព្វញាណ** ដែលឃើញការកើតរលត់មុន ធ្វើឲ្យជួបប្រទះនូវពន្លឺ ឬនិម្មិត្តអារម្មណ៍ មានទុក្ខវេទនា និងការកើតរលត់របស់រូបនាមប្រាកដច្បាស់ ។ ទោះបីយ៉ាងណាក៏ដោយ បុគ្គលដូចពោលមកនេះ រមែងប្រាសចាកសេចក្ដីលំបាក ក្នុងការបដិបត្តិដូចអ្នកដែលនៅមិនទាន់បានសម្រេច តែគេរមែងអាចពន្លះដល់វិបស្សនាជាន់ខ្ពស់ផ្សេងៗ ហើយពន្លះដល់សង្ខារុបេក្ខាញាណបានក្នុងកម្លុំងពេលមួយថ្ងៃ សតិដែលកំណត់ដឹងមានការជាក់ច្បាស់ជាងគ្រាដើម បញ្ញាឃើញប្រចក្ស មានការជាក់ច្បាស់មានសេចក្ដីផូរផង់ ។ ក្រៅពីនោះ សភាវៈរបស់បញ្ញាពួកនេះ គឺ

ការឲ្យខ្វាចទុក្ខក្នុងសង្សារវដ្ត ការឃើញទោស ការនឿយណាយ សេចក្តីត្រូវការនឹងរួចផុតចាកទុក្ខ នឹងថយចេញអំពីក្រសែរូបនាម រមែងប្រាកដច្បាស់ជាងគ្រាដើម បើវិបស្សនាញាណ នៅមិនទាន់ចាស់ក្លា រហូតដល់សម្រេចមគ្គផលជាន់ខ្ពស់បាន ក៏អាចសម្រេចនូវ**សង្ខារុបេក្ខាញាណ** នឹងតាំងនៅក្នុងញាណយូរ រហូតមួយថ្ងៃ ពីរថ្ងៃ បីថ្ងៃ ឬយូររាប់ខែ រាប់ឆ្នាំ ។

កាលវិបស្សនាញាណចាស់ក្លាបរិបូណ៌ហើយ សតិដែលរហ័សរហួនប្រាកដច្បាស់រមែងកើតឡើង គេច្នងទៅកាន់ព្រះនិព្វានដែលរលត់នូវសង្ខារបានដូចគ្រាមុន ហើយសម្រេចមគ្គញាណ និងផលញាណទី ២ ក្រោយពីនោះ ទើបពិចារណាមគ្គ ផលនិព្វាន កិលេសតាមសមគួរ ក្រៅពីនោះហើយ **ឧទយព្វយញាណ** ដែលឃើញការកើតរលត់ និងលំដាប់ចិត្តដែលផូរផង់ ជាដើម រមែងកើតឡើងតទៅ ។

## "គន្លងផ្លូវបដិបត្តិ និងការឃើញច្បាស់ដោយបញ្ញា ក្នុងអនាគាមិផល"

អ្នកដែលត្រូវការនឹងសម្រេចមគ្គផលលំដាប់ទី ៣ គួរកំណត់ដឹងរយៈពេលនៃការបដិបត្តិធម៌ ហើយកាត់បង់សេចក្តី

អាល័យក្នុងការចូលផលសមាបត្តិ គួរអធិដ្ឋានថាសូមឲ្យគុណធម៌វិសេស គឺ មគ្គផលជាន់ខ្ពស់ ដែលយើងនៅមិនទាន់បានសម្រេចដរាបណា ក៏សូមឲ្យប្រចក្សច្បាស់មគ្គផលជាន់ខ្ពស់ ក្នុងកាលជាអនាគតចុះ ។ ហើយកំណត់ដឹងសភាវធម៌ផ្លូវកាយ និងចិត្តដែលប្រាកដក្នុងបច្ចុប្បន្នខណៈ តែរមែងសម្រេចវិបស្សនាញាណផ្សេងៗ មាន ឧទយព្វញាណ តាមលំដាប់ ហើយមិនយូរប៉ុន្មានក៏សម្រេចដល់សង្ខារុបេក្ខាញាណ ប្រសិនបើកម្លាំងរបស់សមាធិនិងបញ្ញានៅមិនចាស់ក្លា ទីងស្ថិតនៅក្នុងញាណនោះ បើកម្លាំងដូចដែលពោលមកនេះចាស់ក្លាហើយ រមែងសម្រេចនូវព្រះនិព្វានដែលជាទីរលត់សង្ខារបានដូចមុន ហើយសម្រេចនូវមគ្គញាណនិង ផលញាណលំដាប់ទី ៣ ការពិចារណា ការកំណត់ដឹងនិងការផ្លូវផង់នៃចិត្ត រមែងប្រាកដដូចន័យមុន ។

**"គន្លងផ្លូវបដិបត្តិ និងការឃើញប្រចក្សដោយបញ្ញា ក្នុងអរហត្តផល"**

អ្នកដែលត្រូវការនឹងសម្រេចមគ្គផល ក្នុងលំដាប់ទី ៤ គួរកំណត់ដឹងរយៈពេល ដែលកាត់បង់នូវសេចក្តីអាល័យ និងអធិដ្ឋានដូចគ្រាដើម ហើយកំណត់សភាវធម៌ផ្លូវកាយ និងចិត្តក្នុង

បច្ចុប្បន្នខណៈ តាមប្រក្រតីមិនចាំបាច់ត្រូវព្យាយាមបដិបត្តិយ៉ាង ពិសេស ព្រោះក្នុងមហាសតិប្បដ្ឋានសូត្របានពោលថា សតិ ជាផ្លូវមូលតែមួយ នៃការរួចផុតចាកទុក្ខ ( ឯកាយនោ ) គេ រមែងសម្រេចនូវវិបស្សនាញាណផ្សេងៗ មានឧទយព្វញាណ ជាដើម រមែងកើតឡើងតាមលំដាប់ ហើយមិនយូរប៉ុន្មាន ក៏សម្រេចដល់សង្ខារុបេក្ខាញាណ បើកម្លាំងសមាធិ និងបញ្ញា នៅមិនទាន់ចាស់ក្លា ក៏នឹងស្ថិតនៅក្នុងញាណនោះ បើកម្លាំង ដូចដែលពោលមកនេះ ចាស់ក្លាហើយ រមែងសម្រេចនូវព្រះ និព្វាន ដែលរលត់សង្ខារបាន ដូចមុនហើយ សម្រេចមគ្គញាណ និង ផលញាណទី ៤ ។

ពាក្យដែលពោលពីមុនថា "មគ្គញាណ និងផលញាណ រមែងកើតឡើង" បញ្ជាក់ដល់បុគ្គលអ្នកដែលមានបារមីគ្រប់គ្រាន់ ដើម្បីនឹងសម្រេចធម៌បាន ចំណែកបុគ្គលដែលបារមីនៅមិនទាន់ បរិបូណ៌ ក៏នឹងឈប់ត្រឹមតែសង្ខារុបេក្ខាញាណ អ្នកដែលនឹង បានសម្រេចមគ្គផលទី ១ ហើយរមែងនឹងសម្រេចមគ្គផលទី ២ តែសម្រេចមគ្គផលទី ៣ បានលំបាក ព្រោះសោតាបន្ន និង

សកទាគាមី ជាអ្នកបរិបូណ៌ដោយសីល ដូចព្រះពុទ្ធវចនៈថា ៖

**សីលេសុ បរិបូរការី** ( អ្នកបរិបូណ៌ក្នុងសីល ) តែព្រះអនាគាមីជាអ្នកមានសមាធិបរិបូណ៌ ដូចព្រះពុទ្ធវចនៈថា ៖

**សមាធិស្មឹ បរិបូរការី** ( អ្នកបរិបូណ៌ក្នុងសមាធិ ) ដូច្នោះ អ្នកដែលមានសមាធិនៅមិនទាន់បរិបូណ៌ ទើបសម្រេចមគ្គផលទី ៣ បានលំបាក ។ ទោះបីយ៉ាងណាក៏ដោយ ប្រសិនបើមិនបានបដិបត្តិធម៌ មិនអាចដឹងថា ខ្លួនឯងមានការបន្សំបារមីល្មមនឹងសម្រេចមគ្គផលបាន ឬមិនបាន ក្រៅពីនោះ មានច្រើននាក់ណាស់ដែលត្រូវបដិបត្តិធម៌ច្រើនខែ ច្រើនឆ្នាំ ទើបមិនបានសម្រេចធម៌ អ្នកដែលមិនអាចបានសម្រេចធម៌ ក្នុងកម្លុងពេលត្រឹមតែប៉ុន្មានថ្ងៃ ឬប៉ុន្មានខែ ទើបមិនគួរពោលថា ខ្លួនឯងមិនមានបារមីបរិបូណ៌ ។ ពិតមែនហើយ ការបដិបត្តិធម៌ក្នុងបច្ចុប្បន្នជាការអប់រំនូវបារមី ដែលនៅមិនទាន់បំពេញឲ្យបានបរិបូណ៌ ក្នុងបច្ចុប្បន្នជាតិនេះ ដូច្នេះ ទើបមិនគួរជល់បារមីចាស់របស់ខ្លួន ។

តាមពិតទៅ ការមិនបដិបត្តិធម៌ ជាការមិនសាងនូវបារមី សូម្បីមិនមានបារមីចាស់ក្តាក៏ដោយ បើមិនបានបដិបត្តិ ក៏មិន

អាចសម្រេចមគ្គផលបានឡើយ ចំណែកឯអ្នកដែលមានបារមីសន្សំមកហើយ រមែងសម្រេចធម៌ក្នុងភពនេះបាន ដោយងាយ ឬយ៉ាងតិចជាទីបំផុត ក៏អាចជាគ្រាប់ពូជនៃបារមីដើម្បីការសម្រេចធម៌ក្នុងភពតទៅខាងមុខទៀតដែរ ។

កាលអ្នកសម្រេចបានប្រាកដនូវអរហត្តផល ជាទីបំផុតហើយរមែងពិចារណាមគ្គផល និងនិព្វាន ព្រមទាំងពិចារណាថា កិលេសទាំងអស់ស្ងប់បាត់ទៅ នឹងមិនកើតទៀត ក្នុងកាលតទៅទៀត យើងមិនមានកិច្ច ដែលគួរធ្វើ ដើម្បីការកំចាត់បង់នូវកិលេស ។

[ ក្នុងមហាសតិប្បដ្ឋានសូត្រ មានរឿងរ៉ាវនៃការចំរើនសតិប្បដ្ឋាន ៧ ឆ្នាំរហូតដល់ ៧ ថ្ងៃ ហើយបានសម្រេចធម៌ជាព្រះអនាគមី ឬព្រះអរហន្ត និងនៅក្នុងពោធិរាជកុមារសូត្រមានការពោលដល់ការចំរើនសតិប្បដ្ឋានក្នុងវេលាព្រឹក ហើយក៏បានសម្រេចធម៌នៅក្នុងវេលាល្ងាច ឬចំរើនសតិប្បដ្ឋានក្នុងវេលាល្ងាច ហើយបានសម្រេចធម៌ក្នុងវេលាព្រឹក ។ តែការសម្រេចធម៌នោះត្រូវអាស្រ័យបារមីចាស់ក្លា ល្មមសមគួរ ទើបនឹងធ្វើ

ឲ្យបញ្ញាចំរើនឡើង រហូតដល់សម្រេចធម៌បាន ប្រសិនបើបុគ្គលប្រាសចាកនូវបារមីហើយ រមែងមិនអាចសម្រេចធម៌បានទេ ។ ដូចសេចក្តីក្នុងគម្ពីរអដ្ឋកថា និងដីកាពោលថា ៖

**[១] កឹ បន សព្វេន បុព្វហេតុសម្បត្តិយា វិនា សច្ចាភិសម្ពោធោ សម្ភវតីតិ ។ [២] ន សម្ភវតិ ។ ន ហិ ឧបនិស្សយសម្បត្តិរហិតស្ស អរិយមគ្គាធិគមោ អត្ថិ តស្ស សុទុក្ករ ទុរភិសម្ភវសភាវតោ ។**

"១.សួរថា : ការបាក់ធ្លុះសច្ចធម៌ រមែងមានដោយប្រាសចាកការដល់នៃហេតុដើមទាំងអស់គ្មានសេសសល់ឬ?

២.ឆ្លើយថា : រកមិនបានទេ ។ ព្រោះការបាក់ធ្លុះនូវសច្ចធម៌ រមែងមិនមាន ដោយប្រាសចាកការដល់ព្រមនៃឧបនិស្ស័យ ក្រៅពីនោះ ការសម្រេចធម៌ដូចដែលពោលមកនេះជាសភាវៈធ្វើបានដោយលំបាក នឹងបាក់ធ្លុះបានដោយលំបាកផងដែរ" ។

**៦រំ វិវដ្ដំ ឧទ្ទិស្ស ឧបាទិតកុសលចិត្តំ សត្តសហស្សាធិ-អសង្ខេយ្យកាលន្តរេ វិមោក្ខាធិគមស្ស ឧបនិស្សយោ ន ហោតីតិ**

នសក្កា វត្តុំ ។

“មិនមាននរណាពោលបានថា ៖ កុសលចិត្តដែលបុគ្គលញ៉ាំងឲ្យកើតឡើង ដោយតាំងចិត្តចំពោះវិវដ្ដ: ( ព្រះនិព្វានដែលផុយគ្នាជាមួយវដ្ដ: ) យ៉ាងនេះ មិនមែនជា ឧបនិស្ស័យចំពោះការសម្រេចការរួបផុតក្នុងរវាង ៤ អសង្ខេយ្យ ១ សែនកប្ប [សម្រាប់ព្រះសម្មាសម្ពុទ្ធ ដែលជាបញ្ញាធិក]” ។

[១] តត្ថ បច្ចេកពោធិយា ឧបនិស្សយសម្បទា កប្បានំ ទ្វេ អសង្ខេយ្យានិ សតសហស្សញ្ច តជ្ជំ បុញ្ញញាណ-សម្ភារណំ ។

[២] សាវកពោធិយា អគ្គសាវកានំ អសង្ខេយ្យំ កប្ប-សតសហស្សញ្ច ។

[៣] មហាសាវកានំ សតសហស្សមេវ តជ្ជំ បុញ្ញ-ញាណសម្ភារណំ ។

[៤] ឥតរេសំ អតីតាសុ ជាតីសុ វិវដ្ដសន្និស្សយវសេន កាលនិយមមន្តរេន និព្វត្តិតំ និព្វេធភាគិយំ កុសលំ ។

“១. ក្នុងរឿងនោះ ការបំពេញនូវបញ្ញាបារមី ២ អសង្ខេយ្យ

និង ១ សែនកប្ប ដែលសមគួរដល់ព្រះបច្ចេកពោធិញាណនោះ ជាការដល់ព្រមនៃឧបនិស្ស័យរបស់បច្ចេកពោធិញាណ ( ការសាងបារមីនៃព្រះបច្ចេកពុទ្ធ ) ។

២. ការបំពេញបញ្ញាបារមី ១ អសង្ខេយ្យ និង១ សែនកប្ប ដែលសមគួរដល់សាវកពោធិញាណនោះ ជាការដល់ព្រមនៃឧបនិស្ស័យរបស់សាវកពោធិញាណ នៃអគ្គសាវក ។

៣.ការបំពេញបញ្ញាបារមី ១សែនកប្ប ដែលសមគួរដល់មហាសាវកពោធិញាណនោះ ជាការដល់ព្រមនៃឧបនិស្ស័យរបស់មហាសាវកពោធិញាណ ( អសីតិមហាសាវក ) ។

៤.កុសលដែលចាក់ធ្លុះរហូតដល់ ( អរិយសច្ចៈ) បុគ្គលធ្វើឲ្យកើតឡើង ប្រាសចាកពេលវេលា ដែលពិតប្រាកដ ជាប់ទាក់ទងដោយការអាស្រ័យវិវដ្តៈក្នុងជាតិមុនៗ ជាការដល់ព្រមនៃឧបនិស្ស័យរបស់បកតិសាវកដទៃ " ។

សូម្បីក្នុងគម្ពីរអដ្ឋកថា ក៏ពោលថា ឧបនិស្ស័យ គឺបច្ច័យដ៏មានកម្លាំង ដើម្បីការសម្រេចធម៌របស់បកតិសាវកនិងមិនមានការកំណត់ច្បាស់លាស់ទេ តែអនុមានដឹងបានថា ពេល

បំពេញនូវបារមីរបស់បកតិសាវ័ក តិចជាងមួយសែនកប្ប ដែលជាការបំពេញបារមីរបស់ព្រះមហាសាវ័ក ដែលគួរជាពេលវេលាមួយពុទ្ធន្តរ គឺរយៈពេលចន្លោះព្រះពុទ្ធជាម្ចាស់មួយអង្គជាមួយព្រះពុទ្ធតទៅចែកជា :

-មួយអសង្ខេយ្យ ដូចជារវាងការឧបត្តិនៃព្រះពុទ្ធ ព្រះនាម**ទីបង្ករ**ក្នុងកប្បមុន និងព្រះពុទ្ធព្រះនាម**កោណ្ឌញ្ញ** ក្នុងកប្បបន្ទាប់មកយូរមួយអសង្ខេយ្យ ។

-ច្រើនដប់កប្ប ដូចជាព្រះពុទ្ធព្រះនាម**កកុសន្ធ** ដែលបានត្រាស់ដឹងជាគ្រាដំបូងក្នុងភទ្ទកប្បនេះ ទ្រង់ឧបត្តិក្នុងសម័យដែលមនុស្សមានអាយុវែង ៤០,០០០ឆ្នាំ តមកមនុស្សអាយុបានថយចុះ រហូតសល់ត្រឹមតែ ១០ ឆ្នាំ ( សម័យកប្បថយចុះ ) ហើយត្រឡប់មានអាយុវែងឡើងទៅទៀតរហូតដល់ ១អសង្ខេយ្យ ( សម័យកប្បចំរើន ) ក្រោយអំពីនោះ កាលបើមនុស្សថយចុះរហូតដល់មានអាយុ ៣០,០០០ឆ្នាំ ព្រះនាម **កោណាគមន** ឧបត្តិឡើង សូម្បីរវាងព្រះពុទ្ធព្រះនាម **កោណាគមន** ជាមួយព្រះពុទ្ធព្រះនាម **កស្សប** និងរវាងព្រះពុទ្ធព្រះនាម **កស្សប** ជាមួយព្រះពុទ្ធ

ព្រះនាម **គោតម** ក៏រាប់ចំនួនឆ្នាំមិនបានដូចគ្នា ។

ក្នុងគម្ពីរថេរគាថា ថេរីគាថានិងអបទាន មានការពោលដល់រឿងនៃការសាងបារមីរបស់បកតិសាវកដែលបានសម្រេចធម៌ក្នុងសម័យព្រះពុទ្ធជាម្ចាស់នៃយើងធ្វើឲ្យដឹងថា សាវកពួកនោះ រួមកសាងនូវអភិនីហារបារមី មកតាំងតែអំពីសម័យព្រះសម្មាសម្ពុទ្ធព្រះនាម **កស្សប** ឬក្នុងមួយរយៈពេលដែលព្រះសម្មាសម្ពុទ្ធ ព្រះនាមកស្សបរលត់ខន្ធបរិនិព្វានហើយ និងមុនពេលដែលនឹងដល់សម័យព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាម**គោតម** យ៉ាងតិចបំផុតដូចជា

-ព្រះ**ធម្មរុចិយៈ** កសាងបារមី ៤ អសង្ខេយ្យ និងមួយសែនកប្ប ។

-ព្រះ**ចូឡវច្ឆៈ** និងព្រះ**មហាវច្ឆៈ** សាងបារមីតាំងតែសម័យព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាម **បទុមុត្តរៈ** ដែលឧបត្តិឡើង ក្នុងមួយសែនកប្បមុន រហូតដល់ភទ្ទកប្បយើងនេះ ។

-ព្រះ**សីតវនិយ** និងព្រះ**វនវច្ឆៈ** សាងបារមីតាំងតែសម័យព្រះសម្មាសម្ពុទ្ធព្រះនាម**អត្ថទស្សី** ដែលឧប្បត្តិឡើងក្នុងរយៈពេល ១,៨០០ កប្បមុន រហូតដល់ភទ្ទកប្បយើងនេះ ។

-ព្រះវីរៈ និងព្រះបុណ្ណមាលៈសាងនូវបារមីតាំងពីសម័យព្រះសម្មាសម្ពុទ្ធព្រះនាមវិបស្សី ដែលឧបត្តិឡើង ក្នុងរយៈពេល ៩១ កប្បមុន ។

-បណ្ឌិតសាមណេរ កសាងបារមីតាំងតែពីសម័យដែលព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ ក្នុងភទ្ទកប្បយើងនេះ ។

-សុខសាមណេរ កសាងបារមីក្នុងសំណាក់នៃព្រះបច្ចេកពុទ្ធក្នុងរវាងនៃព្រះសម្មាសម្ពុទ្ធព្រះនាមកស្សប ស្ដេចរលត់ខន្ធបរិនិព្វានហើយ និងព្រះសម្មាសម្ពុទ្ធព្រះនាម គោតម ដែលនៅមិនទាន់បានឧបត្តិឡើង ។

-នាងថេរិកាថេរី កសាងបារមីតាំងតែសម័យព្រះសម្មាសម្ពុទ្ធព្រះនាម កោណាគមនៈ ក្នុងភទ្ទកប្បនេះ ។

-នាងបអភិរូបនន្ទា កសាងបារមីតាំងតែសម័យ ព្រះសម្មាសម្ពុទ្ធព្រះនាម វិបស្សី ទ្រង់ឧបត្តិឡើងក្នុង ៩១ កប្បមុនរហូតដល់ភទ្ទកប្បនេះ ។

-អនាថបិណ្ឌិកសេដ្ឋី នាងវិសាខា និង ចិត្តគហបតិ កសាងបារមីតាំងពីសម័យព្រះសម្មាសម្ពុទ្ធព្រះនាម បទុមុត្តរៈ ទ្រង់ឧបត្តិ

ឡើងក្នុងលោក រយៈពេលមួយសែនកប្ប ។

-ជោតិកសេដ្ឋី មេណ្ឌកសេដ្ឋី និងជដិលសេដ្ឋី កសាងបារមីតាំងពីសម័យព្រះសម្មាសម្ពុទ្ធព្រះនាមវិបស្សី ទ្រង់ឧបត្តិឡើង ក្នុង ៩១ កប្បមុន ។

ម្យ៉ាងទៀតក្នុងអដ្ឋកថារបស់ថេរគាថា ថេរីគាថា និងអបទាន បានពោលដល់អតីតកធម៌របស់ភិក្ខុ, ភិក្ខុនី អ្នកដែលបានសម្រេចជាព្រះអរហន្តមានចំនួនច្រើនរូប ដោយបញ្ជាក់ដល់ការកសាងបារមីតាំងតែពីសម័យព្រះសម្មាសម្ពុទ្ធអង្គដទៃ ដូចសេចក្តីថា ៖

**សោ កិរ បុរិមពុទ្ធេសុ កតាធិការោ ហុត្វា តត្ថ តត្ថ វិវដ្ដូបនិស្សយំ បុញ្ញសភារំ ឧបចិនន្តោ ។បេ។**

"ដូចបានស្តាប់មកថា បុគ្គលអ្នកធ្វើការតាំងចិត្តក្នុងសំណាក់ព្រះសម្មាសម្ពុទ្ធជាម្ចាស់អង្គមុនៗ សន្សំនូវបុណ្យបារមី ដែលជាឧបនិស្ស័យដើម្បីវិវដ្តៈក្នុងកពនោះៗ ។ល។"

**អយម្បិ បុរិពុទ្ធេសុ កតាធិការោ តត្ថ តត្ថ ភវេ បុញ្ញានិ ឧបចិនន្តោ ។បេ។**

"សូមឲ្យបុគ្គល អ្នកដែលបានធ្វើការតាំងចិត្តទុកក្នុងសំណាក់ព្រះសម្មាសម្ពុទ្ធជាម្ចាស់អង្គមុនៗ សន្សំនូវបុណ្យទាំងឡាយក្នុងភពនេះៗ ។ល។"

អយម្បិ បុរិមពុទ្ធេសុ កតាធិការោ តត្ថ តត្ថ ភវេ វិវដ្ដូបនិស្សយំ កុសលំ ឧបចិនន្តោ ។ល។

"សូមឲ្យបុគ្គល អ្នកដែលបានធ្វើការតាំងចិត្តទុកក្នុងសំណាក់ព្រះ សម្មាសម្ពុទ្ធអង្គមុនៗ សន្សំនូវកុសលដែលឧបនិស្ស័យដើម្បីវិវដ្ដៈក្នុងភពនោះៗ ។ល។"

អយម្បិ បុរិមពុទ្ធេសុ កតាធិការោ តត្ថ តត្ថ ភវេ វិវដ្ដូបនិស្សយំ បុញ្ញំ ឧបចិនន្តោ ។ល។

"សូមឲ្យបុគ្គល អ្នកដែលបានធ្វើការតាំងចិត្តទុកក្នុងសំណាក់ព្រះសម្មាសម្ពុទ្ធអង្គមុនៗ សន្សំនូវបុណ្យដែលឧបនិស្ស័យ ដើម្បីវិវដ្ដៈក្នុងភពនោះៗ ។ល។"

អយម្បិ បុរិមពុទ្ធេសុ កតាធិការោ តត្ថ តត្ថ វិវដ្ដូបនិស្សយានិ បុញ្ញានិ ឧបចិនន្តោ ។ល។

"សូមឲ្យបុគ្គល អ្នកដែលបានធ្វើការតាំងចិត្តទុកក្នុងសំណាក់ព្រះ

សម្មាសម្ពុទ្ធអង្គមុនៗ សន្សំនូវបុណ្យដែលជាឧបនិស្ស័យ ដើម្បីវិវដ្តៈ ( ព្រះនិព្វាន ) ក្នុងភពនោះៗ ។ល។”

ដោយហេតុនេះ ការកសាងបារមីទាំង ១០ មានទានបារមីជាដើម ទើបជាឧបនិស្ស័យ ដើម្បីការសម្រេចធម៌ និង ការចំរើននូវវិបស្សនាភាវនា ក្នុងភពនេះ ក៏ជាការសាងបារមី ដើម្បីបានរួចផុតចាក់ទុក្ខតែម្យ៉ាង ប្រៀបដូចជាមួយ និងការផ្ញើទ្រព្យទុកក្នុងធនាគារ ឬការសន្សំទុកនូវកុសលធម៌ ដើម្បីការបាក់ធ្លុះធម៌ក្នុងកាលជាអនាគតតទៅ ]។

## “ពាក្យបណ្ដាំ”

ភាវេតព្វា សតា ចេវ    សតិបដ្ឋានភាវនា
វិបស្សនារសស្សាទំ    បត្ថយន្តេនិធ សាសនេ ។

“ សប្បុរស អ្នកប្រាថ្នារសនៃវិបស្សនា ដែលគួរត្រេកអរក្នុងព្រះសាសនានេះ គប្បីចំរើនសតិបដ្ឋានភាវនា ដូចបានពណ៌នាមកហើយនេះចុះ ” ។

# "ពាក្យចុងក្រោយ"

វិធីចំរើនវិបស្សនា ដែលសម្ដែងទុកក្នុងគម្ពីរនេះ រមែងគ្រប់គ្រាន់ ដល់បុគ្គលអ្នកមានបញ្ញាថ្នាក់កណ្ដាល បុគ្គលដូចដែលពោលមកនេះ បើបានសិក្សានូវគម្ពីរនេះ ហើយខិតខំព្យាយាមបដិបត្តិដោយសទ្ធា ឆន្ទៈ និង វីរិយៈមិនរួញរា ក៏អាចសម្រេចវិបស្សនាញាណ មគ្គញាណ និងផលញាណ តាមដែលពោលទុកក្នុងទីនេះបុះ ។

ទោះបីយ៉ាងណាក៏ដោយ ក្នុងទីនេះ មិនអាចពោលដល់ការឃើញ និងការប្រចក្សដោយបញ្ញា ដែលប្រាកដដល់មនុស្សគ្រប់គ្នាបានទេ សូម្បីនឹងជួបកន្លែងដែលពោលទុក, តែក្នុងទីនេះមិនមាននរណាម្នាក់ អាចឃើញច្បាស់គ្រប់ៗ ប្រការបានឡើយព្រោះបញ្ញា រមែងកើតឡើងជាក់ច្បាស់ ឬមិនជាក់ច្បាស់ តាមសមគួរដល់បារមីរបស់អ្នកដែលប្រារព្ធនូវសេចក្ដីព្យាយាមម្យ៉ាងទៀតទាំងសទ្ធា ឆន្ទៈ និងវីរិយៈក្នុងខណៈបដិបត្តិធម៌ ក៏មិនបានមាំទាំពិតប្រាកដ ។

អ្នកដែលបដិបត្តិធម៌ដោយប្រាសចាកវិបស្សនាចារ្យ អាចនាំផ្លូវទៅបដិបត្តិមិនត្រឹមត្រូវ ព្រោះនៅកើតសេចក្តីសង្ស័យ ដូចមនុស្សដែលដើរផ្លូវទៅម្នាក់ឯង ក្នុងផ្លូវដែលមិនធ្លាប់ទៅ ។ មនុស្សទូទៅ ដែលមិនមានអ្នកបង្រៀន ណែនាំវិបស្សនា ទើបមិនអាចនឹងសម្រេចនូវវិបស្សនាញាណ មគ្គញាណ និងផលញាណបានដោយងាយស្រួលនោះទេ ។ ដោយហេតុនេះ សប្បុរសជន អ្នកដែលត្រូវការនឹងចាក់ធ្លុះនូវព្រះនិព្វាន ដោយមគ្គញាណ និងផលញាណ ទើបគួរស្វែងរកវិបស្សនាចារ្យ បុគ្គលជាកល្យាណមិត្ត ដែលធ្លាប់ឆ្លងកាត់ការបដិបត្តិធម៌មក យ៉ាងត្រឹមត្រូវ នឹងអាចណែនាំឲ្យបានសម្រេចវិបស្សនាថ្នាក់ផ្សេងៗ រហូតដល់សម្រេចមគ្គញាណ ផលញាណ បច្ចវេក្ខណញាណ និងការចូលផលសមាបត្តិ ដូចសេចក្តីក្នុងគម្ពីរ សំយុត្តនិកាយ និទានវគ្គថា ៖

ជរាមរណំ ភិក្ខវេ អជានតំ អបស្សតំ យថាភូតំ ជរាមរណេ យថាភូតំ ញាណាយ សត្ថា បរិយេសិតព្វោ ។

“ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលបើមិនដឹងច្បាស់ មិន

ឃើញនូវជរាមរណៈ តាមសេចក្តីពិតទេ គប្បីស្វែងរកគ្រូ ដើម្បីឲ្យដឹងច្បាស់ក្នុងជរាមរណៈតាមសេចក្តីពិតចុះ” ។

អ្នកបដិបត្តិធម៌គួរលះបង់មានះ ដែលប្រកាន់ខ្លួនថា យើងខ្លាំងពូកែ មិនចាំបាច់ត្រូវរៀនដឹង អំពីបុគ្គលដទៃទេ ដោយរឭកដល់ព្រះបោដ្ឋិលៈ ជាតួយ៉ាង ( សូមមើលរឿងព្រះបោដ្ឋិលៈ ក្នុងសៀវភៅវិបស្សនានយភាគ ១ ទំព័រ ៣៨៤ ) សូម្បីក្នុងពេលបដិបត្តិធម៌ ក៏គួរខិតខំព្យាយាមបដិបត្តិ ដោយមិនរួញរា តាមព្រះពុទ្ធវចនៈថា ៖

ន ហិ សិថិលមារព្ភ ន ចាបិ អប្បមសា
និព្វានំ អធិគន្តព្វំ សព្វគន្ថប្បមោចនំ ។

“ព្រះនិព្វានដែលរួចផុត ពីគ្រឿងដោតក្រងគ្រប់យ៉ាង (គន្ថៈ) នឹងមិនអាចសម្រេច ដោយសេចក្តីព្យាយាម ដែលថោកថយ និងសេចក្តីព្យាយាមបន្តិចបន្តួចឡើយ ” ។

ដូច្នោះ មានបំណងក្នុងការរួចផុតចាកទុក្ខ ទើបគួរព្យាយាមបដិបត្តិយ៉ាងហ្មត់ចត់ មិនថោកថយ ទើបនឹងបានទទួលផលនៃការព្យាយាម ដែលជានិព្វានសុខ ដែលរលត់ទុក្ខមិនមានសេស

សល់ ៗ!ទា

# ចប់បរិច្ឆេទទី ៥

# បរិច្ឆេទទី ៦

## "សោឡសញ្ញាណ"

## ញាណ ១៦ និង វិសុទ្ធិ ៧

| ញាណ ១៦ | | វិសុទ្ធិ ៧ |
|---|---|---|
| ១.នាមរូបបរិច្ឆេទញាណ | : | ទិដ្ឋិវិសុទ្ធិ |
| ២.នាមរូបបច្ចយបរិគ្គហញាណ | : | កង្ខាវិតរណវិសុទ្ធិ |
| ៣.សម្មសនញាណ | : | មគ្គាមគ្គញាណទស្សនវិសុទ្ធិ |
| ៤.ឧទយព្វយញាណ | : | មគ្គាមគ្គញាណទស្សនវិសុទ្ធិ |
| ៥.ភង្គញាណ | : | បដិបទាញាណទស្សនវិសុទ្ធិ |
| ៦.ភយញាណ | : | បដិបទាញាណទស្សនវិសុទ្ធិ |
| ៧.អាទីនញាណ | : | បដិបទាញាណទស្សនវិសុទ្ធិ |
| ៨.និព្វិទាញាណ | : | បដិបទាញាណទស្សនវិសុទ្ធិ |
| ៩.មុញ្ចិតុកម្យតាញាណ | : | បដិបទាញាណទស្សនវិសុទ្ធិ |
| ១០.បដិសង្ខាញាណ | : | បដិបទាញាណទស្សនវិសុទ្ធិ |

១១.សង្ខារុបេក្ខាញាណ : បដិបទាញាណទស្សនវិសុទ្ធិ

១២.អនុលោមញាណ : បដិបទាញាណទស្សនវិសុទ្ធិ

១៣.គោត្រភូញាណ : [ ញាណទស្សនវិសុទ្ធិ ]

១៤.មគ្គញាណ : ញាណទស្សនវិសុទ្ធិ

១៥.ផលញាណ : [ញាណទស្សនវិសុទ្ធិ]

១៦.បច្ចវេក្ខណញាណ : [ញាណទស្សនវិសុទ្ធិ ]

# ញាណទី ១

# នាមរូបបរិច្ឆេទញាណ

អានាបានសស្សតី យស្ស បរិបុណ្ណា សុភាវិតា

អនុបុព្វំ បរិចិតា យថា ពុទ្ធេន ទេសិតា

សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។

“អ្នកណា ចម្រើនសតិក្នុងខ្យល់ដកដង្ហើមចេញចូលយ៉ាងបរិបូណ៌ សន្សំទុកតាមលំដាប់ ដូចដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងទុក គេរមែងញ៉ាំងនូវលោកនេះឲ្យភ្លឺស្វាង ដូចជាព្រះច័ន្ទ ដែលរួចចេញអំពីពពក” ។

# បរិច្ឆេទទី ៦

## "លំដាប់នៃវិបស្សនាញាណ"

ក្នុងបរិច្ឆេទទី១ បានពោលដល់សីលវិសុទ្ធិ, បរិច្ឆេទទី ២ បានពោលដល់ចិត្តវិសុទ្ធិ និងតាំងតែបរិច្ឆេទទី ៣- ៥ បានពោលដល់គោលនៃការបដិបត្តិវិបស្សនាញាណរហូតបានសម្រេចនូវទិដ្ឋិវិសុទ្ធិ ជាដើម ទៅដល់ញាណទស្សនវិសុទ្ធិ ក្នុងបរិច្ឆេទនេះនឹងពោលដល់វិបស្សនាញាណ មាននាមរូបបរិច្ឆេទញាណជាដើម ដែលកើតឡើងតាមលំដាប់ដល់អ្នកបដិបត្តិធម៌ ដោយវិសុទ្ធិ ៥ មានទិដ្ឋិវិសុទ្ធិជាដើម ។

## "នាមរូបបរិច្ឆេទញាណ និង ទិដ្ឋិវិសុទ្ធិ"

៤...ខ្លឹមសារនៃទិដ្ឋិវិសុទ្ធិ ពោលទុកក្នុងគម្ពីរវិសុទ្ធិថា ៖

**នាមរូបានំ យាថាវទស្សនំ ទិដ្ឋិវិសុទ្ធិ នាម ។**

"ការឃើញរូប ( សភាពប្រែប្រួល, បែកធ្លាយ ) និងនាម ( សភាវៈបង្អោនទៅរកអារម្មណ៍, ដឹងអារម្មណ៍ ) តាមសេចក្តីពិតឈ្មោះថា ទិដ្ឋិវិសុទ្ធិ " ។

អ្នកបដិបត្តិធម៌ តាមន័យដែលពោលទុកក្នុងបរិច្ឆេទទី ៥ ហើយ កាលបើសមាធិមានកម្លាំងច្រើនឡើង សេចក្ដីរវើរវាយ ដែលនីវរណៈ រមែងមិនប្រាកដឡើង រុកគួនចិត្ត សតិមានការជាប់បន្តបន្ទាប់ពិតប្រាកដ សូម្បីក្នុងខណៈខ្លះ ការរវើរវាយ នឹងកើតឡើងខ្លះ ក៏ត្រូវកំណត់ដឹងបាន ដោយលឿនរហ័ស ហើយបាត់ទៅក្នុងខណៈនោះ សភាវធម៌ផ្លូវកាយ គឺវាយោធាតុ ដែលជាមហាភូតរូប ដែលប៉ះជាមួយខ្លួបសម្ផស្សបាន ( វាយោផោដ្ឋព្វ-ភូតរូប ) គឺសភាវៈប៉ោង-ផត អង្គុយ ឈរ ដើរ ដេក បត់លោត កំរើក ញ័រជាដើម រមែងប្រែប្រួលទៅអំពីធាតុដើមយ៉ាងពិតប្រាកដ ។ ទាំងមហាភូតរូបទៀតសោត ដែលជាសភាវៈរឹង-ទន់, ត្រជាក់-ក្ដៅ, ធូរ-តឹង ដែលបុគ្គលគប្បីប៉ះខ្លួបសម្ផស្សបាន ក៏ប្រែប្រួលយ៉ាងពិត អ្នកបដិបត្តិធម៌ រមែងយល់ចូលចិត្តថា "សភាវធម៌ពួកនោះ រមែងប្រែប្រួលពិតប្រាកដ"នឹងយល់ចូលចិត្តថា "ជាសភាវធម៌ ដែលមិនអាចដឹងអារម្មណ៍បាន ដូចជាកំណាត់ឈើ ដុំថ្ម គ្រាប់ខ្សាច់ " ។

ក្រៅអំពីនោះ ក្នុងខណៈខ្លះ អ្នកបដិបត្តធម៌នៅយល់ចូល

ចិត្តដល់ឧបាយរូប ( រូបដែលអាស្រ័យមហាភូតរូប ទើបកើតឡើង ) ជាដើម ដូចជា :

-ពណ៌ជាវត្ថុ ដែលត្រូវឃើញ ដោយចក្ខុបសាទ ជារូបថ្លា ដែលឃើញនូវរូបបាន ។

-សម្លេងជាវត្ថុ ដែលត្រូវឮ ដោយសោតបសាទ ជារូបថ្លា ដែលអាចបានឮនូវសម្លេង ។

-ក្លិនជាវត្ថុ ដែលត្រូវទទួលដឹងដោយឃានបសាទ ជារូបថ្លា ដែលអាចធុំក្លិនបាន ។

-រសជាវត្ថុ ដែលត្រូវលិទ្ធភ្លក្ស ដោយជិវ្ហាបសាទ ជារូបថ្លា ដែលអាចលិទ្ធភ្លក្សនូវរសបាន ។

-ត្រជាក់-ក្តៅ, រឹង-ទន់, ត្រជាក់-ក្តៅ, ធូរ-តឹង ជាវត្ថុ ដែលត្រូវប៉ះខ្ទប់សម្ផស្ស ដោយកាយបសាទ ជារូបថ្លា ដែលអាចប៉ះខ្ទប់សម្ផស្សភាពត្រជាក់-ក្តៅជាដើម ។

-ហទយវត្ថុ ជាទីអាស្រ័យនៃចិត្តដែលជាការនឹកគិត ។

[ ចក្ខុជា បសាទរូប គឺរូបថ្លា ដែលអាចឆ្លុះ ហើយជាស់ត្រឡប់មកវិញនូវរូប ដែលកំពុងតែប្រាកដ ត្រង់ពីមុខរបស់ខ្លួន

បាន ដោយប្រើពន្លឺជាគ្រឿងជំនួយ ដូចកញ្ចក់ថ្លា ដែលឆ្លុះរូបបាន តាមព្រះអភិធម្ម បសាទរូប ដែលដូចកញ្ចក់ឆ្លុះ មាន ៥ ប្រភេទ គឺ :

១.ចក្ខុបសាទ តាំងនៅក្នុងស្រទាប់ភ្នែក ៧ ជាន់ ដូចជាប្រេងផ្តិតប៉ុយសំឡី ៧ ជាន់ ក្នុងឋានដែលឃើញបាន ដែលជាទីកើតនៃសរីរៈសណ្ឋានរបស់អ្នកនៃអ្នកដទៃនៅចំពីខាងមុខ មានទំហំប៉ុនក្បាលចៃ ហើយនៅចំកណ្តាលភ្នែកខ្មៅ ដែលមានភ្នែកសរុំព័ទ្ធជុំវិញ ។

២. សោតបសាទ តាំងនៅ ផ្សព្វផ្សាយទូទៅរហូតស្ថានទីដែលមានរោមក្រហមតូចដុះឡើង
ដូចវង្វង់ចិញ្ចៀនដែលនៅក្នុង រន្ធត្រចៀក ។

៣. ឃានបសាទ តាំងនៅសព្វរហូតស្ថានទី ដែលមានសណ្ឋានដូចជាច្រមុះពពែ ។

៤. ជិវ្ហាបសាទ តាំងនៅសព្វ ស្ថានទីដែលសណ្ឋាន ដូចចុងត្របកឈូក នៅចំកណ្តាលអណ្តាត ដែលប្រកបដោយអវយវៈសណ្ឋាន ។

៥. កាយបសាទ តាំងនៅសព្វសព៌ាង្គកាយទាំងអស់មិនមានសល់ ប្រៀបដូចជាប្រេងចាក់ចុះ កន្ទែងសំពត់សំឡីផ្ទាំងធំ ដោយវៀរចេញនូវកន្លែងតាំងនៅរបស់ភ្លើងធាតុ ដែលរំលាយអាហាររបស់ចុងសក់ ចុងរោម ចុងក្រចក និងសាច់ងាប់ ដែលទទួលដឹងអ្វីៗ ទាំងអស់ ] ។

ការទទួលដឹងរូបក្នុងលក្ខណៈប្រែប្រួល នឹងមិនអាចដឹងអារម្មណ៍ នេះជាការឃើញរូបតាមសភាវៈពិត ( **រូបយាថាវ-ទស្សនំ** ) ព្រោះជាការយល់ចូលចិត្ត រូបដោយលក្ខណៈដែលប្រែប្រួល ( រូបប្បនលក្ខណំ ) នឹងដោយអាការប្រាកដដែលមិនដឹងអារម្មណ៍ ( **អព្យាកតបច្ចុបដ្ឋានំ** ) ដូចសេចក្ដីនៅក្នុងគម្ពីរដីកាថា ៖

**អចេតនោ អព្យាកតោតិ ឯត្ថ វិយ អានារម្មណតា វា អព្យាកតតា ទដ្ឋព្វា ។**

“ ន័យម្យ៉ាងទៀត គប្បីជ្រាបការមិនដឹងអារម្មណ៍ ថាជាអព្យាកតៈ ដូចពាក្យថា **អចេតនោ អព្យាកតោ** (មិនមានចេតនាមិនដឹងអារម្មណ៍ ) នេះ ” ។

សេចក្ដីខាងដើម មានន័យថា ពាក្យថា **អព្យាកតបច្ចុ-បដ្ឋានំ** ប្រែថា “មានអាការប្រាកដដែលមិនដឹងអារម្មណ៍” ដូចពាក្យថា **អព្យាកតោ** ប្រែថា “មិនដឹងអារម្មណ៍” ដែលមានសម្ដែងក្នុងគម្ពីរអដ្ឋកថា ៖

**ឥតិ កេសា នាម ឥមស្មឹ សរីរេ បាដិយេក្កោ កោដ្ឋាសោ បេតនោ អព្យកតោ សុញ្ញោ និស្សត្តោ ថទ្ធោ បឋវីធាតុ ។**

“ ដោយប្រការដូច្នេះ ធម្មតាថា សក់ជាបឋវីធាតុ ជាអវយវៈ ចំពោះតែចំណែកណានីមួយក្នុងសរីរៈនេះ មិនមានចេតនា មិនដឹងអារម្មណ៍ សោះសូន្យ មិនមែនសត្វបុគ្គល មានសេចក្ដីរឹងមាំ ” ។

ពាក្យអធិប្បាយ សេចក្ដីរបស់អព្យាកតៈសព្ទ ដែលពោលទុកក្នុងគម្ពីរដីកាខាងដើម មានសេចក្ដីអនុលោមទៅតាមការឃើញដ៏ក្រៃលែង ដែលអ្នកបដិបត្តិធម៌យល់ចូលចិត្ត ទើបសមគួរក្នុងរឿងនេះ ។

ក្រៅអំពីនោះ អ្នកបដិបត្តិធម៌រមែងដឹងថា ចិត្តដែលកំពុងកំណត់ដឹង ដូចជាការរត់ចូលទៅរកសភាវធម៌ មានការប៉ោង

ផត ជាដើម និងចិត្ត ដែលឃើញ, ឮ, ដឹងក្លិន, ដឹងរស, ដឹងផោដ្ឋព្វៈ ត្រូវការដឹងលាត ឬបត់ ដូចជាមួយការរត់សភាវធម៌ ដែលកំពុងប៉ោង ការរឭកដឹងយ៉ាងនេះ ការឃើញនាម តាមសេចក្ដីពិត ( **នាមយាថាវទស្សនំ** ) ព្រោះការយល់ចូលចិត្ត ដោយលក្ខណៈដែលបង្អោនទៅកាន់អារម្មណ៍ (**នមនលក្ខណំ**)។

ក្នុងពេលមុននឹងបដិបត្តធម៌ មនុស្សទូទៅរមែងទទួលដឹងសម្មតិនូវបញ្ញត្តិ រូបរាងសណ្ឋាន ឬ សមូហបញ្ញត្តិ( រូមរួម, ប្រមូលផ្តុំ) ទើបយល់ចូលចិត្តថា មានតួខ្លួន យើង របស់យើង បុរស ឬ ស្ត្រី ជាដើម ។

**អ្នកដែលឃើញ សភាវៈរបស់រូបនាមតាមសេចក្ដីពិតថា រូបមានសភាពប្រែប្រួល ឬមិនដឹងអារម្មណ៍ ចំណែកនាម ជាសភាពបង្អោនទៅកាន់អារម្មណ៍ រមែងមិនរឭកដឹងថាមាន តួខ្លួន ក្នុងខណៈនោះ នឹងរឭកដល់សេចក្ដីផ្សេងគ្នារបស់រូបនាមដូចជា៖**

-សភាវៈប៉ោង ក្នុងខណៈប៉ោង ជាអ្នកលះបង់ចំណែកចិត្តដែលកំពុងតែកំណត់ដឹង ។

-សភាវៈផត ក្នុងខណៈផត ជាអ្នកលះបង់ចំណែកចិត្ត

ដែលកំពុងកំណត់តែដឹង ។

-សភាវៈអង្គុយក្នុងខណៈអង្គុយ ជាអ្នកលះបង់ចំណែកចិត្តដែលកំពុងតែកំណត់ដឹង ។

-សភាវៈលាតក្នុងខណៈលាត ជាអ្នកលះបង់ ចំណែកចិត្តដែលកំពុងតែកំណត់ដឹង ។

-សភាវៈបត់ក្នុងខណៈបត់ ជាអ្នកលះបង់ ចំណែកចិត្តដែលកំពុងតែកំណត់ដឹង ។

-សភាវៈឃើញក្នុងខណៈឃើញ ជាអ្នកលះបង់ នូវចក្ខុបសាទ ឬចិត្តដែលកំពុងតែកំណត់ដឹង ។

ក្នុងគម្ពីរវិសុទ្ធិមគ្គបានលើកគាថា នៃបោរាណាចារ្យ មកជាសាធកៈទុកថា ៖

**ន ចក្ខុតោ ជាយរេ ផស្សបញ្ចមា ន រូបតោ នោ ច ឧភិន្នមន្តរា ហេតុំ បដិច្ចប្បភវន្តិ សង្ខតា យថាបិ សទ្ទោ បហដាយ ភេរិយា ។**

" សភាវៈឃើញដែលមានផស្សៈជាគម្រប់ ៥ [ ផស្សៈ វេទនា សញ្ញា ចេតនា និងចិត្ត ] មិនបានកើតអំពីភ្នែក ឬ រូប

និងមិនកើតរវាងក្អែក និងរូមជាសការៈ ដែលបច្ច័យតាក់តែង អាស្រ័យហេតុកើតឡើង ដូចសម្លេងស្គរ ដែលបុគ្គលវាយហើយ ដូច្នោះ " ។

សេចក្តីថា "ផស្សៈជាគម្រប់ ៥" រាប់ចិត្តអំពីចិត្ត ជាដើមទៅ រហូតដល់ផលផស្សៈ ដែលនៅលំដាប់ដំបូងក្នុងទី នេះ លោកពោលដល់នាមធម៌ ៥ យ៉ាងដែលប្រាកដច្បាស់ ប៉ុណ្ណោះ តែនៅមាននាមធម៌ដទៃ ដែលប្រកបព្រមគ្នាទៀតផង ដូចគម្ពីរមហាដីការបស់វិសុទ្ធិមគ្គពោលថា ៖

**ផស្សបញ្ចមគ្គហណំ ពេត្ត បាកដអរូបធម្មានំ ទស្សនំ។**

"ម្យ៉ាងទៀត ការពោលដល់ផស្សៈជាគម្រប់ ៥ ក្នុងរឿងនេះ ជាការសម្តែងនូវនាមធម៌ដែលប្រាកដច្បាស់" ។

កាលបុគ្គលនៅមិនទាន់បានវាយស្គរ សម្លេងស្គរ មិនមែនតាំងនៅក្នុងស្គរ ឬ អន្លូងទេ ថែមទាំងមិនបានស្ថិតនៅរវាងវត្ថុទាំងពីរនោះទៀតផងដែរ ដូច្នោះ សម្លេងស្គរ ទើបមិនបានកើតអំពីស្គរ ឬអន្លូង ឬក៏រវាងវត្ថុទាំងពីរ ( ស្គរ និងអន្លូង ) តែជាសម្លេងដែលកើតអំពីហេតុមកប្រជុំគ្នា គឺស្គរ អន្លូង និង

ការវាយ ដូច្នោះ ស្គរ និងអន្ទង ទើបជាអ្នកលះបង់ចំណែករបស់សម្លេងស្គរ យ៉ាងណាសភាវៈឃើញ ដែលប្រាកដក្នុងខណៈឃើញរូប ក៏ដូច្នោះដូចគ្នា គឺមុនទឹងកើតសភាវៈឃើញនោះសភាវៈឃើញមិនបានស្ថិតនៅក្នុងភ្នែក, រូប ឬរវាងចន្លោះភ្នែករូប និងភ្នែកទើបមិនបានកើតអំពីភ្នែក, រូប ពន្លឺ និងមនសិការក្នុងការមើល ដូច្នោះ សភាវៈឃើញទើបជាអ្នកលះបង់ចំណែកនិងរូប ។

ក្នុងគម្ពីរវិសុទ្ធិមគ្គ បានពោលដល់សភាវៈបានឮ ជាដើមទុកតាមលំដាប់ថា ៖

**ន សោតតោ ជាយរេ ផស្សបញ្ចមា ន សទ្ទតោ នោ ច ឧភិន្នមន្តរា ហេតុំ បដិច្ចប្បភវន្តិ សង្ខតា យថាបិ សទ្ទោ បហដាយ ភេរិយា ។**

“ សភាវៈបានឮ ដែលមានផស្សៈជាគម្រប់ ៥ [ ផស្សៈ វេទនា សញ្ញា ចេតនា និងចិត្ត ] មិនបានកើតអំពីត្រចៀក ឬសម្លេង និងមិនកើតរវាងត្រចៀកនិងសម្លេងជាសភាវៈ ដែលបច្ច័យតាក់តែង អាស្រ័យហេតុកើតឡើង ដូចសម្លេងស្គរដែល

បុគ្គលវាយហើយ ដូច្នោះ ” ។

**ន ឃានតោ ជាយរេ ផស្សបញ្ចមា ន គន្ធតោ នោ ច ឧភិន្នមន្តរា ហេតុំ បដិច្ចប្បភវន្តិ សង្ខតា យថាបិ សទ្ទោ បហដាយ ភេរិយា ។**

“សភាវៈដឹងដែលមានផស្សៈជាគម្រប់ ៥ [ ផស្សៈ វេទនា សញ្ញា ចេតនា និងចិត្ត ] មិនបានកើតអំពីច្រមុះ ឬក្លិន និងមិនកើតរវាងច្រមុះ និងក្លិន ជាសភាវៈដែលបច្ច័យតាក់តែងអាស្រ័យហេតុកើតឡើង ដូចសម្លេងស្គរ ដែលបុគ្គលវាយហើយ ដូច្នោះ” ។

**ន ជិវ្ហាតោ ជាយរេ ផស្សបញ្ចមា ន រសតោ នោ ច ឧភិន្នមន្តរា ហេតុំ បដិច្ចប្បភវន្តិ សង្ខតា យថាបិ សទ្ទោ បហដាយ ភេរិយា ។**

“ សភាវៈដឹងរសដែលមានផស្សៈជាគម្រប់ ៥ [ ផស្សៈ វេទនា សញ្ញា ចេតនា និងចិត្ត ] មិនបានកើតអំពីអណ្តាត ឬរស និងមិនកើតរវាងអណ្តាតនិងរសជាសភាវៈ ដែលបច្ច័យតាក់តែងអាស្រ័យហេតុកើតឡើង ដូចសម្លេងស្គរដែលបុគ្គល

វាយហើយ ដូច្នោះ " ។

**ន កាយតោ ជាយរេ ផស្សបញ្ចមា ន ផស្សតោ នោ ច ឧភិន្នមន្តរា ហេតុំ បដិច្ចប្បភវន្តិ សង្ខតា យថាបិ សទ្ទោ បហជាយ ភេរិយា ។**

" សភាវៈប៉ះខ្ទប់ដែលមានផស្សៈជាគម្រប់ ៥ [ ផស្សៈ វេទនា សញ្ញា ចេតនា និងចិត្ត ] មិនបានកើតអំពីកាយ ឬ សម្ផស្ស និងមិនកើតរវាងកាយនិងសម្ផស្សជាសភាវៈ ដែល បច្ច័យតាក់តែង អាស្រ័យហេតុកើតឡើង ដូចសម្លេងស្គរដែល បុគ្គលវាយហើយ ដូច្នោះ " ។

**ន វត្ថុរូបា បភវន្តិ សង្ខតា ន ចាបិ ធម្មាយតេហិ នគ្គតា ហេតុំ បដិច្ចប្បភវន្តិ សង្ខតា យថាបិ សទ្ទោ បហជាយ ភេរិយា ។**

"សភាវៈនឹកគិត ឬការកំណត់ដឹងដែលមានបច្ច័យតាក់ តែង មិនបានកើតឡើងអំពីវត្ថុរូប ( ហទយវត្ថុ ) នឹងមិនបាន កើតឡើងអំពីធម្មាយតនៈ ជាសភាវៈដែលបច្ច័យតាក់តែង អាស្រ័យហេតុកើតឡើង ដូចសម្លេងស្គរដែលបុគ្គលវាយហើយ

ដូច្នោះ ” ។

អ្នកដែលឃើញច្បាស់រូបនាម តាមដែលពោលមកនេះ រមែងយល់ចូលចិត្តថា អាកប្បកិរិយាផ្សេងៗ មានការអង្គុយ ឈរ ដើរ បត់ លាត ឃើញ បានឮ ជាដើម មិនអាចមានទៅបានដោយរូប ឬនាមតែម្យ៉ាងទេ ប៉ុន្តែ ដែលមានទៅបាននោះ ដោយការប្រជុំគ្នា របស់រូបនាមទាំងអស់ ។ ទោះបីយ៉ាងណាក៏ដោយមនុស្សទូទៅ រមែងសម្គាល់ថារូបនាមក្នុងលក្ខណៈសម្មតិបញ្ញត្តិ ទើបពោលថា យើងអង្គុយ យើងឈរ យើងដើរ យើងបត់ យើងលាត យើងឃើញ យើងបានឮ ។ល។ ពិតមែនហើយ មិនមានបុគ្គលអ្នកធ្វើការអង្គុយ ឈរ ដើរជាដើម មានត្រឹមតែរូបនាមពីរយ៉ាង ដែលប្រជុំគ្នាប៉ុណ្ណោះ ។ ដូចគម្ពីរវិសុទ្ធិមគ្គបានអធិប្បាយថា ៖

**[១] អថ ខោ នាមំ និស្សាយ រូបំ បវត្តតិ។ រូបនិស្សាយ នាមំ បវត្តតិ ។ [២] នាមស្ស ខាទិតុកាមតាយ បិវិតុកាមតាយ ព្យាហរិតុកាមតាយ ឥរិយាបថំ កប្បេតុកាម-តាយ សតិ រូបំ ខាទតិ បិវតិ ព្យាហរតិ ឥរិយាបថំ កប្បេតិ ។**

"១. ដោយពិតហើយ រូបរមែងប្រព្រឹត្តដោយអាស្រ័យនាម និងនាម ក៏រមែងប្រព្រឹត្តទៅដោយអាស្រ័យរូប ។

២. កាលនាមត្រូវការទើងទំពារ ផឹក និយាយ និងធ្វើនូវឥរិយាបថ រូបទើបទំពារ ផឹក និយាយ និងធ្វើឥរិយាបថបាន"។

សេចក្តីខាងដើមសម្តែងថា ៖

-សភាវៈចង់ទំពារ ជានាម, សភាវៈទំពារ ជារូប ។

-សភាវៈចង់ផឹក ជានាម, សភាវៈផឹក ជារូប ។

-សភាវៈចង់និយាយ ជានាម, សភាវៈនិយាយ ជារូប ។

-សភាវៈចង់ធ្វើឥរិយាបថ ជានាម, សភាវៈ ធ្វើឥរិយាបថជារូប ។

អ្នកបដិបត្តិធម៌ខ្លះ អាចយល់ចូលចិត្ត ក្នុងរូបនាមដោយការប្រៀបធៀបទៀតផង តួយ៉ាងដូចដែលមានពោលទុកក្នុងគម្ពីរវិសុទ្ធិមគ្គថា រាងកាយរបស់មនុស្សនោះ ចែកជារូបនាម ២ យ៉ាងប៉ុណ្ណោះ ដូចវត្ថុពួកនេះ គឺ ៖

-រថ ជាអង្គរួមប្រកបនៃរថនោះ ដូចជា ភ្លៅ កង់ ទូក...ជាដើម ។ល។

-ផ្ទះ ជាអង្គប្រកបនៃផ្ទះនោះ មាន ឈើ វល្លិ ។ល។

-ដើមឈើ ជាអង្គប្រកបនៃដើមឈើនោះ មាន ស្លឹក មែក ត្រួយ ជាដើម ។ល។

រាងកាយរបស់មនុស្សគ្រប់គ្នា ជាអង្គរួមនៃអវយវៈផ្សេងៗ សភាវៈដែលមានពិតដោយបរមត្ថ គឺរូបនាម ឬ ឧបាទានក្ខន្ធ ៥ មិនមានបុគ្គល តួខ្លួនយើង បុរស ឬស្ត្រី យ៉ាងណាទីមួយ ។ ពិតមែនហើយ រាងកាយនេះជាទីតាំងរបស់កិលេសគឺ ៖

១. **មានះ** ការប្រកាន់តួខ្លួនថា យើងល្អជាងអ្នកដទៃ។

២. **ទិដ្ឋិ** ការយល់ថា មានតួខ្លួន ។

សភាវៈដែលប្រាកដក្នុងរាងកាយនេះ តាមឃើញក្នុងការបដិបត្តិ គឺសភាវៈដែលប្រែប្រួល អំពីរយៈពេលមួយទៅកាន់រយៈពេលមួយ ឬសភាវៈដែលមិនដឹងនូវអារម្មណ៍ ( រូប ) ព្រមទាំងសភាវដែលបង្អោនទៅរកអារម្មណ៍ ឬដឹងអារម្មណ៍នោះឯង ( **នាម** "ចិត្ត និង ចេតសិក" ) បញ្ញាដែលយល់ចូលចិត្តយ៉ាងនោះ ជាការឃើញតាមសេចក្តីពិត ។

ពិតមែនហើយ ការប្រៀបធៀបដូចដែលពោលទុកក្នុងគម្ពីរ

នោះ មិនមែនជាគោលសំខាន់ បើអ្នកបដិបត្តិធម៌យល់ចូលចិត្តក្នុងរូបនាមយ៉ាងចាក់ច្បាស់ហើយ ដោយញែកចេញពីគ្នាបានថា រាងកាយនោះ មានត្រឹមតែសភាវៈដែលមិនដឹងច្បាស់នូវអារម្មណ៍ ( រូប ) និងមានត្រឹមតែសភាវៈ ដែលមិនដឹងច្បាស់នូវអារម្មណ៍ ( នាម "ចិត្ត និង ចេតសិក" ) មិនមានបុគ្គល អត្តា ឬវិញ្ញាណដែលតាំងនៅក្នុងរាងកាយនោះ ការយល់ចូលចិត្ត ដូចដែលពោលជានាមរូបបរិច្ឆេទញាណ យ៉ាងសមគួរបរិបូណ៌ហើយ ញាណប្រភេទនោះឈ្មោះថាទិដ្ឋិវិសុទ្ធិ គឺសេចក្តីបរិសុទ្ធនៃការឃើញ ព្រោះលះបង់នូវការយល់ខុសថាមានតួខ្លួន ( អត្តទិដ្ឋិ ) ដូចគម្ពីរមហាដីកា ពោលថា ៖

*[១] នាមរូបានំ យាថាវទស្សនន្តិ ឥទំ នាមំ, ឯត្តកំ នាមំ, ន ឥតោ ភិយ្យោ ។ ឥទំ រូបំ, ឯត្តកំ រូបំ, ន ឥតោ ភិយ្យោតិ ចតេសំ លក្ខណសលក្ខណមុខេន ធម្មមត្តតាវទស្សនំ ។*

*[២] អត្តទិដ្ឋិមលវិសោធនតោ ទិដ្ឋិវិសុទ្ធីតំ វេទិតព្វំ ។*

"១.ពាក្យថា នាមរូបានំ យាថាវទស្សនំ ( ការដឹងច្បាស់រូបនាមតាមសេចក្តីតាមពិត ) មានន័យថា ការដឹងច្បាស់តាម

សេចក្តីពិត ត្រឹមតែជាសភាវធម៌ ដែលកំណត់ដឹងរូបនាម ប៉ុណ្ណោះថា សភាវៈដែលកំណត់នេះជានាម ដែលបង្អោនទៅកាន់អារម្មណ៍, សភាវៈដែលកំណត់ត្រឹមតែប៉ុណ្ណោះ ជានាម មិនមានបុគ្គលដែលក្រៅអំពីនាមនេះ សភាវៈដែលត្រូវកំណត់ដឹងនេះ ជារូបដែលប្រែប្រួល, សភាវៈដែលត្រូវកំណត់ដឹងត្រឹមតែប៉ុណ្ណោះ ជារូប មិនមានបុគ្គលដែលក្រៅអំពីរូបនោះឡើយ ។

២. គប្បីជ្រាបឈ្មោះថា ទិដ្ឋិវិសុទ្ធិ ព្រោះកំចាត់នូវមន្ទិលគឺការយល់ខុសថា មានតួខ្លួន " ។

ពោលដោយសរុបវិបស្សនាញាណនេះ ឈ្មោះថា នាម-រូបបរិច្ឆេទញាណ គឺបញ្ញា ដែលកំណត់ដឹងនាមរូប អាចកំណត់ដឹងបានថា មានត្រឹមតែរូបនាម ដោយប្រាសចាកសម្មតិបញ្ញត្តិ ដែលជាបុគ្គល យើង របស់យើង បុរស ស្ត្រី ការកំណត់ដឹងរូបនាមនោះ គឺការដឹងលក្ខណៈវិសេស គឺលក្ខណៈរបស់រូបនាម យ៉ាងពិតប្រាកដ ពោលគឺ ៖

-រូប ជាសភាវៈប្រែប្រួល និងមិនដឹងអារម្មណ៍ ។

-នាម ជាសភាវៈដែលបង្អោនទៅកាន់អារម្មណ៍ គឺដឹង

ច្បាស់នូវអារម្មណ៍ ។

ក្រៅពីនោះ វិបស្សនានេះ នៅជាការដឹងលក្ខណៈវិសេស របស់រូប និងនាមតែម្យ៉ាងដូចជា ៖

-សភាវៈរឹង-ទន់ ជាលក្ខណៈវិសេសរបស់ធាតុដី ។

-ការប៉ះខ្ទប់ ជាលក្ខណៈវិសេសរបស់ផស្សៈ ។

-កាសោយ ជាលក្ខណៈវិសេសរបស់វេទនា ។

-ការចងចាំ ជាលក្ខណៈវិសេសរបស់សញ្ញា ។

-ការដឹងអារម្មណ៍ ជាលក្ខណៈវិសេសរបស់វិញ្ញាណ។

ម្យ៉ាងទៀតលក្ខណៈវិសេសរបស់រូបនាមដូចពេលប្រាកដ ក្នុងបច្ចុប្បន្នខណៈ ដែលប្រកបដោយខណៈចិត្ត៣ គឺឧប្បាទខណៈ (ខណៈកើតឡើង) ឋិតខណៈ (ខណៈតាំងនៅ) និងភង្គខណៈ ( ខណៈរលត់ទៅ ) មិនប្រាកដក្នុងអតីត ដែលរលត់ទៅហើយ និងអនាគត ដែលនៅមិនទាន់មកដល់ ដូច្នោះ ទើបគួរកំណត់ដឹង រូបនាមក្នុងបច្ចុប្បន្នខណៈប៉ុណ្ណោះ ។

## " ញាណទី ២ "

➡បច្ចយបរិគ្គហញាណ

ឥមំ កាយំ សម្មសថ  បរិជានាថ បុនប្បុនំ
កាយេ សភាវំ ទិស្វាន  ទុក្ខស្សន្តំ ករិស្សថ ។

"ពួកអ្នកចូរដឹងច្បាស់នូវកាយនេះ ចូរកំណត់ដឹងរឿយៗ កាលបើឃើញច្បាស់សភាវៈក្នុងកាយនេះហើយ រមែងនឹងធ្វើនូវទីបំផុតនៃទុក្ខបានមិនខានឡើយ" (មលិន្ទបញ្ហាទំព័រ ៣៨១)

"បច្ចយបរិគ្គហញាណ និង កង្ខាវិតរណវិសុទ្ធិ"

បច្ចយបរិគ្គហញាណ គឺញាណកំណត់ដឹងនាមរូប ដែលកើតខាងក្នុងខ្លួន ដោយយល់ចូលចិត្តថា មានត្រឹមតែនាមរូបដែលជាផលកើតអំពីនាមរូបដែលជាហេតុ ។

មានន័យថា អ្នកបដិបត្តដែលកំណត់ដឹងសភាវធម៌បច្ចុប្បន្នហើយ ឃើញសភាវៈពិតនូវរូបនាម រមែងយល់ចូលចិត្ត ហេតុកើតរបស់នាមរូបបាន តាមសមគួរ រមែងដឹងច្បាស់ថា រូបនាមក្នុងកាលទាំង ៣ គឺអតីត បច្ចុប្បន្ន និងអនាគត កើតអំពីហេតុ-បច្ច័យ ការដឹងក្នុងលក្ខណៈនេះជា នាម ដែលប្រាកដតាមអធ្យាស្រ័យ និងបារមីរបស់អ្នកបដិបត្តធម៌ ដូចគម្ពីរវិសុទ្ធិមគ្គពោលថា ៖

ឯតស្សេវ បន នាមរូបស្ស បច្ចយបរិគ្គហណេន តីសុ អទ្ធាសុ កង្ខំ វិតរិត្វា ឋិតំ ញាណំ កង្ខាវិតរណវិសុទ្ធិ នាម ។

“ម្យ៉ាងទៀត ញាណដែលឆ្លងផុតពីសេចក្តី ក្នុងកាលទាំង ៣ ដោយការកំណត់ដឹងបច្ច័យរបស់នាមរូបនោះៗ ឯង ឈ្មោះថា កង្ខាវិតរណវិសុទ្ធិ ( សេចក្តីបរិសុទ្ធដោយការឆ្លងផុតពីសេចក្តីសង្ស័យ )” ។

អ្នកបដិបត្តិធម៌ ដែលយល់ចូលចិត្តហើយថាមិនមានបុគ្គល យើង របស់យើង ក្នុងខណៈនោះអាចពិចារណាបានថា នាមរូប មិនបានកើតឡើងដោយឯងៗទេ ព្រោះឃើញការកើតនៃរូបនាម ដោយប្រចក្ស ( ទីងពោលតទៅ ) និងរូបនាមមិនបានកើតអំពី ការនិម្មិតរបស់ព្រះជាម្ចាស់, ព្រះព្រហ្ម, ព្រះឥន្ទ្រ ឬទេវតាអង្គ ណាមួយឡើយ ព្រោះបានឃើញថា ហេតុកើតរបស់ នាមរូប ហើយក្រៅអំពីនោះ នៅអាចពិចារណាតទៅបានថា សូម្បីព្រះជា ម្ចាស់ ក៏នៅមាននាមរូបដូចយើងដែរ ទីងមិនគួរមាននរណា និម្មិតនាមរូបរបស់ព្រះអង្គទេ បើមានពិត ក៏គួរស្វែងរកអ្នកនិម្មិត ដែលតាំងនៅខាងលើទៀតបាន ទើបមិនគួរមាននរណាម្នាក់ ដែល

និម្មិតនូវនាមរូបបាននោះឡើយ ក៏ប៉ុន្តែបើកើតឡើងតាមហេតុបច្ច័យ ដែលផ្គុំគ្នាប៉ុណ្ណោះ ។

## "ការដឹងច្បាស់ហេតុបច្ច័យតាមន័យទី ១"

អ្នកដែលបដិបត្តិធម៌ខ្វះ ដឹងច្បាស់តាមហេតុកើតរបស់រូបតាមន័យថា៖

-រូប គឺរាងកាយនេះ កើតឡើងបានអាស្រ័យហេតុ ៤ គឺ អវិជ្ជា តណ្ហា ឧបាទាន និងកម្ម ដែលធ្វើទុកក្នុងជាតិមុន ។

-រាងកាយនេះ តាំងនៅបាន អាស្រ័យអាហារ ដែលបរិភោគទំពារក្នុងភពនេះ ។

-រូបដែលជាអាកប្បកិរិយាអង្គុយ លាត បត់ មានទៅបានព្រោះចិត្ត ដែលត្រូវការនឹងអង្គុយ លាត បត់ជាដើម ។

-រូបដែលជាសភាវៈត្រជាក់-ក្តៅ មានទៅបាន ក៏ព្រោះតែធាតុត្រជាក់ ធាតុក្តៅ ។

ហេតុកើតរបស់រូបក្នុងបច្ចុប្បន្ន គឺចិត្ត ឧតុ និង អាហារជាវត្ថុដែលឃើញប្រចក្សបានងាយ, ចំណែកក្នុងអតីត គឺអវិជ្ជា តណ្ហា ឧបាទាន និង កម្ម មិនអាចដឹងបានដោយប្រចក្សបាន

ឡើយ ។ ទោះបីយ៉ាងណាក៏ដោយ អ្នកចំរើនវិបស្សនា មាន សម្មាទិដ្ឋិ ដែលជាការឃើញត្រូវ មុននឹងចូលបដិបត្តិធម៌ថា ភព ដែលល្អនិងផល ដែលល្អរមែងកើតអំពីកម្មល្អ, ភពដែលមិនល្អ និងផលដែលមិនល្អ, ឬរមែងកើតអំពីកម្មអាក្រក់ ។ សមដូច ព្រះពុទ្ធវចនៈថា **ទិដ្ឋិ ច ឧជុកា** (និងការឃើញដ៏ត្រឹមត្រូវ) រមែង ពិចារណាដល់អវិជ្ជា តណ្ហា ឧបាទាន និងកម្ម ដែលប្រាកដក្នុង បច្ចុប្បន្ន ហើយទើបអាចអនុមានដឹងហេតុបច្ច័យ ក្នុងអតីត ពួកនោះបាន ។

គប្បីជ្រាប់អវិជ្ជាមាន ២ ប្រភេទ គឺ ៖

**១.អប្បដិបត្តិអវិជ្ជា** ការមិនដឹងព្រោះមិនបដិបត្តិ គឺមិនដឹង ក្នុងទុក្ខសច្ចៈយ៉ាងត្រឹមត្រូវថា រូបនាម និងភពជាទុក្ខ និងមិន យល់ចូលចិត្តក្នុងសមុច្ចយៈថា តណ្ហា ដែលប្រាថ្នាវត្ថុពួកនោះ ជាទុក្ខ ។

**២.មិច្ឆាបដិបត្តិអវិជ្ជា** ការមិនដឹងព្រោះបដិបត្តិ គឺការយល់ ចូលចិត្តក្នុងទុក្ខសច្ចៈថា រូបនាម និងភពជាសុខ និងយល់ចូល ចិត្តខុសក្នុងសមុច្ចយសច្ចៈថា តណ្ហាដែលប្រាថ្នាវត្ថុនោះជាសុខ ។

អវិជ្ជាប្រភេទនេះ នៅគ្រប់ក្នុងចិត្តរបស់បុថុជ្ជនទូទៅ សូម្បីការសិក្សាគោលធម៌ ក៏មិនអាចលះបង់ទៅបានមនុស្សទូទៅ ទើបខំខ្វល់ខ្វាយឲ្យខ្លួនតាំងនៅល្អមានសុខ និងត្រូវវត្តដែលគួរកើតកើនត្រេកអរពុំត័ន្ធ យ៉ាងទៀតទាំងខិតខំព្យាយាមដើម្បីឲ្យរូបនាមនិងភពបច្ចុប្បន្នរស់នៅបានយូរ និងដើម្បីឲ្យរូបនាមក្នុងតទៅមានតែសេចក្តីសុខ ។

ក្រៅអំពីនោះអវិជ្ជានៅមាន ២ ប្រភេទ គឺ ៖

**១.អប្បដិបត្តិអវិជ្ជា** ការមិនដឹងក្នុងនិរោធសច្ចៈ យ៉ាងត្រឹមត្រូវថា ( អនុបាទិសេសនិព្វាន ) ដែលរលត់កម្ម និងកិលេសមិនមានសេសសល់ ហើយមិនកើតជាមនុស្ស ឬទេវតា បុរសឬស្ត្រីទៀត ជាវត្ថុល្អស្អាត និងមិនដឹងក្នុងមគ្គសច្ចៈ គឺការបដិបត្តិវិបស្សនា និងមិនដឹងថា មគ្គជាវត្ថុល្អស្អាត ។

**២. មិច្ឆាបដិបត្តិអវិជ្ជា** ការយល់ចូលចិត្តក្នុងនិរោធសច្ចៈខុសថា ព្រះនិព្វានជាទុក្ខ និងយល់ចូលចិត្តមគ្គសច្ចៈខុសថា ការបដិបត្តិវិបស្សនា និងមគ្គ ជាទុក្ខ ។

បុគ្គលដូចពោលមកនេះ សម្គាល់ខុសថា អ្នកដែលបាន

សម្រេចព្រះនិព្វានហើយ មិនអាចទទួលដឹង ឬរឭកដឹងអ្វីបាន មិនអាចជួបជាមួយនរណាបាន ធ្វើឲ្យខ្លាចការសម្រេចព្រះនព្វាន ថែមទាំងត្រិះរិះថាព្រះនព្វានជាការស្លាប់ ដែលមិនមានសេចក្តីសុខ និងត្រិះរិះ ដែលបដិបត្តិដើម្បីសម្រេចនូវព្រះនិព្វានថា ធ្វើឲ្យខ្លួនឯងជាទុក្ខដោយប្រាថ្នាប្រយោជន៍ ។

[ ព្រះនិព្វានជាសភាវៈ ដែលរលត់រូបនាមទាំងអស់ ទើបមានសភាវៈទៀងប្រាកដនូវការកើតឡើង របស់ដែលត្រូវតាំងនៅ និងរលត់ទៅវិញជាធម្មតា និងមានសភាវៈជាសុខនិរន្តរ៍ ព្រោះប្រាសចាកការកើតឡើងរបស់រូបនាម ដែលជាទុក្ខបៀតបៀនដោយការកើតរលត់ជានិច្ច ] ។

សរុបសេចក្តីមកថា **អវិជ្ជា** គឺការមិនដឹង មិនយល់ចូលចិត្តក្នុងសច្ចៈយ៉ាងត្រឹមត្រូវ និងយល់ចូលចិត្តក្នុងសច្ចៈខុសដូច្នេះ រមែងកើតឡើងតាមសមគួរ ក្នុងចិត្តរបស់បុថុជ្ជន ដោយភាវៈជា**សត្តានុសយ** ( អនុសយ ដែលដេកសម្ងំនៅក្នុងក្រសែចិត្ត ) និងនៅកើតឡើងក្នុងអារម្មណ៍ របស់បុគ្គលដែលមិនបានកំណត់ដឹងដោយភាវៈជា**អារម្មណានុសយ** ( អានុសយដែលដេកសម្ងំ

នៅក្នុងអារម្មណ៍ ) អ្នកចំរើនវិបស្សនារមែងកំណត់ដឹងអវិជ្ជា ក្នុងបច្ចុប្បន្នខណៈ ហើយឃើញច្បាស់បានដោយប្រចក្ស នឹងអាចអនុមានដឹង អវិជ្ជា ដែលធ្លាប់កើតឡើងក្នុងភពមុនទៀតផង ។

ក្រៅអំពីនោះមនុស្សទូទៅ រមែងភ្លឹតភ្លើងត្រេកអររូបនាមនិងភពដោយសម្គាល់ខុសថាជារបស់ដែលល្អស្អាត សេចក្តីនោះជាតណ្ហា គេរមែងប្រកាន់ដើម្បីឲ្យមានសេចក្តីសុខដរាបប៉ុណ្ណោះដែលនៅធ្លាក់ចុះក្នុងការភ្លឹតភ្លើនត្រេកអរ សេចក្តីនេះ ជាឧបាទាននឹងគេរមែងធ្វើការយ៉ាងណាទីមួយ ដើម្បីឲ្យបានទទួលវត្ថុ ដែលខ្លួនប្រកាន់មាំ សេចក្តីនេះជាកម្ម អ្នកបដិបត្តិរមែងកំណត់ដឹងនូវតណ្ហា ឧបាទាន និងកម្ម ក្នុងបច្ចុប្បន្នខណៈ ហើយឃើញច្បាស់បានដោយប្រចក្ស នឹងអាចអនុមានដឹងសភាវៈពួកនេះ ដែលធ្លាប់កើតក្នុងភពមុនទៀតផង ។

គេនឹងបានដឹងច្បាស់ដោយប្រចក្ស ( បច្ចក្ខញាណ ) ថារូបនាមក្នុងភពនេះ កើតអំពីកម្មល្អ ក្នុងមុនហើយអាចអនុមានដឹង (**អនុមានញាណ**) ថារូបនាមពួកនេះនៅកើតអំពីអវិជ្ជា តណ្ហានិងឧបាទានទៀតផង ព្រោះកាលមានកម្ម ក៏មានអវិជ្ជា តណ្ហា

និងឧបាទាន ។

➪ការឃើញច្បាស់នូវហេតុកើតរបស់រូបនាមដូចជា ៖

-ក្នុងខណៈកំណត់ថា"ឃើញហ្ន៎"រមែងយល់ថា ការឃើញដែលមានទៅបាន ព្រោះមានភ្នែក មានពណ៌ [ ហេតុកើតរបស់ការឃើញ ] ឬយល់ចូលចិត្តថា ចិត្តប៉ះខ្ទប់ជាមួយអារម្មណ៍ ( កើតផស្សៈ ) បានព្រោះភ្នែក ពណ៌ និងការឃើញមកប្រជុំគ្នា [ ហេតុកើតរបស់ផស្សៈ] ។

-ក្នុងខណៈកំណត់ថា "បានឮហ្ន៎" រមែងយល់ចូលចិត្តថា ការបានឮមានទៅបាន ព្រោះមានត្រចៀក, មានសម្លេង [ ហេតុកើតរបស់ការបានឮ] ឬយល់ចូលចិត្តថា ចិត្តប៉ះខ្ទប់ជាមួយអារម្មណ៍ ( កើតផស្សៈ ) បានព្រោះត្រចៀកសម្លេង និងការបានឮមកប្រជុំគ្នា [ ហេតុកើតរបស់ផស្សៈ] ។

-ក្នុងខណៈកំណត់ថា "ពាល់ត្រូវហ្ន៎" រមែងយល់ចូលចិត្តថា ការប៉ះខ្ទប់ផស្សៈមានទៅបាន ព្រោះមានរាងកាយ, មានវត្ថុដែលប៉ះខ្ទប់សម្ផស្ស [ហេតុកើតការប៉ះខ្ទប់សម្ផស្ស] ឬយល់ចូលចិត្តថា ចិត្តប៉ះខ្ទប់ជាមួយអារម្មណ៍ ( កើតផស្សៈ ) បាន

ព្រោះមានរាយកាយ វត្ថុ និងប៉ះខ្ទប់សម្ផស្សមកប្រជុំគ្នា [ ហេតុកើតរបស់សម្ផស្ស ] ។

-ក្នុងខណៈកំណត់ថា "គិតហ្ន៎""ដឹងហ្ន៎" ឬ"កំណត់ដឹងហ្ន៎" រមែងយល់ចូលចិត្តថា ការគិត ការដឹង ការកំណត់ដឹង មានទៅបាន ព្រោះមានរាងកាយ, មានហទយវត្ថុដែលទទួលដឹង ឬយល់ចូលចិត្ត ការប៉ះខ្ទប់ជាមួយអារម្មណ៍ [កើតផស្សៈ] បានព្រោះមានរាងកាយ, មានហទយវត្ថុ និងអារម្មណ៍ដែលទទួលដឹង និងការនឹកគិត ឬការកំណត់ដឹងមកប្រជុំគ្នា [ ជាហេតុកើតរបស់ផស្សៈ ] ។

-ក្នុងខណៈដែលកំណត់ថា "ឃើញហ្ន៎" "បានឮហ្ន៎"ឬ "ពាល់ត្រូវហ្ន៎" ឬ"គិតហ្ន៎"រមែងយល់ចូលចិត្តថា រាងកាយ ឬចិត្តមានសេចក្ដីសុខ ឬទុក្ខ កាលបើចិត្តប៉ះខ្ទប់ជាមួយអារម្មណ៍ [ជាហេតុកើតរបស់វេទនា] ឬ ដឹងខ្លួនថាចង់បាននូវសេចក្ដីសុខដ៏ក្រៃលែងឡើងៗ កាលប៉ះខ្ទប់ជាមួយសេចក្ដីសុខ ឬចង់មានសេចក្ដីសុខ កាលប៉ះខ្ទប់ជាមួយសេចក្ដីទុក្ខ [ ហេតុកើតរបស់តណ្ហា] ឬ យល់ថា ខ្លួនមានការប្រកាន់មាំ ព្រោះចង់រស់នៅល្អ

មានសេចក្ដីសុខ [ហេតុកើតរបស់ឧបាទាន] ឬយល់ថា ខ្លួនបាន ធ្វើ, បាននិយាយ ឬបានគិតកម្មល្អ កម្មមិនល្អ ព្រោះសេចក្ដីប្រកាន់មាំ [ ជាហេតុកើតរបស់កម្ម ] ។

## "កាលអនុមានដឹងហេតុដែលជាអតីត និងអនាគត"

អ្នកដែលដឹងហេតុកើតរបស់រូបនាមក្នុងបច្ចុប្បន្ន យ៉ាងនេះ រមែងអនុមានដឹងថា សូម្បីក្នុងអតីត និងអនាគត ក៏មានហេតុកើតតែមួយដូចគ្នា ។ សមដូចគម្ពីរវិសុទ្ធិមគ្គពោលថា ៖

**សោ ឯវំ បច្ចយតោ រូបនាមស្ស បវត្តិំ ទិស្វា យថា ឥទំ ឯតរហិ, ឯវំ អតីតេបិ អទ្ធានេ បច្ចយតោ បវត្តិត្ថ អនាគតេបិ បច្ចយតោ បវត្តិស្សតិ សមនុបស្សតិ ។**

" អ្នកបដិបត្តិធម៌នោះ ឃើញការកើតឡើងរបស់រូបនាម [ក្នុងបច្ច័យ]ព្រោះបច្ច័យយ៉ាងនេះ ហើយយល់ចូលចិត្តថា រូបនាមទាំងអស់កាលអតីត និងក្នុងកាលជាអនាគត ក៏កើតឡើង ព្រោះអាស្រ័យបច្ច័យដូចរូបនាមក្នុងបច្ចុប្បន្នដូចគ្នា " ។

អ្នកដែលយល់ចូលចិត្ត រមែងឃើញថា មានត្រឹមតែរូបនាម ដែលជាហេតុ និងក្នុងកាលទាំង ៣ គឺអតីត បច្ចុប្បន្ន និងអនាគត

មិនមានបុគ្គល យើង គេ របស់យើង បុរស ឬ ស្ត្រី និងរមែង កន្ទងផុតនូវសេចក្តីសង្ស័យ ១៦ ប្រការ ដែលជាប់ទាក់ទងដោយ ខ្លួន ដែលចែកជាសេចក្តីសង្ស័យ ផ្នែកអតីត ៥ អនាគត ៥ និង បច្ចុប្បន្ន ៦ ដូច្នោះ គឺ ៖

## ១.សេចក្តីសង្ស័យផ្នែកអតីត មាន ៥ យ៉ាង

(ក) យើងកើតមុនក្នុងកាលជាអតីតកាលឬ ?

មានន័យថា យើងធ្លាប់កើតមកមុនយ៉ាងបន្តបន្ទាប់ ក្នុងភពមុន និងដល់នេះឬ? ( **អហោសិ នុ ខោ អហំ អតីតមទ្ធានំ** ) ។

(ខ) យើងមិនធ្លាប់កើតមុនក្នុងកាលជាអតីតកាលឬ ?

សេចក្តីថា យើងមិនធ្លាប់កើតមកមុន ហើយកពូនមកកើតក្នុងភព នេះឬ? ( **ន នុ ខោ អហោសិ អតីតមទ្ធានំ** ) ។

(គ) យើងធ្លាប់ជាអ្វីក្នុងកាលជាអតីតកាលឬ ?

សេចក្តីថា យើងធ្លាប់កើតជាស្តេច, ព្រាហ្មណ៍, សេដ្ឋី, យាចក, មនុស្ស, ទេវតា, ព្រហ្ម ឬ សត្វតិរច្ឆាន ជាដើម ហើយកពូនមក កើតក្នុងភពនេះឬ? ( **កឹ នុ ខោ អហោសិ អតីតមទ្ធានំ** ) ។

(ឃ) យើងបានជាយ៉ាងណា?

សេចក្តីថា យើងធ្លាប់មានរូបរាងសណ្ឋាន ខ្មៅ ក្រហម ស ជាដើមៗ ន័យម្យ៉ាង គឺយើងបានកើតក្នុងអតីតព្រោះហេតុណា? មានន័យថា នរណាដែលជាអ្នកនិម្មិតយើងមក គឺព្រះជាម្ចាស់ ព្រះឥន្ទ ព្រះព្រហ្ម ឬទេវតា ឬក៏យើងកើតមកឯងៗ តាមធម្មជាតិ ( **កថំ នុ ខោ អហោសិំ អតីតមទ្ធានំ** ) ។

(ង) យើងបានជាអ្វី ហើយជាអ្វីទៀត ក្នុងអតីតកាលឬ? ( **កិំ ហុត្វា កិំ អហោសិំ នុ ខោ អតីតមទ្ធានំ** ) ។

[សេចក្តីថា "យើងបានជាអ្វី? ហើយបានជាអ្វីទៀត ក្នុងអតីតកាលហ្ន៎ " សំដៅដល់ការវិលកើតវិលស្លាប់ជាអ្វីខ្លះ មកក្នុងជាតិមុន] ។

## ២.សេចក្តីសង្ស័យក្នុងកាលអនាគត មាន ៥ យ៉ាង

(ក) យើងនឹងកើតក្នុងអនាគតកាលឬហ្ន៎ ?

សេចក្តីថា ខ្លួនរបស់យើងតាំងនៅ មិនសោះសូន្យទៅក្រោយអំពីការអស់ជីវិតឬហ្ន៎ ? ( **ភវិស្សាមិ នុ ខោ អហំ អនាគតមទ្ធានំ** ) ។

(ខ) យើងនឹងមិនកើតក្នុងអនាគតកាលឬហ្ន៎ ?

សេចក្តីថា ខ្លួនរបស់យើងនឹងសោះសូន្យទៅក្រោយអំពីអស់ជីវិតហើយ ឬហ្ន៎ ? ( **ន នុ ខោ ភវិស្សាមិ អហំ អនាគតមទ្ធានំ** ) ។

(គ) យើងនឹងជាអ្វី ក្នុងកាលអនាគត ឬហ្ន៎ ?

សេចក្តីថា នឹងទៅជាស្តេច ឬអ្វី? ជាដើម ( **កឹ នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ** ) ។

(ឃ) យើងនឹងជាយ៉ាងណា ក្នុងកាលអនាគតហ្ន៎ ?

សេចក្តីថា នឹងមានរូបរាងសណ្ឋានយ៉ាងណា ? ន័យម្យ៉ាងទៀតគឺ យើងនឹងកើតក្នុងកាលអនាគតបានព្រោះហេតុណា ? សេចក្តីថា នឹងមានអ្នកនិម្មិត្ត ឬយើងនឹងឯងៗ តាមធម្មជាតិ ( **កថំ នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ** ) ។

(ង) យើងនឹងទៅជាអ្វី ? ហើយជាអ្វីទៀតក្នុងអនាគតកាលហ្ន៎? ( **កឹ ហុត្វា កឹ ភវិស្សាមិ នុ ខោ អហំ អនាគតមទ្ធានំ** ) ។

### ៣. សេចក្តីសង្ស័យបច្ចុប្បន្ន មាន ៦ យ៉ាង

(ក) យើងកំពុងតែមានឬ ?

សេចក្តីថា ខ្លួន ឬវិញ្ញាណ កំពុងតែមាននៅក្នុងរាងកាយនេះឬ ? ( **អហំ នុ ខោសិ** ) ។

(ខ) យើងកំពុងតែមិនមានឬ ?

មានន័យថា ខ្លួន ឬវិញ្ញាណ កំពុងតែមិនមាននៅក្នុងរាងកាយនេះឬ?

( នោ នុ ខោសិ ) ។

(គ) យើងកំពុងតែជាអ្វីហ្ន៎?

សេចក្ដីថា យើងកំពុងតែជាស្ដេច ឬកំពុងតែជាអ្វីហ្ន៎? ( កឹ នុ ខោស្មិ ) ។

(ឃ) យើងកំពុងតែជាយ៉ាងណាហ្ន៎?

សេចក្ដីថា យើងកំពុងតែមានរូបរាងសណ្ឋានយ៉ាងណា? ន័យម្យ៉ាងទៀត គឺយើងកំពុងតែកើតក្នុងបច្ចុប្បន្នព្រោះហេតុណាហ្ន៎? ( កថំ នុ ខោស្មិ ) ។

(ង) បុគ្គលនេះកំពុងតែមកអំពីណាហ្ន៎? ( អយំ នុ ខោ សត្តោ កុតោ ) ។

(ច) បុគ្គលនេះ កំពុងតែមកអំពីកពណាហ្ន៎? ហើយនឹងកំពុងតែទៅកាន់កពណាហ្ន៎? ( សោ កុហឹ គាមីភវិស្សតិ ) ។

សេចក្ដីសង្ស័យទាំង ១៦ ប្រភេទនេះ កើតមានដល់បុគ្គលអ្នកប្រកាន់មាំថា មានបុគ្គលតួខ្លួន ។

ដូចគម្ពីរវិសុទ្ធិមគ្គ មហាដីកាពោលថា ៖

**អត្តាភិនិវេសុបនិស្សាយ ហិ អាហោសឹ នុ ខោ អហន្តិ**

**អាទិនយប្បវត្តា សោឡសវត្ថុកា កង្ខា ។**

“ សេចក្ដីសង្ស័យដែលមានទីតាំង ១៦ យ៉ាង ដែលប្រព្រឹត្ត ទៅ ដោយន័យថា យើងកើតមកហើយក្នុងអតីតកាល មានការ ប្រកាន់មាំជាទីអាស្រ័យឬ? ” ។

សេចក្ដីសង្ស័យ ដូចដែលពោលនេះ នឹងកើតឡើងដល់ ដែលយល់ដូចចិត្តថា មានត្រឹមតែរូបនាម ដែលជាហេតុ និងផល នៃគ្នានិងគ្នា មិនមានបុគ្គល យើង របស់យើង ឬ បុរស ស្ត្រី រាប់ថា ជាការរលត់ទៅដោយការគ្រប់សង្កត់ទុក ( **វិក្ខម្ភនវិរោធ** ) ប្រៀបហាក់បីដូចជា មនុស្សដែលមិនដឹងថា ទន្សាយមានខ្នងគេ ឬទេ? ក៏នឹងសង្ស័យមិនដាច់ស្រេចថា ទន្សាយមានខ្នងគេឬទេ? គេជាទន្សាយ មានរូបរាងយ៉ាងណា? តែកាលបើគេដឹងច្បាស់ថា ទន្សាយមិនមានខ្នងគេ ( ខ្នងមិនបានតាំងនៅក្នុងទន្សាយ ) ក៏នឹង មិនសង្ស័យក្នុងរឿងនោះ ។

[ ការយល់ចូលចិត្តថា រូបនាមដែលជាហេតុផល នៃគ្នា និង គ្នា ដោយវិបស្សនាញាណទី ២ នេះ ជារលត់សេចក្ដីសង្ស័យ ដោយការគ្រប់សង្កត់ទុកមួយគ្រា តអំពីកាលអ្នកបដិបត្តិធម៌បាន

សម្រេចជាព្រះសោតាបន្នហើយ ទើបលះបង់សេចក្ដីសង្ស័យបាន ដាច់ជាសមុច្ឆេទ ដោយមគ្គញាណ] ។

## ការដឹងច្បាស់ហេតុបច្ច័យតាមន័យទី ២

អ្នកបដិបត្តិធម៌ខ្លះ រមែងដឹងច្បាស់ហេតុកើតឡើងរបស់នាម ថា ៖

-ការឃើញទៅបាន ព្រោះមានភ្នែក មានពណ៌ ។

-ការឮទៅបាន ព្រោះមានត្រចៀក មានសម្លេង ។

-ការដឹងក្លិនទៅបាន ព្រោះមានច្រមុះ មានក្លិន ។

-ការដឹងរសទៅបាន ព្រោះមានអណ្ដាត មានរស ។

-ការដឹងផោដ្ឋព្វៈទៅបាន ព្រោះមានរាងកាយ មានផោដ្ឋព្វៈ។

-ការនឹកគិត ការដឹង ឬការកំណត់ដឹង មានទៅបាន ព្រោះហទយវត្ថុ មានអារម្មណ៍ ដែលចិត្តទទួលដឹង ។

-កុសល ឬការចំរើនវិបស្សនា មានទៅបានព្រោះការធ្វើទុកក្នុងចិត្តដោយឧបាយដែលត្រូវទំនង ( យោនិសោមនសិការ ) នៅក្នុងស្ថានទីដែលសមគួរសេពគប់សប្បុរស ស្ដាប់ធម៌របស់សប្បុរស និងមានបារមីចាស់ក្លា ។

-អកុសលមានទៅបាន ព្រោះមិនធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា មិនត្រូវទំនង ( អយោនិសោមនសិការ ) នៅក្នុងទីដែលមិនសមគួរ សេពគប់បុគ្គលពាល ស្តាប់ពាក្យរបស់បុគ្គលពាល និងមិនមានបារមីចាស់ក្លា ។

-វិបាកល្អ ព្រោះធ្វើកម្មល្អ ( វិបាកល្អ គឺផលកម្មដែលបានដល់ការកើតក្នុងភពដែលល្អ ការឃើញ, បានឮ, ដឹងក្លិន, ដឹងរស, ដឹងផោដ្ឋព្វៈ, និងទទួលដឹងវត្ថុដែលល្អ ) ។

-វិបាកមិនល្អ ព្រោះធ្វើកម្មអាក្រក់ ( វិបាកមិនល្អ គឺផលកម្មមិនល្អ ដែលបានដល់ការកើតក្នុងភពដែលមិនល្អ ការឃើញ, បានឮ, ដឹងក្លិន, ដឹងរស, ដឹងផោដ្ឋព្វៈ និងទទួលដឹងវត្ថុដែលមិនល្អ )។

-ការពិចារណា ( អាវជ្ជនចិត្ត ) មានទៅបាន ព្រោះមានភវង្គចិត្ត ដែលកើតឡើងមុន ការឃើញហេតុកើតរបស់រូបដូចជា

-ពួករូបក្នុងបច្ចុប្បន្ន បានដល់ ភ្នែក ត្រចៀក ជាដើម មកតាំងតែអំពីកើតក្នុងភពនេះ ព្រោះកម្មចាស់ ។

-រូបដែលជាអាកប្បកិរិយា អង្គុយ បត់ លាត មានទៅបាន

ព្រោះចិត្តដែលត្រូវការនឹងអន្ទុយ បត់ លាត ជាដើម ។

-ការត្រជាក់-ក្តៅ មានទៅបាន ព្រោះធាតុត្រជាក់ ធាតុក្តៅ ។

-រូបរាងកាយនេះ មានកម្លាំងមាំមួន ព្រោះមានអាហារដែលបរិភោគ ទំពារ ផឹក ជាដើម ។

-អ្នកបដិបត្តិធម៌ ឃើញហេតុកើតរបស់រូបនាម ដោយទូទៅ និងមិនទូទៅយ៉ាងនេះ រមែងអនុមានដឹងថា រូបនាមក្នុងភពមុនមកអំពីហេតុបច្ច័យ ដូចរូបនាមក្នុងភពនេះ សូម្បីហេតុបច្ច័យគេរមែងយល់ចូលចិត្ត ហើយនឹងលះបង់នូវសេចក្តីសង្ស័យ ១៦ ប្រការ ដូចដែលពោលមកនេះឯង ។

## ➪ការដឹងច្បាស់ហេតុបច្ច័យ តាមន័យទី ៣

អ្នកបដិបត្តិធម៌ខ្លះ រមែងដឹងច្បាស់ការកើតឡើង ការតាំងនៅ និងការរលត់ទៅ ( ជាតិ ជរា និង មរណៈ ) របស់រូបនាមក្នុង បច្ចុប្បន្នខណៈដែលកំពុងកំណត់ដឹង ធ្វើឲ្យយល់ចូលចិត្តថា ការកើតឡើង ( ជាតិ ) គឺការប្រាកដនៃខណៈចិត្ត ។

ម្យ៉ាងទៀត ការស្លាប់ ( មរណៈ ) គឺការរលត់ទៅរបស់ខណៈចិត្តមួយប៉ុណ្ណោះ ការតាំងនៅ ឬការចាស់ ( ជរា ) ជា

ការតាំងនៅយ៉ាងបន្តបន្ទាប់របស់រូបនាម គេរមែងដឹងច្បាស់នូវហេតុកើតរបស់រូបនាម ដោយបដិច្ចសមុប្បាទ បដិលោមន័យថា

-ការចាស់ ( ជរា ) និងស្លាប់ ( មរណៈ ) មានទៅបាន ព្រោះមានការធ្វើទុកក្នុងភពមុន ( កម្មភព ) ។

-អ្នកដែលធ្វើទុកក្នុងភពមុន ( កម្មភព ) មានទៅបាន ព្រោះមានកម្មដែលធ្លាប់ព្រោះសេចក្ដីប្រកាន់ថា បើធ្វើហើយនឹងបានទទួលផលល្អ ។

-ការប្រកាន់មាំ ( ឧបាទាន ) មានទៅបាន ព្រោះសេចក្ដីត្រូវការរូបនាម ។

-សេចក្ដីត្រូវការរូបនាម ( តណ្ហា ) មានទៅបាន ព្រោះវេទនាដែលពេញចិត្តល្អ ឬមិនល្អ ។

-វេទនា មានទៅបាន ព្រោះការប៉ះខ្ទប់ជាមួយអារម្មណ៍ (ផស្សៈ ) ។

-ការប៉ះខ្ទប់រវាងចិត្តជាមួយអារម្មណ៍ មានទៅបាន ព្រោះមានអាយតនៈ ៦ គឺ មានភ្នែក ត្រចៀក ច្រមុះ កាយ ចិត្ត (កាលមាន ភ្នែកនិងចិត្ត គប្បីឃើញពណ៌ ) ។

អាយតនៈ ៦ (សឡាយតនៈ) មានទៅបានព្រោះ មានរូប-នាមដែលជាទីអាស្រ័យ ពោលគឺអាយតនៈ ៥ បានដល់បសាទរូប ដែលជារូបថ្លា បានដល់ ចក្ខុបសាទរូប សោតប-សាទរូប ឃានបសាទរូប ជិវ្ហាបសាទរូប និង កាយបសាទរូប មានទៅបាន ដោយអាស្រ័យមហាភូតរូប ៤ បឋវីជាដើម ។ ចំណែក មនាយតនៈគឺចិត្តមានទៅបាន ព្រោះដោយអាស្រ័យហទយវត្ថុ និងនាមធម៌ ដែលប្រកបរួមគ្នា ( ចេតសិក ) ។

-រូបនាមមានទៅបាន ព្រោះបដិសន្ធិចិត្តភវង្គចិត្ត និងសភាវៈ ឃើញ បានឮជាដើម ( ចិត្ត ) ។

- ចិត្តដូចដែលពោល មានទៅបាន ព្រោះការធ្វើកម្មដើម្បីឲ្យស្ថិតនៅល្អ មានសុខក្នុងភពមុន( សង្ខារ ) ។

-ការធ្វើកម្មក្នុងភពមុន មានទៅបាន ព្រោះមិនដឹងច្បាស់នូវសេចក្តីពិតនិងមិនដឹងខុស ( អវិជ្ជា ) ។

-ការឃើញច្បាស់ តាមបដិច្ចសមុប្បាទធម៌នេះ រមែងប្រាកដ អ្នកដែលមានបារមីចាស់ក្លានោះ មានតែព្រះសម្មាសម្ពុទ្ធ

ប៉ុណ្ណោះ ជាអ្នកដែលដឹងច្បាស់ហេតុកើតរបស់រូបនាម តាមន័យនេះ រមែងអនុមានដឹងតាមដែលពោលទុក ហើយអាចឆ្លងផុតអំពីសេចក្តីសង្ស័យ ១៦ ប្រភេទ ដូចពោល ។

## ➩ការដឹងច្បាស់ហេតុបច្ច័យតាមន័យទី ៤

អ្នកបដិបត្តិធម៌ខ្លះ រមែងដឹងច្បាស់ហេតុកើតរបស់រូបនាម ដោយបដិច្ចសមុប្បាទ អនុលោមន័យថា ព្រោះមានអវិជ្ជា ទើបមានសង្ខារ ព្រោះសង្ខារ ទើបមានវិញ្ញាណ ជាដើម រាប់ថាជាការដឹងច្បាស់យ៉ាងបរិបូណ៌ របស់អ្នកមានបារមីចាស់ក្លាហើយ អ្នកដែលដឹងច្បាស់ហេតុកើតរបស់រូបនាម តាមន័យនេះ រមែងអនុមានដឹង តាមដែលពោលទុក ទើងឆ្លងផុតអំពីសេចក្តីសង្ស័យ ១៦ ប្រភេទដូចដែលពោលមកនេះឯង ។

## ➩ការដឹងច្បាស់ហេតុបច្ច័យតាមន័យទី ៥

អ្នកបដិបត្តិធម៌ខ្លះ រមែងដឹងច្បាស់ហេតុកើតរបស់រូបនាម ដោយជាប់បន្តគ្នាអំពីកម្មវដ្ដ: ( វិលជុំវិញកម្ម ) និងវិបាកវដ្ដ (វិលជុំវិញវិបាក ) ថាផលកម្ម មានទៅបាន ព្រោះធ្វើកម្ម ។

កម្មថ្មីមានទៅបាន ព្រោះផលកម្មនោះ នឹងផលកម្មថ្មី ក៏មានទៅបាន ព្រោះធ្វើកម្មថ្មី ដូច្នោះជាដើម ដោយអន្តធម៌ចែកជា

-កម្មវដ្ត គឺអវិជ្ជា សង្ខារ តណ្ហា ឧបាទាន និងកម្មភព ។

-វិបាកវដ្ត គឺ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និង វេទនា ។

អ្នកប្រាថ្នាសេចក្តីព្យាយាមខ្លះ អាចរឭកដឹងច្បាស់កម្មវដ្តៈ ៥ និងវិបាកវដ្តៈ ៥ ដោយល្អិតបរិបូណ៌ លោកក៏ដឹងដោយសង្ខេប គឺដឹងច្បាស់ថាកម្មវដ្តៈ ជាហេតុ និងវិបាកវដ្តៈ ជាផលកម្ម ដូចគម្ពីរបដិសម្ភិទាមគ្គពោលថា៖

[១] បុរិមកម្មភវស្មឹ មោហោ អវិជ្ជា, អាយូហនា សង្ខារា, និកន្តិ តណ្ហា, ឧបគមនំ ឧបាទានំ, ចេតនាភវោ ។

[២] ឥមេ បញ្ច ធម្មា បុរិមកម្មភវស្មឹ ឥធ បដិសន្ធិយា បច្ចយា ។

"១. កាលបុគ្គលអ្នកធ្វើកម្ម ក្នុងភពមុន ការវង្វេងខុស

ជាអវិជ្ជា ការខ្វល់ខ្វាយ [ក្នុងការឲ្យទាន ឬសម្លាប់សត្វ ជាដើម ដើម្បីឲ្យខ្លួនបានសុខ] ជាសង្ខារសេចក្តីត្រូវការ [នឹងបានទទួលផលកម្មក្នុងបច្ចុប្បន្ន] និងអនាគត ជាតណ្ហា ការចូលទៅប្រកាន់មាំ [ដោយត្រូវការនឹងបានសុខក្នុងបច្ចុប្បន្ន អនាគត ឬលះបង់ភពជាតិ] ជាឧបាទាន ចេតនាជាកម្មភព [ គឺជាហេតុឲ្យកើតផលថ្មី ] ។

២. ធម៌ទាំង ៥ កើតឡើងក្នុងខណៈធ្វើកម្ម ក្នុងភពមុន ”។ ក្នុងគម្ពីរអដ្ឋកថា សម្តែងដល់កាលផ្សេងៗ គ្នារវាងសង្ខារ និងកម្មភពទុក ៣ ន័យ ក្នុងទីនេះ សូមសម្តែងចំពោះ តែន័យដំបូង ដែលអាចយល់ចូលចិត្តបានងាយថា សង្ខារគឺចេតនាដែលកើតឡើងមុន និងធ្វើកម្មតាំងតែអំពីការចាប់ផ្តើម ដើម្បីនឹងឲ្យទាន ឬសម្លាប់សត្វជាដើម ។ ជាតួជំរុញជាស់ តឿនឲ្យប្រញាប់ធ្វើកម្មនោះៗ ចំណែកកម្មភព គឺចេតនាក្នុងខណៈធ្វើកម្ម ជាតួបាត់បែងការងារក្នុងការធ្វើកម្មៗ ឲ្យសម្រេចយ៉ាងលឿនរហ័ស ដោយការដាក់អ្នកសូម ឬដោយការសម្លាប់សត្វជាដើម ។

លំដាប់នៃកម្មវដ្ដ: ដែលពោលទុកក្នុងព្រះបាលីថា៖

**អវិជ្ជា, សង្ខារ តណ្ហា ឧបាទាន និង កម្មភព** ត្រឹមតែជារៀងលំដាប់នៃទេសនា តែចំណែកការកើតឡើងពិត មានតាមលំដាប់ដូច្នេះ គឺ ៖

ព្រោះមានអវិជ្ជា ដែលមិនដឹងសភាវៈពិត ទើបមានតណ្ហា ដែលអន្ទះអន្ទែងចង់បាន ។

ព្រោះមានតណ្ហា ទើបមានឧបាទាន ដែលប្រកាន់មាំថាកាលធ្វើកម្មនេះ ហើយនឹងតាំងនៅមានសេចក្ដីសុខ ។

ព្រោះមានឧបាទាន ទើបមានសង្ខារ ដែលត្រិះរិះស្វែងរក ។

ព្រោះមានសង្ខារ ទើបមានកម្មភពក្នុងខណៈធ្វើកម្ម ។

ព្រោះមានកម្មភព ទើបមានអវិជ្ជា ដែលយល់ខុសថាកម្ម និងផលកម្ម ជាវត្ថុដែលល្អស្អាត មានតណ្ហា ដែលបំពេញកម្ម និងផលកម្ម មានឧបាទាន ដែលប្រកាន់មាំថា នឹងតាំងនៅមាន សេចក្ដីសុខដោយកម្មនោះ ។

នឹងឃើញបានថា កម្មដែលរុំត្រួវរុំព័ទ្ធដោយអវិជ្ជា និង តណ្ហា

ក្នុងពេលមុន និងពេលខាងក្រោយដែលធ្វើកម្ម រមែងញុំាងឲ្យកើតភពថ្មីបាន ដូចគម្ពីរបដិសម្ភិទាមគ្គពោលថា៖

**កុសលកម្មស្ស ជវនក្ខណេ តយោ ហេតូ កុសលា... និកន្តិក្ខណេ ទ្វេ ហេតូ អកុសលា.... បដិសន្ធិក្ខណេ តយោ ហេតូ អព្យាកតា...គតិសម្បត្តិយា ញាណសម្បយុត្តេ ឥមេសំ អដ្ឋានំ ហេតូនំ បច្ចយា ឧបបត្តិ ហោតិ ។**

"ការបដិសន្ធិ មានទៅបានព្រោះ អាស្រ័យហេតុ ៨ យ៉ាងនេះ ក្នុងខណៈដែលចិត្តប្រកបដោយបញ្ញា កើតឡើងក្នុងសុគតិភូមិ បានដល់៖

ហេតុ ៣ យ៉ាង គឺ អលោភហេតុ អទោសហេតុ និង អមោហហេតុ ដែលប្រាកដក្នុងខណៈធ្វើកម្ម ។ល។ ហេតុ ៣ យ៉ាង ផ្នែកអព្យាក្រឹត គឺ អលោភហេតុ អទោសហេតុ និង អមោហហេតុ ប្រាកដក្នុងខណៈបដិសន្ធិ"។

**➪ វិបាកវដ្តដែលជាផលក្នុងបច្ចុប្បន្ន ៥**

ក្នុងគម្ពីរបដិសម្ភិទាមគ្គពោលថា :

[១] ឥធ បដិសន្ធិ វិញ្ញាណំ, ឱក្កន្តិ នាមរូបំ, បសាទោ អាយតនំ, ផុដ្ឋោ ផស្សោ, វេទយិតំ វេទនា ។

[២] ឥមេ បញ្ច ធម្មា ឥធូបបត្តិ ភវស្មឹ បុរេកតស្ស កម្មស្ស បច្ចយា ។

" ១. ចិត្តដែលតបំពោះភពទុក ( បដិសន្ធិចិត្ត ) ក្នុងភពនេះ ជាវិញ្ញាណ, ការធ្លាក់ចុះ ជានាមរូប, សភាពថ្លា នៃបសាទរូប គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត និង កាយជាអាយតនៈ ( ដែលជួបគ្នាវាងអារម្មណ៍ជាមួយចិត្ត ) ការប៉ះខ្ទប់រវាងអារម្មណ៍ជាមួយចិត្តជាផស្សៈ, ការសោយអារម្មណ៍ ជាវេទនា ។

២. ធម៌ទាំង ៥ យ៉ាងនេះ ជាផលក្នុងទីនេះ ព្រោះអាស្រ័យកម្មដែលធ្វើទុកភពមុន " ។

អ្នកដែលកំណត់ដឹងរូបនាមយ៉ាងបន្តបន្ទាប់ក្នុងបច្ចុប្បន្នខណៈ រមែងរឭកដឹងថា ចិត្តដែលជាសភាវៈឃើញ និងបានឮជាដើម ប្រាកដបន្តបន្ទាប់ ជាមួយចិត្តដូចមុនៗ គេរមែងអនុមានដឹង បដិសន្ធិចិត្ត ដែលកើតជាគ្រាដំបូងរបស់ភពនេះថា កើតអំពី

ចុតិចិត្តក្នុងភពមុន ដូចសេចក្តីក្នុងគម្ពីរវិសុទ្ធិមគ្គពោលថា ៖

**យថេវ ចក្ខុវិញ្ញាណំ មនោធាតុអនន្តរំ ន ចេវ អាគតំ នាបិ ន និព្វត្តំ អនន្តរំ ។ យថេវ បដិសន្ធិម្ហិ វត្តតេ ចិត្តសន្តតិ បុរិមំ ភិជ្ជតេ ចិត្ត បច្ឆិមំ ជាយតោ តតោ ។**

" ចក្ខុវិញ្ញាណ ( ចិត្តដែលឃើញរូប ) ដែលកើតអំពីមនោ-ធាតុ ( ចិត្តដែលពិចារណា ) មិនបានមកអំពីមនោធាតុ តែកើតអំពីមនោធាតុដោយពិត យ៉ាងណា ការជាប់បន្តគ្នារបស់ចិត្តក្នុងខណៈបដិបត្តិធម៌ ក៏ដូច្នោះ គឺចុតិចិត្ត ក្នុងភពមុនរមែងរលត់ទៅក្នុងបដិសន្ធិចិត្តក្នុងភពក្រោយ ទើបកើតឡើងតអំពីនោះ " ។

សេចក្តីខាងដើមមានន័យថា អ្នកបដិបត្តិធម៌រមែងយល់ច្បាស់ចិត្តនូវការជាប់បន្តគ្នានៃចិត្តដោយប្រចក្ស កាលរូបារម្មណ៍មកប្រាកដផ្លូវចក្ខុបសាទ ចិត្តធ្វើនាទីពិចារណាថ្មី ( បញ្ចទ្វារាវជ្ជនចិត្ត ) រមែងកើតឡើង ដោយពិចារណាថា រូបនេះគឺអ្វី? តពីនោះទើបកើតចិត្តឃើញរូប ។ ពិតហើយ ចិត្តដែលឃើញរូបមានមិន

បាន មកពីចិត្តដែលពិចារណា តែកើតពីចិត្ត ដែលពិចារណា ។

ក្រៅអំពីនោះ អ្នកដែលកំណត់ដឹងរូបនាមយ៉ាងបន្តបន្ទាប់ រមែងដឹងច្បាស់ថារូបនាម ដែលកំណត់ដឹងដូចប្រាកដឡើងមក ថ្មីៗ ផ្លូវកាយនិងចិត្ត ទើបអនុមានដឹងរូបនាម ក្នុងខណៈបដិសន្ធិថា មានសភាវៈប្រាកដ ដូចជារូបនាម ដែលកំណត់ដឹងក្នុងបច្ចុប្បន្ន សូម្បីការយល់ចូលចិត្តក្នុងអាយតនៈ ផស្សៈ និងវេទនា ក៏ដូចគ្នាគ្រប់ៗ ប្រការ ។

កាលអាយតនៈចាស់ក្លាហើយ ហេតុ ៥ យ៉ាង គឺអវិជ្ជា តណ្ហា ឧបាទាន សង្ខារ និងកម្មភព រមែងកើតឡើងវិលវល់ តទៅដោយអាស្រ័យផល ៥ យ៉ាងក្នុងបច្ចុប្បន្ន ដូចសេចក្ដីថា :

[១] ឥធ បរិបក្កត្តា អាយតនំ មោហោ អវិជ្ជា, អាយូហនា សង្ខារា, និកន្តិ តណ្ហា, ឧបគមនំ ឧបាទានំ, ចេតនា ភវោ ។

[២]មេ បញ្ច ធម្មា ឥធ កម្មភវស្មឹ អាយតឹ បដិសន្ធិយា បច្ចយា ។

“១.កាលអាយតនៈក្នុងភពនេះ ចាស់ក្លាហើយ ការមិនដឹង ជាអវិជ្ជា, ការស្វែងរក ជាសង្ខារ, សេចក្ដីប្រាថ្នា ជាតណ្ហា, សេចក្ដីប្រកាន់មាំ ជាឧបាទាន, ចេតនា ជាកម្មភព ។

២.ធម៌ទាំង ៥ យ៉ាងនេះ ជាបច្ច័យដល់បដិសន្ធិតទៅ កាលធ្វើកម្មទុកក្នុងភពនេះ ” ។

ផល ៥ យ៉ាងក្នុងអនាគត គឺវិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនា រមែងកើតព្រោះហេតុ ៥ យ៉ាង ក្នុងបច្ចុប្បន្ន”។

៦វិបាកវដ្ដៈដែលជាផលក្នុងអនាគត ៥

[១] អាយតឹ បដិសន្ធិ វិញ្ញាណំ, ឧក្កនតិ នាមរូបំ, បសាទោ អាយតនំ, ផុដ្ឋោ ផស្សោ, វេទយិតំ វេទនា ។

[២] ឥមេ បញ្ច ធម្មា អាយតឹ ឧបបត្តិភវស្មឹ ឥធ កតស្ស កម្មស្ស បច្ចយា ។

“១.ចិត្តដែលតចំពោះភពទុក ក្នុងភពតទៅ ជាវិញ្ញាណ, ការធ្លាក់ចុះជានាមរូប, សភាពថ្លា ជអាយតនៈ, ការប៉ះខ្ទប់ ជា ផស្សៈ,

ការសោយ ជាវេទនា ។

២.ធម៌ទាំង ៥ យ៉ាងនេះ ជាផលក្នុងភពតទៅ ព្រោះអាស្រ័យ
កម្មដែលធ្វើទុកកភពនេះ ” ។

ក្នុងហេតុនិងផលដែលពោលមកនេះ ហេតុក្នុងអតីត ៥ ដូចគ្នាជាមួយហេតុក្នុងបច្ចុប្បន្ន ផលក្នុងអនាគត ៥ ក៏ដូចគ្នាជាមួយផលក្នុងបច្ចុប្បន្ន ដូច្នោះ អ្នកដែលអាចយល់ចូលចិត្តហេតុនិងផលក្នុងបច្ចុប្បន្នដោយប្រចក្ស រមែងអនុមានដឹងហេតុ និងផលក្នុងអនាគតបាន ។ ជាការពិតហើយ ផលទាំង ៥ ជាសភាពដែលប្រាកដក្នុងចិត្តមួយដួងៗ ដែលបុគ្គលកំណត់ដឹង អ្នកដែលយល់ចូលចិត្តផលដោយន័យសង្ខេប រមែងដឹងច្បាស់ផលទាំង ៥ ដោយសភាពជាផលដូចគ្នា ពោលគឺ ការរឭកដឹងទាន់សភាវធម៌ដែលប្រាកដដោយលក្ខណៈល្អ ឬមិនល្អក៏ដោយ គប្បីកំណត់ដឹងត្រឹមតែសភាវៈ ឃើញ បានឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វ និង នឹកគិត ហើយអាចដឹងច្បាស់ថា សភាវៈពួកនោះជាផលដែលកើត អំពីកម្មចាស់ មិនចាំបាច់ត្រូវវែចញែកថា សភាវៈ

នោះ ជាវិញ្ញាណ ឬនាមរូប ជាដើម ។

ដោយន័យតែមួយដូចគ្នានេះ អ្នកបដិបត្តិធម៌ដែលយល់ហេតុនិងផលក្នុងខណៈកំណត់ដឹងសភាវធម៌បច្ចុប្បន្ន រមែងឃើញច្បាស់ថា ផលកម្មនិងកម្ម ដែលជាហេតុបានកើតមក ហើយក្នុងភពមុន និងរមែងកើតឡើងក្នុងភពតទៅ មានត្រឹមតែកម្មនិងផលកម្ម កំពុងតែប្រាកដពិត ដោយប្រាសចាកបុគ្គល អ្នកធ្វើកម្មនិងអ្នកសោយផលកម្ម គេរមែងឆ្លងផុតសេចក្តី សង្ស័យ ១៦ ប្រការបាន ដូចសេចក្តីថា :

[១] សោ ឯវំ កម្មវដ្តវិបាកវដ្តវសេន បច្ចយតោ នាមរូបស្ស បវត្តឹ ទិស្វា“ យថា ឥទំ ឯតរហិ, ឯវំ អតីតេបិ អទ្ធានេ កម្មវដ្តវិបាកវដ្តវសេន បច្ចយតោ បវត្តិត្ថ ។ អនាគតេបិ កម្មវដ្តវិបាកវដ្តវសេនេវ បច្ចយតោ បវត្តិស្សតី”តិ ។

[២] ឥតិ កម្មញ្ចេវ កម្មវិបាកោ ច, កម្មវដ្តញ្ច វិបាកវដ្តញ្ច, កម្មបវត្តញ្ច វិបាកបវត្តញ្ច, កម្មសន្តតិ ច វិបាកសន្តតិ ច, កិរិយា ច កិរិយាផលញ្ច ។

កម្មា វិបាកា វត្តន្តិ វិបាកោ កម្មសម្ភវោ កម្មា បុនព្ភវោ ហោន្តិ ឯវំ លោកោ បវត្តតីតិ សមនុបស្សតិ ។

" ១. អ្នកបដិបត្តិធម៌នោះ ឃើញការប្រព្រឹត្តទៅរបស់រូបនាម តាមហេតុបច្ច័យ បន្តបន្ទាប់ដោយកម្មវដ្ដៈ និងវិបាកវដ្ដៈយ៉ាងនេះ រមែងដឹងច្បាស់ថា រូបនាមប្រព្រឹត្តទៅហើយក្នុងអតីតកាល តាមហេតុបច្ច័យជាបន្តបន្ទាប់ ដោយកម្មវដ្ដៈ និង វិបាកវដ្ដៈ យ៉ាងណា រូបនាមរមែងប្រព្រឹត្តក្នុងអនាគតកាល តាមហេតុបច្ច័យ ជាបន្តបន្ទាប់ ដោយកម្មវដ្ដៈ និងវិបាកវដ្ដៈ ដូច្នោះ ។

២. គេរមែងឃើញច្បាស់ថា មានត្រឹមតែកម្មនិងផលកម្ម វិលជុំវិញកម្មនិងវិបាក ក្រសែកម្ម និងក្រសែវិបាក ការជាប់តគ្នានៃកម្ម និងការជាប់តគ្នានៃវិបាក ការធ្វើ និងផលនៃការធ្វើ ផលរមែងប្រព្រឹត្តទៅ ព្រោះកម្ម និងផលក៏ញុំាងឲ្យកើតកម្ម, ម្យ៉ាងទៀតទាំងភពថ្មី រមែងមានទៅបាន ព្រោះកម្ម សត្វលោក វិលវល់ដោយកម្ម និងផលរបស់កម្មយ៉ាងនេះ" ។

កម្មស្ស ការកោ នត្ថិ     វិបាកស្ស ច វេទកោ

សុទ្ធធម្មា បវត្តន្តិ ឯវេតំ សម្មទស្សនំ ។
ឯវំ កម្មេ វិបាកេ ច វត្តមានេ សហេតុកេ
ពីជរុក្ខាទិកានំវ បុព្វា កោដិ ន នាយតិ
អនាគតេបិ សំសារេ អប្បវត្តំ ន ទិស្សតិ ។

“អ្នកធ្វើកម្មល្អ ឬអាក្រក់រមែងមិនមាន អ្នកសោយផលល្អ ឬអាក្រក់ក៏មិនមាន សភាវធម៌សុទ្ធៗ រមែងប្រព្រឹត្តទៅ ការឃើញយ៉ាងនេះ ជាការឃើញដ៏ប្រពៃ ។

កាលបុគ្គលអ្នកឃើញច្បាស់នូវកម្ម និងផលដែលប្រព្រឹត្តទៅរួមជាមួយហេតុយ៉ាងនេះ ខាងដើមរមែងមិនប្រាកដ ដូចខាងដើមនៃគ្រាប់ពូជនិងដើមឈើ ការដាច់ក្រសែកម្មនិងវិបាក សូម្បីក្នុងសង្សារវដ្ត ដែលជាអនាគត រមែងមិនប្រាកដ ” ។

សេចក្តីដែលលើកឡើងមកដូច្នេះ ក្នុងខណៈឲ្យទាន ចេតនា គឺសេចក្តីតាំងចិត្តក្នុងការឲ្យកើតឡើងរួមជាមួយចិត្ត ឬក្នុងខណៈចេតនា គឺការតាំងចិត្ត ក្នុងការសម្លាប់ក៏កើតឡើងរួមជាមួយ

និងចិត្ត សូម្បីរូបគឺអាកប្បកិរិយា តាមផ្លូវកាយ និងផ្លូវវាចា ដែលធ្វើតាមចេតនានោះ រមែងកើតឡើង ដោយហេតុនេះ ចេតនាព្រមដោយអាកប្បកិរិយាតាមផ្លូវកាយនិងផ្លូវវាចា ទើបបានឈ្មោះថា កម្ម ( ការធ្វើល្អ ឬ អាក្រក់ ) សូម្បីរូបនាមទាំង ២ នឹងបានឈ្មោះថាជា កម្ម តែព្រះពុទ្ធតម្រាស់បញ្ជាក់ដល់ចេតនាដែលជាផលថា កម្ម ព្រោះជាគោលសំខាន់ដែលធ្វើឲ្យកើតនូវអាកប្បកិរិយា ដូចដែលពោលមកនេះ ។ សមដូចព្រះពុទ្ធវចនៈ ពោលថា ៖

**[១] ចេតនាហំ ភិក្ខវេ កម្មំ វទាមិ ។**

**[២] ចេតេត្វា កម្មំ ករោតិ កាយេនវាចាយ មនសា ។**

"១.ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ចេតនាជាតួកម្ម ។ ២.បុគ្គលតាំងចិត្តហើយ ទើបធ្វើកម្មតាមផ្លូវកាយវាចា និងចិត្ត"។ ការប្រើពាក្យក្នុងលក្ខណៈនេះ ជាសំនួនវោហារ ដែលហៅថា **បធានន័យ** គឺន័យដែលពោលដល់វត្ថុជាប្រធាន តែនៅមានបំណងដល់វត្ថុដែលជាប្រធានទៀតផងដែរ ។ ដូច្នោះ កម្មទើប

រួមន័យដល់ចេតនា ព្រមដោយអាកប្បកិរិយាផ្លូវកាយ និងវាចា ដែលជារូបនាមទាំង ២ យ៉ាងនោះ ទីងឃើញបានថា ក្នុងខណៈធ្វើកម្មរូបនាមដូចពោលមកនេះ រមែងប្រាកដ មនុស្សទូទៅ នឹងហៅរូបនាមថា បុគ្គលឲ្យទាន បុគ្គលសម្លាប់សត្វ ពាក្យនោះត្រឹមតែជាសម្មតិបញ្ញត្តិ ដើម្បីការប្រាស្រ័យទាក់ទងគ្នាប៉ុណ្ណោះ មិនមានបុគ្គល យើង គេ អ្នកឲ្យទាន ឬសម្លាប់សត្វយ៉ាងណាមួយឡើយ ត្រឹមតែជាបរមត្ថធម៌សុទ្ធៗ ប៉ុណ្ណោះ ។

ក្រៅពីនោះ ក្នុងខណៈឃើញ បានឮ ។ល។ ផលកម្ម គឺការដឹង ឬសោយអារម្មណ៍ដែលល្អ ឬមិនល្អ រមែងកើតឡើងគ្រប់មនុស្ស រមែងហៅរូបនាមនោះថាជាបុគ្គលសោយផល ពាក្យនេះត្រឹមតែជាសម្មតិបញ្ញត្តិ ដើម្បីប្រាស្រ័យទាក់ទងគ្នា មិនមានបុគ្គល យើង គេ ជាអ្នកសោយផលយ៉ាងណានីមួយឡើយ ។

ដោយហេតុដូចដែលបានពោលមកនេះ កម្មល្អ និងកម្មអាក្រក់ ទើបមិនមានក្នុងខណៈធ្វើកម្ម ក្នុងជាតិមុន ចំណែកឯបដិសន្ធិចិត្ត ភវង្គចិត្ត ដែលឃើញ ដែលបានឮ ។ល។ ក្នុង

ជាតិនេះ ជាផលដែលកើតអំពីកម្មនោះ កម្មល្អ និងកម្មអាក្រក់ ដែលបុគ្គលធ្វើដើម្បីឲ្យខ្លួនបានសុខ សេចក្តីខាងមុខទៀតរមែង ប្រាកដជាមួយផលដូចពោលមកនេះ ម្យ៉ាងទៀតទាំងផលកម្ម ក្នុងជាតិនេះតទៅ ក៏នឹងមានឡើង ព្រោះកម្មថ្មីដែលធ្វើទុកក្នុង ជាតិនេះ តាមន័យនេះ កម្ម និងផលកម្ម រមែងវិលតជាប់ទៅ ជាមួយគ្នា ។ ការយល់ហេតុបច្ច័យរបស់រូបនាម ដោយប្រាស ចាក អ្នកធ្វើកម្ម ( ការរកអត្តាតួខ្លួន ) ឬ អ្នកសោយផលកម្ម ( **វេទកអត្ត** ) ឈ្មោះថាជា **បច្ចយបរិគ្គហញាណ** ដែលមាន ឈ្មោះហៅម្យ៉ាងទៀតថា **សម្មាទស្ស** គឺការឃើញដ៏ប្រពៃ ។

អ្នកដែលយល់ហេតុបច្ច័យរបស់រូបនាម រមែងដឹងច្បាស់ ថា កម្មក្នុងភពមុនរមែងមានពិតប្រាកដ ព្រោះមានផលក្នុងជាតិនេះ ផលដែលជាប់ដោយកម្មចាស់ ដែលធ្លាប់មានមកហើយ សូម្បី កម្មចាស់របស់ផលនោះ ក៏ត្រូវមានក្នុងជាតិមុនៗ ។

សង្សារវដ្ត គឺក្រសែរូបនាម ទើបមិនប្រាកដខាងដើម ប្រៀប ដូចជាការមាននៃគ្រាប់ពូជ ទើបមានដើមឈើ ដែលកើតចេញ

អំពីគ្រាប់ពូជ និងមានពូជដែលកើតចេញពីដើមឈើនោះមក ឬ កាលមានពង ទើបមានមាន់ ដែលកើតចេញពីពងមាន់នោះ និងកាលមានពងមាន់ ដែលកើតចេញពីមេមាន់នោះមក ។

សម្រាប់សេចក្ដីដែលពោលថា រូបនាមអំពីនិម្មិតរបស់ព្រះជាម្ចាស់ រមែងកើតសេចក្ដីសង្ស័យថា នរណានិម្មិតព្រះជាម្ចាស់? និម្មិតនៅពេលណា? និងនិម្មិតព្រោះហេតុអ្វី? កាលតាមគិតរកហេតុផលដែលមានមកតាមលំដាប់តទៅ ក៏នឹងមិនមានពាក្យឆ្លើយវិញឡើយ ដែលមានហេតុផលត្រឹមត្រូវនោះ អាចកាន់យកបានមិនមានឡើយ ។ ព្រោះបើសម្គាល់ថា រូបនាមក្នុងក្នុងអតីតកើតឡើងឯងៗ ដោយប្រាសចាកហេតុបច្ច័យ ហើយរូបនាមក្នុងបច្ចុប្បន្ន ក៏កើតឡើងខ្លួនឯង ដូចគ្នា ដោយមិនចាំបាច់មានហេតុបច្ច័យ តែអ្នកដែលអាចយល់ហេតុបច្ច័យរបស់រូបនាមជាបញ្ញាដែលដឹងច្បាស់ដោយប្រចក្ស (បច្ចក្ខញាណ) ឬ ដោយបញ្ញា ដែលអាចអនុមានដឹង ( **អនុមានញាណ** ) រមែងមិនឃើញរូបនាមដែលកើតឡើងឯង ដូច្នោះ ការវែកញែករូបនាម

ដែលកើតឡើង ឯងដោយប្រាសចាកហេតុបច្ច័យ ទើបបានជា

នៅខ្វះហេតុផល ដែលគួរកាន់យកបាន ។

ម្យ៉ាងទៀត ការប្រៀបធៀប ដែលពោលមកនេះ ត្រឹមតែជាសំនួន

វោហារ ដើម្បីសម្ដែងសេចក្ដីប្រហាក់ប្រហែលគ្នា ចំណែកខ្វះ មិន

បានមានបំណងសម្ដែងសេចក្ដីដូចគ្នាទាំងអស់ទេ ដូចពាក្យថា

"ព្រះភក្ត្ររបស់ព្រះសម្មាសម្ពុទ្ធដូចជាផ្កា បទុម" ។

ក្នុងសេចក្ដីដូចគ្នានេះ សង្សារវដ្ដរមែងមានសេចក្ដីផ្សេងគ្នាវាង

ដើមឈើ និងគ្រាប់ពូជ ឬមេមាន់ និងពងមាន់ ពោល គឺដើម

ឈើ និងគ្រាប់ពូជ ឬមេមាន់និងពងមាន់ ជាវត្ថុ ដែលដឹងបាន

ច្បាស់ដល់សភាពតាំងនៅជាគ្រាដំបូង ។ តែចំណែកឯក្រសែ

របស់រូបនាមដែលកម្មនិងផលនេះ មិនបានមានប្រាកដខាងដើម

ដូចជារបស់ទាំងអស់នោះទេ ប៉ុន្ដែចំពោះក្រសែរូបនាមដែល

ជាកម្ម និងផលកម្មប្រព្រឹត្តទៅមិនមានទីបំផុត ដូចដើមឈើ និង

គ្រាប់ពូជ ឬមេមាន់ និងពងមាន់នោះទេ ។

បើលះបង់កម្មដោយមគ្គញាណមិនបានទេ ផលក៏នឹងមិនអស់ទៅ

បានឡើយ កាលចុតិចិត្តក្នុង ១ ជាតិៗ រលត់ទៅហើយ ផលគឺ បដិសន្ធិចិត្ត ក៏រមែងកើតភ្លាមក្នុងជាតិតទៅ ។

ដូចសេចក្តីក្នុងគម្ពីរវិសុទ្ធមគ្គពោលថា ៖

**កម្មំ នត្ថិ វិបាកម្ហិ បាកោ កម្មេន វិជ្ជតិ អញ្ញមញ្ញំ ឧភោ សុញ្ញា ន ច កម្មំ វិនា ផលំ ។**

"កម្មមិនមានក្នុងផល ផលមិនមានក្នុងកម្មទាំង ២ យ៉ាង សូន្យចាកគ្នានិងគ្នា តែផលរមែងមិនមានដោយការប្រាសចាកកម្មទេ" ។

កម្មនិងផលកម្មវិលជុំវិញគ្នា ដោយភាពជាហេតុនិងផល គឺកម្មជាហេតុដែលញ៉ាំងឲ្យកើតផល, ផលកើតអំពីកម្ម តែទាំង ២ យ៉ាងនេះមកកើតឡើងព្រមគ្នា ដូចជាការផឹក បរិភោគអាហារ ធ្វើឲ្យកើតការឆ្អែតនិងសុខតទៅ ដូច្នេះ កម្មទើបមិនមាននៅក្នុងផល, និងផលក៏មិនមាននៅក្នុងកម្ម ។

**ផលេន សុញ្ញំ តំ កម្មំ ផលំ កម្មេ ន វិជ្ជតិ កម្មញ្ច ខោ ឧបាទាយ តតោ និព្វត្តតេ ផលំ ។**

“ កម្មនោះសូន្យអំពីផល, ផលក៏មិនបានតាំងនៅកម្ម, តែផលរមែងកើតអំពីកម្មនោះ ដោយអាស្រ័យកម្មពិតប្រាកដ ” ។

**ន ហេត្ថ ទេវោ ព្រហ្មា វា សំសារស្សត្ថិ ការកោ សុទ្ធម្មា បវត្តន្តិ ហេតុ សម្ភារបច្ចយា ។**

“ដោយពិតហើយ ក្នុងលោកនេះ មិនមានទេវតា ឬ ព្រះព្រហ្មជាអ្នកសាងសង្សារវដ្តទេ, សភាវធម៌សុទ្ធៗ រមែងប្រព្រឹត្តទៅព្រោះហេតុបច្ច័យប៉ុណ្ណោះ ” ។

សេចក្តីថា“ កម្មមិនមាននៅផល ” អធិប្បាយថា អំពោះជាហេតុឲ្យកើតមាននូវសំពត់ តាំងនៅក្នុងសំពត់ ដែលជាផល តែកម្មមិនមែនមាននៅក្នុងផល ដូចជាសំពត់ ។

សេចក្តីថា ផលក៏មិនមាននៅក្នុងកម្ម មានអធិប្បាយថា គ្រាប់ស្រូវតាំងនៅក្នុងដើមស្រូវ ដែលជាហេតុ, តែផលមិនមែនតាំងនៅក្នុងកម្មដូចជាគ្រាប់ស្រូវនោះទេ ព្រោះជាសភាព ដែលកើតឡើងថ្មីប៉ុណ្ណោះ”។

អ្នកបដិបត្តិធម៌ ដែលយល់ហេតុកើតឡើងនៃរូបនាម តាមកម្ម

និងផលកម្ម ហើយរមែងដឹងច្បាស់នូវការកើតឡើង របស់ចុតិចិត្ត ក្នុងភពមុន និងបដិសន្ធិចិត្តក្នុងភពនេះ បានទៀតផង ពោលគឺ កាលមានពណ៌ប្រាកដតាមផ្លូវចក្ខុទ្វារ ការធ្វើទុកក្នុងចិត្ត ដែលពិចារណាពណ៌ថា គឺអ្វីរមែងកើតឡើង តអំពីនោះ សភាវៈឃើញទើបមានទៅបាននៃការធ្វើក្នុងចិត្ត ទើបជាប់គ្នាជាមួយសភាវៈឃើញយ៉ាងណា ចុតិចិត្តក៏ជាប់តគ្នាជាមួយបដិសន្ធិចិត្ត កាលចុតិចិត្តក្នុងភពមុនរលត់ទៅហើយ បដិសន្ធិចិត្តទើបមានទៅបានក្នុងភពថ្មី ដោយកម្មចាស់ ដូច្នោះ ការដឹងដោយប្រចក្សដូចពោលនេះ រមែងប្រាកដដល់អ្នកសិក្សាគោលធម៌ហើយ ។

អ្នកដែលមិនបានសក្សាធម៌ អាចយល់ថា ការកំណត់ដឹងថា "ឃើញហ្ន៎" រមែងមានទៅបាន តអំពីសភាវៈឃើញ និងសភាវៈក៏មានទៅបានទៀត តអំពីការកំណត់ដឹងសេចក្ដីស្លាប់ ជាការរលត់ទៅរបស់ចិត្តមួយដួង, ការកើត ជាការកើតឡើងនៃចិត្តមួយដួងក្នុងភពថ្មី តអំពីចុតិចិត្ត អ្នកដែលយល់ចូលចិត្តយ៉ាងនេះរាប់ថា បានដឹងច្បាស់នូវសភាវធម៌ ដែលជាអតីត បច្ចុប្បន្ន និង

អនាគតទាំងអស់ព្រមដោយហេតុដែលជាដែនកើតទៀតផង ។

ដូចគម្ពីរវិសុទ្ធិមគ្គពោលថា ៖

**តស្សេវំ កម្មវដ្ដវិបាកវដ្ដវសេន នាមរូបស្ស បច្ចយបរិគ្គហំ កត្វា តីសុ អទ្ធាសុ បហីនវិចិកិច្ឆស្ស សព្វេ អតីតានាគតបច្ចុប្បន្នា ធម្មា ចុតិបដិសន្ធិ វសេន វិទិតា ហោន្តិ ។**

“ កាលអ្នកបដិបត្តិនោះ ធ្វើការកំណត់ដឹងនាមរូប ដោយចែកជាកម្មវដ្ដៈ និងវិបាកវដ្ដៈ យ៉ាងនេះហើយ លះបង់នូវសេចក្ដីសង្ស័យក្នុងកាលទាំង ៣ សភាវធម៌ដែលអតីត អនាគត និងបច្ចុប្បន្នទាំងអស់ រមែងជាការចូលដឹងបាន ដែលជាប់បន្តគ្នាដោយចុតិនិងបដិសន្ធិ ” ។

**៦៖ ចុតិបដិសន្ធិវសេន វិទិតសព្វធម្មស្ស សព្វាការេន នាមរូបស្ស បច្ចយបរិគ្គហញ្ញាណំ ឋាមគតំ ហោតិ ។**

“ ញាណដែលកំណត់ដឹងបច្ច័យរបស់រូបនាម ដោយប្រការទាំងពួង របស់អ្នកដែលដឹងច្បាស់សភាវធម៌ទាំងពួង ដែលជាប់ទាក់ទងដោយចុតិ និងបដិសន្ធិយ៉ាងនេះ រមែងជាសភាវៈ

មានកម្លាំង " ។

សេចក្តីថា "សភាវធម៌ដែលជាអតីត អនាគត និងបច្ចុប្បន្នទាំងអស់ រមែងជាការចូលដឹងបាន" មិនបានមានបំណងដល់ការដឹងច្បាស់ហេតុកើតរបស់នាមរូបគ្រប់យ៉ាង ប្រៀបដូចជា ការដឹងដោយសព្វញ្ញុតញ្ញាណ តែជាការអនុមានដឹងថា ធម៌គ្រប់យ៉ាង ក៏មានហេតុកើតដូចគ្នាជាមួយចុតិ និងបដិសន្ធិ លោកទើបពោលពន្យល់ថា ដោយជាប់ទាក់ទងជាមួយចុតិ និងបដិសន្ធិ ( **ចុតិ-បដិសន្ធិវិសេន** ) ។

អ្នកដែលចម្រើនសតិរឭកដឹងនាមរូបបច្ចុប្បន្ន ហើយយល់ចូលចិត្តហេតុកើតរបស់នាមរូបបាន តាមន័យ ៥ យ៉ាងៗ ណានីមួយ រមែងដឹងច្បាស់ថា មានត្រឹមតែនាមរូប ដែលជាផលកើតឡើងអំពីនាមរូប ដែលជាហេតុក្នុងកាលទាំង ៣ នឹងបាន ឈ្មោះថាជាអ្នកសម្រេចនូវ**បច្ចយបរិគ្គហញ្ញាណ** យ៉ាងខ្ពស់ញាណ ដូចពោលមកនេះ រមែងកន្លងផុតសេចក្តីសង្ស័យ ១៦ ប្រភេទដូចពោលមកហើយ និងសេចក្តីសង្ស័យ ៨ យ៉ាង ដែលសង្ស័យ

ក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សិក្ខា ៣ នាមរូបក្នុងអតីត នាមរូប ក្នុងអនាគត នាមរូបក្នុងបច្ចុប្បន្ន ព្រមដោយហេតុនិងផល ដែលកើតឡើងបន្តជាប់គ្នា ( បដិច្ចសមុប្បាទ ) ទើបបាន ឈ្មោះថា **កង្ខាវិតរណវិសុទ្ធិ** គឺការបរិសុទ្ធ ដោយការឆ្លងផុតសេចក្តីសង្ស័យ ។

ក្រោយអំពីនោះ អ្នកដែលយល់ចូលចិត្តនូវការរលត់ទៅរបស់ចុតិចិត្ត និងការកើតឡើងរបស់បដិសន្ធិចិត្ត ដែលជាប់តគ្នា រមែងដឹងច្បាស់ថា នាមរូបក្នុងភពថ្មី ដោយកម្មចាស់ ក្នុងខណៈខ្លះ អាចពិចារណាថា នាមរូបក្នុងភពមុន មានសភាវៈ មិនទៀងរលត់ទៅក្នុងភពមុនហើយ សូម្បីនាមរូបក្នុងភពនេះ ក៏មានសភាវៈ មិនទៀងទាត់រលត់ទៅក្នុងភពនេះ ដូចគ្នា ការពិចារណា ដូច្នេះជាខាងដើមរបស់សម្មសនញាណ ។

## " ព្រះចូឡសោតាបន្ន "

ក្នុងគម្ពីរវិសុទ្ធមគ្គពោលថា ៖

ឥមិនា បន ញាណេន សមន្នាគតោ វិបស្សកោ ពុទ្ធសាសនេ

លទ្ធស្សាសោ លទ្ធបតិដ្ឋោ និយតគតិកោ ចូឡសោតាបន្នោ នាម ហោតិ ។

"អ្នកចំរើនវិបស្សនាដែលដល់ព្រមដោយញាណនេះ រមែងបាន ទទួលសេចក្ដីធូរចិត្ត និងបានទទួលទីពឹងក្នុងពាក្យទូន្មានរបស់ព្រះសម្មាសម្ពុទ្ធ ឈ្មោះថា ព្រះចូឡសោតាបន្ន អ្នកនឹងទៅកើតក្នុងសុគតិភូមិយ៉ាងពិតប្រាកដ " ។

អ្នកចូលចិត្តយ៉ាងពិតប្រាកដក្នុងព្រះសាសនា គឺអរិយផលចំណែកទីពឹងយ៉ាងពិតប្រាកដ គឺអរិយមគ្គ សូម្បីអ្នកបដិបត្តិធម៌ក្នុងលំដាប់នេះ និងនៅមានដល់ការសម្រេចមគ្គផល ក៏ជាទីតាំងនៃបដិបទា ដែលធ្វើឲ្យសម្រេចមគ្គផលយ៉ាងពិតប្រាកដ ទើបពោលហើយថា ជាអ្នកបានទទួលធូរ នឹងបានទទួលទីពឹង ក្នុងពាក្យទូន្មានរបស់ព្រះសាស្ដា ។

ន័យម្យ៉ាងទៀត អ្នកដែលកំណត់ដឹងនាមរូប តាមសេចក្ដីពិត ដោយនាមរូបបរិច្ឆេទញាណ ហើយរមែងកើតបាមោជ្ជៈ ទើបពោលថា ជាអ្នកបានទទួលសេចក្ដីធូរចិត្ត ចំណែកអ្នក

ដែលកំណត់ដឹងហេតុកើតឡើងរបស់នាមរូប ដោយបច្ចយបរិគ្គ-ហញាណ រមែងលះបង់សេចក្តីយល់ខុសថា មានបុគ្គល តួខ្លួន មានអ្នកនិម្មិតពួកសត្វ ឬពួកសត្វកើតឡើងឯង ដោយមិនមានហេតុបច្ច័យ ជាដើម ។ គេរមែងជាអ្នក ដល់ព្រមដោយសទ្ធាដែលតាំងមាំមិនថយចុះ ព្រោះដោយទិដ្ឋិនោះ ទើបបានឈ្មោះថាជាបានទទួលទីពឹង ។ ដូចគម្ពីរមហាដីកា អធិប្បាយ ថា

[១] អប្បរិហានកង្ខាវិតរណវិសុទ្ធកោ វិបស្សកោ លោកិយាហិ សីលសមាធិបញ្ញាសម្បទាហិ សមន្នាគតត្តា ឧត្តរិ អប្បដិវិជ្ឈន្តោ សុគតិបរាយនោវ ហោតីតិ វុត្តំ “ និយត-គតិកោ”តិ ។

[២] តតោ ឯវ ចូឡសោតាបន្នោ នាម ហោតិ ។

“១. អ្នកចំរើនវិបស្សនាការនា ដែលមិនថយចុះទៅអំពីកង្ខាវិតរណវិសុទ្ធិ សូម្បីទឹងមិនបានបាក់ធ្លុះធម៌នោះ រហូតដល់ជាន់ខ្ពស់ ក៏មានសុគតិភូមិនៅខាងមុខ ព្រោះដល់ព្រមដោយសីល សមាធិ និងបញ្ញាដែលបរិបូណ៌ផ្នែកលោកិយ៍ ដូច្នោះ

លោកទើបពោលថា ជាអ្នកនឹងទៅកើតក្នុងសុគតិភូមិយ៉ាងពិតប្រាកដ ( **និយតគតិនោ** ) ។

២. ដូច្នោះ ទើបឈ្មោះថា ព្រះចូឡសោតាបន្ន ” ។

សេចក្ដីថា “មិនថយទៅអំពីកង្ខាវិតរណវិសុទ្ធិ” គឺអ្នកដែលប្រាសចាកទិដ្ឋិ ( ការយល់ខុសថាមានតួខ្លួន ) វិចិកិច្ឆា នឹងតាំងនៅក្នុងថ្នាក់កង្ខាវិតរណវិសុទ្ធិ ទើបពោលទុកបានថា ជាអ្នកនឹងកើតក្នុងសុគតិភូមិយ៉ាងពិតប្រាកដ តែវិសុទ្ធិនោះ ត្រឹមតែជាលោកិយៈ មិនមែនលោកុត្តរ ទើបអាចថយទៅក្នុងខណៈកើតការយល់ខុសគឺ ទិដ្ឋិ និងវិចិកិច្ឆា ព្រោះពិចារណាខុស ឬស្ដាប់ធម៌ខុស ធ្វើឲ្យវិសុទ្ធិថយចុះទៅក្នុងខណៈនោះ គេមិនមែនជាអ្នកដែលនឹងទៅកើត ក្នុងសុគតិភូមិបានយ៉ាង ពិតប្រាកដនោះទេ ។

ពាក្យថា “ដល់ព្រមដោយសីល សមាធិ និងបញ្ញា ដ៏បរិបូណ៌” មានន័យថា បុគ្គលនោះនឹងទៅកើតក្នុងសុគតិភូមិយ៉ាងពិតប្រាកដ ព្រោះមានសីល សមាធិ និងបញ្ញាដ៏បរិសុទ្ធ ប្រសិនបើគេឈប់

ចំរើនវិបស្សនា ក៏នឹងថយចុះអំពីសីល សមាធិ និងបញ្ញាហើយ នឹងមិនមែនជាអ្នកដែលទៅកើតក្នុងសុគតិភូមិឡើយ ។ ដូច្នេះ អ្នកដែលនឹងបរិបូណ៌ដោយនោះ គឺជាអ្នកដែលតាំងនៅក្នុងការ ចំរើនវិបស្សនាប៉ុណ្ណោះ ក្រោយអំពីមិនបានចំរើនវិបស្សនាហើយ ប្រសិនបើតាំងនៅជាអ្នកដែលប្រាសចាកទិដ្ឋិ និងវិចិកិច្ឆា ថែម ទាំងមានសីលបរិបូណ៌ ភពតទៅរបស់គេ ទើបនឹងទៀងយ៉ាង ពិតប្រាកដ ដោយហេតុនេះ អ្នកដែលបដិបត្តិធម៌ ទើបមិនគួរ ប្រមាទថា យើងជាព្រះចូឡសោបន្ន ហើយនឹងទៅក្នុងសុគតិភូមិ យ៉ាងពិតប្រាកដ ហើយឈប់លះបង់ចោលការបដិបត្តិធម៌តទៅ នឹងលះបង់ការរក្សាសីលឲ្យបរិសុទ្ធ ។

# "ភពរបស់ព្រះចូឡសោតាបន្ន"

ព្រះចូឡសោតាបន្ននឹងកើតក្នុងសុគតិភូមិ យ៉ាងពិតប្រាកដ ក្នុងភពទី ២ ( ភពបន្ទាប់ពីស្លាប់ ) តែមិនពិតប្រាកដក្នុងភព ទី ៣ ជាដើមទៅដូចសេចក្តីក្នុងគម្ពីរដីកាថា " មិនថយទៅអំពី

កង្ខាវិតរណវិសុទ្ធិ” និង “ព្រោះដល់ព្រមដោយសីល សមាធិ និងបញ្ញាដ៏បរិបូណ៌ផ្នែកខាងលោកិយ ដូច្នោះ លោកទើបពោលថា ជាអ្នកនឹងទៅកើតនៅក្នុងសុគតិភូមិយ៉ាងពិតប្រាកដ” ពិតមែន ហើយបុគ្គលអាចថយចុះ អំពីកង្ខាវិតរណវិសុទ្ធិ និង សីល សមាធិ បញ្ញា ក្នុងភពនេះបានភពទី ២ ទើបមិនពិតប្រាកដ ដែលធ្វើឲ្យភពទី ៣ ជាដើម ក៏មិនពិតប្រាកដដូចគ្នា ក្រៅអំពីនោះ ព្រះបរមពោធិសត្វនៃយើងបានឧបសម្បទាជាភិក្ខុត្រឹម ៩ ជាតិ ក្នុងសំណាក់របស់ព្រះពុទ្ធ ៩ ព្រះអង្គ ចាប់ផ្តើមតាំងអំពី ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមថា **កោណ្ឌញ្ញ** ដែលត្រាស់ដឹងក្នុង កាល ៣ អសង្ខេយ្យ កន្លងមក ( មើលវិបស្សនាភាគ ១ ទំព័រ ១៨៧ ) ហើយព្រះអង្គទ្រង់បានចំរើននូវវិបស្សនាដោយ **គតបច្ចាគតវត្ត** រហូតដល់បានសម្រេចនូវសង្ខារុបេក្ខាញាណ ដែលជាវិបស្សនាដ៏ខ្ពង់ខ្ពស់របស់បុថុជ្ជនវិបស្សនាញាណទី ១១ ។ ម្យ៉ាងទៀត ព្រះពុទ្ធទ្រង់បានទទួលការព្យាករណ៍ អំពីព្រះពុទ្ធ ព្រះនាម**សុមន** និងព្រះពុទ្ធព្រះនាម**វិបស្សី** កាលសោយព្រះ ជាតិជាស្តេចនាគ និងបានទទួលព្យាករណ៍អំពីព្រះពុទ្ធនាម **បទុម**

កាលសោយព្រះ ជាតិជាស្តេចរាជសីហ៍ សូម្បីព្រះជាតក ដែលពោលដល់ក្នុងកទ្ទកប្បនេះ ក៏ជួបរឿងដែលព្រះទ្រង់ទៅកើតជាសត្តតិរច្ឆានខ្លះ ដោយចំពោះតែក្នុងរឿងព្រះគេមិយជាតក ឃើញមានរឿង ដែលព្រះធ្លាប់ធ្លាក់នរក ហើយរឭកដល់ជាតិនោះបាន ។

**គតបច្ចាគតវត្ត** ( វត្តកម្មដ្ឋានដែលនាំទៅ និងនាំមក ) គឺវត្តកម្មដ្ឋានម្យ៉ាង ដែលត្រូវកំណត់ដឹងសតិរហូតទាំងពេលទៅបិណ្ឌបាត និងត្រឡប់មកអំពីបិណ្ឌបាត ឬកាលចំរើនសតិនៅក្នុងពេលដើរ បើខ្វះសតិកាលណា ក៏ត្រឡប់មកកន្លែងដើម ហើយចាប់ផ្តើមសារជាថ្មីម្តងទៀត ដោយសតិស្មារតី ។

ព្រះបាលី និងអដ្ឋកថាខាងដើមសម្តែងថា សូម្បីព្រះពោធិសត្វបានសម្រេចរហូតដល់សង្ខារុបេក្ខាញាណ ដែលខ្ពស់ជាងកង្ខាវិតរណវិសុទ្ធិ ក៏នៅមិនអាចរួចផុតអំពីអបាយភូមិបាន ដូច្នោះសម្រាប់មនុស្សទូទៅ ដែលមានសទ្ធា និងវិរិយមិនទាន់មាំទាំម្យ៉ាងទៀតៈទាំងសម្រេចត្រឹមតែកង្ខាវិតរណវិសុទ្ធិ ក៏មិនអាចទៀងទាត់ថា នឹងទៅកើតក្នុងសុគតិភូមិ យ៉ាងពិតប្រាកដនោះដែរ

អ្នកដែលត្រូវការនឹងចង់រួចអំពីអបាយភូមិពិតប្រាកដ គួរបំពេញសេចក្ដីព្យាយាមបដិបត្តិ ដើម្បីលះបង់នូវសក្កាយទិដ្ឋិ ( ការយល់ឃើញថា នាមរូបដែលមានពិតជាជាអត្តាត្លួខ្លួន ) ដោយសោតា-បត្តិមគ្គ កុំត្រេកអរក្នុងកន្លាវិតរណាវិសុទ្ធិឡើយ ។

សមដូចព្រះពុទ្ធោវាទក្នុងគម្ពីរសំយុត្តនិកាយថា ៖

**សត្តិយា វិយ ឱមដ្ឋោ ឌយ្ហមានោវ មត្ថកេ**
**សក្កាយទិដ្ឋិប្បហានាយ សតោ ភិក្ខុ បរិព្វជេ ។**

“អ្នកដែលឃើញភ័យក្នុងវដ្តៈ គប្បីចំរើនសតិដើម្បីលះបង់សក្កាយទិដ្ឋិ ដូចជាការត្រូវលំពែងចាក់ទម្លុះ ឬ ត្រូវភ្លើងឆេះលើក្បាលដូច្នោះ ” ។

## ញាណទី ៣

ន សន្តិ បុត្តា តាណាយ ន បិតា នបិ ពន្ធវា
អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា ។
ឯតមត្ថវសំ ញត្វា បណ្ឌិតោ សីលសំវុតោ
និព្វានគមនំ មគ្គំ ខិប្បមេវ វិសោធយេ ។

“កាលបុគ្គល ត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយ មិនមានដើម្បីជាទីពឹង បិតា ក៏មិនមាន ទាំងផៅពង្ស ក៏មិនមាន ដើម្បីជាទីពឹងឡើយ សេចក្តីទីពឹងក្នុងញាតិទាំងឡាយ ក៏មិនមាន បណ្ឌិតដឹងអំណាចប្រយោជន៍នេះហើយ គួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ប្រញាល់ជម្រះផ្លូវ ជាទីទៅកាន់ព្រះនិព្វានឲ្យបាន” ។

( ខុ.ធ. ៥២ / ៨១ )

# សម្មសនញ្ញាណ និង មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ

មគ្គាមគ្គញ្ញាណ គឺបញ្ញាពិចារណាការមិនទៀង ជាទុក្ខ និង មិនមែនតួខ្លួន ក្រោយអំពីបានប្រចក្សច្បាស់នូវត្រៃលក្ខណ៍នោះ ហើយ សេចក្តីថា អ្នកដែលដឹងច្បាស់នូវសភាពមិនទៀងជាដើម អំពីការឃើញរបស់ខ្លួនហើយ រមែងអនុមានដឹងលក្ខណៈ ដូច ពោលនៃរូបនាម ដែលខ្លួនមិនបានឃើញប្រចក្សច្បាស់បាន ដូច គម្ពីរបដិសម្ភិទាមគ្គពោលថា ៖

អតីតានាគតបច្ចុប្បន្នានំ ធម្មានំ សង្ខិបិត្វា

## ៧/ ត្ថានេ បញ្ញា សម្មសនេ ញាណំ ។

"បញ្ញាក្នុងការកំណត់ដឹងនូវសង្ខារធម៌ ដែលជាអតីត អនាគតនិង បច្ចុប្បន្ន ឈ្មោះថា សម្មសនញ្ញាណ (បញ្ញាក្នុងការពិចារណា)" ។ កាលអ្នកបដិបត្តិធម៌បានសម្រេចនូវបច្ចយបរិគ្គហញ្ញាណហើយ រមែងដឹងនូវការកើតឡើង និងការរលត់ទៅរបស់រូបនាម ក្នុង បច្ចុប្បន្នខណៈ ធ្វើឲ្យដឹងថា នាមរូបដែលឃើញនោះ បានកើត ឡើងត្រឹមតែមួយខណៈ ហើយក៏រលត់ទៅ ទើបយល់ច្បាស់ នូវត្រៃលក្ខណ៍ថា នាមរូបមិនទៀង ព្រោះកើតឡើងហើយនិង រលត់ទៅ មានសភាពជាទុក្ខ ព្រោះពាល់ត្រូវការរលត់បៀត បៀនជានិច្ច និងមិនមែនជាត្តខ្លួន ព្រោះមិនអាចបង្គាប់បញ្ជា ឲ្យទៀងទាត់ និងជាសុខបាន ។

អ្នកដែលយល់ចូលចិត្តយ៉ាងនេះ ត្រឹមតែមួយគ្រា ឬច្រើន គ្រា រមែងពិចារណាដោយអនុមានដឹងនាមរូបទាំងអស់ មាន សភាវៈយ៉ាងនេះ គឺមិនទៀង ជាទុក្ខ និងមិនមែនត្តខ្លួន ដោយ ការប្រៀបធៀបជាមួយនាមរូបបច្ចុប្បន្ន ដែលខ្លួនកំពុងតែដឹង ច្បាស់ដោយប្រចក្ស ដូច្នោះ សម្មសនញ្ញាណ ទើបជាបញ្ញា

ដែលពិចារណាសភាវធម៌ ជាអតីត អនាគត និងបច្ចុប្បន្នទាំងអស់ ដោយរួមថាជាត្រៃលក្ខណ៍ មិនមែនការកំណត់ដឹងត្រៃលក្ខណៈ វិសេសរបស់រូបនាមម្យ៉ាងៗក្នុងបច្ចុប្បន្ន មគ្គាមគ្គញាណ គឺបញ្ញាពិចារណាការមិនទៀង ជាទុក្ខ និងមិនមែនតួខ្លួន ក្រោយអំពីបានប្រចក្សច្បាស់នូវត្រៃលក្ខណ៍នោះហើយ សេចក្តីថា អ្នកដែលដឹងច្បាស់នូវសភាពមិនទៀង ជាដើម អំពីការឃើញរបស់ខ្លួន ហើយរមែងអនុមានដឹងលក្ខណៈ ដូចពោលនៃរូបនាម ដែលខ្លួនមិនបានឃើញប្រចក្សច្បាស់បាន ដូចគម្ពីរបដិសម្ភិទាមគ្គពោលថា ៖

**អតីតានាគតបច្ចុប្បន្នានំ ធម្មានំ សង្ខិបិត្វា**
**វវត្ថានេ បញ្ញា សម្មសនេ ញាណំ ។**

"បញ្ញាក្នុងការកំណត់ដឹងនូវសភាវធម៌ដែលជាអតីត អនាគត និង បច្ចុប្បន្ន ឈ្មោះថា សម្មសនញ្ញាណ ( បញ្ញាក្នុងការពិចារណា ) " ។

កាលអ្នកបដិបត្តិធម៌ បានសម្រេចនូវបច្ចយបរិគ្គហញ្ញាណហើយ រមែងដឹងនូវការកើតឡើង និងការរលត់ទៅរបស់រូបនាម ក្នុង

បច្ចុប្បន្នខណៈ ធ្វើឲ្យដឹងថា នាមរូបដែលឃើញនោះ បានកើតឡើងត្រឹមតែមួយខណៈ ហើយក៏រលត់ទៅ ទើបយល់ច្បាស់នូវត្រៃលក្ខណ៍ថា នាមរូបមិនទៀង ព្រោះកើតឡើងហើយនិងរលត់ទៅ មានសភាពជាទុក្ខ ព្រោះពាល់ត្រូវការរលត់បៀតបៀនជានិច្ច និងមិនមែនជាតួខ្លួន ព្រោះមិនអាចបង្គាប់បញ្ជាឲ្យទៀងទាត់ និងជាសុខបាន ។

អ្នកដែលយល់ចូលចិត្តយ៉ាងនេះ ត្រឹមតែមួយគ្រា ឬ ច្រើនគ្រា រមែងពិចារណាដោយអនុមានដឹងនាមរូបទាំងអស់ មានសភាវៈយ៉ាងនេះ គឺមិនទៀង ជាទុក្ខ និងមិនមែនតួខ្លួន ដោយការប្រៀបធៀបជាមួយនាមរូបបច្ចុប្បន្ន ដែលខ្លួនកំពុងតែដឹងច្បាស់ដោយប្រចក្ស ដូច្នោះ សម្មសនញ្ញាណ ទើបជាបញ្ញាដែលពិចារណាសភាវធម៌ដែលជាអតីត អនាគត និងបច្ចុប្បន្នទាំងអស់ដោយរួមថាជាត្រៃលក្ខណ៍ មិនមែនការកំណត់ដឹងត្រៃលក្ខណៈវិសេសរបស់រូបនាមម្យ៉ាងៗ ក្នុងបច្ចុប្បន្នខណៈ ញាណដូចពោលនិងមានឈ្មោះ ដទៃទៀតថា :

-កលាបសម្មសនញ្ញាណ ញាណពិចារណាដោយភាព

ជាសំណុំ មិនបានឃើញនាមរូបម្តងម្យ៉ាងៗ ដូចបច្ចក្ខញាណ គឺ ញាណដឹងដោយប្រចក្ស ។

**-នយវិបស្សនា** វិបស្សនាញាណដែលឃើញច្បាស់ដោយអាស្រ័យន័យពីនាមរូបដែលខ្លួនឃើញប្រចក្សហើយ ។

**-នយមនសិការ** ការធ្វើទុកក្នុងចិត្ត ដោយអាស្រ័យន័យអំពីនាមរូបដែលខ្លួនឃើញប្រចក្សហើយ ។

**-នយទស្សន** ការដឹងច្បាស់ដោយអាស្រ័យន័យ ដែលខ្លួនឃើញប្រចក្សហើយ ។

ឈ្មោះ ២ យ៉ាងដំបូង មានសម្តែងក្នុងគម្ពីរវិសុទ្ធិមគ្គ ឈ្មោះ ២ យ៉ាងខាងក្រោយ មានសម្តែងក្នុងគម្ពីរអដ្ឋកថារបស់កថាវត្ថុ ដូចសេចក្តីក្នុងគម្ពីរនោះថា :

**តត្ថ ឯកសង្ខារស្សាបិ អនិច្ចតាយ ទិដ្ឋាយ សព្វេសង្ខារា អនិច្ចាតិ អវសេសេសុ នយតោ មនសិការោ ហោតិ ។**

" ក្នុងរឿងនោះ កាលសេចក្តីមិនទៀងនៃសង្ខារ សូម្បីដឹងច្បាស់ហើយ ម្យ៉ាងទៀត ការធ្វើទុកក្នុងចិត្តដោយន័យ [ដែលអនុមានដឹង] រមែងមានទៅបានក្នុងសង្ខារ ដែលសល់ថា សង្ខារទាំងពួង

មិនទៀន" ។

[១] សព្វេ សង្ខារគតិអាទិវចនំ នយតោ ទស្សនំ សន្ធាយ វុត្តំ ។ [២] ន ឯកក្ខណេ អារម្មណតោ ។

"១. ពាក្យថា សព្វេ សង្ខារ ( សង្ខារទាំងពួង ) ជាដើម ពោលទុក ដោយមានបំណងដល់ការដឹងច្បាស់ដោយន័យ [ដែលអនុមានដឹង] ។

២. មិនបានមានបំណងដល់ការដឹងច្បាស់ ដោយភាពជាអារម្មណ៍ក្នុងខណៈចិត្ត តែមួយជាមួយគ្នា" ។

ចំណុចខាងដើម មានន័យថា សម្មសនញ្ញាណ មិនមែនជាវិបស្សនាញាណ ដែលប្រាកដជាលំដាប់ដំបូង តែជាញាណដែលកើតឯង ដោយការពិចារណាត្រៃលក្ខណ៍របស់រូបនាមទាំងពួង ក្រោយអំពីបានឃើញត្រៃលក្ខណ៍ នៃរូបនាមបច្ចុប្បន្នយ៉ាងជាក់ច្បាស់ ។

សម្មសនញ្ញាណនេះ អាចប្រាកដអស់ពេលយូរ ដល់អ្នកមានបញ្ញាចាស់ក្លា ឬ អ្នកបានសិក្សាគោលធម៌ មុនធ្វើឲ្យវិបស្សនា ញាណមិនចំរើនទៅមុខតទៅ ព្រោះបំណងពិចារណា

សភាវធម៌ជាគោល ដូច្នោះអ្នកបដិបត្តិធម៌ ទើបមិនគួរពិចារណា ឲ្យច្រើនពេកនោះទេ ។ ក្នុងគម្ពីរបដិសម្ភិទាមគ្គ បានពោលដល់ ញាណនេះទុកដោយពិស្តារ តាមបុគ្គលច្រើនប្រភេទ ដែល ពិចារណាផ្សេងៗ គ្នា ទីងនាំមកដោយសង្ខេប ជាឧទាហរណ៍ក្នុង ទីនេះថា ៖

[១] យំ កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា ។

[២] សព្វំ រូបំ អនិច្ចតោ វវត្ថេតិ ឯកំ សម្មសនំ, ទុក្ខតោ វវត្ថេតិ ឯកំ សម្មសនំ, អនត្តតោ វវត្ថេតិ ឯកំ សម្មសនំ ។

“១. រូបក្ខន្ធណាទីមួយដែលជាអតីត អនាគត បច្ចុប្បន្នទាំងខាង ក្នុង និងខាងក្រៅ ទាំងគ្រោតគ្រាត និងល្អិត ទាំងថោកទាបនិង ប្រណិត ទាំងនៅឆ្ងាយ ឬនៅជិត ។

២. អ្នកដែលបដិបត្តិធម៌ រមែងកំណត់ដឹងរូបក្ខន្ធទាំងអស់នោះថា មិនទៀង នេះជាសម្មសនញ្ញាណ ការកំណត់ដឹងរូបក្ខន្ធទាំងអស់ នោះថាជាទុក្ខ ជាសម្មសនញ្ញាណម្យ៉ាង, ការកំណត់ដឹងរូបក្ខន្ធទាំង

អស់នោះថា មិនមែនជាខ្លួន នេះជាសម្មសនញាណម្យ៉ាង” ។

រូបំ អតីតានាគតប្បច្ចុប្បន្នំ អនិច្ចំ ខយដ្ឋេន, ទុក្ខំ ភយដ្ឋេន អនត្តា អសារកដ្ឋេនាតិ សង្ខិបិត្វា វវត្ថានេ បញ្ញា សម្មសនេ ញាណំ ។

“បញ្ញាក្នុងការកំណត់ដឹងរូប ដែលជាអតីត អនាគត និង បច្ចុប្បន្ន ថាមិនទៀង ព្រោះសភាវៈបែកធ្លាយទៅ ជាទុក្ខ ព្រោះជាសភាវៈគួរខ្លាច និងមិនមែនខ្លួន ព្រោះជាសភាវៈគ្មានខ្លឹមសារ ឈ្មោះថា សម្មសនញាណ” ។

រូបំ អតីតានាគតប្បច្ចុប្បន្នំ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មន្តិ សង្ខិបិត្វា វវត្ថានេ បញ្ញា សម្មសនេ ញាណំ ។

“បញ្ញាក្នុងការកំណត់ដឹងរូប ដែលជាអតីត អនាគត និង បច្ចុប្បន្ន ថាមិនទៀង ត្រូវបច្ច័យតាក់តែងឲ្យកើតឡើង អាស្រ័យហេតុ មានសភាពអស់ទៅ, សូន្យទៅ, វិនាស់ទៅ, ឈ្មោះថា សម្មសនញាណ” ។

ក្រៅអំពីការពិចារណារូបហើយ នៅមានការពិចារណាជា

៣ លើកទៀត គឺការមិនទៀង ជាទុក្ខ និងមិនមែនជាតួខ្លួន ក្នុងនាមក្ខន្ធ ៤, ទ្វារ ៦, អារម្មណ៍ ៦, វិញ្ញាណ ៦, ផស្សៈ ៦, វេទនា ៦, ជាដើមទៀតផង ។ ក្នុងទីនេះ មិនបានសម្តែងទាំងអស់ទុក ព្រោះធ្វើឲ្យសេចក្តីច្រើនហួសពេក ក៏ប៉ុន្តែនឹងសម្តែងសេចក្តីប្រាកដរបស់ញាណតទៅវិញ ។

[ ក្រៅអំពីវេទនា ៦ ហើយ នៅមានតណ្ហា ៦, វិតក្កៈ ៦, វិចារៈ ៦, ធាតុ ៦, កសិណ ១០, កោដ្ឋាស ៣២, អាយតនៈ១២ ធាតុ ១៨, ឥន្ទ្រិយ ២២, ធាតុ ៣ ( កាមធាតុ រូបធាតុ និងអរូបធាតុ )ភព ៣ ( កាមភព, រូបភព, អរូបភព ) ភព ៣ ភព ៣ យ៉ាងទៀត ( សញ្ញាភព អសញ្ញាភព និង នេវសញ្ញា-នាសញ្ញាភព ] ភព ៣ យ៉ាងទៀត ( ឯកវោការភព ចតុវោកា-រភព និង បញ្ចវោការភព ) រូបជ្ឈាន ៤ អប្បមញ្ញា ៤ អរូប-សមាបត្តិ ៤ បដិច្ចសមុប្បាទ ១២ ] ។

**អនិច្ចសម្មសន** ( ការពិចារណាថា មិនទៀង )

អ្នកបដិបត្តិធម៌ ដែលអាចកំណត់ដឹងទាន់បច្ចុប្បន្ន រមែងឃើញច្បាស់ថា សភាវៈប៉ោង សភាវៈផត សភាវៈអង្គុយ

សភាវៈលាត សភាវៈបត់ សភាវៈកំរើក ជាដើម កើតឡើងហើយ រលត់ទៅ [ ដូចសភាវៈប៉ោងប្រាកដឡើង ហើយប្រព្រឹត្តទៅមួយខណៈហើយទើបស្រុតចុះទៅវិញ ហើយទើបកើតឡើងទឹងឃើញបានថា សភាវៈផតមិនមាននៅក្នុងសភាវៈប៉ោង និងសភាវៈប៉ោង ក៏មិនមាននៅក្នុងសភាវៈផតឡើយ សូម្បីសភាវៈលើកឈាន និងដាក់ ក៏កើតឡើងហើយបាត់ទៅវិញ ក្នុងពេលមួយរំពេចនោះ សភាវៈលើកមិនមាននៅក្នុងសភាវៈដាក់ ដូច្នេះជាដើម ] ។ គេរមែងយល់ថា រូបដែលកំពុងកំណត់ដឹងនោះមិនទៀងទាត់ស្ថិតស្ថេរឡើយ ។

### គេរមែងអនុមានដឹងថា :

-រូបទាំងអស់ក្នុងអតីត មានសភាពមិនទៀង ដូចរូបក្នុងបច្ចុប្បន្ន កាលបើកើតឡើងហើយ ក៏រលត់ទៅ ក្នុងអតីតមិនបានប្រាកដក្នុងបច្ចុប្បន្ន សេចក្តីនេះជា សម្មសនញ្ញាណ ម្យ៉ាង ។

-រូបទាំងអស់ក្នុងអតីត រមែងរលត់ទៅវិញ ដូចរូបដែលកំពុងកំណត់ដឹងក្នុងកាលបច្ចុប្បន្ននេះ មិនមានរូបឯណាទីមួយក្នុងកាលអតីត ទឹងតាំងនៅរហូតដល់បច្ចុប្បន្ននេះទេ ដោយហេតុនេះ

ហើយទើបជារបស់មិនទៀង ព្រោះមានសភាពវិនាសទៅវិញ សេចក្តីនេះ ជាសម្មសនញ្ញាណម្យ៉ាង ។

-រូបទាំងអស់ក្នុងអនាគត មានសភាពមិនទៀងទាត់ដូចរូបដែលកំពុងកំណត់ដឹងក្នុងកាលបច្ចុប្បន្ននេះ កាលកើតឡើងហើយរលត់ទៅវិញ ក្នុងកាលជាអនាគត មិនបានមកប្រាកដក្នុងខណៈដទៃទេ ដោយហេតុនោះ ទើបជារបស់មិនទៀង ព្រោះសភាវៈអស់ទៅវិញ សេចក្តីនេះ ជាសម្មសនញ្ញាណម្យ៉ាង ។

-រូបទាំងអស់ក្នុងបច្ចុប្បន្ន មានសភាពមិនទៀង កាលបើកើតឡើងហើយ រលត់ទៅវិញក្នុងបច្ចុប្បន្ន មិនបានតាំងនៅ ឬស្ថិតនៅទេ ដោយហេតុនោះ ទើបជារបស់មិនទៀង ព្រោះមានសភាពអស់ទៅ,សូន្យទៅ សេចក្តីនេះ ជាសម្មសនញ្ញាណម្យ៉ាង ។

-ក្នុងខណៈដកដង្ហើមចេញ ស្ពោះទឹកមាត់ បន្ទោរបង់នូវឧច្ចារៈ និងបស្សាវៈជាដើម កាលដឹងច្បាស់នៃការកំណត់ដឹងថាសភាវៈដកដង្ហើមចេញជាដើមអស់ទៅ សូន្យទៅ ក្នុងខណៈនោះៗរមែងយល់ចូលចិត្តថា រូបនាមគ្រប់ខណៈទាំងអស់បានរលត់ទៅក្នុងចំណែកខាងក្នុង មិនបានតាំងនៅដល់ផ្នែកខាងក្រៅឡើយ

ដោយហេតុនេះ ទើបជារបស់មិនទៀង ព្រោះមានសភាពអស់ទៅ សូន្យទៅ សេចក្តីនេះជា សម្មសនញ្ញាណម្យ៉ាង ។

-ក្នុងខណៈដកដង្ហើមចូល លេបទឹកមាត់ ផឹក ទំពារ បរិភោគអាហារជាដើម កាលដឹងច្បាស់ក្នុងពេលកំណត់ដឹងថា សភាវៈដកដង្ហើមចូលជាដើម អស់ទៅ សូនទៅ ក្នុងខណៈៗ រមែងយល់ចូលចិត្តថា រូបនាមខាងក្រៅទាំងអស់ បានរលត់ទៅ ក្នុងខណៈផ្នែកខាងក្រៅប៉ុណ្ណោះ មិនបានតាំងនៅដល់ខាងក្នុង ដោយហេតុនេះ ទើបជារបស់មិនទៀង ព្រោះមានសភាវៈអស់ទៅ សូន្យទៅ សេចក្តីនេះ ជាសម្មសនញ្ញាណម្យ៉ាង ។

-ក្នុងខណៈដែលពណ៌ សម្លេង ក្លិន រស ផោដ្ឋព្វៈ ប្រាកដច្បាស់ ហើយល្អិតទៅៗ កាលបើដឹងក្នុងពេលកំណត់ច្បាស់ថា ពណ៌ជាដើមអស់ទៅក្នុងខណៈៗ រមែងយល់ចូលចិត្តថា រូបគ្រោតគ្រាតបានអស់ទៅ រលត់ទៅ ហើយមិនបានតាំងនៅដល់រូបល្អិតនោះទេ ដោយហេតុនោះ ទើបជារបស់មិនទៀង ព្រោះមានសភាពអស់ទៅ សូន្យទៅ សេចក្តីនេះ ជាសម្មសនញ្ញាណម្យ៉ាងដែរ ។

-ក្នុងខណៈដែលពណ៌ សម្លេង ក្លិន រស ផោដ្ឋព្វៈ ប្រាកដច្បាស់ ហើយថយចុះៗ ប្រាកដឡើង កាលដឹងក្នុងពេលកំណត់ពណ៌ជាដើមអស់ទៅក្នុងខណៈៗ រមែងយល់ចូលចិត្តថា រូបល្អិតទាំងអស់បានរលត់ទៅហើយ មិនបានតាំងនៅដល់រូបគ្រោតគ្រាតនោះទេ ដោយហេតុនោះ ទើបជារបស់មិនទៀង ព្រោះមានសភាពអស់ទៅ សូន្យទៅ សេចក្តីនេះ ជាសម្មសនញាណម្យ៉ាងដែរ ។

-ក្នុងខណៈដែលសប្បាយចិត្ត មានសភាពសុខល្អជាងខណៈដែលរឭកដឹងមិនសប្បាយ ការដឹងច្បាស់ក្នុងពេលកំណត់ដឹងថា រូបប្រណីតអស់ទៅ សូន្យទៅ ក្នុងខណៈនោះៗ រមែងយល់ចូលចិត្តថា រូបប្រណីតទាំងអស់ បានរលត់អស់ទៅហើយ មិនបានតាំងនៅរហូតដល់រូបថោកទាប ដោយហេតុនេះ ទើបជារបស់មិនទៀង ព្រោះមានសភាពអស់ទៅ សូន្យទៅ សេចក្តីនេះជាសម្មសនញាណម្យ៉ាង ។

-ក្នុងខណៈលាតដៃ ឬសណ្តូកជើងជាដើម ការដឹងច្បាស់ក្នុងពេលកំណត់ថា សភាវៈបត់អស់ទៅសូន្យទៅ ក្នុងខណៈនោះៗ គេរមែងយល់ថា រូបដែលនៅជិត ទាំងអស់បានរលត់ទៅ ហើយ

មិនតាំងនៅរហូតដល់រូបដែលនៅឆ្ងាយទេ ដោយហេតុនេះ ទើបជារបស់មិនទៀង ព្រោះមានសភាវៈអស់ទៅ សូនទៅ សេចក្ដីនេះជាសម្មសនញាណម្យ៉ាង ។

**ទុក្ខសម្មសនៈ** ( ការពិចារណាថាជាទុក្ខ )

អ្នកដែលមានអាយុតិច សេពគប់ជាមួយមនុស្សក្នុងវ័យប្រហាក់ប្រហែលគ្នា រស់នៅយ៉ាងសុខក្សេម រមែងលំបាកនឹងយល់ចូលចិត្តថា រូបនាមរបស់ខ្លួនជាវត្ថុដែលគួរឲ្យខ្លាច តែអ្នកដែលមានអាយុច្រើនជាង ហើយជួបប្រទះជាមួយសាកសពស្លាប់ដែលអស់ជីវិត ដោយរោគាភ័យ ថែមទាំងខ្លួនឯង ក៏ឈឺទុព្វលភាព មិនអាចសប្បាយ ហើយគិតថា ខ្លួនឯងនឹងត្រូវស្លាប់ រមែងសម្គាល់នូវរូបនាមរបស់ខ្លួនថាជារបស់គួរខ្លាច ។

ក្នុងករណីដូចគ្នានេះ អ្នកដែលមិនដឹងច្បាស់នូវការកើតរលត់របស់រូបនាម ដោយប្រចក្ស រមែងមិនសម្គាល់ថា រូបនាមជាគួរឲ្យខ្លាចទេ តែបន្ទាប់មក ក៏បានដឹងច្បាស់ថា ការកើតរលត់របស់រូបនាមថា មិនតាំងនៅត្រឹមតែមួយខណៈតូចក៏ទេ គេរមែងយល់ចូលចិត្តថា រូបនាមគួរឲ្យខ្លាច ព្រោះកើតឡើងហើយ រលត់

សូន្យទៅវិញ ឬ យល់ថា រូបនាមគួរខ្ពើមគួរឲ្យរង្កាស់ មិនស្អាត ជាទុក្ខ ព្រោះត្រូវទុក្ខបៀតបៀនដោយការកើតរលត់ ។

អ្នកយល់ថា រូបនាមមានសភាពគួរឲ្យខ្លាច ព្រោះខណៈនៃការស្លាប់ប្រាកដគ្រប់ៗ ខណៈដែលរូបនាមចាស់រលត់ទៅហើយ រូបនាមថ្មីនៅមិនទាន់កើតឡើង មិនមានពេលណាដែលជឿថានឹងមិនស្លាប់ ក្រៅអំពីនោះ ក្នុងពេលដែលព្រកដឹងដល់គ្រប់វេទនាដែលអត់ទ្រាំបានដោយលំបាក ក៏យល់ថាជាកងទុក្ខ មិនមែនជាសុខដែលស្ថិតស្ថេរតាមដែលខ្លួនត្រូវការនោះទេ ។

ដោយហេតុនេះ អ្នកដែលដឹងច្បាស់ការកើតរលត់ សភាវៈប៉ោង-ផត អង្គុយ លាត បត់ ។ល។ រមែងយល់ថា រូបដូចដែលពោលគួរខ្ពើម មិនល្អ ជាទុក្ខ ព្រោះត្រូវបៀតបៀនដោយការកើតរលត់ ឬព្រោះរលត់សូន្យ ឬព្រោះជាទីតាំងនៅនៃទុក្ខ ដែលអត់ទ្រាំបានដោយលំបាក ។

អ្នកដែលយល់ថា រូបបច្ចុប្បន្នថាជាទុក្ខ ដោយប្រចក្សបាននេះ រមែងអនុមានដឹង រូបអតីត និងរូបអនាគត ជាដើមថា គួរឲ្យខ្ពើម មិនស្អាត ជាទុក្ខ ព្រោះត្រូវបៀតបៀនដោយការកើតរលត់

ឬព្រោះរលត់សូន្យជានិច្ច ដូចរូបបច្ចុប្បន្ន សេចក្ដីពិស្ដារក្នុងរឿងនេះ ដូចគ្នានឹងអនិច្ចសម្មសនៈ ។

**អនត្តសម្មសនៈ** ( ការពិចារណាថា មិនមែនខ្លួន )

មនុស្សល្ងង់ ដែលមិនដឹងច្បាស់សភាវៈពិតរបស់រូបនាមដោយប្រចក្ស គេរមែងយល់ថា អត្តា ឬ វិញ្ញាណតាំងនៅក្នុងរូបរាងកាយ សាសនាព្រាហ្មណ៍ ទើបពោលដល់វិញ្ញាណទុកច្រើនលក្ខណៈដោយចំពោះតែគម្ពីរ**វិសេសិកទស្សនៈ** និង **នយាយទស្សនៈ** ពោលថា ជាអត្តា ជាម្ចាស់របស់រូបរាងកាយ (សាមិ) អ្នកគ្រប់គ្រងរាងកាយទាំងអស់ ឬរាងកាយខ្លះជាចំណែកដែលបែកជា :

១-ពុទ្ធិន្ទ្រីយ៍ ៥ គឺ : ឥន្ទ្រីយ៍ ដែលទទួលដឹងអារម្មណ៍បានដល់ ត្រចៀក ស្បែក ភ្នែក អណ្ដាត និងច្រមុះ ។

២-កម្មិន្ទ្រីយ៍ ៥ គឺ : ឥន្ទ្រីយ៍ ដែលជាកម្មបានដល់ មាត់ ដៃ ជើង អវយវៈភេទ និងទ្វារធំ ។

៣-ឧភយិន្ទ្រីយ៍ ៥ គឺ : ឥន្ទ្រីយ៍ ដែលទទួលដឹងអារម្មណ៍និងជាកម្ម បានដល់ចិត្ត ។

ព្រះសម្មាសម្ពុទ្ធទ្រង់បំណាង នឹងឲ្យលះបង់នូវការប្រកាន់មាំក្នុងអត្តា ទើបត្រាស់ទុកក្នុងអនត្តលក្ខណៈសូត្រថា :

[១] រូបំ ភិក្ខវេ អនត្តា ។ [២] រូបញ្ច ហិទំ ភិក្ខវេ អត្តា អភវិស្ស, នយិទំ រូបំ អាពាធាយ សំវត្តេយ្យ ។ [៣]សព្ភេថ ច រូបេ "ឯវំ មេ រូបំ ហោតុ, ឯវំ មេ រូបំ ម អហោសី"តិ។

"១. ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជាខ្លួន ។

២. ម្នាលភិក្ខុទាំងឡាយ ប្រសិនបើរូបនេះ ជាខ្លួនពិតមែន ក៏មិនគួរប្រព្រឹត្តដើម្បីអាពាធឡើយ ។

៣. នឹងគួរមានការបង្គាប់បញ្ជាបានថា ចូរឲ្យរូបយើងយ៉ាងនេះ រូបរបស់យើង ចូរកុំយ៉ាងនេះ " ។

អ្នកតែងគម្ពីរមីមង្សាពោលថា អត្តាជាអ្នកធ្វើអាកប្បកិរិយាផ្លូវកាយ វាចា និងចិត្ត (ការក,កត្តា) ធ្វើដោយកិរិយាឃើញដោយភ្នែក និង ឮដោយត្រចៀក ។ ល។ ព្រមដោយការដើរឈរ អង្គុយ លាត បត់ ជាដើម ដូចគម្ពីរអភិធម្មត្ថវិភាវិនី បានជំទាស់សេចក្តីយល់ឃើញនោះថា :

យថានិទស្សនំ បន ធម្មសភាវវិនិមុត្តស្ស

កត្តាទិនោ អភាវទីបនត្ថំ វេទិតព្វំ ។

“ម្យ៉ាងទៀតគប្បីជ្រាបការសម្តែងយ៉ាងនោះ ព្រោះមានប្រយោជន៍ដើម្បីការមិនមានរបស់អ្នកធ្វើ ( អត្តា ) ជាដើម រួចផុតទៅអំពីសភាវៈធម៌ ” ។

សូម្បីក្នុងគម្ពីរអដ្ឋកថា មជ្ឈិមនិកាយ សតិប្បដ្ឋានសូត្រក៏ពោលថា ៖

ឥធ ភិក្ខវេ អភិក្កមន្តោ វា បដិក្កមន្តោ វា យថា អន្ធបុថុជ្ជនា អភិក្កមាទីសុ “ អត្តា អភិក្កមតិ, អត្តនា អភិក្កមោ នព្វត្តិតោ” តិ វា “ អហំ អភិក្កមាមិ, មយា អភិក្កមោ នព្វត្តិតោ” តិ វា សម្មុយ្ហន្តិ ។ តថា សម្មុយ្ហន្តោ ។បេ។

“ភិក្ខុក្នុងធម្មវិន័យនេះ ឈានទៅមុខ ឬ ថយក្រោយ រមែងមិនវង្វេងយល់ខុស ដូចបុថុជ្ជន អ្នកវង្វេងខុស ក្នុងការឈានទៅមុខជាដើម “អត្តាឈានទៅ ការឈានទៅមាន អត្តាធ្វើឲ្យកើតឡើង” ឬយល់ខុសថា “យើងឈានទៅ ការឈានទៅមានយើង ធ្វើឲ្យកើតឡើង ។ល។” ។

អព្ភន្តរេ អត្តា នាម អាលោកេតា វា វិលោកេតា វា នត្ថិ ។

“ដែលឈ្មោះថា អត្តាអ្នកក្រឡេកមើល ឬបែរមើល មិនមានក្នុងរាងកាយ [ កាយ] ។

**អព្ភន្តរេ អត្តា នាម កោចិ សមិញ្ជេន្តោ វា បសារេន្តោ វា នត្ថិ ។**

“ដែលឈ្មោះថា អត្តា អ្នកលាត ឬបត់មិនមានក្នុង [កាយ]។

អ្នកតែងគម្ពីរមីមង្សា និងសង្ខារពោលថា អត្តាដែលជាអ្នកសោយផល ដែលជាសុខ ឬទុក្ខដោយសំដៅយកវេទនា គឺការដឹងថាជាអត្តា ។ ក្នុងអដ្ឋកថា របស់សតិប្បដ្ឋានសូត្របានពោលជំទាស់នៃការឃើញក្នុងរឿងនេះថា ៖

**[១] តត្ថ កោ វេទយតីតិ ន កោចិ សត្តោ វា បុគ្គលោ វា វេទយតិ ។**

**[២] កស្ស វេទនាតិ ន កស្សចិ សត្តស្ស វា បុគ្គលោ វា វេទនា ។**

**[៣] កឹការណា វេទនាតិ វត្ថុ អារម្មណា បនស្ស វេទនា ។**

**[៤] តស្មា ឯស ឯវំ បជានាតិ “តំ តំ សុខាទីនំ វត្ថុំ អារម្មណំ កត្វា វេទនា វេទយតិ ។ តំ បន វេទនាបវត្តិំ ឧបាទាយ**

**អហំ វេទយាមីតិ វោហារមត្តំ ហោតី”តិ ។**

“១. ក្នុងរឿងនោះ ពាក្យថា **វេទយតិ** ( នរណាដឹង? ) សេចក្ដីថា សត្វ បុគ្គលណាៗ ព្រេកដឹង ។

២. ពាក្យថា **កស្ស វេទនា** ( ការព្រេកដឹងរបស់នរណា? ) សេចក្ដីថា ការដឹងសត្វ ឬបុគ្គលណាៗ ។

៣. ពាក្យថា **កឹការណា វេទនា** (ការព្រេកដឹងកើតអំពីអ្វី?) សេចក្ដីថា ការព្រេកដឹងរបស់គេមានទីតាំងជាអារម្មណ៍ ។

៤. ដូច្នោះ ភិក្ខុរមែងដឹងច្បាស់យ៉ាងនេះ “វេទនាប៉ុណ្ណោះរមែងព្រេកដឹង ដោយធ្វើទីតាំងរបស់សុខជាដើមនោះៗ ឲ្យជាអារម្មណ៍ មានត្រឹមតែពាក្យពោលថា យើងព្រេកដឹងដោយជាប់ទាក់ទងជាមួយការប្រព្រឹត្តទៅជាមួយវេទនាប៉ុណ្ណោះ ” ។

ម្យ៉ាងទៀត ក្នុងដីការបស់សតិប្បដ្ឋានសូត្របានជំទាស់ការឃើញថា អត្តា គឺវេទនាជាអ្នកធ្វើកម្ម ( **ការក** ) នោះថា :-

**ធម្មវិនិមុត្តស្ស អញ្ញស្ស កត្តុ អការកោ ធម្មស្សេវ កត្តុភាវំ ទស្សេន្តោ “ វេទនា វេទយតី”តិ អាហ ។**

“ព្រះអដ្ឋកថាចារ្យ ទឹងសម្ដែងសេចក្ដីនៃការធ្វើរបស់សភាវៈ

ធម៌នោះឯង ព្រោះមិនមានការធ្វើដទៃ ដែលផុតទៅអំពីសភាវៈធម៌ ទើបពោលថា **វេទនា វេទយតិ** ( វេទនាប៉ុណ្ណោះ រមែងរឿកដឹង)"

គណាចារ្យពួកព្រហ្មណ៍ទាំងអស់ មានការឃើញជាប់ទាក់ទងជាមួយនឹងអត្តាថាជា :-

-វត្ថុដែលតាំងនៅជារៀងរហូត សូម្បីរូបចាស់ដែលរលត់បែកធ្លាយហើយ ក៏តាំងនៅដោយប្តូរទៅកាន់រូបថ្មី ( **និរាសី** )

-វត្ថុដែលញុំាងរាងកាយទាំងអស់ និងចំណែកខ្លះ គឺឥន្ទ្រីយ៍ជាដើមឲ្យទៅតាមសេចក្តីត្រូវការរបស់ខ្លួន ( **សយិវសី** ) ។

-វត្ថុដែលត្រួតត្រារាងកាយឲ្យប្រព្រឹត្តទៅ តាមដែលត្រូវការ ( **អធិដ្ឋាយក** ) ។

ព្រះសម្មាសម្ពុទ្ធទ្រង់ជម្រះ ការឃើញរឿងអត្តាក្នុងលក្ខណៈដែលតាំងនៅជារៀងរហូត ជាដើមទុកក្នុងឆក្កសូត្រ និងអនត្តលក្ខណសូត្រជាដើម ។

✍...ការប្រកាន់មាំក្នុងអត្តា មានច្រើនប្រការគឺ :

អត្តមាននៅក្នុងខន្ធមួយៗខ្លះ, ខន្ធ ២ ខ្លះ, ខន្ធ ៣ ខ្លះ, ខន្ធ ៤ ខ្លះ, ខន្ធ ៥ ខ្លះ, ក្នុងសម័យពុទ្ធកាលមានពួកនិគ្រន្ថឈ្មោះ សច្ចក: បានប្រកាន់ខន្ធ ៥ ថាជាអត្តាតួខ្លួន ដូចពាក្យព្រមទទួល ចំពោះព្រះភ័ក្ត្ររបស់ព្រះអង្គថា :-

*អហំ ហិ ភោ គោតម ឯវំ វទាមិ "រូបំ មេ អត្តា, វេទនា មេ អត្តា, សញ្ញា មេ អត្តា, សង្ខារា មេ អត្តា, វិញ្ញាណំ មេ អត្តា"តិ ។*

"បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គពោលយ៉ាងនេះ ថារូបជាអត្តា របស់យើង វេទនាជាអត្តា របស់យើង សញ្ញាជាអត្តា របស់យើង សង្ខារជាអត្តា របស់យើង វិញ្ញាណជាអត្តា របស់យើង" ។

ក្រៅពីនេះ អ្នកខ្លះ នៅប្រកាន់ បញ្ញត្តិ គឺវង្វេងកសិណ ជាដើមដែលផុតទៅពីខន្ធ ៥ ថាជាអត្តា ការប្រកាន់ដូចពោលនេះ ជាប់ដោយខន្ធ ៥ ទើបរាប់ចូលក្នុងខន្ធនោះឯង ។ មយ៉ាងទៀត រូបរាងរបស់អត្តានោះ ពោលទុកក្នុងគម្ពីរសាសនាព្រហ្មណ៍

អ្នកចាប់ចិត្តអាចសិក្សាអំពីគម្ពីរ អភិធានិស្សយថ្មី ( ពាក្យអធិប្បាយគាថា ៩២ ) របស់**អគ្គធម្មាភិវំស:** ក៏មានសម្ដែង ។

មនុស្សក្នុងបច្ចុប្បន្ន រមែងប្រកាន់មាំ សម្គាល់ថាយើងជា អ្នកឃើញ បានឮ បានឈរ ដើរ អង្គុយ ដេក បត់ លាត និយាយ ។ល។ ឬ សំគាល់ថាយើងមានអារម្មណ៍ជាសុខ ឬទុក្ខ យើងឃើញ ឬដើរបាន តាមត្រូវការមានវិញ្ញាណ ឬកាយទិព្វ ដែលតាំងនៅជារៀងរហូតមិនបែកធ្លាយ ការសម្គាល់ដូចពោលមកនេះ ចាត់ជាការប្រកាន់មាំនូវអត្តា តាមការឃើញរបស់សាសនាព្រាហ្មណ៍ ដូច្នោះ អ្នកដែលពិចារណា ដោយការយល់អំពីការស្ដាប់ថា មានត្រឹមតែរូបនាម ដែលកើតរលត់ មិនមានវិញ្ញាណ ឬកាយទិព្វ ដែលធ្វើកិច្ចការងារ តាមដែលត្រូវការបាន រមែងមិនអាចកំចាត់បង់នូវសេចក្ដីប្រកាន់មាំ ដូចពោលមកនេះ ឲ្យអស់ទៅបាន ។

ការប្រាកដរបស់អនត្តា អ្នកប្រារព្ធសេចក្ដីព្យាយាម ដែលឃើញច្បាស់ការកើតរលត់របស់រូបនាម ដោយច្បាស់លាស់បាន ហើយរមែងយល់យ៉ាងជាក់ច្បាស់ថា តួខ្លួនមិនមានពិត

មានត្រឹមតែរូបនាម ដែលកើតរលត់មិនដាច់ចន្លោះប៉ុណ្ណោះ ព្រោះគេជួបត្រឹមតែរូបនាម ក្នុងបច្ចុប្បន្ន ដោយមិនឃើញវត្ថុដែលជាតួខ្លួន ដូច្នោះ កាល គេឃើញច្បាស់ សភាវៈប៉ោងផត អន្ទុយ បត់ លាត កម្រើក ។ល។ ដែលកើតឡើង តាមហេតុបច្ច័យហើយរលត់ទៅមិនដាច់ចន្លោះ រមែងយល់ថា រូបទាំងនេះកើតតាមហេតុបច្ច័យ កាលបើមានហេតុបច្ច័យ រមែងកើតឡើង កាលហេតុបច្ច័យអស់ហើយ រមែងរលត់ទៅវិញ មិនមានខ្លឹមសារ ដែលគួរហៅថា ជាអត្តាដែលតាំងនៅជារៀងរហូត ទីងធ្វើដំណើរ តាមសេចក្ដីត្រូវការរបស់ខ្លួន ឬតាក់តែងក្នុងរូបដែលកើតរលត់យ៉ាងនេះ គេរមែងយល់ថា អត្តាតួខ្លួន មិនមាននៅក្នុងរូបយ៉ាងពិតប្រាកដ ការយល់ចូលចិត្ត ដូចពោលមកនេះ ជាការឃើញច្បាស់អនត្តា គឺអនត្តសម្មសនញ្ញាណ រមែងកើតឡើងក្នុងពួកនេះ គឺ :-

-កាលជួបការកើតឡើងរបស់រូប ដែលត្រូវការឲ្យកើតឡើង ។

-កាលជួបការរលត់ទៅរបស់រូប ដែលមិនត្រូវការឲ្យរលត់ទៅ ។

-កាលជួបការរលត់ទៅ និងការកើតឡើងរបស់រូបនាម ក្នុងបច្ចុប្បន្នខណៈ ។

ដោយហេតុនេះ ក្នុងព្រះបាលី ព្រះមានព្រះភាគ ទើបត្រាស់ថា :-

អនត្តា អសារកដ្ឋេនាតិ សង្ខិបិត្វា វវត្ថានេ បញ្ញាសនេ ញាណំ ។

"បញ្ញាក្នុងការកំណត់រូបនាម ( សភាវធម៌ ) ថាជា អនត្តា ព្រោះ ជាសភាវគ្មានខ្លឹមសារ ឈ្មោះថា សម្មសនញ្ញាណ" ។

ក្នុងគម្ពីរវិសុទ្ធិមគ្គ បានអធិប្បាយសេចក្តីខាងដើមថា :-

[១] សព្វម្បិ តំ អនត្តា អសារកដ្ឋេន។

[២] អសារកដ្ឋេនាតិ សាមី និវាសី ការកោ វេទកោ សយំវសីតិ ឯវំ បរិកប្បិតស្ស អត្តសារស្ស អភាវេន ។

[៣] យញ្ហិ អនិច្ចំ ទុក្ខំ, តំ អត្តនោបិ អនិច្ចតំ វា ឧទយព្វយបីឡនំ វា វាវេយតុ ន សក្កោតិ ។

[៤] កុតោ តស្ស ការកាទិភាវោ ។

“១.រូបទាំងអស់ឈ្មោះថាអនត្តា ព្រោះជាវត្ថុដែលគ្មានខ្លឹមសារ ។

២.ពាក្យថា **អសារកត្ថេន** ( ព្រោះជាវត្ថុ ដែលគ្មានខ្លឹមសារ ) មានន័យថា ព្រោះគ្មានខ្លឹមសារ តាមដែលមនុស្សល្ងង់ខ្លៅយល់ គឺ អនត្តា ជាម្ចាស់នៃខន្ធ វត្ថុដែលជារបស់តាំងនៅជារៀងរហូត វត្ថុដែលធ្វើកម្ម វត្ថុដែលសោយផលកម្ម ឬវត្ថុដែលមានអំណាច លើរាងកាយ ។

៣. ដោយពិតហើយ សភាពមិនទៀង និងជាទុក្ខ មិនអាចហាមសេចក្តីមិនទៀង ឬសេចក្តីបៀតបៀន ដោយការកើតរលត់របស់ខ្លួនឯងបាន ។

៤.ភាពជាអ្នកធ្វើកម្ម ជាដើមរបស់សភាពនោះ ទើបមិនមានពិត”។

ក្រៅពីនោះ ក្នុងគម្ពីរវិសុទ្ធិមគ្គបានអធិប្បាយ សេចក្ដីនៃពាក្យថា សុញ្ញតោ និងអនត្តតោ ថា:-

[១] សាមិនិវាសិការកវេទកាធិដ្ឋាយកវិរហិតតាយ-សុញ្ញតោ ។ [២] សយញ្ច អស្សាមិកាភាវតាយ អនត្តតោ។

"១.អ្នកបដិបត្តិធម៌ រមែងដឹងច្បាស់ថាសូន្យទេ ព្រោះប្រាសចាកម្ចាស់របស់នៃខ្លួន វត្ថុដែលតាំងនៅជារៀងរហូត វត្ថុដែលធ្វើកម្ម វត្ថុដែលសោយផលកម្ម វត្ថុដែលតាក់តែងនូវការមើលថែរក្សា ។

២.និងរមែងដឹងច្បាស់ថា មិនមែនជាតួខ្លួន ព្រោះសេចក្ដីមិនមែនម្ចាស់របស់នៃខ្លួនផ្ទាល់ ។

សេចក្ដីខាងដើមនេះ សម្ដែងថា ការធ្វើទុកក្នុងចិត្តពិចារណាថាជាខ្លួនមិនមានទេ នៅតែមិនមែនជាបញ្ញាដែលឃើញច្បាស់ថាជាអនត្តា តែការឃើញច្បាស់ថា មិនមានតួខ្លួន ដែលធ្លាប់សម្គាល់ខុសថាជាម្ចាស់របស់នៃខ្លួន និងវត្ថុដែលតាំងនៅជារៀងរហូតជាដើម ទើបជាបញ្ញា ដែលឃើញច្បាស់ថា អនត្តា

យ៉ាងពិតប្រាកដ និងឃើញបានថាសូម្បីអរូបព្រហ្ម និងមិនមាន

រូបកាយ ក៏នៅមានអត្តាទិដ្ឋិ គឺការឃើញខុសថា មានអត្តាតួខ្លួន ។

អ្នកបដិបត្តិធម៌ ដែលឃើញច្បាស់រូបបច្ចុប្បន្ន ជាអនត្តាដោយច្បាស់លាស់ហើយ រមែងអនុមានដឹងរូបអតីត ជាដើម ថាមិនមានតួខ្លួន ដូចរូបបច្ចុប្បន្ន ព្រោះមិនទៅក្នុងការបង្គាប់បញ្ជា ត្រឹមតែជាសភាវធម៌ ដែលកើតរលត់ទៅតាមធម្មជាតិប៉ុណ្ណោះ ។ សេចក្ដីពិស្ដារនៅក្នុងរឿងនេះ ដូចសេចក្ដីពិចារណាថា មិនទៀង ដែលពោលមកហើយ សូម្បីការប្រាកដរបស់សម្មសនញាណក្នុងវេទនាខន្ធ សញ្ញាខន្ធ សង្ខារខន្ធ និងវិញ្ញាណខន្ធ ក៏ដូចគ្នា ក្នុងទីនេះ នឹងពោលតែរឿងវិញ្ញាណខន្ធ គឺចិត្តដោយសភាពជាខាងក្នុង ( **អជ្ឈត្ត** ) និងសភាពខាងក្រៅ ( **ពហិទ្ធ** ) ជាដើម ។

ចិត្តដែលកំណត់ដឹងនូវការទទួលអារម្មណ៍ខាងក្នុងកាយ ឈ្មោះថា **អជ្ឈត្តចិត្ត** គឺចិត្តខាងក្នុង ចំណែកចិត្តដែល

កំណត់ដឹងនូវការទទួលយកអារម្មណ៍ខាងក្រៅរាងកាយ ឈ្មោះថា **ពហិទ្ធចិត្ត** គឺចិត្តខាងក្រៅ កាលបើសតិមានកម្លាំងច្រើនឡើងហើយ អ្នកបដិបត្តិធម៌ អាចដឹងច្បាស់នូវចិត្តខាងក្នុង និងចិត្តខាងក្រៅថា រលត់ទៅក្នុងខណៈនោះៗ កាលកំណត់ដឹងចិត្តផ្លាស់គ្នាត្រង់ខាងក្នុង និងខាងក្រៅ រមែងយល់ថាចិត្តខាងក្នុងមិនបានចេញ នៅខាងក្រៅតែរលត់ទៅ ខាងក្នុងទើបមិនទៀង ទាំងចិត្តខាងក្រៅ ក៏មិនបានចូលមកខាងក្នុង តែរលត់ទៅត្រង់ខាងក្រៅ ទើបជារបស់មិនទៀង ។

កាលបើកំណត់ដឹងចិត្តគ្រោតគ្រាត និងចិត្តល្អិតផ្លាស់គ្នា គេរមែងយល់ថា ចិត្តគ្រោតគ្រាតមិនបានក្លាយជាចិត្តល្អិតទេ សូម្បីចិត្តល្អិត ក៏មិនបានក្លាយ ជាចិត្តគ្រោតគ្រាតចិត្ត ដូចពោលមកនេះ រលត់ទៅក្នុងខណៈនោះៗ ទើបជារបស់មិនទៀង ។

កាលបើអកុសលចិត្តជាដើម ផ្លាស់ប្តូរអំពីសភាពដើម គេរមែងយល់ថា អកុសលចិត្ត ដែលជាចិត្តអាក្រក់មិនបានក្លាយជាកុសលចិត្ត ដ៏ប្រណិត សូម្បីកុសលចិត្ត ក៏មិនបានផ្លាស់

ទៅជាអកុសលចិត្តទេ, ចិត្តដូចពោលមកនេះ រលត់ទៅក្នុងខណៈនោះៗ ទើបជារបស់មិនទៀង ។

កាលកំណត់ដឹងចិត្តឆ្ងាយ និងចិត្តជិត ផ្លាស់ប្ដូរគ្នា គេរមែងយល់ ថាចិត្តឆ្ងាយ មិនបានក្លាយជាចិត្តជិត សូម្បីចិត្តជិតក៏មិនបានក្លាយជាចិត្តឆ្ងាយ ចិត្តដូចពោលមកនេះ រលត់ទៅក្នុងខណៈនោះៗ ទើបជារបស់មិនទៀង ។

ម្យ៉ាងទៀត ក្នុងគម្ពីរវិសុទ្ធិមគ្គពោលថាៈ-

[១] យំ បន អនិច្ចំ, តំ យស្មា និយមតោ សង្ខតាទិភេទំ ហោតិ ។ [២] តេនស្ស បរិយាយទស្សនត្ថំ រូបំ អតីតានាគតប្បច្ចុប្បន្នំ អនិច្ចំ និរោធធម្មន្តិ បុន បាឡិ វុត្តា ។

“១.រូបខន្ធ ដែលមិនទៀង បែកជារូបខន្ធដែលត្រូវបច្ច័យតាក់តែងជាដើម យ៉ាងពិតប្រាកដ ។

២. ដូច្នោះព្រះអង្គ ទើបត្រាស់ព្រះបាលី [ក្នុងវារៈទី ៣] ទៀតថាៈ-

[១]រូបំ អតីតានាគតបច្ចុប្បន្នំ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ

**ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មំ** (រូបខន្ធដែល ជាអតីត អនាគត និងបច្ចុប្បន្ន មិនទៀង ត្រូវបច្ច័យប្រជុំ តាក់តែង មានសភាពថយចុះទៅ អស់ទៅ សូន្យទៅ និង រលត់ទៅ ) ដើម្បីសំដែងពាក្យវេវចនៈ( ពាក្យន័យដូចគ្នា ) របស់រូបខន្ធនោះ ឬដើម្បីសម្តែងការប្រព្រឹត្តទៅនៃការកំណត់ ដឹងដោយលក្ខណៈ ផ្សេងៗ ។

ដោយហេតុនេះ ការពិចារណា សភាវៈមិនទៀងនៃរូបខន្ធ ទើបមិនត្រឹមតែជាការពិចារណា មិនថាទៀងប៉ុណ្ណោះទេ តែ នៅសំដៅដល់ការពិចារណារូបខន្ធថា :-

-ត្រូវបច្ច័យប្រជុំតាក់តែង ( **សង្ខត** )

-មានសភាពថយចុះទៅ ( **បដិច្ចសមុប្បន្ន** )

-មានសភាពអស់ទៅ ( **វយធម្មា** )

-មានសភាពសូន្យទៅ ( **ខយធម្ម** )

-មានសភាពរលត់ទៅ ( **និរោធធម្មា** )

ក្រៅពីនោះ ការកំណត់ដឹងដោយលក្ខណៈ ៤០ ថា

**អនិច្ចតោ** ( មិនទៀង ) **ទុក្ខតោ** ( ជាទុក្ខ ) **រោគតោ** ( ជារោគ) ដូច្នេះជាដើម ក៏រាប់ចូលក្នុងការពិចារណាថាមិនទៀង ជាទុក្ខ និងមិនមែនជាតួខ្លួន តាមគោលនៃ**សម្មសនញ្ញាណ** ដូចសេចក្តីក្នុងគម្ពីរបដិសម្ភិទាមគ្គ និងគម្ពីរវិសុទ្ធិមគ្គ ក្នុងទីនេះ និងពោលដល់លក្ខណៈទាំង ៤០ នោះ ទុកដោយសង្ខេបក្នុងរឿងនៃបដិសង្ខាញាណ ដែលជាវិបស្សនាញាណលំដាប់ទី ១០ ។

អ្នកដែលកំណត់ដឹងរូបនាមបច្ចុប្បន្ន ហើយឃើញច្បាស់ការកើតឡើង តាំងនៅ និងរលត់ទៅយ៉ាងជាក់ច្បាស់ រមែងយល់ថា កាលបើមានការកើតឡើង ទើបមានការតាំងនៅ និងការរលត់ទៅ ក៏មិនមានដូចគ្នា, កាលបើមានការកើតក្នុងភពមុន ការចាស់ និងសេចក្តីស្លាប់ទើបមាន បើការកើតក្នុងភពមុនមិនមាន ការចាស់ និងសេចក្តីស្លាប់ ក៏មិនមាន សូម្បីក្នុងភពតទៅ ក៏ដូចគ្នា ការយល់នេះ ស្របជាមួយ និងភារៈទី ៤ ដែលពោលទុកក្នុងគម្ពីរបដិសម្ភិទាមគ្គថាៈ-

**ជាតិបច្ចយា ជាតិបច្ចយា ជរាមរណំ, អសតិ ជាតិយា**

**នត្ថិ ជរាមរណន្តិ សន្និដ្ឋានេ បញ្ញា សម្មសនេ ញាណំ ។**

“បញ្ញាក្នុងការកំណត់ដឹងរួមសភាវធម៌ថា មរណៈរមែងមានទៅបាន ព្រោះជាតិជាបច្ច័យ កាលបើមិនមានជាតិ ជរានិងមរណៈ រមែងមិនមាន នេះឈ្មោះថា **សម្មសនញាណ** ។

ការពិចារណាឃើញហេតុ និងផលជាគូគ្នា ដែលជាអង្គរបស់បដិច្ចសមុប្បាទ ដោយរួមបញ្ចូលក្នុងកាល ៣ យ៉ាងនេះត្រឹមតែជាបច្ចយបរិគ្គហញាណ មិនមែនសម្មសនញាណ ដូចគម្ពីរអដ្ឋកថារបស់បដិសម្ភិទាមគ្គពោធា :-

[១] ជាតិបច្ចយា ជរាមរណន្តិអាទិ ន វិបស្សនាវសេន វុត្តំ ។ [២] កេវលំ បដិច្ចសមុប្បាទស្ស ឯកេកអង្គវសេន **សន្និដ្ឋានតោ សម្មសនញាណំ នាម ហោតីតិ បរិយាយេន វុត្តំ ។ [៣] ន កលាបសម្មសនញាណំ ហោតីតិ ។**

“១.ពាក្យថា **ជាតិបច្ចយា ជរាមរណំ** ( មរណៈរមែងមានព្រោះជាតិជាបច្ច័យ ) មិនបានពោលទុកដោយភាពជាវិបស្សនា ។

២. លោកពោលទុកដោយអមថា ដែលឈ្មោះថា **សម្ម-**

សនញ្ញាណ រមែងមានបាន ព្រោះកំណត់ដឹងរួមបដិច្ចសមុប្បាទ ដោយសេចក្តីជាអង្គ មួយប៉ុណ្ណោះ ។

៣. តែញាណដូចពោលមកនេះ មិនមែនជាកលាបសម្មសនញ្ញាណ ( ញាណពិចារណា ដោយភាពជាក្រុម ) ត្រឹមតែជាធម្មដ្ឋិតិញាណ ( ញាណឃើញច្បាស់ នូវការតាំងនៅរបស់សភាវធម៌ )" ។

ពាក្យអធិប្បាយទាំងអស់នេះ ជាការប្រមូលការកើតឡើងរបស់សម្មសនញ្ញាណទាំងអស់ ដែលសម្តែងទុកដោយត្រង់នៅក្នុងគម្ពីរបដិសម្ភិទាមគ្គ ។

"អដ្ឋកថានយ័ ដែលក្រៅអំពីព្រះបាលី"

ក្នុងគម្ពីរវិសុទ្ធិមគ្គ បានពោលដល់វិធីកំណត់សេចក្តីប្រព្រឹត្តទៅរបស់រូបនាមតាំងតែពីបដិសន្ធិ វិធីកំណត់ដឹងរូប ៧ យ៉ាង ( **រូបសត្តកនយ័** ) និងវិធីកំណត់ដឹងនូវនាម ៧ យ៉ាង ( **នាមសត្តកនយ័** ) ដោយហេតុដែលនយ័ដំបូងរាប់បញ្ចូលក្នុងព្រះបាលី ដែលនាំមកសម្តែងទុក ហើយដោយសង្ខេប និងជាការពិចារណាដោយអាស្រ័យការសិក្សាដឹងរបស់មនុស្សម្នាក់ៗ

ទាំងមានសេចក្ដីពិស្ដារច្រើន ដូច្នោះ ទើបសេចក្ដីសម្ដែងចំពោះ ន័យទី ២ និងទី ៣ ទុកដោយសង្ខេបក្នុងទីនេះ ព្រមដោយ វិធីកែតម្រូវឥន្ទ្រីយ៍ ៩ ប្រការ ដែលអ្នកបដិបត្តិធម៌គួរយល់ ។

# "វិធីកែតម្រូវឥន្ទ្រីយ៍ ៩ ប្រការ"

ក្នុងគម្ពីរវិសុទ្ធិមគ្គពោលថា :-

នវហាការេហិ ឥន្ទ្រិយានិ តិក្ខានិ ភវន្តិ ។ [១] ឧប្បន្នុប្បន្នានំ សង្ខារានំ ខយមេវ បស្សតិ ។ [២] តត្ថ ច សក្កច្ចកិរិយាយ សម្បាទេតិ ។ [៣] សាតច្ចកិរិយាយ សម្បាទេតិ ។ [៤] សប្បាយកិរិយាយ សម្បាទេតិ ។ [៥] សមាធិស្ស ច និមិត្តគ្គាហេន ។ [៦] ពោជ្ឈង្គានញ្ច អនុបវត្តនតាយ ។ [៧] កាយេ ច ជីវិតេ ច អនបេក្ខតំ ឧបដ្ឋាបេតិ ។ [៨] តត្ថ ច អភិភុយ្យ នេក្ខម្មេន ។ [៩] អន្តរា ច អព្យោសានេនាតិ ។

"ឥន្ទ្រីយ៍ ៥ ចាស់ក្លាបានដោយហេតុ ៩ ប្រការគឺ :-

១-ព្យាយាមកំណត់ដឹងឲ្យជាក់ច្បាស់ដល់ការរលត់ទៅ

របស់សង្ខារទាំងឡាយ ដែលកើតឡើងហើយ សូម្បីការរលត់របស់សង្ខារគឺ រូបនាមនៅមិនទាន់ប្រាកដច្បាស់ក្នុងខាងដើមនៃការបដិបត្តិធម៌ អ្នកប្រារព្ធសេចក្តីព្យាយាម ក៏គួរយល់ថា សង្ខារមានសភាពរលត់ទៅជាធម្មតា កុំត្រិះរិះថាជាវត្ថុ ដែលមាំមួនមិនរលត់ទៅ និងកាលបើការរលត់របស់សង្ខារប្រាកដ ហើយក៏គួរយល់តាមដែលឃើញច្បាស់កុំរកហេតុផលជំទាស់ ដើម្បីឲ្យឃើញថា មិនរលត់ទៅ ។

២. ក្នុងខណៈឃើញការរលត់ទៅនោះ គួរញុំាងវិបស្សនាញាណឲ្យប្រាកដ ដោយការផ្តោតអារម្មណ៍ ( ការផ្តោតអារម្មណ៍ជាការបន្ថែមវីរិយៈផ្លូវចិត្តដូចការបាញ់ធ្នូដោយកំលាំងខ្លាំង ឲ្យស្ទុះចូលទៅកាន់ទិសដៅ បញ្ចូនផលឲ្យឃើញច្បាស់នូវការរលត់របស់សង្ខារបានយ៉ាងឆាប់រហ័ស ) ។

៣.គួរញុំាងវិបស្សនាញាណឲ្យប្រាកដ ដោយការបដិបត្តិយ៉ាងតភ្ជាប់ ( ការតភ្ជាប់ក្នុងការកំណត់តាំងពីភ្ញាក់ រហូតដល់លក់ ធ្វើឲ្យសតិតភ្ជាប់មិនដាច់ចន្លោះ បញ្ចូនផលឲ្យសមាធិមាន

កម្លាំងនិងបញ្ញាចាស់ក្លា រហូតអាចឃើញច្បាស់ការរលត់របស់សង្ខារបាន ) ។

៤.ការញុំាងវិបស្សនាញាណឲ្យប្រាកដ ដោយការបដិបត្តិយ៉ាងសមរម្យ ( ការនៅក្នុងទីសេសនៈ ឬភូមិបិណ្ឌបាត្រ ពាក្យពេចន៍ បុគ្គល អាហារ រដូវកាល និងឥរិយាបថ ដែលសមរម្យរ មែងធ្វើឲ្យវិបស្សនាញាណដែលនៅមិនទាន់កើតឡើង អាចកើតឡើងបាន និងធ្វើឲ្យវិបស្សនាញាណដែលកើតឡើង ហើយចម្រើនបានឆាប់រហ័សទៀតផង ) ។

៥.ការញុំាងវិបស្សនាញាណ ឲ្យប្រាកដដោយកំណត់ដឹងអារម្មណ៍ ដែលជាហេតុកើតរបស់សមាធិ កាលកំណត់ដឹងអារម្មណ៍ណាហើយ ធ្វើឲ្យសមាធិកើតងាយ គួរកំណត់អារម្មណ៍នោះ ជាគោលក្នុងខណៈនោះៗ ដូចជាការដើរចង្ក្រម ហើយកើតសមាធិល្អ ក៏គួរដើរចង្ក្រមយ៉ាងតភ្ជាប់រហូតដល់ពេលដ៏សមគួរមិនគួរប្តូរជាឥរិយាអន្ទ័យក្នុងខណៈនោះ ។

៦. គួរញុំាងវិបស្សនាញាណ ឲ្យប្រាកដដោយការចម្រើន

ពោជ្ឈង្គៈ កាលភាវនាចិត្តមានកម្លាំងតិចធ្វើឲ្យទៀយនាយ គួរចំរើនពោជ្ឈង្គៈ ៣ គឺបីតិ វិរិយៈ និង ធម្មវិចយរយៈ កាលបើរវើរវាយ ព្រោះវិរិយខ្លាំងជាងសមាធិ គួរចម្រើននូវពោជ្ឈង្គៈ ៣ គឺបស្សទ្ធិ សមាធិ និងឧបេក្ខាវិញ ។

៧.ព្យាយាមមិនអាល័យក្នុងរាងកាយ និងជីវិតមានការប្រាថ្នាមាំ ដើម្បីសម្រេចធម៌ ដោយមិនស្តាយរាងកាយ និងជីវិតរបស់ខ្លួន ។

៨.ក្នុងការមិនអាល័យក្នុងរាងកាយ និងជីវិតនោះ គួរញុំាងវិបស្សនាញាណឲ្យប្រាកដ ដោយគ្រប់គ្រងទុក្ខ ដែលកើតឡើងដោយវិបស្សនា វិរិយៈដែលរួចផុតទៅអំពីការខ្ជិលច្រអូស គួរគ្រប់គ្រងទុក្ខផ្លូវកាយ និងទុក្ខផ្លូវចិត្តទាំងអស់ ដែលកើតពីការបដិបត្តិធម៌ ដោយការព្យាយាម ដែលមិនទម្រន់ ។

៩. គួរញុំាងវិបស្សនាញាណឲ្យប្រាកដ ដោយការមិនបោះបង់ចោលមុន និងសម្រេចមគ្គផលមិនបោះបង់ការបដិបត្តិធម៌ កាលនៅមិនបានសម្រេចមគ្គផលតាមដែលបាន តាំងចិត្តទុក

តែព្យាយាមបដិបត្តិយ៉ាងតក្តាប់ រហូតដល់សម្រេចមគ្គផល”។

ពាក្យថា **សក្កច្ចកិរិយា** ប្រែតាមសព្ទថា “ការធ្វើដោយ អើពើ” សំដៅដល់ការបដិបត្តិដោយ ការផ្តោតអារម្មណ៍ នោះឯង ព្រោះការផ្តោតអារម្មណ៍ ជាការបន្ថែមសេចក្តីព្យាយាមផ្លូវចិត្ត ដែលហៅថា **វីរិយចេតសិក** ។

អ្នកបដិបត្តិធម៌គួរអប់រំវិធីកែតម្រូវឥន្ទ្រិយទាំង ៩ ប្រការ នេះ តាមសមគួរ ដើម្បីឲ្យវិបស្សនាញាណ ដែលនៅមិនទាន់ ឈានទៅមុខបានឈានទៅមុខឡើង និងធ្វើឲ្យវិបស្សនាញាណ ដែលឈានទៅមុខហើយមានការឈានទៅមុខឡើង ជាដើម ។ ការកំណត់ដឹងរូបផ្លូវ រូបសត្តកៈការកំណត់រូបធម៌ ដើម្បីឲ្យ ឃើញច្បាស់ព្រះត្រៃលក្ខណ៍នោះ មានវិធីកំណត់រូប ៧ យ៉ាង ដែលត្រូវកំណត់ដឹងគឺ :-

១/ ការពិចារណាសេចក្តីប្រកាន់ និងការកំណត់ដឹង (**អទាននិក្ខេបន័យ**) ។

២/ ការពិចារណាសេចក្តីបែកធ្លាយ,រលត់ របស់រូបដែល ធំធាត់ឡើងតាមវ័យ ( **វយោវុឌ្ឍត្ថង្គន័យ** ) ។

៣/ ការពិចារណារូបដែលកើតពីអាហារ ( **អាហារជរូប** ) ។

៤/ ការពិចារណារូបដែលកើតពីឧតុ ( **ឧតុជរូប** ) ។

៥/ ការពិចារណារូបដែលកើតពីកម្ម ( **កម្មជរូប** ) ។

៦/ ការពិចារណារូបដែលកើតពីចិត្ត ( **ចិត្តជរូប** ) ។

៧/ ការពិចារណារូបធម្មតា ( **រូបធម្មតា** ) ។

គម្ពីរវិសុទ្ធិមគ្គនាំពាក្យរបស់បោរាណាចារ្យមកអាងថាៈ-

**អាទាននិក្ខេបនតោ វយោវុឌ្ឍត្ថគាមិតោ ។**

**អាហារតោ ច ឧតុតោ កម្មតោ ចាបិ ចិត្តតោ ។**

**ធម្មតារូបតោ សត្ត វិត្ថារេន វិបស្សតិ ។**

“អ្នកបដិបត្តិធម៌ រមែងឃើញច្បាស់ ត្រៃលក្ខណ៍ ដោយពិស្តារ ៧ ប្រការគឺ ការប្រកាន់ និងការប្រលែងចោល ការបែកធ្លាយរលត់របស់រូប ដែលធំឡើងតាមវ័យ អាហារ ឧតុ កម្ម ចិត្ត និងរូបធម្មតា” ។

➪១. ការពិចារណានូវសេចក្តីប្រកាន់ និងការកំណត់ ( **អាទាននិក្ខេបន័យ** ) ។

ការប្រកាន់គឺបដិសន្ធិ ព្រោះទទួលយកខន្ធថ្មី ការកំណត់

គឺចុតិ ព្រោះលះបង់ខន្ធចាស់ ការពិចារណា សេចក្តីប្រកាន់ និងកំណត់ ជាអនុមានឲ្យដឹងរូបបច្ចុប្បន្ន ដែលកំណត់ដោយ បដិសន្ធិ និងចុតិថា មិនទៀង ជាទុក្ខ និងមិនមែនជាតួខ្លួន ។ ក្រោយពីបានឃើញច្បាស់ ការកើតឡើង និងការរត់ទៅរបស់ រូប ដោយប្រចក្សហើយ ការពិចារណា ដូចពោលមកនេះ ឈ្មោះ ថា ការលើកត្រៃលក្ខណ៍ ( សាមញ្ញលក្ខណៈ ) ចូលក្នុងរូប ថារូបទាំងឡាយ ក្នុងភពនេះ រាប់តាំងតែពីបដិសន្ធិ រហូត ដល់ចុតិ មិនទៀង ព្រោះហេតុថា :-

-មានការកើតឡើង និងវិនាសទៅ ។

-មានការប្រែប្រួល ។

-តាំងនៅត្រឹមតែមួយខណៈ ។

-មានការជំទាស់ជាមួយ សភាពទៀង គឺមានសភាវៈ មិនពិតប្រាកដ ដែលមិនទៀង, ជំទាស់ជាមួយនឹងការយល់ របស់មនុស្សទូទៅ ។

រូបទាំងឡាយក្នុងភពនេះ ចាប់តាំងតែពីបដិសន្ធិ រហូតដល់ ចុតិ ជាទុក្ខព្រោះហេតុថា :-

-ត្រូវបៀតបៀនរឿយៗ ដោយការកើតឡើង និងការរលត់ទៅវិញ ព្រោះរូបដែលកើតឡើង រមែងដល់ការតាំងនៅ រូបដែលតាំងនៅហើយ រមែងចាស់ជរា រូបដែលចាស់ជរាហើយ រមែងស្លាប់ ។

-អត់ធន់បានដោយលំបាក ព្រោះរូបដែលកើតរលត់មិនអាចស្ថិតនៅយូរ ។

-ជាទីតាំងនៅនៃទុក្ខផ្លូវកាយ និងទុក្ខផ្លូវចិត្ត ។

-ជំទាស់និងសេចក្តីសុខ ។

-រូបទាំងឡាយក្នុងភពនេះ តាំងពីបដិសន្ធិរហូតដល់ចុតិជាអនត្តា ព្រោះហេតុថាជាសភាពសូន្យចាកអត្តា ព្រោះមិនប្រព្រឹត្តទៅតាមអំណាចខ្លួន ៣ យ៉ាង គឺ រូបដែលកើតឡើងហើយ ចូរតាំងនៅ រូបដែលតាំងនៅហើយ ចូរកុំចាស់ជរា និងរូបដែលចាស់ជរាហើយ ចូរកុំស្លាប់ ដែលមិនមែនអត្តាតាមដែលយល់ខុសនាំគ្នាគិតទូទៅថា គង់មាននៅក្នុងកាយត្រួតត្រានូវកាយទាំងជាអ្នកធ្វើនិងសោយផលកម្ម ។ មិនមានម្ចាស់របស់ដែលអាចត្រួតត្រារូបបាន មិនប្រព្រឹត្តទៅតាមអំណាចត្រូវ

ការបដិសេធអត្តា ។

ពាក្យថា **អនត្តា** មានន័យ ២ ប្រការ គឺ :

១. សភាវៈមិនមានអត្តា **នត្ថិ អត្តា ឯតេសន្តិ អនត្តា ។**

២. សភាវៈមិនមែនអត្តា **ន អត្តា អនត្តា ។**

**➢ការលើកត្រៃព្រះលក្ខណ៍ចូលក្នុងរូបនាម**

បុគ្គលដែល ឃើញនូវការកើតឡើង និងការរលត់ទៅ របស់រូបនាមក្នុងបច្ចុប្បន្នខណៈ ដោយច្បាស់លាស់ ហើយយល់ថាជាវត្ថុមិនទៀង ព្រោះកើតឡើងហើយរលត់ទៅ ជាទុក្ខព្រោះត្រូវបៀតបៀន ដោយការកើតរលត់ និងមិនមែនតួខ្លួន ព្រោះមិនប្រព្រឹត្តទៅតាមត្រូវការ ចាត់ជាការលើកព្រះត្រៃលក្ខណ៍ចូលក្នុងរូបនាមដោយ ត្រង់ដោយបច្ចក្ខញាណ គឺបញ្ញាដែលដឹងច្បាស់ដោយប្រចក្ស ចំណែកការពិចារណារូបនាម ដោយប្រការដទៃ ដែលមិនបានឃើញច្បាស់ក្រោយពីបានដឹងច្បាស់ដោយប្រចក្ស ហើយទើបរាប់ថា ជាការលើកត្រៃលក្ខណ៍ ចូលក្នុងរូបនាម ដោយអមដោយអនុមានញាណ គឺបញ្ញាដែលអនុមានដឹងដោយទូទៅត្រៃលក្ខណ៍ ឬសាមញ្ញលក្ខណៈ គឺលក្ខណៈ

ទូទៅ ដែលមានក្នុងរូបនាមទាំងអស់ ដែលបានដល់សេចក្តីមិនទៀង សេចក្តីជាទុក្ខ និងសេចក្តីមិនមែនតួខ្លួន ជាសភាពដែលមានទៅជាដើម ហើយបុគ្គលដែលមិនបានចម្រើនសតិ ឬចាប់ផ្តើមទីងចំរើនសតិ នៅមិនអាចឃើញច្បាស់ព្រះត្រៃលក្ខណៈនោះបាន បន្ទាប់ពីការនាមានកម្លាំងច្រើនឡើង ក៏រមែងឃើញច្បាស់ដោយប្រចក្សបាន ដូច្នោះក្នុងគម្ពីរផ្សេងៗ ទើបពោលជាសំនួនថា លើកព្រះត្រៃលក្ខណ៍ចូលក្នុងរូបនាម ព្រោះជាការយល់ត្រៃលក្ខណ៍ ដែលនៅមិនធ្លាប់ឃើញពីមុន ដូចសេចក្តីក្នុងគម្ពីរមហាដីកាថា :-

រូបធម្មេ និរូឡ្ហំ លក្ខណត្តយំ បុព្វេ អនត្តា អសល្លក្ខិតំ សល្លក្ខេត្វា សម្មសន្តោ តំ តត្ថ អរោបេតីតិ វុច្ចតិ ។

“អ្នកបដិបត្តិធម៌ ដែលកំណត់ដឹងការពិចារណាឃើញត្រៃលក្ខណ៍ប្រាកដជានិច្ច ដែលខ្លួនមិនធ្លាប់បានកំណត់ដឹងមកពីមុនក្នុងរូបធម៌ រមែងហៅថា លើកត្រៃលក្ខណ៍ចូលក្នុងរូបធម៌នោះ” ។

ក្នុងទីនេះ លើកមកបញ្ជាក់ សល់ការលើកព្រះត្រៃលក្ខណ៍

ចូលក្នុងរូបធម៌ ព្រោះពោលដល់ការពិចារណា រូបក្នុងពួករូបសម្មសនៈ សូម្បីការលើកព្រះត្រៃលក្ខណ៍ ចូលក្នុងនាមធម៌ក៏ដូចគ្នា ។

ក្រៅពីនេះ រូបនាមទាំងអស់ប្រកបដោយ សភាវៈលក្ខណៈគឺពិសេសចំពោះខ្លួនដូចជាសភាពរឹងរបស់ធាតុដី ( **កក្ខឡត្ត** ) សភាពសោយអារម្មណ៍របស់វេទនា ( **វេទិយន** ) ជាសភាពកំណត់ដឹងរបស់សញ្ញា (**សញ្ជានន** )សភាពប៉ះខ្ទប់របស់ផស្សៈ(**ផុសន** )សភាពដឹងអារម្មណ៍ របស់ចិត្ត ( **វិជានន** ) ជាដើមលក្ខណៈពិសេសដូចពោលជាធម្មជាតិរបស់រូបនាម ដែលជួបបានក្នុងលក្ខណៈទាំង ៣ គឺៈ ខណៈកើតឡើង( **ឧប្បាទក្ខណ** ) តាំងនៅ ( **ឋិតិខណ** ) និងរលត់នៅ (**ភង្គខណ** )និងជាវត្ថុដែលអាចឃើញច្បាស់បានក្នុងខាងដើម របស់ការបដិបត្តិទើបមិនពោលថា លើកសភាវលក្ខណៈ ចូលក្នុងរូបធម៌ តែសាមញ្ញលក្ខណៈមិនមែនសភាពដែលជួបបានក្នុងលក្ខណៈទាំង ៣ មិនបានប្រាកដជាលក្ខណៈចំពោះរូបនាម ទាំងជាវត្ថុដែលបុគ្គលមិនអាចឃើញច្បាស់បានក្នុង ពេលចាប់ផ្ដើមបដិបត្តិបន្ទាប់ពីបដិបត្តិរហូតទាំង

មានបញ្ញាចាស់ក្លាល្មមសមគួរហើយ ទើបនឹងឃើញច្បាស់ថា រូបនាមមិនទៀងជាទុក្ខ និងមិនមែនតួខ្លួនដូច្នោះ ទើបពោលជាសំនួនថា លើកព្រះត្រៃលក្ខណ៍ ចូលក្នុងសភាវលក្ខណៈ សមពិតដូចកស្តុតាងក្នុងគម្ពីរមហាដីកាថា :

[១] យថា បឋវីផស្សាទីនំ កក្ខឡផុសនាទិលក្ខណានិ គីសុបិ ខណេសុ សល្លក្ខិតព្វានិ បជិនិយតរូបតាយ សភាវសិទ្ធានេវ ហុត្វា គយ្ហន្តិ [២] ន ឯវំ អនិច្ចតាទិលក្ខណានិ ។ [៣] តានិ បន ភង្គុទយព្វយបីឡាវវត្តនាការមុខេន គហេតព្វតោ សមារោបរូបានិ វិយ គយ្ហន្តីតិ វុត្តំ សាមញ្ញលក្ខណំ អារោបេត្វាតិ ។

"១.លក្ខណៈមានការរឹង និងការប៉ះខ្ទប់ជាដើម របស់រូប មានធាតុដី និងនាម មានផស្សៈ ជាដើមបុគ្គលគប្បីកំណត់ដឹងបានក្នុងខណៈទាំង ៣ ជាវត្ថុដែលប្រាកដតាមធម្មជាតិ ដោយសភាពជារបស់មិនទៀងទាត់ ដោយចំពោះ របស់រូបនាមរមែងត្រូវដឹងច្បាស់បាន ។

២.តែលក្ខណៈគឺសេចក្តីមិនទៀងជាដើម មិនមែនដូច្នោះទេ។

៣.លក្ខណៈដូចពោល ត្រូវឃើញច្បាស់ ដូចជាសភាព ដែលលើកឡើងទុកក្នុងសភាវលក្ខណៈ ព្រោះឃើញច្បាស់ដោយមានលក្ខណៈ គឺការរលត់ទៅ ការបៀតបៀនដោយការកើតឡើង និងការមិនប្រព្រឹត្តទៅតាមត្រូវការជាគោល ដូច្នោះ ទើបពោលថា **សាមញ្ញលក្ខណំ អារោបេត្វា** ( លើកព្រះត្រៃលក្ខណ៍ ចូលក្នុងសភាវលក្ខណៈ ) ។

សេចក្តីខាងដើមមានន័យថា បុគ្គលត្រូវឃើញច្បាស់នូវលក្ខណៈថា មិនទៀង, ជាទុក្ខ, មិនមែនខ្លួនរបស់រូបនាម ដែលមានសភាវៈ គឺការរលត់ទៅការបៀតបៀនដោយការកើតឡើង និងរលត់ទៅ និងការមិនប្រព្រឹត្តទៅតាមសេចក្តីត្រូវការឲ្យច្បាស់លាស់ជាមុនសិន ទើបនឹងអនុមានដឹងត្រៃលក្ខណ៍របស់រូបនាមដទៃទាំងអស់បាន លោកទើបពោលថាជាវោហារថា លើកត្រៃលក្ខណ៍ ដូច្នោះ បើបុគ្គលនៅមិនទាន់ឃើញច្បាស់នូវការកើតរលត់មុនទេ ក៏គួរពិចារណាត្រៃលក្ខណ៍ ពិតហើយ អ្នកបដិបត្តិធម៌ គួរបានឃើញច្បាស់លក្ខណៈពិសេសរបស់រូបនាមក្នុងបច្ចុប្បន្នមុន ទើបឃើញច្បាស់ការកើតរលត់ដោយច្បាស់

លាស់ ក្រោយពីនោះ ទើបអនុមានដឹងរូបនាមដទៃថា មិនទៀង ជាទុក្ខនិងមិនមែនខ្លួន ដោយការឃើញច្បាស់ និងអនុមានដឹងយ៉ាងនេះ ថាជាលក្ខណៈរបស់សម្មសនញាណ ។

**២.ការពិចារណាសេចក្ដីស្លាប់របស់រូប ដែលធំធាត់ឡើងតាមវ័យ ( វយោវុឌ្ឍត្ថង្គមន័យ )**

ពាក្យថា **វយោវុឌ្ឍត្ថង្គម:** គឺសេចក្ដីស្លាប់របស់រូបដែលធំធាត់ឡើងតាមវ័យផ្សេងៗ ថាមិនទៀង ជាទុក្ខ មិនមែនតួខ្លួន ដូចអ្នកដែលឃើញច្បាស់នូវការកើតឡើង និងរលត់ទៅរបស់រូបក្នុងបច្ចុប្បន្នខណៈដោយច្បាស់លាស់ ហើយក្នុងខណៈនោះអាចពិចារណាដោយច្បាស់លាស់ទាំងនេះគឺ:

២/១ អាយុខៃ ចែកចេញជា ៣ ផ្នែកថា :-

-រូបដែលប្រព្រឹត្តទៅក្នុងបឋមវ័យ មិនទាន់ដល់មជ្ឈិមវ័យក៏រលត់ទៅក្នុងបឋមវ័យនោះឯង ទើបមានសភាពមិនទៀង ជាទុក្ខ និងមិនមែនតួខ្លួន ។

-រូបដែលប្រព្រឹត្តទៅក្នុងមជ្ឈិមវ័យ មិនទាន់ដល់បច្ឆិមវ័យក៏រលត់ទៅក្នុងមជ្ឈិមវ័យនោះឯង ទើបមានសភាពមិនទៀង ជា

ទុក្ខ និងមិនមែនតួខ្លួន ។

**២/២** ចែក ១០០ ឆ្នាំចេញជា ១០ រយៈថា :-

-រូបដែលប្រព្រឹត្តទៅក្នុងចន្លោះ ១០ ឆ្នាំដំបូងនៅមិនដល់ ១០ ឆ្នាំចន្លោះទី ២ ក៏រលត់ទៅក្នុងចន្លោះ ១០ ឆ្នាំដំបូង ដូចរូបក្នុងបច្ចុប្បន្ន ដែលប្រាកដការកើតរលត់ ទើបមានសភាពមិនទៀង ជាទុក្ខ និងមិនមែនតួខ្លួន ។ ល ។

-រូបដែលប្រព្រឹត្តិទៅ ១០ ឆ្នាំ ចន្លោះទី ១០នៅមិនដល់ភពខាងមុខ ក៏រលត់ទៅក្នុង ១០ឆ្នាំចន្លោះ ទី ១០ ដូចរូបបច្ចុប្បន្ន ដែលប្រាកដការកើតរលត់ ទើបមានសភាពមិនទៀង ជាទុក្ខ និងមិនមែនតួខ្លួន ។

**២/៣** ចែក ១០០ឆ្នាំជា ២០ រយៈ បែងចេញជារយៈម្តង ៥ ឆ្នាំ ។

**២/៤** ចែក ១០០ឆ្នាំជា ២៥.៥០.១០០ បែងចេញជារយៈ ៤ ឆ្នាំ ២ឆ្នាំ និង ១ ឆ្នាំតាមលំដាប់ ។

**២/៥** ចែក ១ ឆ្នាំ តាម ៣ រដូវ គឺរដូវក្តៅ រដូវរងារ និង រដូវភ្លៀង ។

២/៦ ចែក ១ ឆ្នាំតាម ៦ រដូវគឺ រដូវហេមន្ត រដូវផ្ការ រដូវស្លឹកឈើជ្រុះ រដូវក្តៅ រដូវភ្លៀង និងរដូវខ្យល់ ។

២/៧ ចែក ១ ខែជា ២ បក្ខ គឺ ខាងខ្នើត និងរនោច ។

២/៨ ចែក ១ ថ្ងៃ គឺ ជាថ្ងៃ និងយប់ ។

២/៩ ចែក ១ថ្ងៃ ជា ៦ ចំណែក គឺពេលព្រឹក ពេលថ្ងៃ ពេលល្ងាច បឋមយាម ( តាំងពីម៉ោង ១៨:០០-២២:០០ន. ) មជ្ឈិមយាម ( តាំងពីម៉ោង ២២:០០-០២:០០ន. ) និងមច្ឆិមយាម ( តាំងពីម៉ោង ០២:០០-០៦:០០ន. ) ។

អ្នកបដិបត្តិធម៌ អាចឃើញច្បាស់សេចក្តីមិនទៀងរបស់រូបដែលប្រព្រឹត្តិទៅក្នុងរយៈផ្សេងៗ ថា រូបដែលប្រព្រឹត្តមួយរយៈ ទៅមិនទាន់ដល់រយៈតទៅ ក៏រលត់ចុះក្នុងរយៈ ដែលកំពុងដំណើរទៅ ដូចរូបក្នុងបច្ចុប្បន្ន ដែលប្រាកដការកើតរលត់ ទើបមានសភាពមិនទៀង ជាទុក្ខ និងមិនមែនតួខ្លួន ការអនុមានដឹងដូចពោលប្រាកដបន្ទាប់ ពីការឃើញច្បាស់ការកើតរលត់របស់រូបនាមដោយជាក់ច្បាស់ហើយ ។

២/១០ ចែកដោយអាការ: ៦ ដោយបែងសភាវ:ផ្លូវកាង

កាយ ចែកចេញជា ៦ រយៈគឺ :-

-ការដើរទៅខាងមុខ

-ការថយក្រោយ

-ការក្រឡេកមើល

-ការបត់ចូល

-ការលាតចេញ

មានសេចក្ដីទាក់ទងរឿងនេះ ក្នុងគម្ពីរវិសុទ្ធិមគ្គថា:-

អភិក្កមេ បវត្តរូបំ បដិក្កម្មំ អប្បត្វា តត្ថេវ និរុជ្ឈតិ ។ បដិក្កម្មេ បវត្តរូបំ អាលោកនំ, អាលោកេន បវត្តរូបំ វិលោកនំ, វិលោកេន បវត្តរូបំ សមិជ្ជនំ, សមិជ្ជេន បវត្តរូបំ បសារណំ អប្បត្វា តត្ថេវ និរុជ្ឈតិ ។ តស្មា អនិច្ចំ ទុក្ខំ អនត្តាតិ តិលក្ខណំ អារោបេតិ ។

អ្នកបដិបត្តិធម៌រមែងលើកឡើងកាន់ ព្រះត្រៃលក្ខណ៍ថា:

-រូបដែលប្រព្រឹត្តទៅក្នុងខណៈដើរទៅខាងមុខ នៅមិនទាន់ថយត្រឡប់ ក៏រលត់នៅក្នុងខណៈដើរទៅខាងមុខនោះឯង ។

-រូបដែលប្រព្រឹត្តទៅក្នុងខណៈថយត្រឡប់ នៅមិនទាន់

ក្រឡេកមើល ក៏រលត់នៅក្នុងថយត្រឡប់ ។

-រូបដែលប្រព្រឹត្តទៅក្នុងខណៈក្រឡេក មើលនៅមិនទាន់បែរមើល ក៏រលត់ទៅក្នុងខណៈ ក្រឡេកមើល ។

-រូបដែលប្រព្រឹត្តទៅក្នុងខណៈបែរមើល នៅមិនទាន់បត់ចូល ក៏រលត់ទៅក្នុងខណៈបែរមើលនោះឯង ។

-រូបដែលប្រព្រឹត្តទៅក្នុងខណៈបត់ចូល នៅមិនទាន់លាចេញ ក៏រលត់ទៅក្នុងខណៈបត់ចូល ។

ដូច្នោះ ទើបមិនទៀង ជាទុក្ខ និងមិនមែនតួខ្លួន ។

ម្យ៉ាងទៀត លំដាប់ក្នុងគម្ពីរអដ្ឋកថា ខាងដើមពោលទុកដោយស្រេបតាមសេចក្តី ដែលជួបក្នុងមហាសតិបដ្ឋានសូត្រ មិនមែនប្រាថ្នាទីងឲ្យអ្នកបដិបត្តិធម៌ទន្ទេញស្វាធ្យាយពិចារណាតាមលំដាប់នោះទេ ព្រោះការក្រឡេកមើលមិនបានកើតឡើងគ្រប់គ្រា កាលបើថយត្រឡប់ហើយ តែអាចប្រាកដសភាវៈដទៃដូចការដើរទៅខាងមុខ ការត្រឡប់ខ្លួន ការបែរមើល ការបត់ការលាសូម្បីការបែរមើល មិនមែនថាកើតឡើងជានិច្ចនោះទេ កាលបើក្រឡេកមើលហើយ តែអាចប្រាកដដល់សភាវៈដទៃ

មានការដើរទៅខាងមុខជាដើម ក្រៅពីនោះការបែរមើលហើយ ការបត់នឹងកើតឡើងជានិច្ច តែក៏អាចប្រាកដសភាវៈដទៃ ដូចជាការត្រឡប់ខ្លួនទៅខាងមុខ ដូច្នោះលំដាប់ដែលពោលមកខាងដើម ទើបមិនបានប្រាថ្នា សម្តែងនូវការកើតឡើង របស់អាកប្បកិរិយា ដែលប្រាកដយ៉ាងបន្តបន្ទាប់ ។

អ្នកបដិបត្តិធម៌ គួរកំណត់ដឹងអាកប្បកិរិយារបស់រូបនោះៗ ក្នុងបច្ចុប្បន្នខណៈ កាលបើបានឃើញច្បាស់នូវការរលត់ទៅរបស់រូប ដែលកើតឡើងហើយ រមែងឃើញច្បាស់ថារូប ដូចពោលមិនទៀង ជាទុក្ខ និងមិនមែនតួខ្លួន ដូចសភាវៈឈានជើងទៅមិនទាន់ដល់ខណៈឈានជើងឆ្វេង ក៏រលត់ទៅក្នុងខណៈជើងស្តាំ និងសភាវៈឈានជើងឆ្វេង ក៏រលត់ទៅក្នុងខណៈឈានជើងឆ្វេង ដែលមុននឹងប្តូរមករំកិលជើងស្តាំ ទើបមិនទៀង ជាទុក្ខ និងជាមិនមែនតួខ្លួន ។ ក្រៅពីនោះរូបដែលលើក នៅមិនទាន់ដល់ឈានក៏រលត់ទៅក្នុងខណៈ លើកជាដើម ដូច្នោះសភាវៈ លើកឈានជាន់ទាំងនោះ ទើបមិនទៀង ជាទុក្ខ និងមិនមែនជាតួខ្លួន កាលបើសម្មសនញ្ញាណចាស់ក្លាពេញបរិបូណ៌ ហើយសភាវៈ ៦ យ៉ាង

រមែងប្រាកដជា ៦ ចន្លោះ ក្នុងមួយជំហានឈាន ដូច្នេះ គឺ:

- រយៈទី ១ ការលើក ( **ឧទ្ធរណ** ) ។
- រយៈទី ២ ការឈាន ( **អតិហរណ** ) ។
- រយៈទី ៣ ការឈានទៅខាងមុខ( **វីតិហរណ** ) ។
- រយៈទី ៤ ការជាន់ ( **វោស្សជ្ជន** ) ។
- រយៈទី ៥ ការដាក់ ( **សន្និក្ខេបន** ) ។
- រយៈទី ៦ ការសង្កត់ ( **សន្និរុម្ភន** ) ។

រយៈទី ២ និងទី ៣ ពោលទុកតាមមតិរបស់គម្ពីរមូលដីកា និងដីការបស់ទីឃនិកាយ ចំណែកគម្ពីរអដ្ឋកថា ពោលថា **អតិហរណ** គឺការឈាន **វីតិហរណ** គឺការប្តូរ ការប្តូរជើងក្នុងខណៈឈានដើម្បីគេចចេញអំពីបន្លា ឬជន្លត់ឈើជាដើម ។ ក្នុងអាកប្បកិរិយារបស់រូប ៦ យ៉ាងនេះសភាវៈលើកនឹងមិនអាចនៅទាន់ដល់ខណៈឈាន សភាវៈឈាន នឹងមិនអាចទៅដល់ខណៈឈានទៅខាងមុខ សភាវៈឈានទៅខាងមុខ នឹងមិនអាចទៅដល់ខណៈជាន់ សភាវៈជាន់មិនអាចទៅដល់ខណៈដាក់ និងសភាវៈដាក់ ក៏មិនអាចទៅដល់ខណៈសង្កត់ រូបទាំងនោះ

រលត់ទៅម្ដងមួយខណៈៗ ទើបមិនទៀង ជាទុក្ខនិងមិនមែនជាតួខ្លួន ។

បុគ្គលដែលឃើញច្បាស់សភាវៈទាំង ៦ យ៉ាងក្នុងខណៈដើរយ៉ាងជាក់ច្បាស់ដូចនេះរាប់ថាជា អ្នកបានសម្រេចនូវសម្មសនញាណ ដែលចាស់ក្លាហើយ និងចាប់ផ្ដើមសម្រេចនូវឧទយព្វយញាណទៀតផង ដូចសេចក្ដីក្នុងគម្ពីរវិសុទ្ធិមគ្គថា:

**តស្សេវំ បព្វបព្វគតេ សង្ខារេ វិបស្សតោ រូបសម្មសនំ សុខុមំ ហោតិ ។**

"កាលអ្នកបដិបត្តិធម៌ ឃើញច្បាស់នូវសង្ខារធម៌ម្ដងមួយចំណែក ៗ ការពិចារណារូប រមែងល្អិតឡើង" ។

សេចក្ដីខាងដើមមានន័យថា កាលបុគ្គលឃើញច្បាស់នូវសភាវៈ ៦ រយៈក្នុងម្ដងមួយចន្លោះថា សភាវៈលើក មិនប្រព្រឹត្តទៅដល់ខណៈឈានជាដើម ឈ្មោះថាជាអ្នកបានសម្រេចសម្មសនញាណ ដែលចាស់ក្លា ជាការពិតហើយ សូម្បីនឹងពោលដល់ការពិចារណា អាហារជាដើមបន្ទាប់ពីនេះទៅ ក៏ជាន័យម្យ៉ាង ដូចគ្នា មិនមែនមានន័យថា ន័យក្រោយមានការល្អិត

ជាន័យដែលពោលមុននោះទេ និងមិនមែនត្រូវពិចារណាតាមលំដាប់ន័យទាំងអស់ តែឲ្យឃើញច្បាស់សភាវៈរបស់រូបនាមដែលមកប្រាកដ ក្នុងបច្ចុប្បន្នខណៈ ជាគោល កាលបើឃើញច្បាស់ន័យណាទីមួយហើយ ក៏អាចយល់ន័យដទៃបាន ។

ម្យ៉ាងទៀត អ្នកដែលឃើញច្បាស់ខាងដើម និងទីបំផុតរបស់សភាវៈលើក ឈាននិងជាន់ក្នុងខណៈដើរ រាប់ថាបានសម្រេចសម្មសនញាណ ដែលចាស់ក្លាហើយ ។ ចំណែកអ្នកដែលមានបញ្ញាច្រើន អាចឃើញច្បាស់សភាវៈទាំង ៦ ក្នុងខណៈដើរនោះ ។

ក្រៅពីនេះ សូម្បីក្នុងគម្ពីរអដ្ឋកថា ទឹងពោលដល់ការពិចារណានាម ៧ យ៉ាង ( **នាមសត្តក** ) បន្ទាប់ពីការពិចារណារូប ក៏ជាពាក្យអធិប្បាយ ដែលពោលទុកដើម្បីឲ្យយល់ងាយព្រោះការកំណត់រូប ងាយជាងការកំណត់នាម តែអ្នកបដិបត្តិគួរបម្រើនសតិដឹងទាន់ រូបនាមដែលមកប្រាកដច្បាស់ផ្លូវទ្វារទាំង ៦ ដោយមិនជ្រើសថា ត្រូវកំណត់តែម្យ៉ាង ។ កាលបើកំណត់រូបជាគោលហើយ នាមនឹងប្រាកដច្បាស់ក្នុងពេលខាង

ក្រោយ ។

### ៣.ពិចារណារូបដែលកើតពីអាហារ ( អាហារជរូប )

ក្នុងគម្ពីរវិសុទ្ធិមគ្គពោលដល់រឿងនេះថា :-

[១]អាហារមយំ រូបំ ឆាតសុហិតវសេន បាកដំ ហោន្តិ ។

[២]ឆាតកាលេ សមុដ្ឋិតំ រូបញ្ហិ ឈត្តំ ហោតិ កិលន្តំ, ឈាមខាណុកោ វិយ អង្គារបច្ឆិយំ និលីនកាកោ វិយ ច ទុព្វណ្ណំ ទុស្សណ្ឋិតំ ។ សុហិតកាលេ សមុដ្ឋិតំ ធាតំ បីណិតំ មុទុ សិនិទ្ធំ ផស្សវន្តំ ហោតិ ។ [៣] សោ តំ បរិគ្គហេត្វា "ឆាតកាលេ បវត្តរូបំ សុហិតកាលំ អប្បត្វា ឯត្ថេវ និរុជ្ឈតិ ។ សុហិតកាលេ សមុដ្ឋិតបតម្បិ ឆាតកាលំ អប្បត្វា ឯត្ថេវ និរុជ្ឈតិ ។ តស្មា តំ អនិច្ចំ ទុក្ខមនត្តា"តិ ឯវំ តត្ថ តិលក្ខណំ អារោបេតិ ។

"១/ រូបដែលកើតពីអាហារ រមែងប្រាកដជាប់ដោយការឃ្លាន ឬឆ្អែត ។

២/ ដូច្នេះ នឹងឃើញបានថា រូបដែលកើតក្នុងពេលឃ្លាន រមែងស្រពោន មានពណ៌សម្បុរ និងរូបរាងសៅហ្មង ដូចជា

ផង្គត់ឈើផង្កោ ឬក្អែកដែលទុំនៅក្នុងកញ្ជើដាក់ផ្សេង រូបដែលកើតនៅក្នុងពេលឆ្អែត រមែងស្រស់ថ្លា គួរឲ្យចង់ទំនាក់ទំនង ។

៣/ លោកកំណត់រូបនោះហើយ រមែងលើកឡើងកាន់ត្រៃលក្ខណ៍ ក្នុងរូបនោះ យ៉ាងនេះថា រូបដែលប្រព្រឹត្តទៅក្នុងខណៈឃ្លាន នៅមិនទាន់ដល់ខណៈឆ្អែត រមែងរលត់ទៅក្នុងខណៈឃ្លាននោះឯង ដូច្នោះ រូបនោះ ទើបជារបស់មិនទៀងជាទុក្ខ និង មិនមែនជាតួខ្លួន" ។

៤.ពិចារណារូបដែលកើតពីឧតុ (ឧតុជរូប )

ក្នុងគម្ពីរវិសុទ្ធិមគ្គពោលថា :-

[១] ឧតុមមយំ សីតុណ្ហវសេន បាកដំ ហោតិ ។

[២] ឧណ្ហកាលេ សមុដ្ឋិតំ រូបំ ហិ ឈត្តំ ហោតិ កិលន្តំ ទុព្វណ្ណំ ។ សីតឧតុនា សមុដ្ឋិតំ រូបំ ធាតំ បីណិតំ សិនិទ្ធំ ហោតិ ។ [៣] សោ តំ បរិគ្គហេត្វា "ឧតុកាលេ បវត្តរូបំ សីតកាលំ អប្បត្វា ឯត្ថេវ និរុជ្ឈតិ ។ សីតកាលេ បវត្តរូបំ ឧណ្ហកាលំ អប្បត្វា និរុជ្ឈតិ ។ តស្មា តំ អនិច្ចំ ទុក្ខមនត្តា"តិ ឯវំ តត្ថ តិលក្ខណំ អារោបេតិ ។

"១.រូបដែលកើតឡើងពីឧតុ រមែងប្រាកដដោយការជាប់ទាក់ទងជាមួយការត្រជាក់ ឬក្តៅ ។

២/ ដូច្នេះ ទើងឃើញបានថា រូបដែលកើតក្នុងពេលក្តៅ រមែងស្រពោន អស់កម្លាំង មានពណ៌សៅហ្មង រូបដែលកើតឡើងក្នុងពេលត្រជាក់ រមែងស្រស់ថ្លា ។

៣/ លោកកំណត់រូបនោះហើយ រមែងលើកឡើងកាន់នូវត្រៃលក្ខណ៍ ចូលក្នុងរូបនោះ យ៉ាងនេះថា រូបដែលប្រព្រឹត្តទៅក្នុងខណៈក្តៅ មិនទាន់ដល់ខណៈត្រជាក់ រមែងរលត់ទៅក្នុងខណៈក្តៅនោះឯង រូបដែលប្រព្រឹត្តទៅក្នុងខណៈត្រជាក់ មិនទាន់ដល់ខណៈក្តៅ រមែងរលត់ទៅក្នុងខណៈត្រជាក់នោះឯង ដូច្នោះ រូបនោះ ទើបមិនទៀង ជាទុក្ខ និងមិនមែនជាតួខ្លួន" ។

## ៥.ពិចារណារូបដែលកើតពីកម្ម ( កម្មជរូប )

ក្នុងគម្ពីរវិសុទ្ធិមគ្គពោលថា :-

[១] កម្មជំ អាយតនទ្វារវសេន បាកដំ ហោតិ ។

[២] ចក្ខុទ្វារស្មឹ ហិ ចក្ខុកាយភាវទសកវសេន តឹស កម្មជរូបានិ, ឧបត្ថម្ភកានិ បន តេសំ ឧតុចិត្តាហារសមុដ្ឋានានិ

ចតុវីសតីតិ ចតុបណ្ណាស ហោន្តិ ។ [៣] តថា សោតឃាន-ជិវ្ហាទ្វារេសុ ។ [៤] កាយទ្វារេ កាយទសកវសេន ចេវ ឧតុសមុដ្ឋានាទិវសេន ច ចតុចត្តាឡីស ។ មនោទ្វារេ ហទយវត្ថុកាយភាវទសកវសេន ចេវ ឧតុសមុដ្ឋានាទិវសេន ច ចតុបណ្ណាសមេវ ។

"១. កម្មជរូបរមែងប្រាកដ រមែងជាប់ទាក់ទងដោយទ្វារដែលជាហេតុកើតរបស់ផស្សៈ គឺកាលចក្ខុបសាទរូប ដែលជាហេតុឲ្យកើតអារម្មណ៍ ជាមួយចិត្តប៉ះខ្ទប់គ្នា និងសោតបសាទ-រូប ជាដើមទៅ រហូតដល់ហទយវត្ថុប្រាកដច្បាស់ កម្មជរូបដទៃទាំងអស់ ដែលកើតរួមជាមួយកម្មជរូប ពួកនោះ រមែងប្រាកដច្បាស់ ។

២.សំដៅសេចក្តីថា កម្មជរូប ៣០ ដោយចែកចេញជាចក្ខុទសកកលាប ( សំណុំរូបដែលមានចក្ខុបសាទជាគម្រប់ ១០ គឺ អវិនិភោគរូប ៨ ជីវិតរូប ១ និង ចក្ខុបសាទរូប ១ ) កាយ-ទសកកលាប ( សំណុំរូប ដែលមានកាយបសាទជាគម្រប់ ១០ គឺ អវិនិភោគរូប ៨ ជីវិតរូប ១ និង កាយបសាទរូប ១ ) ភាវ-

ទសកកលាប ( សំណុំរូប ដែលមានភាវរូបជាគម្រប់ ១០ គឺ អវិនិភោគរូប ៨ ជីវិតរូប ១ និង ភាវរូប ១ ) ព្រមដោយ ឧតុជរូប ចិត្តជរូប និងអាហារជរូប ២៤ ដែលឧបត្ថម្ភរូប ទាំងនោះ រមែងប្រាកដក្នុងចក្ខុទ្វារ, រួមទាំង ( កម្មជរូប ៣០ ជា ) ៥៤ យ៉ាង រមែងមកប្រាកដក្នុងចក្ខុទ្វារ ។

៣. សោតទ្វារ ឃានទ្វារ និងជិវ្ហាទ្វារ ក៏ន័យនេះ ដូចគ្នា គឺមានរូប ៥៤ យ៉ាង ប្រាកដក្នុងទ្វារទាំងនោះ ។

៤. រូប ៤៤ ដោយចែកជា កាយទសកកលាប, ភាវទសកកលាប, និងឧតុជរូប ជាដើម រមែងប្រាកដក្នុងកាយទ្វារ រូប ៥៤ ដោយចែកជា ហទយវត្ថុ កាយទសកកលាប ភាវទសកកលាប និងឧតុជរូបជាដើម រមែងប្រាកដក្នុងមនោទ្វារ"។

កាលអ្នកបដិបត្តិធម៌ ដឹងច្បាស់ដល់ភាពថ្លានៃកែវភ្នែក ក្នុងខណៈឃើញ រមែងយល់ថា រូប ៥៤ យ៉ាង ខាងដើម ដែលកើតរួមជាមួយចក្ខុបសាទ រមែងប្រាកដផ្លូវចក្ខុទ្វារ រឿងនេះ មិនមែនជាការពិចារណា តាមគោលទ្រឹស្តីក្នុងការចែកអង្គធម៌ របស់រូបថា តើមានរូបប៉ុន្មានយ៉ាង? ប៉ុន្មានកលាប? ដែលប្រាកដក្នុង

ផ្លូវចក្ខុទ្វារ ព្រោះតែម្នាក់ឯង ការពិចារណាថា រូប ៦ កលាប ឬ រូប ៥៤ យ៉ាង ដែលប្រាកដផ្លូវចក្ខុទ្វារ ក្នុងខណៈឃើញ ត្រឹមតែជាការយល់តាមគោលបរិយត្តិប៉ុណ្ណោះ មិនមែនជាការឃើញច្បាស់ ពីលោកទស្សនៈខាងក្នុងខ្លួននោះទេ ។

ពិតមែនហើយ ការដឹងច្បាស់ចំនួនរូបថា មានប៉ុន្មានយ៉ាង ប៉ុន្មានកលាប នេះជាវិស័យនៃព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ ចំណែកមនុស្សទូទៅ សូម្បីនឹងគិតដល់អង្គធម៌ ក៏មិនអាចដឹងច្បាស់នូវសភាវៈរបស់រូប ដូចពោលមកនេះ ឲ្យជាក់ច្បាស់បាន ។ នឹងដឹងថា ក្នុងខណៈឃើញតែមួយគ្រា យើងមិនអាចដឹងដល់ចំនួនរូបដែលប្រាកដក្នុងបច្ចុប្បន្នខណៈបានទេ ឬ សូម្បីនឹងអាចដឹងបាន ក៏មិនចំបាច់ត្រូវទៅពិចារណាតាមនោះទេ ព្រោះទិសដៅរបស់វិបស្សនា គឺការកំចាត់បង់នូវសេចក្តីប្រកាន់មាំ ដែលជាទីតាំងរបស់អនុស្សយកិលេស អ្នកដែលរឭកដឹងទាន់សភាវៈឃើញនៅក្នុងបច្ចុប្បន្នខណៈ ហើយឃើញច្បាស់ថា ចក្ខុបសាទមិនទៀង ជាទុក្ខ និងមិនមែនជាតួខ្លួន រមែងមិនប្រកាន់ខុសថា រូបទាំងអស់ដែលកើតរួមជាមួយចក្ខុបសាទ ជាសភាវៈទៀង ជាសុខ និងជា

ត្តូខន គេរាប់ថា បានកំចាត់បង់នូវសេចក្តីប្រកាន់មាំ ក្នុងរូបកលាប ៦ ក្រុម និងរូប ៥៤ យ៉ាង ដោយពិត ។ ដោយហេតុនេះ ក្នុងព្រះសូត្រ ដែលទាក់ទងជាមួយវិបស្សនាភាវនា ទើបមិនបានត្រាស់ដល់រូបកលាប និងចំនួនរូបដូចពោលទេ តែបញ្ជាក់ការដឹងច្បាស់ចក្ខុបសាទម្យ៉ាង ដោយព្រះតម្រាស់ថា :-

**ចក្ខុញ្ច បជានាតិ ។**

"រមែងដឹងច្បាស់នូវចក្ខុ គឺ ភ្នែក" ។

**ចក្ខុ អនិច្ចន្តិ យថាភូតំ បជានាតិ ។**

"រមែងដឹងតាមសេចក្តីពិតថា ចក្ខុមិនទៀង" ។

ក្រៅពីនោះ ក្នុងគម្ពីរវិសុទ្ធិមគ្គមិនបានបំណាំងដល់ កលាប និងចំនួនរូបក្នុងការពិចារណាអាហាររូប ឧតុជរូប និងចិត្តជរូប ដោយល្អិត ដូច្នោះ ការសម្តែងនូវកលាប និងចំនួនរូប ក្នុងការពិចារណា កម្មជរូបនេះ ទើបមានបំណងប្រាថ្នា ដើម្បីឲ្យជ្រាបថា មានរូបកលាប ៦ ក្រុម និងរូប ៥៤ យ៉ាង ប្រាកដរួមគ្នាក្នុងផ្លូវចក្ខុទ្វារ ខណៈដែលឃើញម្តងមួយគ្រា របស់ចក្ខុបសាទមិនមែនមានបំណងដើម្បីសម្តែងវិធីបដិបត្តិ ដោយការពិចារណា

យ៉ាងនោះ ។

សោ សព្វម្បិ តំ រូបំ បរិគ្គហេត្វា “ ចក្ខុទ្វារេ បវត្តរូបំ សោតទ្វារំ អប្បត្វា ឯត្ថេវ និរុជ្ឈតិ ។ សោតទ្វារេ បវត្តរូបំ ឃានទ្វារំ, ឃានទ្វារេ បវត្តរូបំ ជិវ្ហាទ្វារំ, ជិវ្ហាទ្វារេ បវត្តរូបំ កាយទ្វារំ, កាយទ្វារេ បវត្តរូបំ មនោទ្វារំ អប្បត្វា ឯត្ថេវ និរុជ្ឈតិ ។ តស្មា តំ អនិច្ចំ ទុក្ខំ អនត្តា”តិ ឯវំ តត្ថតិលក្ខណំ អារោបេតិ ។

“ អ្នកបដិបត្តិធម៌ រមែងកំណត់ដឹងរូបសូម្បីទាំងអស់នោះហើយ រមែងលើកឡើងកាន់ត្រៃលក្ខណ៍ចូលក្នុងរូបនោះ យ៉ាងនេះថា :-

-រូបដែលប្រព្រឹត្តទៅក្នុងចក្ខុទ្វារ នៅមិនទាន់ដល់សោតទ្វារ ក៏រលត់ទៅក្នុងចក្ខុទ្វារនោះឯង ។

-រូបដែលប្រព្រឹត្តទៅក្នុងសោតទ្វារ នៅមិនទាន់ដល់ឃានទ្វារ ក៏រលត់ទៅក្នុងសោតទ្វារនោះឯង ។

-រូបដែលប្រព្រឹត្តទៅក្នុងឃានទ្វារ នៅមិនទាន់ដល់ជិវ្ហាទ្វារ ក៏រលត់ទៅក្នុងឃានទ្វារនោះឯង ។

-រូបដែលប្រព្រឹត្តទៅក្នុងជិវ្ហាទ្វារ នៅមិនទាន់ដល់កាយទ្វារ ក៏រលត់ទៅក្នុងជិវ្ហាទ្វារនោះឯង ។

-រូបដែលប្រព្រឹត្តទៅក្នុងកាយទ្វារ នៅមិនទាន់ដល់មនោទ្វារ ក៏រលត់ទៅក្នុងកាយទ្វារនោះឯង ។

ដូច្នោះ ទើបមិនទៀង ជាទុក្ខ និងមិនមែនជាតួខ្លួន" ។

លំដាប់ក្នុងគម្ពីរអដ្ឋកថា ខាងដើមពោលទុកតាមលំដាប់ការឃើញ បានឮ ។ល។ មិនមែនជាលំដាប់ នៃការបដិបត្តិយ៉ាងពិតប្រាកដ ព្រោះមនុស្សទូទៅដឹងថា អាចមានការដឹងក្លិនជាដើម បន្ទាប់ពីការឃើញបាន ទើបរមែងយល់ខុសថា រូបក្នុងខណៈឃើញ បន្តភ្ជាប់តទៅរហូតដល់ខណៈដឹងក្លិន ទាំងរូបថាក្នុងខណៈនិងដឹងក្លិន ក៏ជាបុគ្គលមានតួខ្លួន ដូច្នេះ ជាដើម ។ ពិតមែនហើយ វិបស្សនាជាផ្លូវនៃការកំចាត់បង់នូវសេចក្តីប្រកាន់មាំ ដែលជាទីតាំងរបស់អនុស្ស័យ ដូច្នោះ អ្នកបដិបត្តិធម៌ ទើបគួរកំណត់ដឹងសភាវៈរូបនាម ដែលប្រាកដច្បាស់ផ្លូវទ្វារទាំង ៦ តាមសភាវៈពិត ដូចជា:

-រូបដែលប្រព្រឹត្តទៅក្នុងខណៈឃើញ នៅមិនទាន់ដល់ខណៈបានឮ ក៏រលត់ទៅក្នុងខណៈឃើញនោះឯង ។

-រូបដែលប្រព្រឹត្តទៅក្នុងខណៈឃើញ នៅមិនទាន់ដល់ខណៈដឹងក្លិន ភ្លក្សរស ប៉ះខ្ទប់សម្ផស្ស ឬនឹកគិត ក៏រលត់ទៅក្នុងខណៈឃើញនោះឯង ។

-រូបដែលប្រព្រឹត្តទៅក្នុងខណៈបានឮ នៅមិនទាន់ដល់ខណៈឃើញ ដឹងក្លិន ភ្លក្សរស ប៉ះខ្ទប់សម្ផស្ស ឬនឹកគិត ក៏រលត់ទៅក្នុងខណៈបានឮនោះឯង ។

-រូបដែលប្រព្រឹត្តទៅក្នុងខណៈដឹងក្លិន នៅមិនទាន់ដល់ខណៈឃើញ បានឮ ភ្លក្សរស ប៉ះខ្ទប់សម្ផស្ស ឬនឹកគិត ក៏រលត់ទៅក្នុងខណៈដឹងក្លិននោះឯង ។

-រូបដែលប្រព្រឹត្តទៅក្នុងខណៈភ្លក្សរស នៅមិនទាន់ដល់ខណៈឃើញ បានឮ ដឹងក្លិន ប៉ះខ្ទប់សម្ផស្ស ឬនឹកគិត ក៏រលត់ទៅក្នុងខណៈភ្លក្សរសនោះឯង ។

-រូបដែលប្រព្រឹត្តទៅក្នុងខណៈប៉ះខ្ទប់សម្ផស្ស នៅមិនទាន់ដល់ខណៈឃើញ បានឮ ដឹងក្លិន ភ្លក្សរស ឬនឹកគិត ក៏រលត់ទៅក្នុងខណៈប៉ះខ្ទប់សម្ផស្សនោះឯង ។

-រូបដែលប្រព្រឹត្តទៅក្នុងខណៈនឹកគិត នៅមិនទាន់ដល់

ខណៈឃើញ បានឮ ដឹងក្លិន ភ្លក្សរស ប៉ះខ្ទប់សម្ផស្ស ក៏រលត់ទៅ
ក្នុងខណៈនឹកគិតនោះឯង ។

ក្រោយពីនោះ អ្នកបដិបត្តិធម៌ គប្បីកំណត់ដឹងរយៈរបស់រូប
ដែលប្រាកដច្រើនគ្រាថា រូបគ្រាក្នុងពេលឃើញ ។ល។ នៅមិន
ទាន់ដល់គ្រាទី ២ ក៏រលត់ទៅក្នុងគ្រាដំបូង និងតៗ ទៅរូបដែល
ប្រព្រឹត្តទៅក្នុងរយៈពេលតែមួយៗ និងរលត់ទៅរយៈជាមួយគ្នា
មិនមានសេសសល់នៅ រហូតតភ្ជាប់ដល់រយៈដទៃនោះទេ ដូច្នោះ
ទើបមិនទៀង ជាទុក្ខ និងមិនមែនជាតួខ្លួន ។

## ៦. ពិចារណារូបដែលកើតពីចិត្ត ( ចិត្តជរូប )

រូបដែលកើតពីចិត្ត រមែងប្រាកដក្នុងខណៈសោមនស្ស ឬ
ទោមនស្សកើតឡើងដូចសេចក្តីក្នុងគម្ពីរវិសុទ្ធិមគ្គថា :-

**ចិត្តសមុដ្ឋានំ សោមនស្សិតទោមនស្សិតវសេន បាកដំ ហោតិ ។**

“រូបដែលមានចិត្តជាសមុដ្ឋាន រមែងប្រាកដជាប់ទាក់ទង
ដោយចិត្ត ដែលអាស្រ័យសោមនស្ស ឬទោមនស្ស” ។

សេចក្តីនេះ ពោលទុកដោយប្រាថ្នា នឹងសម្តែងវេទនា ដែល
ប្រាកដច្បាស់ប៉ុណ្ណោះ ក្នុងខណៈចិត្តត្រេកអរ និងចិត្តដែលត្រូវការ

នឹងអន្តរាយ ក្រោក បត់ លាត ។ល។ ក៏ប្រាកដបានដល់អ្នកដែលបដិបត្តិធម៌ ដែលឃើញច្បាស់សភាវៈរបស់រូបនាមហើយ ដូច្នោះក្នុងខណៈដែលសេចក្ដីសោមនស្ស ( សប្បាយចិត្ត ) ឬទោមនស្ស ( ខូចចិត្ត ) ប្រែប្រួលទៅអំពីសភាពដើម បុគ្គលគួរកំណត់ដឹងចិត្តជាសោមនស្ស និងរូប ដែលកើតឡើងក្នុងពេលសោមនស្ស ឬកំណត់ដឹងចិត្តទោមនស្ស និងរូបដែលកើតឡើងក្នុងពេលទោមនស្សថា រូបដែលប្រព្រឹត្តទៅក្នុងពេលសោមនស្ស នៅមិនទាន់ដល់ពេលដែលទោមនស្ស ក៏រលត់ទៅពេលដែលសោមនស្សនោះឯង សូម្បីរូបដែលប្រព្រឹត្តទៅ ក្នុងពេលទោមនស្ស ក៏រលត់ទៅក្នុងពេលទោមនស្សនោះឯង មិនបានសេសសល់រហូតដល់ពេលសោមនស្សទេ ដូច្នោះ សូម្បីដែលកើតពីចិត្តក៏មិនទៀង ជាទុក្ខ និងមិនមែនជាតួខ្លួន ។

ក្នុងករណីដូចគ្នានេះ កាលបើអ្នកបដិបត្តិធម៌ កំណត់ដឹងចិត្តត្រូវការនឹងធ្វើនូវអាកប្បកិរិយា យ៉ាងណានីមួយ ព្រមដោយរូបដែលកើតឡើងក្នុងខណៈអន្តរាយជាដើម រមែងឃើញច្បាស់ថារូបទាំងនោះ រលត់ទៅក្នុងខណៈអន្តរាយជាដើម ទើបមិនទៀង

ជាទុក្ខ និងមិនមែនជាខ្លួន ។

អ្នកដែលឃើញច្បាស់នូវត្រៃលក្ខណ៍ ក្នុងចិត្តជួរបតាម ន័យដែលពោលមកនេះ រមែងយល់ថា សង្ខារទាំងឡាយមាន ខណៈខ្លី មិនតាំងនៅយូរ ដូចសេចក្ដីពោលថា :-

ជីវិតំ អត្តភាវោ ច　　សុខទុក្ខា ច កេវលា
ឯកចិត្តសមាយុត្តា　　លហុសោ វត្តតេ ខណោ ។

"ជីវិត អត្តភាព សុខនិងទុក្ខ ត្រឹមតែជាសភាវធម៌សុទ្ធៗ ប្រកបដោយខណៈចិត្តតែមួយ ខណៈកន្លងទៅលឿនរហ័ស"។

សេចក្ដីនេះ មានន័យថា វត្ថុដែលមនុស្សក្នុងលោកនាំគ្នា សម្គាល់ថា ជាជីវិត អត្តភាព សុខ និងទុក្ខ ទាំងអស់នេះ មិន មែនជាខ្លួន ជាយើង របស់យើង ត្រឹមតែជាសភាវធម៌ដែល កើតឡើង នឹងរលត់ទៅតាមហេតុបច្ច័យ តាំងនៅត្រឹមតែមួយ ខណៈចិត្តប៉ុណ្ណោះ សូម្បីចន្លោះពេល ១០០ឆ្នាំ ក៏កន្លងទៅរហ័ស មិនតាំងនៅយូរឡើយ ។

ចុល្លាសីតិសហស្សានិ　　កប្បំ តិដ្ឋន្តិ យេ នរូ
ន ត្វេវ តេបិ តិដ្ឋន្តិ　　ទ្វីហិ ចិត្តេហិ សមោហិតា ។

“ព្រហ្មពួកណាតាំងនៅរហូត ៨៤,០០០ មហាកប្ប សូម្បីពួកព្រហ្មទាំងនោះ ក៏មិនបានតាំងនៅ ២ ខណៈចិត្ត ដោយពិត”។

សេចក្តីនេះ មានន័យថា ទាំងព្រហ្មជាន់នេវសញ្ញានាសញ្ញាយតនៈ ដែលមានអាយុ ៨៤,០០០ មហាកប្ប ក៏មានជីវិតរស់នៅត្រឹមតែមួយខណៈចិត្ត ដូចគ្នាជាមួយមនុស្សដែរ ។

**យេ និរុទ្ធា មរន្តស្ស តិដ្ឋមានស្ស វា ឥធ**
**សព្វេបិ សទិសា ខន្ធា គតា អប្បដិសន្ធិកា ។**

“ ខន្ធដែលរលត់ទៅហើយ របស់អ្នកដែលកំពុងអស់ជីវិត ឬរបស់អ្នកដែលតាំងនៅក្នុងភពនេះ ខន្ធទាំងអស់នោះ មានការរលត់ទៅ ដូចគ្នា កាលរលត់ទៅហើយ មិនកើតឡើងទៀត”។

កាលបុគ្គលចំរើនសតិរឭកដឹងបច្ចុប្បន្ន ហើយឃើញច្បាស់នូវការរលត់ទៅរបស់រូបនាម ក្នុងខណៈឃើញ បានឮ បត់លាត ។ល។ មុននិងអស់ជីវិតរមែងយល់ថា រូបនាមក្នុង ខណៈឃើញ ជាដើមមានសភាពរលត់ទៅ ដូចរូបនាមដែលរលត់ទៅជាទីបំផុត ក្នុងពេលអស់ជីវិត ការរលត់ហើយ មិនកើតទៀត ជាការរលត់សូន្យទៅក្នុងមួយខណៈ ។

**អនន្តរា ច យេ ភគ្គា យេ ច ភគ្គា អនាគតេ**
**ទតន្តរា និរុទ្ធានំ វេសនំ នត្ថិ លក្ខណេ ។**

“ខន្ធពួកណា រលត់ទៅហើយ ក្នុងអតីត ខន្ធពួកណាទឹង រលត់ទៅក្នុងអនាគត ខន្ធទាំងឡាយ ដែលរលត់ទៅក្នុងបច្ចុប្បន្ន រវាងអតីត និងអានាគត ខន្ធទាំងនោះ មិនមានសេចក្តីផ្សេងគ្នា ព្រោះមានលក្ខណៈរលត់ទៅដូចគ្នា ” ។

លក្ខណៈ គឺការរលត់ទៅរបស់រូបនាម, ដែលរលត់ទៅហើយ និងដល់នូវការរលត់ទៅ ឬកំពុងតែរលត់ មិនផ្សេងទេ ដូច្នោះ អ្នកដែលឃើញច្បាស់នូវការរលត់ទៅរបស់រូបនាមក្នុងបច្ចុប្បន្នខណៈ រមែងអនុមានដឹងរូបនាមក្នុងអតីត និងអនាគតថា មានសភាវៈរលត់ទៅជាធម្មតា ដូចរូបនាមដែលឃើញច្បាស់ក្នុងបច្ចុប្បន្ន ។

**អនិព្វត្តេន ន ជាតោ បច្ចុប្បន្នេន ជីវតិ**
**ចិត្តភង្គា មតោ លោកោ បញ្ញត្តិ បរមត្ថិយា ។**

“សត្វលោក ឈ្មោះថា មិនមាន ក្នុងពេលដែលចិត្តមិនទាន់កើតឡើង សត្វលោក ឈ្មោះថា មានជីវិត ដែលចិត្តកំពុង

កើតឡើង សត្វលោក ឈ្មោះថា ស្លាប់ហើយ ព្រោះចិត្តរលត់ទៅហើយ ពាក្យបញ្ញត្តិថាមានជីវិត ក៏ដូចមានពិត" ។

កាលចិត្តមួយដួងៗ នៅមិនទាន់មិនទាន់កើតឡើង សត្វលោកមិនហៅថា មានជីវិតរស់នៅ គេទើបមិនមានឈ្មោះថា មានជីវិតរស់នៅដោយចិត្ត ដែលនៅមិនទាន់កើតឡើង តែមានជីវិតរស់នៅដោយចិត្ត ដែលកំពុងកើតឡើង ព្រោះចិត្តដូចពោលប្រាកដជាក់ច្បាស់ សូម្បីចិត្តដែលរលត់ទៅហើយ ក៏មិនបានតាំងនៅក្នុងទីណាមួយឡើយ និងមិនកើតឡើងទៀតទេ ដូចជាចុតិចិត្តរបស់មនុស្សដែលអស់ជីវិត ដូច្នោះ សត្វលោកទើបហៅថា ស្លាប់ទៅគ្រប់ខណៈៗ ចិត្តដែលរលត់យ៉ាងណា ពាក្យបញ្ញត្តិដែលប្រើជាប់ទាក់ទងគ្នាផ្លូវលោកថានាយ"ក" មានជីវិតរស់នៅ នាយ"ខ"មានជីវិរស់នៅ ដូចជាវត្ថុដែលមានពិតក្នុងខណៈនិយាយចរចា ទំនាក់ទំនង ព្រោះមានជីវិតរស់ នៅពិតដោយចិត្តដួងថ្មីៗ ដែលកើតឡើងរហ័សយ៉ាងបន្តបន្ទាប់ បើចិត្តដួងថ្មីមិនកើតឡើង បន្ទាប់ពីចិត្តដួងចាស់ សេចក្តីស្លាប់ រមែងប្រាកដ អ្នកបដិបត្តិធម៌ រមែងឃើញច្បាស់ សេចក្តីស្លាប់ គ្រប់ៗ ខណៈចិត្ត

យ៉ាងនេះ ទើបយល់ថា សេចក្តីដូចជាមួយនិង សេចក្តីរលត់ទៅចិត្តមួយដួងៗ ដែលកំពុងកំណត់ដឹងក្នុងពេលបច្ចុប្បន្ន ។

អនិធានគតា ភគ្គា បុញ្ញោ នត្ថិ អនាគតេ
និព្វត្តា យេបិ តិដ្ឋន្តិ អារគ្គេ សាសបូបមា ។

" សង្ខារដែលរលត់ទៅហើយ មិនបានមកប្រជុំគ្នាទេ កងសង្ខារក្នុងអនាគត រមែងមិនមាន សូម្បីសង្ខារដែលកំពុងកើតឡើង ក៏តាំងនៅត្រឹមតែមួយខណៈ ដូចជាគ្រាប់ស្ពៃនៅលើចុងម្ជុល" ។

សង្ខារ គឺរូបនាម ដែលរលត់ទៅហើយ មិនបានតាំងនៅក្នុងទីកន្លែងណាមួយទេ តែរលត់សូន្យទៅហើយ ដោយមិនមានសេសសល់ សង្ខារដែលនៅមិនទាន់កើតឡើង ក៏មិនបានរួមគ្នារង់ចាំនឹងកើតឡើងតទៅ សង្ខារដែលកើតឡើងតាមហេតុបច្ច័យមានប្រាកដនៅពិត តែស្ថិតនៅត្រឹមតែមួយខណៈ កាលបើកើតឡើងហើយ ក៏រលត់ទៅគ្រប់ខណៈៗ ចិត្ត ដូចជាគ្រាប់ ស្ពៃដែលដាក់ទុកលើចុងម្ជុល ហើយក៏ធ្លាក់ចុះពីម្ជុលភ្លាម ។

និព្វត្តានញ្ច ធម្មានំ ភង្គោ នេសំ បុរក្ខតោ

**បលោកធម្មា តិដ្ឋន្តិ បុរាណោហិ អនិស្សិតា ។**

“ សង្ខារធម៌ ដែលកើតឡើងហើយនោះ មានការរលត់ទៅជា ខាងមុខ ធម៌ដូចពោលមានសភាពរលត់ទៅ មិនលាយឡំជាមួយនិងសង្ខារចាស់ រមែងស្ថិតនៅមួយខណៈ” ។

**អទស្សនតោ អាយន្តិ ភគ្គា គច្ឆន្ត្យទស្សនំ**
**វិជ្ជុប្បាទោវ អាកាសេ ឧបជ្ជន្តិ វយន្តិ ច ។**

“ សង្ខារធម៌មកពីទីដែលមិនមាននរណាធ្លាប់ជួបប្រទះបែកធ្លាយហើយ ក៏ទៅកាន់ការមិនឃើញ រមែងកើតឡើង និងរលត់ទៅដូចក្រសែភ្លេកផ្លេកបន្ទោរ ក្នុងអាកាស ដូច្នេះ” ។

សេចក្តីខាងដើមមានន័យថា សង្ខារធម៌មុននឹងកើតឡើងមិនបានរួមគ្នាតាំងនៅក្នុងទីណាឡើយ កាលបើកើតឡើង ទើបមិនបានរសាត់ចេញពីទីណាទេ តែប្រាកដឡើងតាមឋានៈដោយស្របតាមហេតុបច្ច័យ ដែលសមរម្យ ។ ន័យម្យ៉ាងទៀត កាលមុននឹងសង្ខារដែលកើតឡើង សភាពដែលមានពិត នៅមិនទាន់ប្រាកដ ទើបមិនអាចជួបប្រទះសង្ខារនោះបាន បន្ទាប់ពីសង្ខារដែលប្រាកដឡើងហើយ ទើបជួបសភាវៈរបស់សង្ខារបាន

ពោលថា សង្ខារមកពីសភាវៈដែលមិនមាននរណាជួបប្រទះ និង កាលសង្ខាររលត់ទៅក៏មិនបានរួមគ្នា នៅក្នុងទីណា តែរលត់ទៅក្នុងទីនោះៗ ឯង ដោយសភាពជារបស់មានពិត រលត់សូន្យទៅខណៈបន្តិចបន្តួចរបស់សង្ខារ និងការរលត់ទៅយ៉ាងឆាប់រហ័ស តាមដែលពោលទុកក្នុងគាថាទាំងនេះ រមែងប្រាកដដល់អ្នកដែលប្រារព្ធសេចក្តីព្យាយាម កាលសម្រេចឧទយព្វយញ្ញាណ ដែលឃើញការពិត រលត់យ៉ាងជាក់ច្បាស់ អ្នកដែលមានបញ្ញា មិនទាន់ចាស់ក្លា អាចឃើញច្បាស់បាន ការសម្រេចវិបស្សនាញាណជាន់ខ្ពស់ ជាងឧទយព្វយញ្ញាណ តែអ្នកមានបញ្ញាចាស់ក្លា អាចឃើញច្បាស់សភាវៈយ៉ាងនោះ កាលបានសម្រេចនូវសម្មសនញ្ញាណនេះហើយ ។ ព្រះអដ្ឋកថា ទើបពោលរឿងនេះទុកក្នុងសម្មសនញ្ញាណ លោកមិនបាន មានបំណងយកគ្រប់គ្នាដែលបានសម្រេចញ្ញាណនេះ និងត្រូវឃើញយ៉ាងជាក់ច្បាស់ដូច្នោះទេ ។

## ៦៧.ពិចារណារូបធម្មតា ( ធម្មតារូប )

រូបធម្មតា គឺរូបខាងក្រៅ ( ពហិទ្ធារូប ) ទាំងអស់ដែល

បានឈ្មោះថា **អនិន្ទ្រិយពហិទ្ធរូប** គឺរូបដែលមិនមានជីវិត មិនមានចិត្តគ្រប់គ្រង ដូចជា ខោអាវ កន្ទេល ខ្នើយ ថ្នាំង ពេង ដី ទឹក ភ្លើង ខ្យល់ កំណាត់ឈើ ដុំថ្ម ជាដើម ។ អ្នកបដិបត្តិធម៌ កំណត់ដឹងរូបទាំងនោះ ក្នុងខណៈដែលឃើញ បានឮ ដឹងក្លិន ភ្លក្សរស និងការប៉ះខ្ទប់សម្ផស្ស ហើយឃើញថា រលត់ទៅដោយមិនកើតឡើងតជាប់គ្នា ទើបមិនទៀង ជាទុក្ខ និងមិនមែនជាតួខ្លួន ។ ក្រៅពីនោះ ក្នុងខណៈខ្លះ អាចពិចារណា ប្រៀបធៀបជាមួយនឹងរូបខាងក្នុង និងរូបខាងក្រៅដែលកំពុងតែកំណត់ដឹងហើយ អនុមានដឹងថា រូបខាងក្រៅទាំងអស់កើតឡើង និងរលត់ទៅ ដូច្នេះ រូបក្នុងបច្ចុប្បន្ន ទើបមិនទៀង ជាទុក្ខ និងមិនមែនជាខ្លួន ។

**៦.ការកំណត់នាមផ្លូវនាមសត្តកៈ**

ការកំណត់ដឹងនាមធម៌ ឲ្យឃើញត្រៃលក្ខណ៍ ដោយវិធី ៧ យ៉ាង គឺ :-

**១/ កលាបនយ័** គឺ ការកំណត់ដឹងជាក្រុម ជាសំណុំ មាននយ័ថា កាលអ្នកបដិបត្តិធម៌ បានកំណត់ដឹងរូបយ៉ាងណា

ទីមួយ តាមដែលសម្ដែងទុកក្នុងរូប ៧ ប្រការហើយ តមកទើប
កំណត់ដឹងសតិ ដែលតាមដឹងនោះថា "កំណត់ហ្ន៎" "ដឹងហ្ន៎"
ហើយឃើញច្បាស់ថា មិនទៀង ជាទុក្ខ និងមិនមែនជាតួខ្លួន ។

**២/ យមកន័យ** គឺ ការកំណត់ដឹង ដោយន័យជាគូ មាន
ន័យថា អ្នកដែលកំណត់ដឹងរូបយ៉ាងណាទីមួយ ហើយបាន
កំណត់ដឹងចិត្ត ដែលកំណត់ដឹងរូបដូចពោលមកនេះ ហើយទើប
ឃើញច្បាស់ថា មិនទៀង ជាទុក្ខ និងមិនមែនជាតួខ្លួន ឈ្មោះ
ថា កំណត់ដឹងរូបជាគូ ។

សេចក្ដីផ្សេងគ្នារវាង **កលាបន័យ** និង **យមកន័យ** គឺ
**កលាបន័យ** ប្រាថ្នាកំណត់ភាពរួម របស់នាមធម៌ ដោយមិន
វែចញែកយ៉ាងច្បាស់លាស់ថា ជាចិត្ត សតិ បញ្ញា សមាធិ
វិរិយ ផស្សៈ វេទនា សញ្ញា ចេតនា ។ល។ តែចំពោះ
**យមកន័យ** ប្រាថ្នាកំណត់ដឹងនាមធម៌ ដែលប្រាកដច្បាស់ជា
គោល ។

កាលបើពោលដល់ការកំណត់ដឹងចិត្តក្នុងពួកនាមសត្តកៈ
នេះ ជាការសម្ដែងចិត្តដែលជាប្រធាន ដូច្នោះ អ្នកបដិបត្តិធម៌

ទើបគួរកំណត់ដឹងចេតសិក ដែលកើតរួមជាមួយនិងចិត្ត គឺ ផស្សៈ វេទនា សញ្ញា ចេតនា សតិ បញ្ញា សមាធិ និងវិរិយ ជាដើម ទៀតផង ដូចគម្ពីរមហាដីកាពោលថា :

**ចិត្តសីសេន ហិ និទ្ទេសោ ។**

" ពិតមែនហើយ ការសម្តែងដោយមានចិត្តជាប្រធាន រមែងមាន " ។

**៣/ ខណិកន័យ** គឺ ការកំណត់ដឹង ការប្រព្រឹត្តទៅតាមខណៈចិត្ត មានន័យថា កាលបើកំណត់ដឹងរូបធម៌ហើយ ឲ្យកំណត់ដឹងចិត្តដួងដំបូងៗ និងចិត្តដួងបន្តបន្ទាប់មក ៤ ខណៈចិត្តគឺ :-

- កំណត់ដឹងចិត្តដួងទី ១ ដោយចិត្តដួងទី ២
- កំណត់ដឹងចិត្តដួងទី ២ ដោយចិត្តដួងទី ៣
- កំណត់ដឹងចិត្តដួងទី ៣ ដោយចិត្តដួងទី ៤
- កំណត់ដឹងចិត្តដួងទី ៤ ដោយចិត្តដួងទី ៥

បន្ទាប់ពីនោះ ទើបយល់ថា សព្វចិត្តដួងទី ១-៤ ក៏មិនទៀង ជាទុក្ខ និងមិនមែនជាខ្លួន ។

ការកំណត់ដឹងចិត្តដួងដំបូងៗ តាមលំដាប់យ៉ាងនេះ រហូតគ្រប់ ៤ ខណៈចិត្ត ធ្វើឲ្យយល់ថា ចិត្តតាំងនៅត្រឹមតែមួយខណៈចិត្តប៉ុណ្ណោះ ទើបមានសភាពមិនទៀងជាដើម ។

**៤. បដិបាដិន័យ** គឺការកំណត់ដឹងន័យ ដែលប្រព្រឹត្តទៅតាមលំដាប់ មានន័យថា កាលកំណត់ដឹងរូបធម៌ហើយ ឲ្យកំណត់ដឹងចិត្តដួងដំបូងៗ ដោយចិត្តដួងបន្តបន្ទាប់មក ១០ ខណៈចិត្ត គឺ :-

- កំណត់ដឹងចិត្តដួងទី ១ ដោយចិត្តដួងទី ២
- កំណត់ដឹងចិត្តដួងទី ២ ដោយចិត្តដួងទី ៣
- កំណត់ដឹងចិត្តដួងទី ៣ ដោយចិត្តដួងទី ៤
- កំណត់ដឹងចិត្តដួងទី ៤ ដោយចិត្តដួងទី ៥
- កំណត់ដឹងចិត្តដួងទី ៥ ដោយចិត្តដួងទី ៦
- កំណត់ដឹងចិត្តដួងទី ៦ ដោយចិត្តដួងទី ៧
- កំណត់ដឹងចិត្តដួងទី ៧ ដោយចិត្តដួងទី ៨
- កំណត់ដឹងចិត្តដួងទី ៨ ដោយចិត្តដួងទី ៩

៦កំណត់ដឹងចិត្តដួងទី ៩ ដោយចិត្តដួងទី ១០

៦កំណត់ដឹងចិត្តដួងទី ១០ ដោយចិត្តដួងទី ១១

បន្ទាប់ពីនោះទើបយល់ថា សូម្បីចិត្តដួងទី១-១០ ក៏មិនទៀង ជាទុក្ខ និងមិនមែនជាតួខ្លួន ។ ការកំណត់ដឹងចិត្ត ដួងជំបូង១ តាមលំដាប់យ៉ាងនេះ រហូតគ្រប់ ១០ ខណៈចិត្ត ធ្វើឲ្យយល់ថា ចិត្តតាំងនៅត្រឹមតែមួយខណៈចិត្តប៉ុណ្ណោះ ទើបមានសភាពមិនទៀងជាដើម ដូចគម្ពីរវិសុទ្ធិមគ្គពោលថា :-

[១] ឯវំ វិបស្សនាបដិបាដិយា សកលម្បិ ទិវសភាគំ សម្មសិតុំ វដ្ដេយ្យ ។ [២] យាវ ទសមចិត្តសម្មសនា បន រូបកម្មដ្ឋានម្បិ អរូបកម្មដ្ឋានម្បិ បគុណំ ហោតិ, តស្មា ទសមេយេវ ឋបេតព្វន្តិ វុត្តំ ។

“១អ្នកបដិបត្តិធម៌ អាចកំណត់ដឹងតាមលំដាប់វិបស្សនាបានរហូតមួយថ្ងៃ ។

២. ប៉ុន្តែខ្ញុំ[ មហាស៊ីយ្យាដ័រ ] ណែនាំថា គួរបញ្ឈប់ទុកក្នុងចិត្តដួងទី ១០ ព្រោះការកំណត់ដឹងរូប និងការកំណត់នាម

រមែងរហ័សរហួន រហូតដល់ការពិចារណាចិត្តដួងទី ១០” ។

សេចក្ដីនេះមានន័យថា សូម្បីបុគ្គលអាចកំណត់ដឹងចិត្តដួងទី ១០ ជាដើម ដោយចិត្តដួងទី ១១ និងដួងតៗ ទៅទៀតបានជារៀងរាល់ថ្ងៃ ក៏មិនគួរកំណត់ដឹងចិត្តតែម្យ៉ាង តែគួរត្រឡប់កំណត់ដឹងរូប កាលកំណត់ចិត្តដួងទី ១០ ដែលកំណត់រូបដូច្នេះ ជាដើម ។

ក្រោយពីការពិចារណាទាំងអស់ ដែលបានពោលទុកក្នុងរឿងសម្មសនញាណនេះ មានបំណងប្រាថ្នា ដើម្បីឲ្យប្រៀបធៀបជាមួយនឹងវិបស្សនាញាណ ដែលប្រាកដក្នុងខណៈចំរើនសតិរឭកដឹងតាមន័យ ដែលពោលទុកក្នុងបរិច្ឆេទទី ៥ មិនបានមានបំណងឲ្យជាផ្លូវនៃការបដិបត្តិទេ ។ ដូច្នោះអ្នកបដិបត្តិធម៌ ទើបគួរខ្វល់ខ្វាយថា ត្រូវកំណត់ដឹងឲ្យស្រេបជាមួយគ្នានឹងន័យ ដែលសម្ដែងរូប ៧ យ៉ាង ឬន័យដែលសម្ដែងនាម ៧ យ៉ាង ព្រោះសេចក្ដីខ្វល់ខ្វាយ នឹងធ្វើឲ្យអ្នកចាប់ផ្ដើមបដិបត្តិធម៌ កើតការប្រឫកប្របល់ថា ត្រូវធ្វើបដិបត្តិ ឬទេហ្ន៎...? អាចបណ្ដាលឲ្យ

ការចំរើនសតិមិនតជាប់គ្នា និងជាហេតុឲ្យសមាធិ និងបញ្ញាមិនចាស់ក្លា ។ ចំណែកបុគ្គលអ្នកសម្រេចមគ្គផលហើយ អាចចូលផលសមាបត្តិបានយ៉ាងជំនាញ រមែងអាចកំណត់ដឹងវិបស្សនាចិត្ត ដែលកើតឡើងបានយ៉ាងបន្តបន្ទាប់ ។ សូម្បីនឹងត្រឹមតែច្រើនគ្រា ក៏ឃើញបានយ៉ាងជាក់ច្បាស់ បុគ្គលដូចពោលមក អាចនឹងសាកល្បង កំណត់ដឹងចិត្តតាមលំដាប់យ៉ាងនេះ តែមនុស្សទូទៅដែលនៅមិនទាន់បានសម្រេចមគ្គផល មិនគួរព្យាយាមកំណត់ដឹងចិត្តតាមលំដាប់នោះទេ ។

ពិតមែនហើយ ការកំណត់ដឹងនូវវិបស្សនាចិត្តដួងដំបូងៗដោយចិត្តដួងក្រោយ តាមលំដាប់នេះ មិនសាកសមជាមួយនឹងការបដិបត្តិធម៌ទេ ព្រោះចិត្តពោលមកនេះ រមែងមិនប្រាកដច្បាស់ធ្វើឲ្យអ្នកបដិបត្តិត្រូវសោយអារម្មណ៍ថ្មី ដើម្បីឲ្យកំណត់ដឹងបានច្បាស់លាស់ ការធ្វើដូច្នេះ ញុំាងផលឲ្យការបដិបត្តិមិនឈានទៅមុខតាមសមគួរ ដូច្នោះ ទើបគួរកំណត់ដឹងនូវចិត្តដែលនឹងប្រាកដច្បាស់ ។ ដូចគម្ពីរវិសុទ្ធិមគ្គពោលដល់ការស្វែងរកអារម្មណ៍ថ្មី

ក្នុងចិត្តដែលមិនប្រាកដច្បាស់ថា :-

**តថា សតិ កម្មដ្ឋានំ នវំ នវំ ឯវ សិយា ។**

"កាលបើដូច្នោះ កម្មដ្ឋានក៏ត្រូវមានអារម្មណ៍ថ្មីរឿយៗ ដោយពិត" ។

ម្យ៉ាងទៀតក្នុងព្រះបាលី និងអដ្ឋកថា ដែលពោលក្នុងរឿងញាណ ជួបសេចក្តីដែលសម្តែងដល់ការកំណត់ដឹងរូប និងនាមផ្លាស់ប្តូរគ្នាទៅ ការកំណត់ដឹងរូប និងនាមផ្លាស់ប្តូរគ្នាទៅដោយមិនបានកំណត់ដឹងយ៉ាងបន្តបន្ទាប់ ទើបជាផ្លូវក្នុងការសម្រេចនូវមគ្គផលយ៉ាងពិតប្រាកដ ។

**៥. ទិដ្ឋិឧគ្ឃាដនន័យ** គឺ ន័យការកំណត់ដឹងដោយការបេញនូវទិដ្ឋិ ។ អធិប្បាយបានថា អ្នកដែលនៅគិតថាជាសត្វបុគ្គល តួខ្លួន ថាយើងកំពុងតែកំណត់ដឹង ឬការកំណត់ដឹងថាជាការងាររបស់យើង នៅមិនទាន់អាចដកចេញនូវការឃើញខុសថា មានតួខ្លួនបានទេ សូម្បីអ្នកបដិបត្តិធម៌ នឹងដកចេញនូវទិដ្ឋិបាន ដោយទិដ្ឋិវិសុទ្ធិ និងកង្ខាវិតរណាវិសុទ្ធិ ក៏អាចកើត

ល្អិតបានក្នុងខណៈខ្លះ ព្រោះនៅមិនទាន់បានកំចាត់បង់នូវទិដ្ឋិ ដោយមគ្គញ្ញាណ ដូចគម្ពីរបរមត្ថមញ្ជូសាមហាដីកាពោលថាៈ-

**[១]កាមញ្ចាយំ ទិដ្ឋិវិសុទ្ធិកង្ខាវិតរណវិសុទ្ធិសមធិគមេន វិសុទ្ធិទិដ្ឋិកោ ។ [២] មគ្គេន បន អសមគ្ឃាដិតត្តា អនោឡារិកា ច ទិដ្ឋិយា វសេនេវ វុត្តំ ។**

“១. បដិបត្តិធម៌ ដែលសម្រេចសម្មសនញ្ញាណនេះ ជាអ្នកមានទិដ្ឋិផូរផង់ ដោយការសម្រេចទិដ្ឋិវិសុទ្ធិ និងកង្ខាវិតរណវិសុទ្ធិទិដ្ឋិ ។

២. តែលោកពោលទុកយ៉ាងនោះ ជាការជាប់ទាក់ទង ដោយទិដ្ឋិល្អិត ព្រោះនៅមិនទាន់បានកំចាត់បង់នូវទិដ្ឋិ ដោយមគ្គញ្ញាណទេ” ។

សេចក្តីខាងដើមចង្អុលឲ្យឃើញថា អ្នកដែលសម្រេចនូវសម្មសនញ្ញាណ ហើយនៅមានទិដ្ឋិ និងវិចិកិច្ឆាយ៉ាងល្អិតសុខុម ។

អ្នកដែលឃើញច្បាស់ក្នុងខណៈកំណត់ដឹងទាន់បច្ចុប្បន្នថា សង្ខារដែលមិនមែនជាខ្លួនយើង ទើបជាអ្នកដកចេញនូវ

ទិដ្ឋិបានយ៉ាងពិតប្រាកដ ការឃើញច្បាស់ក្នុងលក្ខណៈនេះ ជា **អនត្តានុបស្សនា** ដែលមានកម្លាំងចាស់ក្លាហើយ ដូចសេចក្តីពោលថា :-

**៦រំ សង្ខារេ អនត្តតោ បស្សន្តស្ស ទិដ្ឋិសមុគ្ឃាដនំ នាម ហោតិ ។**

"ការឃើញរបស់អ្នក ដែលប្រចក្សច្បាស់នូវសង្ខារថា មិនមែនតួខ្លួន យ៉ាងនេះ ឈ្មោះថា ការដកចេញនូវទិដ្ឋិ" ។

**[១] យទា អនត្តានុបស្សនា តិក្ខា សូរា វិសទា បវត្តតិ ។ [២] តតោ ទ្វេបិ តទនុគតិកា ។ [៣] តទានេន ទិដ្ឋិឧគ្ឃាដនំ កតំ ហោតិ ។**

"១/ កាលណា ការឃើញច្បាស់ថា មិនមែនតួខ្លួន មានកម្លាំងចាស់ក្លាផូរផង់ ។

២/ ការឃើញច្បាស់ទាំងពីរយ៉ាង ថាមិនទៀង ជាទុក្ខ ជាសភាវៈដែលស្របតាមការឃើញច្បាស់នោះ គឺឃើញប្រចក្ស

ដោយភាវៈជាអនត្តា និងអនុមានដឹងនូវការមិនទៀង ជាទុក្ខ ។

៣/ កាលនោះ ទើបហៅថា ជាអ្នកដកចេញនូវទិដ្ឋិ" ។

**៦. មានសមុគ្ឃាដននយ** គឺការកំណត់ដឹង ដោយការដក ចេញនូវមានះ ។ អធិប្បាយថា អ្នកដែលនៅគិតថា ខ្លួនយើង ល្អជាងអ្នកដទៃ កំណត់ដឹងបានល្អជាងអ្នកដទៃ នៅមិនទាន់ អាចដកចេញនូវមានះបាន តែអ្នកដែលឃើញច្បាស់ក្នុងខណៈ ដឹងទាន់បច្ចុប្បន្នថា សង្ខារមិនទៀងទេ ជាសភាវៈកំណត់ដឹងនូវ សង្ខារថាមិនទៀង ទើបជាអ្នកដក់ចេញនូវមានះយ៉ាងពិតប្រាកដ ការឃើញច្បាស់ក្នុងខណៈនេះ ជាអនិច្ចានុបស្សនា ដែលមាន កម្លាំងចាស់ក្លាហើយ ។ ដូចសេចក្តីពោលថា :-

**អនិច្ចតោ បស្សន្តស្ស មានសមុគ្ឃាដនំ នាម ហោតិ ។**

"ការឃើញរបស់អ្នកដែលប្រចក្សច្បាស់នូវសង្ខារថា មិន ទៀងយ៉ាងនេះ ឈ្មោះថា ការដក់ចេញនូវមានះបាន" ។

**[១]យទា អនិច្ចានុបស្សនា តិក្ខា សូរា វិសទា បវត្តតិ ។**

**[២] ឥតក ទេ្វបិ តេទនុគតិកា ។ [៣] តទានេន មានឧត្សាជនំ កតំ ហោតិ ។**

“១/ កាលណា ការឃើញច្បាស់ថា មិនមែនជាតួខ្លួន មានកម្លាំងចាស់ក្លាផូរផង់ ។

២/ ការឃើញច្បាស់ទាំងពីរយ៉ាង ជាទុក្ខ និងមិនមែនជាតួខ្លួន ជាសភាវៈដែលស្របតាម ការឃើញច្បាស់នោះ គឺឃើញប្រចក្សដោយសភាវៈជាអនិច្ចា និងអនុមានដឹងនូវសភាវៈជាទុក្ខ និងមិនមែនជាតួខ្លួន ។

៣/ កាលនោះ ទើបហៅថា ជាអ្នកដកចេញនូវមានះ” ។

**៧. និកន្តិបរិយាទាននយ័** គឺការកំណត់ដឹង ដោយសភាវៈអស់ទៅនៃសេចក្តីត្រេកអរពេញចិត្ត ក្នុងវិបស្សនាថា យើងកំណត់បានល្អ មានសតិរឭកដឹងតក្លាប់ល្អ រប់ថា នៅមិនទាន់អាចដកចេញនូវសេចក្តីត្រេកអរ ពេញចិត្តបាន តែអ្នកដែល

ឃើញច្បាស់ក្នុងខណៈដែលកំណត់ដឹង ទាន់បច្ចុប្បន្នថា សន្ទារដែលកើតឡើង ហើយរលត់ទៅវិញ ជាសភាវៈដែល

កំណត់ដឹងនូវសង្ខារដែលកើតឡើងរលត់ទៅ ទើបជាអ្នកដែលកំណត់ដឹង សេចក្តីត្រេកអរពេញចិត្តក្នុងវិបស្សនាបាន យ៉ាងពិតប្រាកដ ការឃើញច្បាស់ក្នុងខណៈនេះ ជាទុក្ខានុបស្សនា ដែលមានកម្លាំងចាស់ក្លាហើយ ។ ដូចសេចក្តីពោលថា :-

**ទុក្ខាតោ បស្សន្តស្ស និកន្តិសមុគ្ឃាតំ នាម ហោតិ ។**

“ការឃើញរបស់អ្នកដល់ប្រចក្សច្បាស់នូវសង្ខារ ថាជាទុក្ខយ៉ាងនេះ ឈ្មោះថា ការដកចេញនូវសេចក្តីត្រេកអរពេញចិត្តបាន” ។

**[១] យទា ទុក្ខានុបស្សនា តិក្ខា សូរា វិសទា បវត្តតិ ។**

**[២] ឥតរា ទ្វេបិ តទនុគតិកា ។ [៣] តទានេន និកន្តិឧគ្ឃាដនំ កតំ ហោតិ ។**

“១/ កាលណា ការឃើញច្បាស់ថាជាទុក្ខ មានកម្លាំងចាស់ក្លាផូរផង់ ។

២/ ការឃើញច្បាស់ទាំងពីរយ៉ាងថា មិនទៀង និងមិនមែនជាតួខ្លួន ជាសភាវៈដែលស្របតាមការឃើញច្បាស់នោះ

គឺ ការឃើញប្រចក្សដោយភាវៈជាអនិច្ចា និងអនុមានដឹងនូវសភាវៈមិនទៀង និងមិនមែនជាតួខ្លួន ។

៣/ កាលនោះ ទើបហៅថា ជាអ្នកដកចេញនូវសេចក្តីត្រេកអរពេញចិត្តចេញបាន" ។!១៧៩

# ញាណទី ៤

## ឧទយព្វយញ្ញាណ

យំ បុព្វេ តំ វិសោសេហិ បច្ឆា តេ មាហុ កិញ្ចនំ
មជ្ឈេ ចេ នោ គហេស្សសិ ឧបសន្តោ ចរិស្សសិ។

" កិលេសជាតណាកើតឡើង ( ព្រោះប្រារព្ធ ) សង្ខារជា អតីត អ្នកចូរធ្វើកិលេសនោះ ឲ្យរីងស្ងួតទៅ កិលេសគ្រឿងកង្វល់ ( មានរាគៈជាដើមកើតឡើងព្រោះប្រារព្ធ ) សង្ខារដែលនឹងមានទៅខាងក្រោយ ចូរកុំមានដល់អ្នកឡើយ បើអ្នកមិនប្រកាន់ក្នុងធម៌ជាកណ្តាល ( មានរូបជាដើមដែលជាបច្ចុប្បន្ន ) អ្នកនឹងទៅជាបុគ្គលស្ងប់" ។

# ញាណទី ៤
# និង
# មគ្គាមគ្គញាណទស្សនវិសុទ្ធិ

អ្នកដែលសម្រេចសម្មសនញាណ អាចឃើញច្បាស់នូវត្រៃលក្ខណ៍ របស់រូបនាមក្នុងបច្ចុប្បន្នដោយជាក់ច្បាស់ និងអនុមានដឹងត្រៃលក្ខណ៍របស់រូបនាមដទៃបានទៀតផង ដោយមិនបាច់បរិកម្មច្រើន ក្នុងលំដាប់នោះ វិបស្សនូបេក្ខា គឺការឃើញប្រេចក្សនូវត្រៃលក្ខណ៍ ហើយព្រងើយកន្តើយ ក្នុងការកើតឡើងនិងការរលត់ទៅខាងដើម និងទីបំផុត របស់រូបនាមក្នុងបច្ចុប្បន្នខណៈបាន វិបស្សនូបេក្ខាដូចពោលមកនេះ ឈ្មោះថា ឧទយព្វយញាណ គឺបញ្ញាឃើញប្រេចក្សនូវការកើតរលត់របស់រូបនាមបច្ចុប្បន្ន ។ គម្ពីរវិសុទ្ធិមគ្គ អធិប្បាយលក្ខណៈរបស់វិបស្សនូបេក្ខាថា :-

**[១] យា "យទត្ថិ យំ ភូតំ, តំ បជហតិ, ឧបេក្ខំ បដិលភតី"តិ ឯវមាគតា វិចិនេន មជ្ឈត្តភូតា ឧបេក្ខា អយំ**

វិបស្សនូបេក្ខា នាម ។បេ។ [២] បញ្ញា ឯវ ហិ សា កិច្ចវសេន ទ្វិធា ភិន្នា ។ [៣] យថា ហិ បុរិសស្ស សាយំ គេហំ បវិដ្ឋំ សប្បំ អជបទទណ្ឌំ គហេត្វា បរិយេសមានស្ស តំ ថុសកោដ្ឋកេ និបន្នំ ទិស្វា " សប្បោ នុ ខោ, នោ"តិ អវលោកេន្តស្ស សោវត្ថិកត្តយំ ទិស្វា និព្វេមតិកស្ស "សប្បោ ន សប្បោ"តិ វិចិននេ មជ្ឈត្តតា ហោតិ ។ [៤] ឯវមេវ យា អារទ្ធវិបស្សកស្ស វិបស្សនាញាណេន លក្ខណត្តយំ ទិដ្ឋេ សង្ខារានំ អនិច្ចភាវាទិវិចិននេ មជ្ឈត្តតា ឧប្បជ្ជតិ, [៥] អយំ វិបស្សនូបេក្ខា ។

"១.ឧបេក្ខា គឺសេចក្តីជាកណ្តាលនៃការពិចារណា ដែលប្រាកដយ៉ាងនេះថា "ខន្ធ ៥ ណា មានទៅ ដោយបរមត្ថ ប្រាកដនៅតាមហេតុបច្ច័យ អ្នកបដិបត្តិធម៌ រមែងលះបង់នូវខន្ធ ៥ នោះ រមែងជាឧបេក្ខា" ឧបេក្ខានោះឯង ឈ្មោះថា វិបស្សនូបេក្ខា ។ល។

២.ឧបេក្ខាទាំងពីរនោះ គឺវិបស្សនូបេក្ខា និងសង្ខារុបេក្ខា ជាបញ្ញាដូចគ្នា តែផ្សេងគ្នាដោយនាទី ដែលចែកជាពីរយ៉ាង ។

៣.ប្រៀបដូចជាបុរស អ្នកកាន់ឈើច្រត់ក្រចកពពែ ហើយស្វែងរកពស់ដែលវារចូលទៅក្នុងផ្ទះ ពេលល្ងាចជួបពស់ នោះសម្ងំនៅក្នុងបាវអង្កាម ត្រិះរិះថា តើនេះជាពស់ ឬមិនមែនហ្ន៎? គ្រាឃើញច្បាស់ពស់នោះហើយ ក៏អស់នូវសេចក្តីសង្ស័យ ក្រោយពីនោះ រមែងកើតការព្រងើយកន្តើយក្នុងការពិចារណាថា នេះជាពស់ ឬមិនមែនពស់ យ៉ាងណា ។

៤. កាលព្រះវិបស្សនា ឃើញច្បាស់នូវលក្ខណៈទាំង ៣ ថាជាអនិច្ចំ ទុក្ខំ និងអនត្តា ដោយវិបស្សនាញាណ ការព្រងើយកន្តើយក្នុងការពិចារណា ការមិនទៀងជាដើម របស់សង្ខារ រមែងកើតឡើង ដូច្នេះ ។

៥.ការព្រងើយកន្តើយនេះ ឈ្មោះថា វិបស្សនូបេក្ខា" ។

ក្នុងពេលខាងដើមនៃការបដិបត្តិ រមែងមិនអាចឃើញច្បាស់បានថា រូបនាមបច្ចុប្បន្ន មិនទៀង ជាទុក្ខ និងមិនមែនជាតួខ្លួន ទើបកើតសេចក្តីត្រេកអរពេញចិត្ត ក្នុងខន្ធថា ទៀង ជាសុខ និងជារបស់ខ្លួន តែកាលបើវិបស្សនាញាណមានកម្លាំង

ចាស់ក្លាក្នុងលំដាប់សម្មសនញ្ញាណហើយ គេរមែងឃើញច្បាស់នូវរូបនាមបច្ចុប្បន្ននោះថា នៅក្នុងបញ្ញត្តិរបស់ត្រៃលក្ខណ៍បានដោយមិនលំបាក ក្នុងខណៈនោះសេចក្តីត្រេកអរពេញចិត្តនូវខន្ធថា របស់ទៀង ជាសុខ និងជាជាតួខ្លួន រមែងអន្តរធានបាត់ទៅ បន្ទាប់ពីនោះ គេរមែងឃើញច្បាស់នូវការកើតរលត់យ៉ាងឆាប់រហ័សរបស់រូបនាម ព្រមដោយសេចក្តីជាទុក្ខ និងមិនមែនជាតួខ្លួន ការឃើញច្បាស់នូវត្រៃលក្ខណ៍លំដាប់របស់ឧទយព្វយញ្ញាណ នេះជាការលះបង់នូវសេចក្តីត្រេកអរពេញចិត្តក្នុងខន្ធថា ទៀងជាដើម និងនៅជាការបន្សាត់សាត់បង់នូវខន្ធទៀតផង ទើបចាត់ជាឧបេក្ខាមួយ៉ាង ដែលមានឈ្មោះថាវិបស្សនូបេក្ខា តាមលំដាប់ញ្ញាណ ជាការរាប់បញ្ចូលក្នុងឧទយព្វយញ្ញាណ ដែលជាបញ្ញាដឹងច្បាស់នូវការកើតរលត់រូបនាមបច្ចុប្បន្ន ដែលកើតឡើងយ៉ាងលឿនរហ័ស ដូចជាការផុសឡើងហើយរលត់ទៅ បែកធ្លាយទៅក្លាម ឬដូចជា អណ្តាតភ្លើង ដែលរលត់ទៅមួយរំពេច ដូចក្នុគម្ពីរបដិសម្ភិទាមគ្គ ពោលថា :-

បច្ចុប្បន្នានំ ធម្មានំ វិបរិណាមានុបស្សនេ បញ្ញា ឧទយព្វយានុបស្សនេ ញាណំ ។

“បញ្ញា ក្នុងការឃើញច្បាស់នូវការប្រែប្រួលរបស់សង្ខារៈធម៌បច្ចុប្បន្ន ឈ្មោះថា បញ្ញាឃើញការកើតរលត់” ។

[១] ជាតំ រូបំ បច្ចុប្បន្នំ ។ [២] តស្ស និព្វត្តិលក្ខណំ ឧទយោ ។ [៣] វិបរិណាមលក្ខណំ វយោ ។ [៤]អនុបស្សនាញាណំ ។

“១. រូបដែលកំពុងតែកើតឡើង ឈ្មោះថា រូបបច្ចុប្បន្ន ។

២.លក្ខណៈកើតឡើងរបស់រូបបច្ចុប្បន្ននោះ ឈ្មោះថាជាការកើតឡើង ។

៣. លក្ខណៈនៃការប្រែប្រួល ឈ្មោះថា ការរលត់ទៅ ។

៤.ការកើតឡើង និងការរលត់ទៅ ឈ្មោះថា ឧទយព្វយញាណ” ។

☞ក្នុងគម្ពីរបរមត្ថមញ្ជូសាមហាដីកា អធិប្បាយសេចក្តី

នេះថា:-

សន្តតិបច្ចុប្បន្នេ ខណបច្ចុប្បន្នេ វា ធម្មេ ឧទយព្វយ-ទស្សនាភិនិវេសោ កាតព្វោ, ន អតីតនាគតេបិ វុត្តំ បច្ចុប្បន្នានំ ធម្មានន្តិ ។

"គប្បីធ្វើទុកក្នុងចិត្ត ចំពោះការឃើញនូវការកើតនិងរលត់ទៅរបស់ធម៌ដែលជាសន្តតិបច្ចុប្បន្ន ឬខណៈបច្ចុប្បន្ន មិនគប្បីធ្វើទុកក្នុងចិត្តនូវការឃើញច្បាស់ការកើតរលត់របស់សភាវធម៌នោះទេ ដែលជាអតីត ឬអនាគត ដូច្នោះ លោកទើបពោលថា "បច្ចុប្បន្នានំ ធម្មានំ" ( សភាវធម៌បច្ចុប្បន្ន ) ។

[១] ជាតន្តិ និព្វត្តំ បដិលទ្ធត្តភាវំ ។បេ។

[២] បច្ចុប្បន្នរូបំ នាម ជាតំ ខណត្តយបរិយាបន្នន្តិ អត្ថោ ។ [៣] តំ បន អាទិតោ ទុប្បរិគ្គហន្តិ សន្តតិបច្ចុប្បន្ន-វសេន វិបស្សនាភិនិវេសោ កាតព្វោ ។

"១. ពាក្យថា ជាតំ ប្រែថា រូបដែលកំពុងកើតឡើង មានន័យថា កំពុងតែប្រាកដសភាវៈរបស់ខ្លួន ។ល។

២.ឈ្មោះថា រូបបច្ចុប្បន្ន ជារូបដែលរាប់បញ្ចូលក្នុងខណៈទាំង ៣ ដែលកំពុងកើតឡើង ។

៣. តែបុគ្គលកំណត់ដឹងរូបនាម ដូចពោលមកនេះ រមែងមានខាងដើម ដូច្នោះ ទើបគួរធ្វើទុកក្នុងចិត្តចំពោះការឃើញនូវសន្តតិបច្ចុប្បន្ន" ។

សេចក្តីខាងដើមអធិប្បាយថា រូបដែលកំពុងកើតឡើងពិតក្នុងខណៈបច្ចុប្បន្ននោះ ជាបច្ចុប្បន្នដែលប្រកបដោយការកើតឡើង ( ឧប្បាទៈ ) ការតាំងនៅ ( ឋិតិ ) និងការរលត់ទៅ ( ភង្គៈ ) មិនមែនជាសន្តតិបច្ចុប្បន្ន គឺបច្ចុប្បន្នដែលជាប់បន្តពីអតីត ដែលទើបតែនឹងរលត់ទៅថ្មីៗ ឬអទ្ធាបច្ចុប្បន្ន គឺបច្ចុប្បន្នដោយរយៈកាល តែបុគ្គលអាចដឹងប្រចក្សនូវការកើតរលត់របស់រូបនាមដោយសន្តតិបច្ចុប្បន្ន ពេលចាប់ផ្តើមកើតឧទយព្វយ-ញាណ តែកាលញាណនេះ ចាស់ក្លាហើយ ទើបនឹងអាចដឹងប្រចក្សដោយបញ្ញានូវការកើតរលត់ក្នុងបច្ចុប្បន្នបាន ។

### ➪ខណៈបច្ចុប្បន្ន និងសន្តតិបច្ចុប្បន្ន

រូបដែលប្រាកដផ្លូវកាយ ក្នុងខណៈពោន-ផត អង្គុយ-ដើរ បត់-លាត ។ល។ ជារូបបច្ចុប្បន្ន ដែលកំពុងតែកើតឡើងពិតៗ ខណៈចាប់ផ្ដើមរបស់រូបពួកនេះ ឈ្មោះថា **ឧទយៈ** ( ការកើតឡើង ) ខណៈអស់ទៅឈ្មោះថា **វយៈ** ( ការរលត់ទៅ ) រួមពីរបទនេះ ជា**ឧទយព្វយៈ ឧទយព្វយញាណ** គឺការឃើញច្បាស់ខាងដើមនិងទីបំផុតរបស់រូបតែម្យ៉ាង មិនលាយឡំគ្នា ដោយការចាប់ផ្ដើមឃើញច្បាស់ ការកើតរលត់របស់រូប ដែលតភ្ជាប់ ជាសន្តតិបច្ចុប្បន្ន អ្នកដែលចាប់ផ្ដើមសម្រេចនូវឧទយព្វយញាណ រមែងឃើញច្បាស់នូវអាកប្បកិរិយាផ្លូវកាយនោះ ដែលផ្សេងគ្នាម្យ៉ាងម្នាក់ ដូចជា :-

- សភាវៈពោន ផ្សេងគ្នាពីសភាវៈផត ។
- សភាវៈផត ផ្សេងគ្នាពីសភាវៈ ពោន ។
- សភាវៈលាត ផ្សេងគ្នាពីសភាវៈបត់ ។
- សភាវៈបត់ ផ្សេងគ្នាពីសភាវៈលាត ។
- សភាវៈឈានជើងឆ្វេង ផ្សេងគ្នាពីសភាវៈឈានជើង

ស្តាំ ។

កាលបើញាណនេះ ចាស់ក្លាហើយ អ្នកបដិបត្តិរមែង ឃើញច្បាស់នូវការកើតរលត់យ៉ាងឆាប់រហ័សរបស់រូប ដែលជាខណៈបច្ចុប្បន្ន ដោយជាក់ច្បាស់ថា សភាវៈប៉ោង-ផត, អង្គុយដើរ, លាត-បត់, កម្រើក ។ល។ កើតរលត់ឆាប់ ដូចជាពពុះទឹក ដែលកើតពីគ្រាប់ភ្លៀងធ្លាប់ចុះលើផ្ទៃទឹក ហើយបែកខ្ចាយទៅ សូម្បីក្នុងខណៈឃើញ និងបានឮជាដើម គេរមែងឃើញច្បាស់នូវការកើតយ៉ាងឆាប់រហ័ស របស់រូបដែលបានឃើញ សម្លេងដែលបានឮ ចក្ខុបសាទរូប ឬសោតបសាទរូបជាដើម ។ ក្នុងខណៈនោះ គេមិនអាចបរិកម្មឲ្យទាន់ការកើតរលត់ ដែលប្រាកដក្នុងបច្ចុប្បន្នខណៈបាន ទើបគួរដឹងទាន់សភាវៈកើតរលត់ដែលខ្លួនកំពុងតែជួបនោះឯង ។

ក្រៅពីនេះ ការឃើញច្បាស់នូវការកើតឡើង និងការរលត់ទៅរបស់វេទនាជាដើម ដោយសន្តតិបច្ចុប្បន្ន ឬបច្ចុប្បន្នខណៈ ចាត់ជាឧទយព្វយញាណ ដូចគ្នា ចែកបានជា :-

➥វេទនាបច្ចុប្បន្ន គឺការសោយអារម្មណ៍ ដែលប្រាកដក្នុងការឃើញ, បានឮ, ដឹងក្លិន, ដឹងរស, ប៉ះខ្ទប់សម្ផស្ស ឬទឹកគិតរឿងរ៉ាវផ្សេងៗ ។

➥សញ្ញាបច្ចុប្បន្ន គឺការចាំសម្គាល់ ដែលប្រាកដក្នុងខណៈនោះ ។

➥វិញ្ញាណបច្ចុប្បន្ន គឺការដឹងអារម្មណ៍ផ្លូវទ្វារ ៦ ដែលបានដល់ការឃើញជាដើម ។

➥ **សង្ខារបច្ចុប្បន្ន** គឺនាមធម៌ដែលក្រៅអំពីវេទនា សញ្ញា និងវិញ្ញាណ ( គឺ ចេតសិក ៥០ វៀរ វេទនា និងសញ្ញា ) ដែលជាការតាក់តែងដើម្បីធ្វើកិរិយាឃើញ និងបាន ឮជាដើម ដូចជា:

➥ **ផស្សៈ** ការប៉ះខ្ទប់រវាងចិត្តជាមួយនិងអារម្មណ៍ ដូចជាការចូលទៅរកអារម្មណ៍ ឬអារម្មណ៍ចូលមករកចិត្ត ។

➥ **ចេតនា** ការតាក់តែង ជាការជំរុញឲ្យចិត្តដឹងអារម្មណ៍ ដូចជាការរិលទៅរកអារម្មណ៍ ឬបញ្ជាការថា ចូរឃើញ ចូរឮ ជាដើម ។ល។

➢ **វិតក្កៈ** ការត្រិះរិះ គឺការបង្អោនចិត្តទៅកាន់អារម្មណ៍ ។

➢ **វិចារៈ** ការពិចារណា គឺការស្ទាបអង្អែលអារម្មណ៍ ។

➢ **បីតិ** ការឆ្អែតកាយ ឆ្អែតចិត្ត ។

➢ **បស្សទ្ធិ** សេចក្តីស្ងប់ ( កាយបស្សទ្ធិ ចិត្តបស្សទ្ធិ )។

➢ **សទ្ធា** សេចក្តីជឿមាំ ជ្រះថ្លា ក្នុងគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាដើម ។

➢ **សតិ** ការរឭកដឹងទាន់ ។

➢ **វីរិយ** សេចក្តីព្យាយាមក្នុងកុសលធម៌ ។

➢**សមាធិ** ការដំកល់ចិត្តមាំក្នុងអារម្មណ៍តែមួយ ឆ្ពោះទៅកុសលធម៌ ( ឯកគ្គតាចេតសិក ) ។

➢ **បញ្ញា** ការឃើញច្បាស់ ( បញ្ញិន្ទ្រិយចេតសិ ) ។

➢ **លោភៈ** សេចក្តីលោភ ។

➢ **ទោសៈ** សេចក្តីក្រោធ ។

➢**មោហៈ** សេចក្តីវង្វេង ដោយសម្គាល់ថា រូបនាមជារបស់ស្អាត ទៀង ជាសុខ និងជារបស់ខ្លួន...។

➥ **មានះ** ការប្រកាន់ខ្លួន ។

➥ **ឧទ្ធច្ចះ** សេចក្តីរវើរវាយ រាយមាយ ។

➥**ទិដ្ឋិ** ការឃើញខុស ដោយសម្គាល់ថា រូបនាមជារបស់ខ្លួន ។

➥**វិចិកិច្ឆា** សេចក្តីសង្ស័យមិនដាច់ស្រេច មានការសង្ស័យក្នុងគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាដើម ។

☞ដូចសេចក្តីក្នុងគម្ពីរវិសុទ្ធិមគ្គពោលថា :-

[១]ជាតា វេទនា បច្ចុប្បន្នា ។ [២] ជាតា សញ្ញា បច្ចុប្បន្នា ។ [៣] ជាតា សង្ខារា បច្ចុប្បន្នា ។ [៤] ជាតំ វិញ្ញាណំ បច្ចុប្បន្នំ ។បេ។ [៥] តស្ស និព្វត្តិលក្ខណំ ឧទយោ ។ [៦] វិបរិណាមលក្ខណំ វយោ ។ [៧] អនុបស្សនាញាណំ ។

“១.វេទនាដែលកំពុងកើតឡើងឈ្មោះថា វេទនាបច្ចុប្បន្ន ។

២.សញ្ញាដែលកំពុងកើតឡើង ឈ្មោះថាសញ្ញាបច្ចុប្បន្ន ។

៣.សង្ខារដែលកំពុងកើតឡើង ឈ្មោះថា សង្ខារបច្ចុប្បន្ន ។

៤. វិញ្ញាណដែលកំពុងកើតឡើង ឈ្មោះថា វិញ្ញាណ-បច្ចុប្បន្ន ។

៥. លក្ខណៈកើតឡើងរបស់វិញ្ញាណ ឈ្មោះថា ការកើតឡើង ។

៦. លក្ខណៈនៃការប្រែប្រួល ឈ្មោះថា ការរលត់ទៅ ។

៧. ការឃើញការកើតឡើង និងការរលត់ទៅ ឈ្មោះថា ឧទយព្វយញាណ" ។

**❦លក្ខណរបស់វេទនាជាដើមដោយសន្តតិបច្ចុប្បន្ន** ជាការឃើញប្រចក្សនូវការកើតរលត់របស់វេទនាជាដើម ដោយការបន្តគ្នាក្នុងមួយខណៈៗ ដូចជា :-

-សន្តតិបច្ចុប្បន្នរបស់វេទនា ប្រាកដក្នុងខណៈដែលសោយអារម្មណ៍ ថាជាទុក្ខ ឬសុខផ្សេងគ្នាដូច្នេះ គឺ :-

-ការសប្បាយផ្សេងគ្នាអំពីការនឿយហត់ ការក្តៅ ការឈឺចុកចាប់ ការស្ពឹកស្រពន់ ក្នុងខណៈដែលការសប្បាយកើតឡើង គតីនោះ ការនឿយហត់ៗលៗ រមែងបាត់ទៅ ។

-ការនឿយហត់ៗលៗ ផ្សេងគ្នាអំពីការសប្បាយក្នុងខណៈ

ដែលការនឿយហត់ ។ល។ ប្រាកដឡើង ការសប្បាយរមែង បាត់ទៅវិញភ្លាម ។

-សន្តតិបច្ចុប្បន្នរបស់សញ្ញា ប្រាកដក្នុងខណៈដែលចង ចាំនូវរូប ឬសម្លេងជាដើមយ៉ាងណាទីមួយ ។

-សន្តតិបច្ចុប្បន្នរបស់សង្ខារ ប្រាកដក្នុងខណៈដែលតាក់ តែងដើម្បីធ្វើនូវអាកប្បកិរិយាផ្សេងៗ ។

-សន្តតិបច្ចុប្បន្នរបស់វិញ្ញាណ ប្រាកដក្នុងខណៈដែល ឃើញរូប ឬបានឮសម្លេងជាដើម ។

➪**លក្ខណៈរបស់វេទនាជាដើមដែលជាខណៈបច្ចុប្បន្ន** ជា ការឃើញច្បាស់នូវកើតរលត់យ៉ាងលឿនរហ័ស របស់វេទនា ពួកនោះ ដូចជា សេចក្តីនឿយហត់កើតឡើង និងរលត់ទៅ ដែលជាសភាវៈគ្រាដំបូង គ្រាទី ២ និងគ្រាទី ៣ ជាដើម ប្រាកដយ៉ាងបន្តបន្ទាប់មិនលាយឡំគ្នា ដូចជាចំណុចតូចៗ ដែល កើតរលត់យ៉ាងឆាប់រហ័ស សូម្បីសញ្ញា។ល។ ដែលជាខណៈ បច្ចុប្បន្នក៏ដូចគ្នា ក្នុងខណៈនោះ អ្នកបដិបត្តិធម៌ មិនអាចបរិកម្ម

ឲ្យទាន់នូវការកើតរលត់ដែលកំពុង តែប្រាកដក្នុងខណៈបច្ចុប្បន្ន ខណៈនោះបានទេ ដូច្នោះទើបគួរជាអ្នក ដឹងទាន់សភាវបច្ចុប្បន្ន ដែលខ្លួនកំពុងតែជួបប៉ុណ្ណោះ ។

☞ក្នុងគម្ពីរបដិសម្ភិទាមគ្គ នៅបែកខន្ធ ៥ ជាទ្វារ ៦ អារម្មណ៍ ៦ វិញ្ញាណ ៦ ផស្សៈ ៦ និង វេទនា ៦ ជាដើម ដោយពិស្តារ មានពាក្យជាដើមថា : **ជាតំ ចក្ខុ បច្ចុប្បន្នំ** ( ចក្ខុបសាទដែលកំពុង តែកើតឡើង ឈ្មោះថា រូបបច្ចុប្បន្ន ) **ជាតំ សោតំ បច្ចុប្បន្នំ** ( សោតបសាទ ដែលកំពុងតែកើតឡើង ឈ្មោះថា រូបបច្ចុប្បន្ន ) ។ល។ ក្នុងទីនេះមិនបានពោលទុកទាំងអស់ទេ ដើម្បីកុំឲ្យលឿនហួសពេក ។

បុគ្គលដែលឃើញនូវការកើតរលត់របស់រូបនាម ដោយប្រចក្សក្នុងបច្ចុប្បន្ន តាមន័យដូចដែលពោលមកហើយនេះ រមែងយល់ចូលចិត្តថា រូបនាមដែលកើតឡើងយ៉ាងលឿនរហ័សនេះ កាលដែលមិនទាន់កើតឡើង ក៏មិនបានមកអំពីណាទេ កាលកើតឡើងហើយ ក៏មិនបានផ្លាស់មកអំពីណាដែរ ជាសភាវៈ

ដែលកើតឡើងតាមហេតុបច្ច័យ ហើយរលត់ទៅវិញត្រង់កន្លែងនោះឯង ទឹងឃើញច្បាស់ផ្សេងគ្នាពីពេលមុន ដែលយល់ខុសថា រូបទៀង ស្ថិតស្ថេរ មិនមានការរលត់ទៅ ដូចជា ដៃ ដែលបត់ចូលមក ហើយសម្គាល់ថាជា ដៃ របស់ខ្លួន ក្នុងខណៈមុននឹងបត់ និងខណៈបត់ចូលមកហើយ សូម្បីសភាវៈ ប៉ោង-ផត អង្គុយ លើក ឈាន ជាន់ និងសភាវៈជាដើម ក៏ដូចគ្នា ការឃើញច្បាស់នូវការកើតរលត់យ៉ាងឆាប់រហ័សនេះជា លក្ខណៈរបស់ឧទយព្វយញ្ញាណដែលចាស់ក្លា ។

**➩ការអនុមានដឹងលក្ខណៈកើត ២៥**

**និងលក្ខណៈរលត់ ២៥ ដោយហេតុបច្ច័យ...➪**

ក្រៅអំពីនោះ អ្នកដែលប្រារព្ធសេចក្តីព្យាយាម អាចអនុមានដឹងលក្ខណៈកើត ២៥ ( ការកើត ៥ គុណនិងខន្ធ ៥ ) និងការរលត់ ២៥ ( ការរលត់ ៥ គុណនិងខន្ធ ៥ ) របស់ខន្ធ ៥ ដោយហេតុបច្ច័យ ដូចសេចក្តីក្នុងគម្ពីរបដិសម្ភិទាមគ្គថា :-

[១] បញ្ចន្នំ ខន្ធានំ ឧទយំ បស្សន្តោ បញ្ចវីសតិ

លក្ខណានិ បស្សតិ ។ [២] វយំ បស្សន្តោ បញ្ចវីសតិ លក្ខណានិ បស្សតិ ។ [៣] ឧទយវយំ បស្សន្តោ លក្ខណានិ បស្សតិ ។

“១.អ្នកបដិបត្តិ រមែងឃើញច្បាស់នូវការកើតឡើងរបស់ខន្ធ ៥ រមែងឃើញច្បាស់លក្ខណៈ ២៥ ។

២. អ្នកឃើញការរលត់ទៅរបស់ខន្ធ ៥ រមែងឃើញច្បាស់ឃើញច្បាស់នូវលក្ខណៈ ២៥ ។

៣. អ្នកឃើញច្បាស់ការកើតឡើង និងការរលត់ទៅរបស់ខន្ធ ៥ រមែងឃើញច្បាស់នូវលក្ខណៈ ៥០” ។

[១] អវិជ្ជាសមុទយា រូបសមុទយោ បច្ចយសមុដ្ឋេន រូបក្ខន្ធស្ស ឧទយំ បស្សតិ។ តណ្ហាសមុទយា, កម្មសមុទយា, អាហារសមុទយា រូបសមុទយោតិ បច្ចយសមុដ្ឋេន រូបក្ខន្ធស្ស ឧទយំ បស្សតិ ។ [២] និព្វត្តិលក្ខណំ បស្សន្តោបិ រូបក្ខន្ធស្ស ឧទយំ បស្សតិ [៣] រូបក្ខន្ធស្ស ឧទយំ បស្សន្តោ ឥមានិ

បញ្ច លក្ខណានិ បស្សតិ ។

“១. អ្នកបដិបត្តិធម៌ រមែងច្បាស់នូវការកើតឡើង របស់រូបក្ខន្ធ ព្រោះជាសភាវៈដែលកើតអំពីហេតុបច្ច័យ រូបដែលកើតឡើង ព្រោះអវិជ្ជា តណ្ហា កម្ម និងអាហារ ។

២.សូម្បីអ្នកឃើញច្បាស់លក្ខណៈ ដែលកំពុងតែកើតឡើង ក៏ដឹងច្បាស់នូវការកើតឡើងរបស់រូបក្ខន្ធនោះ ។

៣.ឃើញច្បាស់នូវការកើតរបស់រូបក្ខន្ធ រមែងដឹងច្បាស់នូវលក្ខណៈទាំង ៥ ពួកនោះ” ។

☞ លក្ខណៈ៥ ប្រការ ដែលឃើញនូវការកើតឡើងរបស់រូបក្ខន្ធ ដោយបច្ច័យ គឺ :

➩១. រូបដែលកើតឡើង ព្រោះមានអវិជ្ជាក្នុងខណៈធ្វើកម្មកាលពីជាតិមុន ។

➩២. រូបកើតឡើង ព្រោះមានតណ្ហា ។

➩៣. រូបកើតឡើង ព្រោះមានកម្ម ។

៦៤. រូបកើតឡើង ព្រោះមានអាហារ ដែលបរិភោគក្នុង បច្ចុប្បន្ន ។

៦៥. ការកើតឡើងរបស់រូបបច្ចុប្បន្ន ដែលខនកំពុងតែ កំណត់ដឹង ។

[១] អវិជ្ជានិរោធា រូបនិរោធោតិ បច្ចយនិរោធដ្ឋេន រូបក្ខន្ធស្ស វយំ បស្សតិ ។ តណ្ហានិរោធា, កម្មនិរោធា, អាហារនិរោធា រូបនិរោធោតិ បច្ចយនិរោធដ្ឋេន រូបក្ខន្ធស្ស វយំ បស្សតិ ។ [២] វិបរិណាមលក្ខណំ បស្សន្តោបិ រូបក្ខន្ធស្ស វយំ បស្សតិ ។ [៣] រូបក្ខន្ធស្ស វយំ បស្សន្តោ ឥមានិ បញ្ច លក្ខណានិ បស្សតិ ។

"១. អ្នកបដិបត្តិធម៌ រមែងច្បាស់នូវការរលត់ទៅ របស់ រូបក្ខន្ធ ព្រោះជាសភាវៈរលត់ហេតុបច្ច័យ រូបដែលរលត់ទៅ ព្រោះរលត់អវិជ្ជា តណ្ហា កម្ម និងអាហារ ។

២. សូម្បីអ្នកឃើញច្បាស់លក្ខណៈ ដែលកំពុងតែរលត់ ក៏ដឹងច្បាស់នូវការរលត់របស់រូបក្ខន្ធនោះ ។

៣. ឃើញច្បាស់នូវការរលត់ទៅ របស់រូបក្ខន្ធ រមែងដឹងច្បាស់នូវលក្ខណៈទាំង ៥ ពួកនោះ" ។

☞លក្ខណៈ ៥ ប្រការ ដែលឃើញនូការរលត់ទៅ របស់ រូបក្ខន្ធ ដោយបច្ច័យ គឺ :-

➪១. រូបដែលរលត់ទៅ ព្រោះមិនមានអវិជ្ជា ដែលត្រូវលះបង់ដោយអរហត្តមគ្គ ( មគ្គទី ៤ )។

➪២. រូបរលត់ទៅ ព្រោះមិនមានតណ្ហា ។

➪៣. រូបរលត់ទៅ ព្រោះមិនមានកម្ម ។

➪៤. រូបរលត់ទៅ ព្រោះមិនមានអាហារ ដែលបរិភោគក្នុងបច្ចុប្បន្ន ។

➪៥. ការរលត់ទៅរបស់រូបបច្ចុប្បន្ន ដែលខ្ទួនកំពុងតែកំណត់ដឹង ។

ព្រះបរមសាស្តាទ្រង់នៅសម្តែងលក្ខណៈកើត ៥ និងលក្ខណៈរលត់ ៥ ប្រការទុកក្នុងនាមខន្ធ ៤ ដូចជាមួយរូបក្ខន្ធ

តែមាន ផ្សេងគ្នាក្នុងលក្ខណៈទី ៤ របស់វេទនាខន្ធ សញ្ញាខន្ធ និង សង្ខារក្ខន្ធផង **ផស្សសមុទយា** ( ព្រោះការកើតឡើងរបស់ផស្សៈ ) **ផស្សនិរោធា** ( ព្រោះការរលត់របស់ផស្សៈ ) និងលក្ខណៈទី ៤ របស់វិញ្ញាណក្ខន្ធផង **នាមរូបសមុទយោ** ( ព្រោះជាការកើតឡើងរបស់រូបនាម ) **នាមរូបនិរោធា** ( ព្រោះការរលត់ទៅរបស់រូបនាម ) ។

ដោយប្រការដូចដែលពោលមកនេះ ខន្ធមួយមានលក្ខណៈកើត ៥ មានលក្ខណៈរលត់ ៥ រួមជាលក្ខណៈ ១០ ដូច្នេះ ខន្ធ ៥ ទើបមានលក្ខណៈកើត ២៥ និងលក្ខណៈរលត់ ២៥ រួមជាលក្ខណៈ៥០ លក្ខណៈកើតជាការឧប្បត្តិឡើងនៃខន្ធ ៥ (ឧប្បាទ) លក្ខណៈរលត់ជាការបែកធ្លាយនៃខន្ធ ៥ ( ភង្គៈ ) ដែលកំពុងតែកំណាត់ដឹងនូវសភាវធម៌បច្ចុប្បន្ន រមែងជាការឃើញឃើញប្រចក្សនូវការកើតឡើង និងការរលត់ទៅ របស់ខន្ធដែលកំពុងតែកំណាត់ដឹង និងក្នុងខណៈខ្លះ អាចអនុមានដឹងលក្ខណៈដូចពោលរបស់ខន្ធដទៃៗ ក្នុងវាងនៃការបដិបត្តិធម៌ ។

ការអនុមានដឹងដូចពោលមកនេះ មិនមែនជាការឃើញដោយប្រចក្សទេ គឺត្រឹមតែជាការយល់ចូលចិត្តថា រូបនាមកំពុងតែកើតឡើងព្រោះមានអវិជ្ជាជាដើម និងកំពុងតែរលត់ទៅវិញព្រោះរលត់អវិជ្ជាហើយ ដូច្នេះជាដើម ដូចក្នុងគម្ពីរមហាដីកាវិសុទ្ធិមគ្គ ទីងមានពាក្យអធិប្បាយតាមលំដាប់ ដូច្នេះ :

**[១] ឯត្ថ ច កេចិ តាវ អាហុ "អរូបកម្មដ្ឋានំ ឧទយព្វ-ទស្សនំ អទ្ធាសន្តតិវសេនេវ, ន ខណវសេនា"តិ ។[២] តេសំ មតេន ខណតោ ឧទយព្វយទស្សនមេវ ន សិយា ។**

"១. ម្យ៉ាងទៀត ក្នុងរឿងនេះ លំដាប់ដំបូង អ្នកខ្លះពោលថា "ការឃើញច្បាស់នូវការកើតរលត់ទៅរបស់ខន្ធមានទៅបាន អាស្រ័យអទ្ធាបច្ចុប្បន្ន និងសន្តតិបច្ចុប្បន្ន មិនអាចមានបានដោយខណៈបច្ចុប្បន្នទេ" ។

២. ការឃើញច្បាស់នូវកាកើតរលត់ ដោយខណៈបច្ចុប្បន្ន មិនអាចមានបានដោយអាស្រ័យបុគ្គលពួកនោះទេ" ។

សេចក្តីថា "ការឃើញច្បាស់នូវការកើតរលត់ទៅរបស់

នាមខន្ធ មានទៅបានអាស្រ័យអទ្ធាបច្ចុប្បន្ន និងសន្តតិបច្ចុប្បន្ន តែមិនអាចមានទៅបានព្រោះខណៈបច្ចុប្បន្នទេ” មានន័យថា : នាមខន្ធដែលជាខណៈបច្ចុប្បន្ន ជាវិបស្សនាចិត្តុប្បាទបច្ចុប្បន្ន ទើបគួរដឹងដោយចិត្តុប្បាទតែម្យ៉ាងដូចគ្នា ជាវត្ថុដែលប្រព្រឹត្តទៅបាន ប្រៀបដូចជាការទម្លាយម្រាមដៃមួយ ឲ្យបែកចេញពីគ្នាបាន ដូច្នោះ ទើបមានអ្នកយល់ខុសថា អ្នកបដិបត្តិធម៌មិនអាចឃើញច្បាស់នូវការកើតរលត់របស់នាមខន្ធដោយបច្ចុប្បន្នបានទេ ។

សូម្បីការយល់ឃើញខាងដើម នឹងមានហេតុផល ដែលសមគួរ តែជំទាស់ជាមួយព្រះបាលី ដែលបញ្ជាក់ដល់ខណៈបច្ចុប្បន្នថា :

**និព្វត្តិលក្ខណំ បស្សន្តោបិ រូបក្ខន្ធស្ស ឧទយំ បស្សតិ ។**

“អ្នកឃើញច្បាស់លក្ខណៈកើតឡើង ក៏ដឹងការកើតរបស់រូបក្ខន្ធ” ។

**វិបរិណាមលក្ខណំ បស្សន្តោបិ រូបក្ខន្ធស្ស វយំ បស្សតិ ។**

“អ្នកឃើញច្បាស់លក្ខណៈរលត់ទៅ ក៏ដឹងការរលត់របស់រូបក្ខន្ធ” ។

**តស្សេ ធម្មា វិទិតា ឧប្បជ្ជតិ ។ វិទតា ឧបដ្ឋហន្តិ ។ វិទិតា អព្ភត្ថំ គច្ឆន្តិ ។**

“ធម៌ពួកនោះ កំពុងតែប្រាកដដល់គេ រមែងកើតឡើង, កំពុងប្រាកដរមែងតាំងនៅ, កំពុងប្រាកដរមែងរលត់ទៅ” ។

[ ពាក្យថា **បស្សន្តោ** ( កំពុងឃើញច្បាស់ ) សម្រេចមកពី **ទិស**ធាតុ ( បេក្ខនេ=ឃើញ )+**អ**បច្ច័យ+**អន្ត**បច្ច័យ ជាពាក្យសម្ដែងបច្ចុប្បន្នកាល ដោយលក្ខណៈបច្ចុប្បន្ន ព្រោះអន្តបច្ច័យក្នុងពាក្យនេះចុះក្នុងបច្ចុប្បន្នកាល ដោយសូត្រក្នុងគម្ពីរវេយ្យាករណ៍កច្ចាយនៈ ( សូត្រ ៥៦៥ ) ថា **វត្តមានេ មានន្តា** ( កាលប្រាកដក្នុងបច្ចុប្បន្នកាល ចុះ **មាន** និង **អន្ត** បច្ច័យ ) ។

ពាក្យថា **វិទិតា** ( កំពុងប្រាកដ ) សម្រេចរូបមកពី **វិទ**ធាតុ ( ភាវេ = មាន, ប្រាកដ )+**ត**បច្ច័យក្នុងបច្ចុប្បន្នកាល ដោយសូត្រក្នុងវេយ្យាករណ៍កច្ចាយនៈ ( សូត្រ ៥៥៧ ) ថា **ពុទ្ធគមាទិត្ថេ កត្តរិ** ( កាលអត្ថរបស់ពុធធាតុ និងគមធាតុ ជា ដើមប្រាកដឲ្យចុះ

តបច្ច័យក្នុងកត្តុសាធនៈ )] ។

ក្នុងគម្ពីរអដ្ឋកថា អធិប្បាយរឿងនេះ “ ខណៈកើតឡើង តាំងនៅ និងរលត់ទៅ របស់នាមធម៌ ដែលទើបតែនឹង កើតឡើង ហើយរលត់ទៅ រមែងប្រាកដដល់អ្នកបដិបត្តិធម៌ ដូចជាការដែល កំពុងតែកើតឡើង តាំងនៅ និងរលត់ទៅ ដូច្នោះ ទើបត្រាស់ថា **វិទិតា ឧប្បជ្ជន្តិ** ( កំពុងប្រាកដរមែងកើតឡើង ) ជាដើម” មតិដូចពោលនេះ ទើបជំទាស់ជាមួយព្រះបាលី និងពាក្យ អធិប្បាយក្នុងគម្ពីរអដ្ឋកថា ថែមទាំងមិនស្របគ្នាជាមួយការ ស្គាល់ជំនាញរបស់អ្នកបដិបត្តិធម៌តាមព្រះ ដីកាចារ្យបានសម្តែង ជំទាស់ទុកថា :

[១] អបរេ បនាហុ “បច្ចយតោ ឧទយព្វយទស្សនេ អតីតាទិវិភាគំ អនាមសិត្វា សព្វសាធារណតោ អវិជ្ជាទិបច្ចយា វេទនានំ សម្ភវំ សម្ភមានតំ បស្សតិ, ន ឧប្បាទំ ។ អវិជ្ជា ទិអភាវេ ច តេសំ សម្ភវំ អលព្ភមានតំ បស្សតិ, ន ភង្គំ ។ ភង្គញ្ច បញ្ចវីសតិ”តិ [២] តំ យុត្តំ ។ [៣] សន្តតិវសេន ហិ

រូបារូបធម្មេ ឧទយតោ វយតោ ច មនសិការោន្តស្ស អនុក្កមេន ភាវនាយ ពលប្បត្តកាលេ ញាណស្ស តិក្ខវិសទភាវប្បត្តិយា ខណតោ ឧទយព្វយា ឧបដ្ឋហន្តីតិ ។

“១. អាចារ្យដទៃពោលថា “ឃើញនូវការកើតរលត់ដោយហេតុបច្ច័យ អ្នកបដិបត្តិធម៌រមែងឃើញច្បាស់ថា វេទនាជាដើមនេះ កំពុងប្រាកដ ព្រោះអវិជ្ជា ជាសាធារណៈទូទៅក្នុងកាលទាំងអស់ ដែលចែកជាអតីតជាដើម មិនមែនជាការឃើញប្រចក្សនូវការកើតឡើងទេ និងមិនមែនឃើញថា វេទនាជាដើមនោះមិនមានប្រាកដ ព្រោះមិនមានអវិជ្ជាជាដើម មិនមែននូវការកើតរលត់ ប៉ុន្តែជាការឃើញច្បាស់នូវការកើតរលត់ក្នុងខណៈបច្ចុប្បន្ន រមែងយល់ឃើញច្បាស់នូវការកើតរលត់រូបនាមបច្ចុប្បន្នប៉ុណ្ណោះ” ។

២. ការយល់ឃើញនោះសមគួរ ។

៣. ព្រោះកាលគេកំណត់ដឹងរូបនាមបច្ចុប្បន្ន និងនាមធម៌ថា កើតឡើង និងរលត់ទៅ ដោយភាពជាសន្តតិបច្ចុប្បន្ន ការកើត

រលត់ រមែងប្រាកដដោយខណៈបច្ចុប្បន្ន ជាការបាក់ធ្លុះដល់ញាណចាស់ក្លារបស់វិបស្សនាញាណ ក្នុងកាលណាដែលភាវនាមានកម្លាំងច្រើនតាមលំដាប់" ។

សេចក្តីនេះមានន័យថា ការឃើញច្បាស់នូវការកើតរលត់ខន្ធ ៥ តាមហេតុបច្ច័យថា វេទនាកើតឡើងព្រោះមានអវិជ្ជា វេទនារលត់ទៅព្រោះមិនមានអវិជ្ជា នេះមិនមែនជាការឃើញដោយប្រចក្សនូវការកើតរលត់របស់នាមខន្ធក្នុងបច្ចុប្បន្នយ៉ាងពិតប្រាកដទេ គឺត្រឹមតែជាការអនុមានដឹងដោយ សាមញ្ញទូទៅមិនជំទាស់ជាមួយសេចក្តីដែលជាអតីត អនាគត ឬបច្ចុប្បន្នថាវេទនាកើតឡើងព្រោះមានអវិជ្ជា វេទនារលត់ទៅព្រោះមិនមានអវិជ្ជា ជាដើម តែឃើញច្បាស់នូវការកើតរលត់របស់នាមខន្ធបច្ចុប្បន្នប៉ុណ្ណោះ នោះទើបជាការឃើញដោយប្រចក្សយ៉ាងពិត ។

ការឃើញដែលព្រះដីកាចារ្យពោលដល់នោះ មានក្នុងគម្ពីរបដិសម្ភិទាមគ្គ ព្រះដីកាចារ្យបានជ្រើសរើសយកការ ឃើញនោះ

ហើយគាំទ្រនៅការឃើញរបស់អាចារ្យដទៃ ដែលបានទទួលការយល់ព្រមដោយទូទៅ ជាសមានធន្ទៈ ( សមានភាទៈ ) ។

អ្នកដែលឃើញនូវការកើតរលត់របស់រូបនាមបច្ចុប្បន្ន ដោយច្បាស់លាស់បានហើយ រមែងអនុមានដឹងរូបនាមដែលជាអតីត និងអនាគតបានថា ដូចជាមួយរូបនាមបច្ចុប្បន្ន ដែលខ្លួនឃើញច្បាស់ដោយន័យថា រូបនាមក្នុងអតីត កើតរលត់ដូចរូបនាមក្នុងបច្ចុប្បន្ន សូម្បីរូបនាមក្នុងអនាគត ក៏កើតរលត់ដូចជារូបនាមបច្ចុប្បន្នដែរ ដូច្នោះ ការឃើញច្បាស់នូវការកើតរលត់របស់រូបនាមបច្ចុប្បន្ន ទើបជាគោលសំខាន់ក្នុងរឿងនេះ ដូចគម្ពីរមហាដីការបស់វិសុទ្ធិមគ្គពោលថា :

**បឋមញ្ហិ បច្ចុប្បន្នធម្មានំ ឧទយព្វយំ ទិស្វា អថ អតីតានាគតេ នយំ នេតិ ។**

“ពិតមែនហើយ បុគ្គលឃើញច្បាស់នូវការកើតរលត់របស់សភាវធម៌បច្ចុប្បន្ន ហើយបន្ទាប់ពីនោះ ទើបនាំន័យទៅ គឺអនុមានដឹងដោយអមក្នុងសភាវធម៌ដែលជាអតីត និងអនាគត” ។

អ្នកប្រារព្ធសេចក្តីព្យាយាម អាចឃើញច្បាស់ការកើតរលត់យ៉ាងរហ័សរបស់រូបនាមក្នុងបច្ចុប្បន្នបាន ហើយរមែងយល់ថាសភាវធម៌ដែលមិនមាននៅពីមុន រមែងប្រាកដឡើងថ្មី សភាវធម៌ដែលប្រាកដហើយ រមែងរលត់សូន្យទៅ គេឃើញច្បាស់ដល់រូបនាម ដែលមកប្រាកដថ្មី ៗ ដែលតាំងនៅត្រឹមតែមួយខណៈ ហើយរលត់ទៅយ៉ាងឆាប់រហ័ស ដូចជាពពុះទឹកដែលកើតពីគ្រាប់ភ្លៀង ហើយធ្លាក់ចុះលើផ្ទៃទឹក រមែងបែកធ្លាយទៅយ៉ាងឆាប់រហ័ស ស្នាមឆូតមាននៅលើផ្ទៃទឹកមួយខណៈ ហើយទឹកក៏នាំចូលដូចដើម ផ្លេកបន្ទោរដែលភ្លឺចេញអំពីពពក ហើយបាត់ទៅយ៉ាងឆាប់រហ័ស ឬសម្លេងគ្រឿងយន្ត ដែលឮខ្លាំងហើយបាត់ទៅដោយឆាប់រហ័ស ។

គេឃើញសង្ខារទាំងនោះ ប្រាកដក្នុងញាណថា មិនមានខ្លឹមសារ ដូចជា មាសប្រាក់ ដែលអ្នកលេងល្បិចក្រឡែឡើង ឬ ការយល់សប្តិដែលគិតថាជារឿងពិត ឬរង្វង់មូលរបស់ភ្លើងដែលគ្រវីក្នុងពេលយប់ ឬនគរ ស្រុក ដែលត្រូវនិម្មិតឡើង ឬ

ក្រពេញទឹកជាដើម គេឈ្មោះថា បានសម្រេច តរុណវិបស្សនា គឺវិបស្សនាទន់ខ្ចី ដែលមានឈ្មោះថា ឧទយព្វយានុបស្សនា គឺបញ្ញាដែលឃើញច្បាស់នូវការកើតរលត់ និងបាន ឈ្មោះថា អារទ្ធវិបស្សកៈ ( អ្នកដែលផ្ដើមប្រារព្ធវិបស្សនា ) ព្រោះផ្ដើមបដិបត្តិវិបស្សនាភាវនា ដូចសេចក្ដីថា :

[១] ឯត្តាវតេន "ធម្មមេវ ឧបជ្ជតិ, ឧប្បន្នញ្ច វយំ ឧបេតី"តិ ឥមិនា អាការេន សមបញ្ញាសលក្ខណានិ បដិវិជ្ឈិត្វា ឋិតំ ឧទយព្វយានុបស្សនា នាម បឋមំ តរុណវិបស្សនាញាណំ អធិគតំ ហោតិ ។ [២] យស្សាធិគមនា អារទ្ធវិបស្សកោតិ សង្ខំ គច្ឆតិ ។

"១. ដោយការឃើញច្បាស់នូវការកើតរលត់ត្រឹមនេះ អ្នកបដិបត្តិ បានសម្រេចវិបស្សនាញាណទន់ខ្ចីជាលំដាប់ដំបូង ឈ្មោះថា ឧទយព្វយានុបស្សនា ដែលចាក់ធ្លុះរហូតលក្ខណៈ ៥០ យ៉ាង ដោយការឃើញប្រចក្សច្បាស់ថា សភាវធម៌ដែលរលត់ទៅរមែងកើតឡើង និងសភាវធម៌ដែលកើតឡើង ហើយរមែងដល់

នូវការរលត់ទៅ ។

២. ដែលជាហេតុឲ្យបុគ្គលរាប់បានថា ជាអ្នកចាប់ផ្ដើមប្រារព្ធនូវវិបស្សនា" ។

**[១] កាលបសម្មសនាទិវសេន បវត្តយំ សម្មសនំ ន និប្បរិយាយេន វិបស្សសមញ្ញំ លភតិ ។ [២] ឧទយព្វយានុបស្សនាទិវសេន បវត្តមេវ ភលតិ ។**

"១. ការពិចារណា ជាការប្រព្រឹត្តទៅ ដែលជាប់ទាក់ទងដោយការពិចារណា ដោយសភាពជាសេចក្ដីជាក្រុមជាដើម មិនមែនឈ្មោះថាជា វិបស្សនាដោយត្រង់ទេ ។

២. តែបញ្ញា ជាការប្រព្រឹត្តទៅ ដោយការឃើញច្បាស់នូវការកើតរលត់ជាដើមប៉ុណ្ណោះ ទើបមានឈ្មោះដូចដែលបានពោលមក" ។

# "វិបស្សនូបក្កិលេស"

កាលឧទយព្វយញាណយ៉ាងទន់ខ្ចី ផ្ដើមប្រាកដវិបស្សនូបក្កិលេស គឺវត្ថុដែលធ្វើឲ្យវិបស្សនាសៅហ្មង ១០ ប្រការ

រមែង កើតឡើង ដូចគម្ពីរវិសុទ្ធិមគ្គពោលដល់បុគ្គលអ្នកកើត ឬមិនកើត វិបស្សនូបក្កិលេសនេះថា :-

[១] វិបស្សនូបក្កិលេសា ហិ បដិវេធប្បត្តស្ស អរិយសាវកស្ស ចេវ វិប្បដិបន្នកស្ស ច និកន្តិកម្មដ្ឋានស្ស កុសីតបុគ្គលស្ស នុបជ្ជន្តិ ។

[២] សម្មាបដិបន្នកស្ស បន យុត្តប្បយុត្តស្ស អារទ្ធវិប ស្សកស្ស កុលបុត្តស្ស ឧប្បជ្ជន្តិយេវ ។

“១. ពិតមែនហើយ វិបស្សនូបក្កិលេស នឹងមិនកើតឡើងដល់ :

-អរិយសាវក អ្នកពន្លុះបដិវេធហើយ ( ព្រះនិព្វាន )

-អ្នកបដិបត្តិខុស

-អ្នកលះបង់កម្មដ្ឋាន

-អ្នកខ្ជិលច្រអូស

២. តែរមែងកើតឡើង ដល់កុលបុត្តអ្នកបដិបត្តិត្រូវ រមែងព្យាយាមមិនថោកថយ អ្នកដែលផ្តើមប្រារព្ធវិបស្សនាហើយ

ប៉ុណ្ណោះ” ។

[ក្នុងគម្ពីរដីកាវិសុទ្ធិមគ្គ អធិប្បាយបន្ថែមថា ត្រង់ពាក្យថា **អរិយសាវកស្ស** ( ព្រះអរិយសាវ័ក ) ជាសំនួនវោហារ ដែលមានបំណងដល់វត្ថុ ដែលហៅថា **ឧក្កដ្ឋន័យ** និងមានន័យថា អ្នកចំរើនវិបស្សនាយ៉ាងមានកម្លាំង ( ពលវវិបស្សក) ទៀតផង ព្រោះបុគ្គលពួកនោះ មិនមានជាវិបស្សនូបក្កិលេសដូច្នោះ អ្នកដែលពន្ធះវិបស្សនាញាណ និព្វិទាញាណជាដើមទៅ ទើបប្រាសចាកវិបស្សនូបក្កិលេសពួកនោះបាន] ។

☞ គប្បីជ្រាបវិបស្សនូបក្កិលេស តាមន័យដែលនៅក្នុងគម្ពីរបដិសម្ភិទា មគ្គពោលថា :

ឱភាសេ ចេវ ញាណេ ច បីតិយា ច វិកម្បតិ
ទស្សទ្ធិយា សុខេ ចេវ យេហិ ចិត្តំ បវេធតិ ។
អធិមោក្ខេ ច បគ្គហេ ឧបដ្ឋានេ ច កម្បតិ
ឧបេក្ខាវជ្ជនាយញ្ច ឧបេក្ខាយ និកន្តិយា ។

“ចិត្តរបស់អ្នកបដិបត្តិរមែងញាប់ញ័រ ព្រោះ :

➥១-ពន្លឺ ( ឱភាសៈ )

ៗ២-ញាណ ( ញាណ )

ៗ៣-បីតិ ( ការឆ្អែតកាយ និងឆ្អែតចិត្ត )

ៗ៤-បស្សទ្ធិ ( ការស្ងប់ )

ៗ៥-សុខៈ ( សេចក្ដីសុខ ដែលកើតអំពីសមាធិ )

ៗ៦-អធិមោក្ខៈ (ការជឿស៊ប់ )

ៗ៧-បគ្គហៈ ( សេចក្ដីព្យាយាម )

ៗ៨-ឧបដ្ឋានៈ ( សតិ )

ៗ៩-ឧបេក្ខា ( ឧបេក្ខាដែលកើតរួមជាមួយអាវជ្ជនុបេក្ខា ការពិចារណាដោយការរាវរកហើយព្រងើយៗ ) ។

ៗ១០-និកន្តិ ( ការពេញចិត្ត )" ។

វិបស្សនូបក្កិលេស គឺជាវត្ថុ ដែលធ្វើឲ្យវិបស្សនាអន់ថយ ចុះទៅ ព្រោះការបដិបត្តិធម៌ ដែលប្រចក្សច្បាស់នូវវត្ថុពួកនោះហើយ អាចសម្គាល់ខុសថា ពន្លឺជាដើម ថាជាព្រះនិព្វាន ហើយក៏ឈប់បដិបត្តិធម៌ ឬសូម្បីនឹងមិនសម្គាល់ខុសយ៉ាងនោះ ក៏អាចត្រេកអរពេញចិត្ត ហើយបណ្ដាលឲ្យបម្រើនសតិដាច់ចន្លោះ នឹងមិនមានឈាន

តែបើអ្នកបដិបត្តិធម៌យល់ថា ត្រឹមតែជាផ្លូវចូល ដូចជា ផ្លាកប្រាប់ផ្លូវ ហើយក៏កំណត់ដឹង តាមសេចក្តីពិត ពន្លឺ ក៏មិនអាចធ្វើឲ្យវិបស្សនាអន់ថយបានឡើយ] ។

## ១/ ពន្លឺ ( ឱភាសៈ )

ពន្លឺនេះអាច ប្រាសចាកដោយអំណាចកម្លាំងសមាធិ ឬវិបស្សនាញាណ ពោលគឺអ្នកដែលចម្រើន សមថភាវនា មានពុទ្ធានុស្សតិ ជាដើម ឬអ្នកបដិបត្តិវិបស្សនា ក្នុងលំដាប់វិបស្សនាញាណ ៣ ថ្នាក់ដំបូង ដែលនៅមិនទាន់អាចឃើញច្បាស់នូវការកើតរលត់យ៉ាងឆាប់រហ័សរបស់រូបនាមបាន អាចឃើញពន្លឺដោយអំណាចរបស់សមាធិ ដូចជារឿងរបស់អនាថបិណ្ឌិកសេដ្ឋីសូមលើកយកមកសម្តែងដូចតទៅនេះ :

ក្នុងសម័យពុទ្ធកាល អនាថបិណ្ឌិកសេដ្ឋីធ្វើដំណើរតាមផ្លូវបានស្នាក់នៅក្នុងផ្ទះរបស់សេដ្ឋី នាក្រុងរាជគ្រឹះ បានជ្រាបដំណឹងថា ព្រះពុទ្ធទ្រង់ឧប្បត្តិឡើងក្នុងលោក ទើបតាំងចិត្តថានឹងទៅក្នុងវេលាព្រឹក ហើយក៏ចូលដេកដោយនឹកដល់គុណព្រះពុទ្ធជាអារម្មណ៍ យប់នោះលោកភ្ញាក់កណ្តាលអាធ្រាត

ហួតដល់ទៅ ៣ ដង ទីងជួបពន្ទឹដែលកើតឡើង ដោយអំណាច
របស់សមាធិ ក្នុងការចំរើនព្រះពុទ្ធគុណ ក្នុងគ្រាដែលភ្ញាក់ជា
លើកចុងក្រោយ លោកគិតថា មេឃភ្លឺហើយ ទើបមិនសម្រាន
តទៅទៀត ទីងក្រោកអំពីដំណេក ដើម្បីទីងចេញទៅគាល់ព្រះ
សម្មាសម្ពុទ្ធ តាមលំដាប់ ក្នុងពេលដែលដើរដល់ព្រៃស្មសាន្ត
ខាងក្រៅក្រុង រវាងផ្លូវបានជួបសាកសព ហើយកើតការខ្លាច គិត
រវើរវាយ ធ្វើឲ្យពន្លឺបាត់ទៅ ព្រោះកម្លាំងសមាធិថយចុះ គ្រានោះ
លោកទើបគិតថា ទីងត្រឡប់ទៅផ្ទះវិញ ក្នុងខណៈនោះឯង ទេវតា
ដែលនៅរក្សាព្រៃស្មសាន្ត បានឲ្យកម្លាំងចិត្តដល់ជាគាថា ដូច្នេះថា

សតំ ហត្ថី សតំ អស្សា សតំ អស្សរថា
សតំ កញ្ញាសហស្សានិ អាមុត្តមណិកុណ្ឌលា
ឯកស្ស បទវីតិហារស្ស កាលំ នគ្ឃន្តិ សោឡសិ ។

“ដំរីរាប់រយសេះរាប់រយ និងរយមេសេះអស្សតរា
ពួករថទឹមសេះរយស្មើគ្នា ពាន់នាងកញ្ញាស្រស់ប៉ប្រិម ។
សឹងពាក់កណ្ឌលជាតិកែវមណី ថ្លៃថ្លាឥតអ្វីទីងប្រៀបផ្ទឹម

លុះយកមកផ្គុំបឲ្យត្រូវត្រឹម តម្រឹមទីផលជំហានវិញ ។ មិនស្មើសូម្បីមួយចំណិត ដែលអ្នកប្រាជ្ញចិតហើយចែកចេញ ចែកហើយចែកទៀតរាប់គិតកាញ់ ចម្រាញ់ដល់ដប់ប្រាំមួយជង ។ គង់ថ្លៃអស់នោះនៅតិចពិត មិនស្មើចំណិតតូចឡើងហោង ផលជំហានតូច-ធំកន្លង ព្រោះមានបំណងស្តាប់ទេសនា ។

កាលបានទទួលកម្លាំងចិត្តពីទេវតាហើយ លោកទើបនឹកថាមានមនុស្សដទៃនៅក្នុងបរិវេណនោះ មិនមែនត្រឹមតែម្នាក់ទេ ទើបរឭកដល់ព្រះពុទ្ធគុណធ្វើឲ្យពន្លឺប្រាកដឡើងទៀត ក្នុងកាលជាទីបំផុត លោកបានទៅដល់ទីប្រថាប់របស់ព្រះអង្គ ដោយសុវត្ថិភាព ។ រឿងពន្លឺកើតឡើង ហើយបាត់ទៅរហូតដល់ ៣ គ្រា ហើយក៏ត្រឡប់ប្រាកដឡើងទៀត ដោយអំណាចរបស់សមាធិដែលចំរើននូវព្រះគុណជាអារម្មណ៍ នេះមាននៅក្នុងព្រះអដ្ឋកថា របស់សំយុត្តនិកាយ ជាដើម ។

អ្នកដែលចំរើនវិបស្សនារហូតបានសម្រេចនូវនាមរូបប-រិច្ឆេទញាណចាស់ក្លាហើយ រមែងឃើញពន្លឺត្រឹមតែមួយប៉ប្រិច

ភ្នែកបានខ្លះ អ្នកដែលសម្រេចនូវបច្ចយបរិគ្គហញាណ អាចឃើញនូវពន្លឺផ្សេងៗដូចជាពណ៌ខៀវ ពណ៌ក្រហម ពណ៌ទឹកប្រាក់ ពណ៌លឿង ជាដើម និងអ្នកដែលសម្រេចសម្មសនញាណ អាចឃើញពន្លឺរឿយៗ ក្រៅពីនេះ នៅអាចឃើញនិម្មិត្តសណ្ឋានផ្សេងៗ ដូចជាព្រះពុទ្ធជាម្ចាស់ ព្រះអរហន្ត តាមសមគួរដល់សមាធិ ពន្លឺនិងរូបរាងសណ្ឋានទាំងនេះ និងប្រាកដដោយ អំណាចរបស់សមាធិ ក្នុងលំដាប់ញាណទាំង ៣ ថ្នាក់ខាងដើម សូម្បីក្នុងឧទយព្វយញាណ មានកម្លាំងតិច ក៏អាចជួបពន្លឺបានដោយអំណាចរបស់វិបស្សនា ។

និម្មិត្តដែលជាពន្លឺ ឬសណ្ឋាន ដែលជួបក្នុងលំដាប់ញាណផ្សេងៗ សេចក្ដីផ្សេងគ្នា ដូច្នេះ :

-នាមរូបបរិច្ឆេទញាណខាងដើម និងទីបំផុតរបស់និម្មិត្តមិនប្រាកដច្បាស់ ។

-បច្ចយបរិគ្គញាណខាងដើម របស់និម្មិត្តប្រាកដច្បាស់ តែទីបំផុតមិនប្រាកដច្បាស់ ដោយច្រើនអ្នកបដិបត្តិធម៌ រមែងតាម

កំណត់ដឹងនិមិត្តថ្មីជានិច្ច ធ្វើឲ្យនិមិត្តចាស់បាត់ទៅយ៉ាងរហ័ស ។

-សម្មសនញ្ញាណខាងដើម កណ្តាល និងទីបំផុត របស់និមិត្តប្រាកដច្បាស់ ដោយការកើតឡើង ហើយតាំងនៅត្រឹមតែមួយខណៈ ហើយទើបសន្សឹមៗ បាត់ទៅ ។

-ឧទយព្វយញ្ញាណ ការកើតរលត់យ៉ាងឆាប់រហ័ស របស់និមិត្តប្រាកដច្បាស់ អ្នកបដិបត្តិធម៌ត្រឹមតែកំណត់ដឹងមួយគ្រាក៏បាត់ភ្លាម ឬត្រឹមតែទទួលដឹង ដោយមិនបានបរិកម្មក៏បាត់ទៅវិញ មិនផ្លាស់ប្តូរទីកន្លែង ឬសន្សឹមៗ បាត់ទៅ កើតឡើងភ្លាម ហើយក៏រលត់ទៅក្នុងទីនោះ មួយរំពេច ដោយប្រាសចាកការតាំងនៅមួយខណៈ ។

ក្រោយពីនោះ ក្នុងញាណដំបូងទាំង ៣ លំដាប់ អាចដឹងបីតិដែលមានអារម្មណ៍ឆ្អែតចិត្ត បស្សទ្ធិ ដែលមានអារម្មណ៍ស្ងប់មនុស្សមួយរូបនៅក្នុងលោក សុខផ្លូវចិត្តដែលមិនធ្លាប់ជួបមកពីមុន និងសទ្ធាដែលជឿមាំជ្រះថ្លាយ៉ាងក្រៃលែង ដោយអំណាចរបស់សមាធិទៀតផង ។

អ្នកដែលអាចឃើញច្បាស់ ការកើតរលត់យ៉ាងឆាប់

របស់របស់រូបនាម អាចឃើញពន្លឺមួយខណៈ ឬឃើញអស់កាលយូរ មានច្រើន លក្ខណៈដូចជា

-ភ្លើងពិលតូចៗ ដែលមកបាំងមុខ ។

-ភ្លើងមុខរថយន្ត ដែលមកបាំងមុខ ។

-ដុំភ្លើងមូលៗ ខ្នាតប៉ុនបាត្រ ។

-ពន្លឺមូលៗ មូលដូចជាថាស ។

-ពន្លឺដែលបាំងពេញបន្ទប់ ឲ្យភ្លឺ ។

-ពន្លឺដូចជា ដួងព្រះច័ន្ទ ។

-ពន្លឺដូចជា ដួងព្រះអាទិត្យ ជាដើម ។!

ក្នុងខណៈខ្លះពន្លឺអាចប្រាកដច្បាស់ អស់កាលយូរ សូម្បីអ្នកបដិបត្តិធម៌ ទឹងកំណត់ដឹង ក៏មិនបាត់ទៅ ក្នុងខណៈខ្លះ អាចមានអារម្មណ៍ថាជាវត្ថុ ដែលជ្រៀបចេញមកពីរាងកាយ ចំហៀងខាងលើ ខាងក្រោម វត្ថុដែលនៅក្នុងស្នើរបស់ពន្លឺ សូម្បីក្នុងពេលកណ្តាលអាធ្រាត ក៏ប្រាកដដូចជាពេលថ្ងៃ ក្នុងពេលថ្ងៃក៏អាចជួបពន្លឺយ៉ាងជាក់ច្បាស់បាន ក្នុងខណៈខ្លះ ពន្លឺនេះអាចធ្វើឲ្យឃើញ

នូវវត្ថុ ដែលនៅឆ្ងាយពីក្រសែភ្នែក ឬវត្ថុដែលត្រូវបិទបាំងទុក មកប្រាកដច្បាស់នៅចំពោះមុខ ។

ការឃើញពន្លឺជាដើមនេះ មិនមែនជាការឃើញ ដោយសមញ្ញចក្ខុតាទេ តែជាការឃើញដូចទទួលដឹង ដោយមនោវិញ្ញាណចិត្ត ប្រៀបដូចជាការឃើញដោយទិព្វចក្ខុ ( ភ្នែកទិព្វ ) ដូចគម្ពីរមហាដីការបស់វិសុទ្ធិមគ្គពោលថា:

ការប៉ុនប្រសប់ដូច្នេះ ដូចជាការឃើញដោយភ្នែកប្រក្រតី ក្នុងឋានៈដែលឃើញបាន សូមអ្នកបដិបត្តិធម៌ ពិចារណារឿងនេះ ក្នុងខណៈត្រឹមតែបដិបត្តិរហូតកាលប្រាកដពន្លឺឡើង ក៏នឹងដឹងដោយខ្លួនឯង ។

អ្នកដែលប្រារព្ធសេចក្តីព្យាយាម កាលឃើញពន្លឺហើយ អាចសម្គាល់ថា ជាពន្លឺដែលកើតពីការសម្រេចមគ្គផល និងនិព្វាន ធ្វើឲ្យសម្គាល់ថា ពន្លឺគឺព្រះនិព្វាន ឬសូម្បីនឹងមិនបានសម្គាល់ថា ជាគុណធម៌ពិសេស ក៏អាចពេញចិត្តក្នុងពន្លឺធ្វើឲ្យការចំរើនសតិកំណត់ដឹងមិនតជាប់គ្នា ញ៉ាំងផលឲ្យរូបនាមមិនប្រាកដ

ច្បាស់ ដូចគ្រាមុន ពន្ទីទើបបានឈ្មោះថា វិបស្សនូបក្កិលេស ដែលធ្វើឲ្យវិបស្សនាអន់ថយ ពោលដោយត្រង់ហើយគឺ កិលេស ដែលបានដល់តណ្ហា ការពេញចិត្ត មានះ ការប្រកាន់ខ្លួន និង ទិដ្ឋិ ការឃើញខុស ។

## ២/ ញាណ

ញាណ គឺការឃើញច្បាស់រូបនាម ដែលកើតរលត់តាម ទ្វារទាំង ៣ ដូចជាការប្រើកាំបិតមុតកាត់នូវផ្លែត្រឡាច ឬហាន់ ប៉េងប៉ោះ ឲ្យដាច់ក្នុងមួយកាំបិត ញាណនេះ ជាបញ្ញាដែលច្បាស់ នូវលក្ខណៈរបស់រូបនាមយ៉ាងប្រចក្សបាន និងយល់ចូលចិត្តនូវ ត្រៃលក្ខណ៍ ( គឺការមិនទៀង ជាទុក្ខ និងមិនមែនជាតួខ្លួន ) របស់រូបនាមបានទៀតផង ដោយមិនបានពិចារណាត្រិះរិះ តាម ដែលធ្លាប់បានឮមកទេ តែជាការដឹងដោយជាក់ច្បាស់ពី លោកទស្សនៈ ខាងក្នុងកាយរបស់ខ្លួន ។

ញាណនេះ អាចធ្វើឲ្យអ្នកបដិបត្តិយល់ខុសថា ជាព្រះ និព្វាន ឬធ្វើឲ្យត្រេកអរពេញចិត្ត ( និកន្តិ ) ញ៉ាំងផលឲ្យការ ចំរើនសតិមិនតជាប់គ្នា និងរូបនាមមិនប្រាកដច្បាស់ ទើបបាត់

ជាវិបស្សនូបក្កិលេស តែបើពោលដោយត្រង់ហើយ គឺ កិលេស ៣ យ៉ាង ដូចដែលសម្ដែងមកហើយ សូម្បីវិបស្សនូបក្កិលេស ៧ ដែលនៅសល់ ក៏ដូចគ្នា ។

## ៣/ បីតិ

បីតិ គឺសេចក្ដីឆ្អែតចិត្ត ដែលប្រាកដក្នុងខណៈបដិបត្តិធម៌ បែកជា ៥ ប្រការគឺ :

១. **ខុទ្ទកាបីតិ** គឺបីតិ ដែលមានអារម្មណ៍ឆ្អែតចិត្ត ដោយមានរោមបះពេញសរីរៈរាងកាយ សាច់ស្បែកញ័រ ទឹកភ្នែកហូរ ឬមានអារម្មណ៍ស្រស់ថ្លា ស្រាលសប្បាយ ដែលប្រាកដមួយគ្រា ហើយបាត់ទៅ ។

**២. ខណិកាបីតិ** គឺបីតិមួយខណៈ ការឆ្អែតចិត្ត ដែលមានលក្ខណៈបះរោមច្រើនដងយ៉ាងបន្តបន្ទាប់ ដូចជាក្រសែនៃផ្លេកបន្ទោរ កើតឡើងច្រើនគ្រា ដូចសេចក្ដីថា :-

[១] យា បនេសា កថេន្តស្ស វា សុណន្តស្ស វា វាចេន្តស្ស វា អន្តស្ស ឧប្បជ្ជមានា ឧទគ្គភាវំ ជនេតិ ។ អស្សូនិ បវត្តេតិ ។ លោមហំសំ ខនេតិ ។ [២] សាយំ

សំសារវដ្ដស្ស អន្តំ កត្វា អរហត្តបរិយោសនា ហោតិ ។

[៣] តស្មា សព្វរតីនំ ឯវរូបា ធម្មរត្តិយេវ សេដ្ឋា ។

“១.បីតិដែលកើតឡើងខាងក្នុងដល់អ្នកសម្ដែងធម៌ អ្នកស្ដាប់ធម៌ ឬអ្នកបង្រៀនធម៌ រមែងញុំាងឲ្យកើតនូវការផ្អែតចិត្ត ញុំាងទឹកភ្នែកឲ្យហូរ បណ្ដាលឲ្យកើតការបះរោម ។

២. បីតិនោះធ្វើនូវទីបំផុតនៃសង្សារវដ្ដ ដែលមាននៅអរហត្តផល ជាទីបំផុត ជាទិសដៅ ។

៣.ដូច្នោះ សេចក្ដីត្រេកអរក្នុងធម៌ ទើបប្រសើជាងការត្រេកអរនូវអ្វីៗ ទាំងពួង ។

[១] ភន្តេ នាគសេន យោ ច មាតរិ មតាយ រោទតិ, យោ ច ធម្មបេមេន រោទតិ ។ [២] ឧភិន្នំ តេសំ រោទន្តានំ កស្ស អស្សុ ភេសជ្ជំ, កស្ស អស្សុ ន ភេសជ្ជន្តិ ។ [៣] ឯកស្ស ខោ មហារាជ អស្សុ រាគហោតិ សមលំ ឧណ្ហំ, ឯកស្ស បីតិសោមនស្សេន វិមលំ សីតលំ ។ [៤] យំ ខោ មហារាជ សីតលំ, តំ ភេសជ្ជំ ។ យំ ឧណ្ហំ, តំ ន ភេសជ្ជន្តិ ។

“១.បពិត្រព្រះនាគសេនដ៏ចំរើន អ្នកដែលស្រែកយំ ព្រោះមាតាអស់ជីវិត និងអ្នកដែលយំព្រោះបាមោជ្ជៈក្នុងធម៌ ។

២. បុគ្គលទាំងពីរដែលកំពុងយំនោះ ផ្សេងគ្នាយ៉ាងណា ទឹកភ្នែករបស់អ្នកណាជាថ្នាំ? ទឹកភ្នែករបស់អ្នកណាមិនមែនជាថ្នាំ? លោកម្ចាស់? ។

៣. មហាបពិត្រ..! ទឹកភ្នែករបស់អ្នកទីមួយ មិនស្អាត ក្តៅអន្ទះអន្ទែង ដោយរាគៈ និងទោសៈ ចំណែកទឹកភ្នែករបស់បុគ្គលម្នាក់ទៀត ប្រាសចាកមន្ទិល ត្រជាក់ស្អាត ។

៤. ទឹកភ្នែកដែលជាត្រជាក់ស្អាតជាថ្នាំ ទឹកភ្នែកដែលក្តៅអន្ទះអន្ទែងមិនមែនជាថ្នាំទេ” ។

៣/ **ឱក្កន្តិកាបីតិ** គឺបីតិដែលផ្អែតចិត្ត ប្រាកដដូចជាទឹករលក បក់ចូលទៅរកច្រាំង សមុទ្រកើតឡើងជាទឹកហូរហៀរលិចចុះក្នុងរាងកាយ ហើយក៏បាត់ទៅវិញ ។

៤/ **ឧព្វេង្គាបីតិ** គឺបីតិ ដែលញាំងកាយឲ្យអណ្តែតឡើង ក្នុងគម្ពីរព្រះអដ្ឋកថា បានលើកតួយ៉ាងដូចជាភិក្ខុមួយអង្គ និង

ស្ត្រីមួយរូប ក្នុងប្រទេសស្រីលង្កា បានកើតសេចក្ដីជ្រះថ្លា ដោយរឭកដល់ព្រះចេតិយ៍ ហើយក៏អណ្ដែតទៅកាន់ព្រះចេតិយ៍ ដោយអំណាចរបស់ឧព្វេង្គាបីតិ ក្នុងបច្ចុប្បន្នយើងនេះ ជួនកាលអ្នកខ្លះ ដឹងដល់រាងកាយចំណែកណាទីមួយ ដែលអណ្ដែតឡើង ឬដៃ ជើង ក្បាល កម្រើកទៅឯងៗ អ្នកខ្លះ អាចអណ្ដែតខ្លួនទៅលើផ្ទៃដី បានមួយហត្ថក្នុងខណៈអង្គុយចំរើនសមាធិ លក្ខណៈដូចពោលមកនេះ កើតឡើងពីឧព្វេង្គាបីតិ នោះឯង ។

**៥. ផរណាបីតិ** បីតិជ្រួតជ្រាប គឺការផ្អែតចិត្ត ដែលប្រាកដនូវភាពទ្រជាក់គ្របដណ្ដប់ចិត្តទុក ធ្វើឲ្យកើតការសប្បាយចិត្តពាសពេញរាងកាយ ដូចជាបាល់ទាត់ដែលប៉ោងខ្យល់ពេញ ក្នុងខណៈនោះ អ្នកបដិបត្តិធម៌ នឹងត្រូវការនៅស្ងៀមយ៉ាងបន្តបន្ទាប់ត្រឹមតែជាការត្រូវការសេពគប់របស់បីតិយ៉ាងស្ងប់ល្អិត រហូតទាំងមិនត្រូវការសូម្បីតែព្រិចភ្នែក ឬបើកភ្នែកមើលនូវវត្ថុរបស់របរខាងក្រៅ ។

❧បីតិទាំង ៥ ប្រភេទនេះ ចំរើនកពូនតាមលំដាប់ តាំងតែពីឧទយព្វយញាណ ជាដើមទៅហើយប្រាកដនូវ**ផរណាបីតិ**តែម្យ៉ាង

ក្នុងកាលដែលឧទយព្វយញ្ញាណចាស់ក្លាហើយ រឿងនេះ មាន ពោលទុកក្នុងគម្ពីរមហាដីកាវិសុទ្ធិមគ្គយ៉ាងពិស្ដារ ។

អ្នកដែលមានបីតិទាំង ៥ យ៉ាងចាស់ក្លា អាចមានអារម្មណ៍ ភ្លេចសតិទៅមួយខណៈ ដូចជាសុមេធតាបស អនាថបិណ្ឌិក សេដ្ឋី និងព្រះមហាកប្បិន មានអារម្មណ៍ថា ភ្លេចសតិ កាលបើ បានឮថា ព្រះពុទ្ធទ្រង់ឧប្បត្តិឡើងក្នុងលោក ( **ពុទ្ធោ ឧប្បន្នោ លោកេ** ) សូម្បីក្នុងខណៈដែលសម្រេចនូវវិបស្សនាញាណ លំដាប់ខ្ពស់តាំងអំពីភង្គញ្ញាណ ជាដើមទៅ ការភ្លេចសតិដោយ អំណាចរបស់បីតិ អាចប្រាកដបានខ្លះ ក្រោយពីនោះ ការ កំណត់ដឹងរបស់អ្នកបដិបត្តិធម៌ នឹងល្អដូចគ្រាដើម ឬល្អជាង គ្រាដើម បីតិ ដូចពោលមកនេះ ជាវត្ថុដែលមានកម្លាំង ដែល ប្រាកដ កាលដែលវិបស្សនាញាណចាស់ក្លាហើយ ការភ្លេច សតិក្នុងខណៈ បដិបត្តិធម៌ ក្រៅពីនេះ អាចប្រាកដ ដោយអំណាច របស់ធម៌ ដទៃ គឺ :

**-បស្សទ្ធិ** សេចក្ដីស្ងប់ ដោយមានអារម្មណ៍ថា ភ្លេច សតិទៅ កាលមានសេចក្ដីស្ងប់ប្រាកដច្បាស់ កាលមានសតិ

ត្រឡប់មកកំណត់ដឹងទៀត ក៏អាចកំណត់ដឹងបានល្អដូចជាគ្រាដើម ។

-**ឧបេក្ខា** សេចក្តីព្រងើយ គឺតត្រមជ្ឈត្តុបេក្ខា ដោយមានអារម្មណ៍ថា ភ្លេចសតិទៅ ការកំណត់បានស្រួល មិនត្រូវផ្តោតអារម្មណ៍ច្រើនពេកទេ កាលបើមានសតិត្រឡប់មកកំណត់ទៀត ក៏អាចកំណត់ដឹងបានល្អដូចជាគ្រាដើម ។

-**ថីនមិទ្ធ** ការងងុយងោកងក់ ដោយមានអារម្មណ៍ថា កំណត់បានស្រួល អារម្មណ៍បច្ចុប្បន្នសន្សឹមៗ បាត់ទៅហើយលក់ទៅមួយខណៈ កាលមានសតិត្រឡប់មកកំណត់ទៀត ក៏អាចកំណត់ដឹង ដូចជាគ្រាដើម ខណៈនេះ កើតអំពីវីរិយៈដែលផ្តោតអារម្មណ៍ មានកម្លាំងតិចជាងសមាធិ ញ៉ាំងផលឲ្យថីនមិទ្ធៈកើតឡើងគ្របសង្កត់ចិត្តបាន ។

## ៤/ បស្សទ្ធិ

បស្សទ្ធិ គឺសេចក្តីស្ងប់កាយ និងចិត្តដែលប្រាសចាកនូវសេចក្តីរវើរវាយរាយមាយ ព្រោះការផ្តោតអារម្មណ៍ដ៏ក្រៃលែង ដូចជាការចេញពីទីក្តៅកាន់ទៅទីត្រជាក់ ឬការបាត់ពីការហត់

ទៀយ អស់កម្លាំង មួយរំពេចនោះ ក្នុងខណៈដែលបស្សទ្ធិប្រាកដនេះ មានសភាវៈធម៌ខ្លះ កើតរួមគ្នា គឺ :

-**លហុតា** ការស្រាលរបស់កាយ និងចិត្ត ដែលអ្នកបដិបត្តិធម៌ រមែងដឹងអារម្មណ៍ថា រាងកាយស្រាលក្នុងពេលដើរ ជើងមានសភាពស្រាលដូចបាត់ទៅ សូម្បីក្នុងពេលអង្គុយដេក បត់ ។ល។ រាងកាយដៃជើង ក៏ស្រាលដូចបាត់ទៅ អ្នកខ្លះអាច មានអារម្មណ៍ថា កំរើកជើងទៅដោយរហ័ស និងអាចកើតចិត្ត ដែលត្រូវការទឹងរត់ឲ្យលឿនៗ តែមិនគួរធ្វើដូច្នោះទេព្រោះអាចធ្វើឲ្យសតិដាច់ចន្លោះ មិនតជាប់គ្នា ។

-**មុទុតា** សភាពទន់របស់កាយ និងចិត្ត ដោយប្រាសចាក់សភាពរឹង អាចតាំងចិត្តក្នុងអារម្មណ៍ ដែលត្រូវការទឹងកំណត់បានជាក់ច្បាស់ និងត្រូវការបដិបត្តិធម៌ ដោយសេចក្តីស្ងប់ មិនចង់ជួបជាមួយបុគ្គល ឬអារម្មណ៍គ្រោតគ្រាត ។

-**កម្មញ្ញតា** ជាការសមគួរដល់ការងារ របស់កាយ និងចិត្តដោយអំណាចការបដិបត្តិធម៌ បានយូរ មួយ ឬពីរម៉ោង ដោយការអង្គុយនៅផ្ទួនតែមួយ មិនផ្លាស់ប្តូរ និងប្រាសចាកការចុកចាប់

ក្នុងរាងកាយ ទាំងមិនមាននូវសេចក្ដីរវើរវាយ ឬដាច់សតិកំណត់ដឹង ។

-បាគុញ្ញតា សេចក្ដីរហ័សរហួនរបស់កាយ និងចិត្ត ដោយរាងកាយជាប្រក្រតីមិនស្ងួវអស់កម្លាំង ស្ងួមរៀនឹងបដិបត្តិធម៌អស់កាលយូរ និងចិត្តក៏កំណត់ដឹងបានឆាប់រហ័ស ដូចជាការស្វាធ្យាយព្រះធម៌ ដែលទន្ទេញចាំបានល្អ ។

-ឧជុកតា សេចក្ដីទៀងត្រង់របស់កាយ និងចិត្ត ដោយប្រាសចាកការជាប់ជំពាក់នូវវត្ថុ ដែលមិនល្អ សេចក្ដីត្រូវការនិងបាំងទោស ឬមាយា សាថេយ្យ ដែលក្លែងធ្វើជាមនុស្សល្អមានគុណធម៌ ។

បុគ្គលអ្នកដល់ព្រមដោយបស្សទ្ធិជាដើម ទាំង ៣ យ៉ាងនេះ រមែងយល់ថា ក្នុងខណៈឈរ ដើរ អង្គុយ បត់ លាត ឬចំរើនសតិរឭកដឹងទាន់បច្ចុប្បន្ន រមែងកំណត់ដឹងអារម្មណ៍បានយ៉ាងជាក់ច្បាស់ទៀតផង មានការសប្បាយកាយ និងចិត្ត និងរីករាយក្នុងការបដិបត្តធម៌យ៉ាងក្រៃលែង ។

កាយបស្សទ្ធិជាដើម មិនបានសំដៅដល់សេចក្ដីស្ងប់របស់

កងចេតសិក មានវេទនាខន្ធជាដើម តែម្យ៉ាងទេ តែនៅសំដៅដល់សេចក្តីស្ងប់របស់កាយទៀតផង ដូចគម្ពីរមហាដីការបស់វិសុទ្ធិមគ្គពោលថា :

[១] តត្ថ កាយគ្គហណេន រូបកាយស្សាបិ គហណំ វេទិតព្វំ, ន វេទនាទិក្ខន្ធត្តយស្សេវ [២] កាយបស្សទ្ធិអាទយោ ហិ រូបកាយស្សាបិ ទរថទិនិម្មទ្ទិកាតិ ។

"១. ក្នុងរឿងនេះ គប្បីជ្រាបការកាន់យករូបកាយផង កាយសត្វទៀតផង មិនបានកាន់យកខន្ធ ៣ មានវេទនាជាដើមទេ ។

២. ព្រោះកាយបស្សទ្ធិជាដើម កំចាត់ការក្តៅអន្ទះអន្ទែងជាដើមរបស់រូបកាយទៀតផង" ។

## ៥/ សុខៈ

សុខ គឺសេចក្តីសុខចិត្ត ដែលប្រកបដោយវិបស្សនា និងសេចក្តីសុខកាយ ដែលកើតឡើង ព្រោះសេចក្តីសុខចិត្ត ក្នុងគ្រាដែលសេចក្តីសុខនេះប្រាកដ រោគដែលធ្លាប់កើតឡើងអាចបាត់ទៅបាន ក្រៅពីនោះក្នុងខណៈខ្លះ អាចនឹកគិតពិចារណា ហើយមានអារម្មណ៍ជាសុខយ៉ាងក្រៃលែង រហូតទាំងចង់បរិយាយឲ្យ

អ្នកដទៃស្តាប់ទៀតផង ។

អ្នកដែលដល់ព្រមដោយសុខៈ បីតិ និងបស្សទ្ធិជាដើម នេះ រមែងបានទទួលសេចក្តីរីករាយចិត្ត ដ៏កំពូលជាងសេចក្តីរីករាយរបស់មនុស្ស និងទេវតាទាំងអស់ ដូចព្រះតម្រាស់ថា :

សុញ្ញាគារំ បវិដ្ឋស្ស សន្តចិត្តស្ស ភិក្ខុនោ
អមានុសី រតិ ហោតិ តស្មា ធម្មំ វិបស្សតោ ។

" ភិក្ខុទៅកាន់ទីស្ងាត់ មានចិត្តស្ងប់ ឃើញច្បាស់នូវព្រះធម៌ដោយប្រពៃ រមែងកើតសេចក្តីត្រេកអរ ដែលមិនមែនជារបស់មនុស្សទូទៅ " ។

យតោ យតោ សម្មសតិ ខន្ធានំ ឧទយព្វយំ
លភតេ បីតិបាមុជ្ជំ អមតំ តំ វិជានតំ ។

"កាលបើអ្នកឃើញច្បាស់នូវការកើតឡើង និងការរលត់ទៅនៃខន្ធហើយ រមែងបាននូវបីតិបាមោជ្ជៈ ដែលជាវត្ថុអមតៈ ដែលដឹងច្បាស់ទាំងឡាយ" ។

## ៦/ អធិមោក្ខៈ

អធិមោក្ខៈ គឺសេចក្តីជឿមាំ ជ្រះថ្លា ដែលប្រកបដោយ

វិបស្សនា ចិត្តដែលចំរើនសតិរឭកដឹងក្នុងបច្ចុប្បន្ន រមែងផូរផង់មិនសៅហ្មង ដោយកម្លាំងរបស់អធិមោក្ខ សូម្បីអ្នកបដិបត្តិធម៌ និងឈប់សម្រាក ការចំរើនសតិត្រឹមតែមួយខណៈ ក៏នៅតែងមានចិត្តផូរផង់ដូចគ្នា ការជឿមាំ ជ្រះថ្លា ក្នុងព្រះរតនត្រៃ កម្ម និងផលកម្ម រមែងប្រាកដច្បាស់យ៉ាងមានកម្លាំង ដោយអំណាចរបស់ពន្លឺញាណ និងអធិមោក្ខនេះ ញ៉ាំងផលឲ្យអ្នកចំរើនសតិប្បដ្ឋាន ត្រិះរិះដើម្បីនឹងបដិបត្តិធម៌តទៅ និងត្រិះរិះក្នុងការបបួលបុគ្គលដទៃផ្សេងទៀតផង ថែមទាំងកើតសេចក្ដីជ្រះថ្លា ចំពោះអ្នកបដិបត្តិធម៌ និងវិបស្សនាចារ្យដែរ ។

## ៧/ បគ្គហៈ

បគ្គហៈ គឺសេចក្ដីព្យាយាម ដែលប្រកបដោយវិបស្សនា ជាការព្យាយាមដ៏ស្មើមិនតឹង ឬធូរពេក ។ ការព្យាយាមដូចបានពោលមកនេះ ធ្វើឲ្យអ្នកបដិបត្តិធម៌ ចំរើនសតិរឭកដឹងយ៉ាងបន្តបន្ទាប់ជានិច្ច ដោយមិនបាច់ផ្ដោតអារម្មណ៍ច្រើនពេក ។

## ៨/ ឧបដ្ឋានៈ

ឧបដ្ឋានៈ គឺសតិដែលប្រកបដោយវិបស្សនា ជាសតិដែល

ប្រាកដច្បាស់ ដូចជារូបនាមក្នុងបច្ចុប្បន្នខណៈ ចូលមករកចិត្ត ឬចិត្តដែលកំណត់ចូលទៅរករូបនាម សតិដែលធ្វើឲ្យអារម្មណ៍ ប្រាកដច្បាស់នេះ ធ្វើឲ្យសភាវៈរូបនាម ដែលល្អិតសុខុម ក៏ជាវត្ថុដែលឃើញច្បាស់ដល់អ្នកបដិបត្តិធម៌ កាលបើសតិដែលកើតមុនរលត់ទៅហើយ សភាវធម៌បច្ចុប្បន្នក៏ប្រាកដមួយរំពេចនោះឯង អ្នកខ្លះ អាចគិតដល់រឿងដែលកន្លងមកហើយ ប្រៀបដូចត្រឡប់ពេលវេលា ទៅជួបជាមួយរឿងនោះយ៉ាងជាក់ច្បាស់ តែមិនគួរគិតពិចារណាទេ ។

[ អ្នកបដិបត្តិធម៌ខ្លះ អាចមានអារម្មណ៍ដែលកន្លងហើយក្នុងកាលជាអតីតយ៉ាងជាក់ច្បាស់ ប្រៀបដូចកំពុងតែប្រាកដក្នុងបច្ចុប្បន្ន ដូចក្នុងខណៈដែលខ្លួនមានអាយុ ២ ឬ ៣ ខួប អាចមានអារម្មណ៍ថា ខ្លួននៅលើទ្រូងរបស់ម៉ែ ស្រែកច្រៀងបំពេ ក្លិនសំពត់និងទឹកដោះរបស់ម៉ែ ដូច្នេះ ជាដើម] ។

## ៩/ ឧបេក្ខា

ឧបេក្ខា គឺវិបស្សនូបេក្ខា ដូចពោលមកហើយ ព្រមទាំងអាវជ្ជនុបេក្ខា ដែលកើតឡើងមុន មានន័យថា កាលចិត្តដូងណា

នីមួយ ដែលជាសភាវៈឃើញ បានឮ ឬកំណត់ដឹង ។ល។ មកប្រាកដ អាវជ្ជនចិត្ត គឺចិត្តដែលពិចារណាគិត រាវរក អារម្មណ៍ រមែងកើតឡើងមុនចិត្តដួងដទៃ បើចិត្តដួចពោលពិចារណាល្អ ចិត្តនេះក៏នឹងដំណើរការទៅល្អ បើចិត្តនោះពិចារណាមិនល្អ ចិត្តដួងក្រោយក៏នឹងមិនដំណើរការទៅល្អទេ ។ ខាងអ្នកបដិបត្តិធម៌បានតាំងចិត្តទុកមុនថា នឹងកំណត់ដឹងរូបនាមដែលកើតរលត់យ៉ាងឆាប់រហ័ស ទាំងបានឃើញច្បាស់នូវសភាវធម៌នោះ ច្រើនគ្រាមកហើយ ធ្វើឲ្យអាវជ្ជនចិត្តដែលពិចារណា ការកើតរលត់របស់រូបនាមប្រាកដឡើង លំដាប់វិបស្សនាជវនចិត្ត ដែលជាការពិចារណានូវការកើតរលត់រូបនាម យ៉ាងជាក់ច្បាស់ រមែងកើតឡើងជាបន្តមក ។

ទោះយ៉ាងក៏ដោយ ក្នុងគ្រាខាងដើមនៃការបដិបត្តិ កាលបើបញ្ញានៅមិនទាន់ចាស់ក្លា បុគ្គលអ្នកប្រារព្ធនូវសេចក្ដីព្យាយាម ត្រូវតាំងចិត្តពិចារណាឲ្យទាន់បច្ចុប្បន្ន ដូចជាការចងចិត្តស្វែងរកក្នុងខណៈខ្លះ អាចគិតវើវវាយដល់អតីត ឬអនាគតបានខ្លះ ធ្វើឲ្យចិត្តមិនអាចពិចារណាទាន់បច្ចុប្បន្នយ៉ាងជាក់ច្បាស់ ដោយ

អាវជ្ជនចិត្តបានទេ បន្ទាប់មកកាលឧទយព្វយញ្ញាណ មានកម្លាំងហើយ គេក៏អាចពិចារណានូវការកើតរលត់របស់រូបនាម បានច្បាស់លាស់បន្ទាប់ពីការកំណត់ដឹងដោយចិត្តដួងមុន អាវជ្ជនចិត្តរបស់អ្នកបដិបត្តធម៌ ប្រៀបជាការរត់ចូលទៅរកសភាវរូបនាមដោយខ្លួនឯង អាវជ្ជនចិត្តដែលពិចារណាយ៉ាងនេះ ឈ្មោះថា អាវជ្ជនុបេក្ខា ចំណែកវិបស្សនាញាណ ដែលឃើញច្បាស់នូវការកើតរលត់របស់រូបនាម យ៉ាងជាក់ច្បាស់មិនចាំត្រូវផ្តោតអារម្មណ៍ច្រើន ឈ្មោះថា វិបស្សនូបេក្ខា ។

ឧបេក្ខាទាំងពីរយ៉ាងដែលពិចារណា នឹងឃើញនូវការកើតរលត់របស់រូបនាមយ៉ាងរឿយៗ ដូច្នេះ ជាវិបស្សនូបក្កិលេសក្នុងគម្ពីរមហាដីរបស់វិសុទ្ធិមគ្គពោលថា ជាតត្រមជ្ឈត្តតា ( ការប្រព្រឹត្តទៅស្មើនៃចិត្ត និងចេតសិកក្នុងកម្មដែលល្អស្អាត ) ដោយត្រូវការទឹងចែកអត្ថធម៌ របស់ឧបេក្ខា ឲ្យផ្សេងគ្នាអំពីញាណ ចំណែកក្នុងអដ្ឋកថា របស់បដិសម្ភិទាមគ្គពោលដល់មតិខាងដើមថា នេះជាការឃើញរបស់អាចារ្យ ហើយផ្តល់មតិរបស់អ្នកតែងខ្លួនឯង ថាជាសមាធិ ។ ទោះបីយ៉ាងណាក៏

ដោយក្នុងគម្ពីរបដិសម្ភិទាមគ្គគណ្ឋីបទ ពោលថា“ សូម្បីតែជាវិបស្សនូបក្កិលេស នឹងជាញាណតាមដែលអធិប្បាយទុកក្នុងគម្ពីរវិសុទ្ធិមគ្គ ក៏មានលក្ខណៈ ផ្សេងគ្នាពីញាណ ព្រោះមាននាទីរៀយៗ ក្នុងការពិចារណានូវសង្ខារទើបមិនជំទាស់ជាមួយនឹងញាណ” ខ្ញុំយល់ឃើញជាមួយមតិក្នុងគម្ពីរខាងនេះ ទើបសម្ដែងថាញាណដូចគ្នា ។

## ១០/ និកន្តិ

និកន្តិ គឺសេចក្ដីត្រេកអរពេញចិត្ត ក្នុងវិបស្សនា ដែលកើតឡើងឃើញពន្លឺជាដើម សេចក្ដីត្រេកអរពេញចិត្ត ដូចពោលមកនេះ ជាសភាវៈល្អិតសុខុម ទើបធ្វើឲ្យសម្គាល់ខុសថា ជាការសប្បាយនៃភាវនា មិនមែនជាកិលេស អ្នកបដិបត្តិវិបស្សនាភាវនា អាចយល់ខុសថា សភាវៈដូចពោលមកនេះ ជាគុណធម៌វិសេស ឬកើតពីការសម្រេចគុណធម៌វិសេស សេចក្ដីត្រេកអរពេញចិត្តនេះ ជាវិបស្សនូបក្កិលេស យ៉ាងពិតប្រាដក ដូច្នេះវិបស្សនា ទើបថយចុះទៅដោយសេចក្ដីត្រេកអរពេញចិត្ត ទើបអ្នកបដិបត្តិធម៌ ប្រកាន់មាំនូវសេចក្ដីត្រេកអរពេញចិត្ត ដោយ

តណ្ហា មានៈ និងទិដ្ឋិ ក៏អាចធ្វើឲ្យវិបស្សនាថយចុះទៅរហ័សឡើង ។

វិបស្សនូបក្កិលេស កិលេសដែលពោលមកទាំងអស់នេះ ៩ យ៉ាងខាងដើម វៀរនិកន្តិ អាចប្រកដព្រមគ្នាបានក្នុងពេលតែមួយ ចំណែកនិកន្តិ នឹងមកប្រាកដបានម្តងមួយគ្រាៗ ទៅដូចជាសេចក្តីពេញចិត្តត្រេកអរក្នុងពន្លឺជាដើម លំដាប់របស់វិបស្សនូ-បក្កិលេសដែលសម្តែងទុកនេះ ទើបប្រព្រឹត្តដោយលំដាប់ទេសនា មិនមែនជាលំដាប់នៃការកើតឡើងរបស់សភាវធម៌ ដូចជាការពោលថា :

**[១] និភាបិ ហិ ឧបក្កិលេសា ឯកក្ខណេបិ ឧបជ្ជន្តិ ។ [២] បច្ចវេក្ខណា បន វិសុំ វិសុំ ហោតិ ។**

"១. ពិតមែនហើយ វិបស្សនូបក្កិលេស ៩ យ៉ាង រមែងកើតឡើង សូម្បីត្រឹមតែមួយខណៈ"

២. តែការពិចារណា រមែងមានបានម្តងមួយៗ" ។

[ អបិ សទ្ទ ក្នុងពាក្យថា នភាបិ ធ្វើនាទីរួបរួមនូវការកើតឡើងរបស់វិបស្សនូបក្កិលេសម្តងមួយៗ តាំងតែពី ៨ យ៉ាងជាដើម

ទៅ អបិ ស័ព្ទក្នុងពាក្យថា ឯកក្ខណេបិ ធ្វើនាទីរួមនូវការកើតឡើងរបស់វិបស្សនូបក្កិលេស ក្នុងខណៈផ្សេងគ្នា] ។

អ្នកដែលយល់ខុសថា ពន្លឺញាណ និងបីតិជាដើម មិនធ្លាប់ជួបមកពីនោះ ជាគុណធម៌វិសេស ឬកើតពីការសម្រេចនូវគុណធម៌ រមែងថយចុះទៅពីផ្លូវវិបស្សនា គឺការចំរើនសតិរឭកដឹងសភាវធម៌ គេរមែងនឹងមិនព្យាយាមបដិបត្តិ ដើម្បីសម្រេចនូវវិបស្សនាញាណថ្នាក់ខ្ពស់តទៅ ឬអាចពេញចិត្ត ប្រកាន់មាំនូវពន្លឺជាដើមដោយ មិនបានកំណត់ដឹងទាន់បច្ចុប្បន្ន ក្នុងខណៈនោះ គេកើតសេចក្តីប្រកាន់មាំ ( **គាហៈ** ) ដែលចែកបាន ៣ ប្រការគឺ :

១. **តណ្ហា** សេចក្តីត្រេកអរពេញចិត្ត ពន្លឺជាដើម ។

២. **មានះ** សេចក្តីប្រកាន់ខ្លួនថា ល្អជាងអ្នកដទៃ ។

៣. **ទិដ្ឋិ** ការយល់ខុសថា ពន្លឺជាយើង ឬរបស់យើង ។

កាលរួមវិបស្សនូបក្កិលេស ១០ យ៉ាងជាមួយនឹងការប្រកាន់មាំទាំង ៣ ក្នុងមួយៗ មាន ៣០ យ៉ាង បើរាប់នូវសេចក្តីប្រកាន់មាំ ក្នុងវិបស្សនូបក្កិលេសទាំងនោះ ដោយរួបរួមជាការ

ប្រកាន់មាំតែម្យ៉ាង ដោយមិនចែកជាប្រការដទៃ ក្នុងវិបស្សនូប-ក្កិលេសនោះ មានត្រឹមតែ ១០ យ៉ាង ដូចជាក្នុងគម្ពីរវិសុទ្ធិមគ្គពោលថា :

**[១] ឯត្ថ ច ឱភាសាទយោ ឧបក្កិលេសវត្ថុតាយ ឧបក្កិ-លេសាតិ វុត្តា, ន អកុសលត្តា ។ [២] និកន្តិ បន ឧបក្កិលេសោ ចេវ ឧបក្កិលេសវត្ថុ ច ។ [៣] វត្ថុវសេនេវ ចេតេ ទស ។ [៤] គាហវសេន បន សមត្តឹស ហោន្តីតិ ។**

"១. ម្យ៉ាងទៀត ក្នុងឧបក្កិលេស ១០ ពួកនេះ ពន្លឺជាដើម ពោលថា ជាឧបក្កិលេស ព្រោះជាទីតាំងរបស់ឧបក្កិលេស មិនមែនព្រោះអកុសលទេ ។

២. ចំណែកនិកន្តិ ជាឧបក្កិលេស និងជាទីតាំងរបស់ឧបក្កិ-លេស ។

៣. ប៉ុន្តែ ឧបក្កិលេស ១០ យ៉ាងនេះ មានទៅបាន ដោយអាស្រ័យវត្ថុ ។

៤. ចំណែកឯ ការប្រកាន់មាន ៣០ គត់ " ។

សេចក្តីខាងដើម មានន័យថា វិបស្សនូបក្កិលេស ៩ យ៉ាង

ជាដើម មានពន្លឺជាដើម ដែលជាទីតាំងរបស់ឧបក្កិលេសនេះ ទើងជាឧបក្កិលេសបាន ដែលបន្ទាប់ពីការប្រកាន់ដោយតណ្ហា មានះ និងទិដ្ឋិ បើមិនប្រកាន់ដោយអកុសលដូចពោលមកនេះ ក៏មិនបាត់ជាឧបក្កិលេស ដូច្នោះ ពោជ្ឈង្គៈ មានសតិសម្ពោជ្ឈង្គជាដើម ដែលប្រាកដច្បាស់ក្នុងលំដាប់កង្គញាណ ជាដើម ទៅរហូតដល់សង្ខារុបេក្ខាញាណ ព្រមទាំងសុខៈ និងអធិមោក្ខៈ ជាដើម ដែលកើតរួមជាមួយពោជ្ឈង្គៈ ទើបមិនហៅថាជា ឧបក្កិលេស ព្រោះមិនបានធ្វើឲ្យវិបស្សនាថយចុះ ក្រៅពីនោះ ពន្លឺដែលប្រាកដដល់ព្រះអរិយបុគ្គលពេលដែលចាប់ផ្តើមបដិបត្តិ ចំណែកក្នុងឧទយព្វយញាណ ក៏មិនមែនជាឧបក្កិលេស ។

អ្នកដែលបានទទួលពាក្យណែនាំ ពីវិបស្សនាចារ្យយ៉ាងត្រឹមត្រូវ រមែងយល់ថា ពន្លឺញាណ និងបីតិជាដើម នេះជាឧបសគ្គដែលធ្វើឲ្យវិបស្សនាថយចុះ មិនមែនជាគុណធម៌វិសេសទេ ឬកើតពីការសម្រេចគុណវិសេស ការពិចារណាដល់វត្ថុទាំងនេះ មិនមែនជាវិបស្សនាមគ្គដ៏ត្រឹមត្រូវទេ ។ ពិតមែនហើយ វត្ថុទាំងនេះ ធ្លាក់នៅក្នុងអំណាចរបស់ត្រៃលក្ខណ៍ គឺមិនទៀង ជាទុក្ខ និងមិនមែនជាតួខ្លួន ការកំណត់ដឹងទាន់រូបនាមបច្ចុប្បន្នប៉ុណ្ណោះ ទើបជាផ្លូវបដិបត្តិ

ដ៏ត្រឹមត្រូវ ដែលជាហេតុឲ្យសម្រេចគុណធម៌វិសេស កាលបើយល់ដូច្នេះ នឹងអាចលះបង់នូវការធ្វើទុកក្នុងចិត្តចំពោះពន្លឺជាដើម ហើយចំរើនសតិរឭកដឹងសភាវធម៌តទៅ កាលនោះការកើតរលត់របស់រូបនាម រមែងប្រាកដច្បាស់ដល់អ្នកបដិបត្តិ ទាំងសេចក្តីមិនទៀង គឺសភាពកើត និងរលត់ទៅ សេចក្តីទុក្ខ គឺការបៀតបៀន ដោយការរលត់ និងសភាពមិនមែនជាខ្លួន ដែលមិនប្រព្រឹត្តទៅតាមផ្លូវកាយរមែង ប្រាកដច្បាស់ គ្រានោះ ការឃើញនូវការកើតរលត់យ៉ាងឆាប់រហ័ស គ្រប់ខណៈ ដែលកំពុងតែកំណត់ដឹង នេះទើបជាឧទយព្វយញ្ញាណ ដែលផុតទៅអំពីវិបស្សនូបក្កិលេស ។

## "មគ្គាមគ្គញាណទស្សនវិសុទ្ធិ"

បញ្ញាដែលយល់ថា ពន្លឺជាដើម មិនមែនជាផ្លូវនៃការបដិបត្តិដែលត្រឹមត្រូវទេ ការធ្វើទុកក្នុងចិត្តនូវវត្ថុទាំងនោះ ក៏មិនមែនជាផ្លូវបដិបត្តិដែលត្រឹមត្រូវដែរ តែការកំណត់ដឹងរូបនាម តាមសភាវៈពិត ដោយមិនយកចិត្តទុកដាក់នូវវត្ថុទាំងនោះ ទើបជាផ្លូវបដិបត្តិដ៏ត្រឹមត្រូវ នេះឈ្មោះថា មគ្គញាណទស្សនវិសុទ្ធិ ។

ម្យ៉ាងទៀត ឧទយព្វយញ្ញាណ ក្នុងលំដាប់ទន់ខ្ចី ( **តរុណ-**

វិបស្សនា ) រាប់ចូលក្នុងមគ្គាមគ្គញាណទស្សនវិសុទ្ធិ ចំណែក ឧទយព្វយញាណលំដាប់ចាស់ក្លា ( ពលវវិបស្សនា ) រាប់ បញ្ចូលក្នុងបដិបទាញាណទស្សនវិសុទ្ធិ ដែលនឹងពោលតទៅ ។

# "ញាណទី ៥ ភង្គញាណ"

យោគា វេ ជាយតេ ភូរិ អយោគា ភូរិសង្ខយោ
ឯតំ ទ្វេធា បថំ ញត្វា ភវាយ វិភវាយ ច
តថត្តានំ និវេសេយ្យ យថា ភូរិ បវឌ្ឍតិ ។

"ប្រាជ្ញា រមែងកើតពីការប្រកប សេចក្តីវិនាសប្រាជ្ញា រមែងកើតពីការមិនប្រកប អ្នកមានប្រាជ្ញា ដឹងការប្រកប នឹងការមិនប្រកប ទាំងពីរនេះថា ជាគន្លងនៃសេចក្តីចម្រើននឹងសេចក្តីវិនាស ហើយប្រាជ្ញាចម្រើនឡើង ដោយប្រការណា គួរដំកល់ខ្លួនទុក ដោយប្រការនោះ" ។ បិដកខ្មែរ ៥២. ៨០

# "ឧទយព្វយញាណ

# និង

# បដិបទាញាណទស្សនវិសុទ្ធិ"

បញ្ញាដែលឃើញច្បាស់នូវការកើតរលត់របស់រូបនាមរមែង រួចផុតពីឧបក្កិលេស ព្រោះមិនប្រកាន់មាំនូវមានពទ្ធីជាដើម និងបានឈ្មោះថា **ឧទយព្វយញាណ** ដែលចាស់ក្លា ព្រោះដឹងច្បាស់នូវការកើតរលត់យ៉ាងជាក់ច្បាស់ ។

ញាណដូចពោលមកនេះ និងកន្តញាណជាដើមទៅរហូតដល់អនុលោមញាណ រួមជាវិបស្សនាញាណ ៩ ឈ្មោះថា **បដិបទាញាណទស្សនវិសុទ្ធិ** គឺការផូរផង់នៃការឃើញរបស់បដិបទា សំដៅដល់ការឃើញច្បាស់នៃផ្លូវដ៏ផូរផង់ ជាបដិបទាសម្រេចនូវអរិយមគ្គ ។ វិសុទ្ធិនេះកើតឡើង តាំងតែពីពេលដែលអ្នកបដិបត្តិធម៌ បានដឹងត្រៃលក្ខណ៍យ៉ាងជាក់ច្បាស់នូវការកើតរលត់របស់រូបនាមយ៉ាងប្រចក្ស ។

ការប្រាកដរបស់ត្រៃលក្ខណ៍ ដែលប្រព្រឹត្តទៅដោយការឃើញ ការកើតរលត់ នឹងពោលតទៅក្នុងបរិច្ឆេទទី ៧ និងជួប

ក្នុងគម្ពីរមហាដីការបស់វិសុទ្ធិមគ្គដូច្នេះថា :

[១] ឧទយព្វយេ បន បដិវិទ្ធេ អនិច្ចលក្ខណំ បាកដំ ហុត្វា ឧបដ្ឋាតិ ។ [២] តតោ យទនិច្ចំ តំ ទុក្ខំ, យំ ទុក្ខំ តទ-នត្តាតិ ឥតរលក្ខណម្បិ ។ [៣] អថ វា ឧទយព្វគ្គហណេន ហុត្វា អភាវការោ អភិណ្ហសម្បដិបីឡនាការោ អវសវត្តនាការោ ច វិភូតតរោ ហោតិ ។

"១. កាលបុគ្គលចាក់ធ្លុះនូវការកើតរលត់ហើយ អនិច្ច-លក្ខណៈ រមែងប្រាកដឡើង ។

២. បន្ទាប់ពីនោះ លក្ខណៈដទៃរមែងកើតឡើង ដោយន័យថា សភាវធម៌ណា មិនទៀង សភាវធម៌នោះ រមែងជាទុក្ខ សភាវធម៌ណាជាទុក្ខ សភាវធម៌នោះ មិនមែនជារបស់ខ្លួន ។

៣. ន័យម្យ៉ាងទៀត លក្ខណៈគឺការកើតឡើង ហើយក៏រលត់ទៅ លក្ខណៈគឺការបៀតបៀនរឿយៗ និងលក្ខណៈគឺការមិនប្រព្រឹត្តទៅតាមអំណាចនៃសេចក្ដីត្រូវការ រមែងប្រាកដរមែងប្រាកដច្បាស់ដោយឃើញនូវការកើតរលត់" ។

អ្នកដែលឃើញច្បាស់នូវការកើតរលត់របស់រូបនាមហើយ

រមែងយល់ច្បាស់នូវត្រៃលក្ខណ៍យ៉ាងពិតប្រាកដ តាមដែលពោលមកហើយ សតិរបស់គេ ដែលរឭកដឹងទាន់បច្ចុប្បន្នក្នុងខណៈនោះ រមែងកំណត់ដឹងបានច្បាស់ និងឆាប់រហ័ស ធ្វើឲ្យគេមិនអាចធ្វើទុកក្នុងចិត្តនូវសភាវកើតឡើង និងការតាំងនៅរបស់រូបនាម មិនបានធ្វើទុកក្នុងចិត្តចំពោះក្រសែចិត្តដែលកំពុងតែប្រព្រឹត្តទៅ ប្រៀបដូចជាទឹកហូរទៅមិនដាច់ ។ម្យ៉ាងទៀត ទាំងមិនបានធ្វើក្នុងចិត្តចំពោះរូបរាងសណ្ឋាន ដោយរឭកដឹងថាគ្មានរូបរាង របស់ដៃ ជើង ឬរាងកាយ ដូចជាក្នុងពេលដែលចាប់ផ្ដើម ក្នុងខណៈនោះ គេរមែងយល់ចូលចិត្តថា នេះជាការរលត់ទៅរបស់រូបនាមតែប៉ុណ្ណោះ រាប់ថាសម្រេចនូវភង្គញាណ គឺបញ្ញាឃើញច្បាស់នូវការរលត់ទៅ ។ ដូចគម្ពីរវិសុទ្ធិមគ្គពោលថា :

[១] តស្សេវំ សព្វម្បិ អយំ យោគាវចរោ ឧបក្កិលេស-វិនិមុត្តេន វីថិបដិបន្នវិបស្សនាសង្ខាតេន ឧទយព្វយានុបស្ស-នាញាណេន យាថាសរសតោ សល្លក្ខេតិ ។ [២] តស្សេវំ សល្លក្ខេត្វា បុនប្បុនំ អនិច្ចំ ទុក្ខំ អនត្តាតិ រូបារូបធម្មេ

តុលយតោ តីរយតោ តំ ញាណំ តិក្ខំ ហុត្វា វហតិ ។ [៣] សង្ខារា លហុំ ឧបដ្ឋហន្តិ ។ [៤] ញាណេ តិក្ខេ វហន្តេ សង្ខារេសុ លហុំ ឧបដ្ឋហន្តេសុ ឧប្បាទំ វា ឋិតឹ វា បវត្តំ វា និមិត្តំ វា ន សម្បាបុណាតិ ។ [៥] ខយវយភេទនិរោធេយេវ សតិ សន្តិដ្ឋតិ ។ [៦] តស្សេវំ ឧបដ្ឋិត្វា ឯវំ នាម សង្ខារគតំ និរុជ្ឈតីតិ បស្សតោ ឯតស្មឹ ឋានេ ភង្គានុបស្សនា នាម វិបស្សញាណំ ឧប្បជ្ជតិ ។

“១. អ្នកបដិបត្តិធម៌នេះ រមែងកំណត់ដឹងខន្ធ ៥ និងត្រៃលក្ខណ៍ ទាំងអស់នោះ តាមសភាពដែលមានពិត ដោយឧទយព្វយញាណដែលហៅថា វិបស្សនា ដែលជាដំណើរទៅតាមវិថី រួចផុតទៅអំពីកិលេស ។

២. កាលបើគេកំណត់ដឹងយ៉ាងនេះ ហើយពិចារណាធ្វើទុកក្នុងចិត្តរឿយៗ ថា រូបមិនទៀង ជាទុក្ខ និងមិនមែនជាខ្លួន ញាណនេះ ក៏ប្រព្រឹត្តទៅចាស់ក្លា ។

៣. សង្ខារប្រាកដឡើងលឿនរហ័ស ។

៤. កាលបើញាណប្រព្រឹត្តទៅចាស់ក្លា និងសង្ខារប្រាកដ

ឡើងលឿនរហ័ស គេរមែងមិនធ្វើទុកក្នុងចិត្តនូវការកើតឡើង ការតាំងនៅ ការប្រព្រឹត្តទៅរឿយៗ របស់រូបនាម និងរូបកង សណ្ឋានទេ ។

៥. សតិតាំងមាំនៅក្នុងនិរោធ គឺការអស់ទៅ ការថយចុះ និងការវិនាសទៅតែម្យ៉ាង ។

៦. កាលគេឃើញច្បាស់នូវសង្ខារ កើតឡើងយ៉ាងនេះ ហើយរលត់ទៅយ៉ាងនេះ ជាធម្មតា វិបស្សនាញាណដែលឈ្មោះថា កង្ខានុបស្សនា ( បញ្ញាដឹងច្បាស់នូវការរលត់ទៅ ) រមែងកើតឡើងក្នុងទីនេះ" ។

[ ការរលត់មាន ២ យ៉ាង គឺ :

១. ឧប្បាទិសេសនិរោធ ការរលត់រូបនាមដែលនៅមានការកើតឡើងទៀត ( សំដៅយកការកើតរបស់រូបបច្ចុប្បន្ន ) ។

២. អនុប្បាទិសេសនិរោធ ការរលត់រូបនាមដែលមិនមានការកើតឡើងទៀត ដូចជា ការរលត់ទៅរបស់អ្នកដែលកំពុងចូលនូវផលសមាបត្តិ ឬនិរោធសមាបត្តិ ។

ការរលត់ទៅក្នុងទីនេះ សំដៅដល់ឧប្បាទិសេសនិរោធ ព្រះ

ដីកាចារ្យ ទើបបន្ថែមស័ព្ទថា ខយវយភេទនិរោធ ( និរោធគឺ ការអស់ទៅ សូន្យទៅ និងវិនាសទៅ )] ។

ក្នុងគម្ពីរបដិសម្ភិទាមគ្គបានសម្ដែងការកើតឡើង របស់កង្ខាញាណទុកដោយពិស្ដារ ក្នុងទីនេះ សូមលើកយកមកសម្ដែងត្រឹមតែចំណែកខ្លះ ព្រមដោយពាក្យអធិប្បាយអំពីគម្ពីរអដ្ឋកថាថា :

**អារម្មណប្បដិសង្ខា ភង្គានុបស្សនេ បញ្ញា វិបស្សនេ ញាណំ ។**

"បញ្ញាក្នុងការឃើញច្បាស់ការរលត់ទៅ ដោយដឹងច្បាស់អារម្មណ៍ [ ថារលត់ទៅ ] ឈ្មោះថា វិបស្សនាញាណ" ។

[១] **អារម្មណប្បដិសង្ខាតិ យំ កិញ្ចិ អារម្មណំ បដិសង្ខាយ ជានិត្វា, ខយតោ វយតោ ទិស្វាតិ អត្ថោ ។** [២] **ភង្គានុបស្សនេ បញ្ញាតិ តស្ស អារម្មណំ ខយតោ វយតោ បដិសង្ខាយ ឧប្បន្នស្ស ញាណស្ស ភង្គំ អនុបស្សនេ យា បញ្ញា** [៣] **ឥទំ វិបស្សនេ ញាណំ ។**

" ១. ពាក្យថា **អារម្មណប្បដិសង្ខា** ( ដោយការដឹងច្បាស់

អារម្មណ៍ ) [ថារលត់ទៅ] មានន័យថា ដឹងអារម្មណ៍យ៉ាង ណាទីមួយ គឺឃើញថា ការអស់ទៅ ការសូន្យទៅ ។

២. ពាក្យថា **ភង្គានុបស្សនេ បញ្ញា** ( បញ្ញាក្នុងការឃើញច្បាស់ការរលត់ទៅ ) មានន័យថា បញ្ញាក្នុងការឃើញច្បាស់ការរលត់ទៅបញ្ញា ដែលកើតឡើងដឹងច្បាស់នូវអារម្មណ៍ថា អស់ទៅ សូន្យទៅនោះ កំពុងតែមាននៅ ។

៣. បញ្ញានេះបាត់ជា **វិបស្សនាញាណ**" ។

សេចក្តីខាងដើម អធិប្បាយក្នុងស័ព្ទ ដូចតទៅនេះថា : ពាក្យថា **បដិសង្ខាយ ជានិត្វា** ( ដឹង ) អធិប្បាយ **បដិសង្ខា** ស័ព្ទថា ប្រែថា "ដឹង" មិនមែនប្រែថា "ពិចារណា"ទេ ដូចពាក្យថា **បដិសង្ខា យោនិសោ ចីវរំ បដិសេវាមិ** ( យើងពិចារណាដោយបញ្ញា ហើយប្រើប្រាស់ចីវរ ) ចំណែកពាក្យថា **ខយតោ វយតោ ទិស្វា** ( ឃើញថា អស់ទៅ សូន្យទៅ ) អធិប្បាយថា ការដឹងដូចពោលជាការឃើញច្បាស់ ការអស់ទៅ សូន្យទៅ ព្រោះជាឋានៈរបស់ភង្គញាណ មិនមែនជាការដឹងដោយទូទៅ ដែលជាការសិក្សាដឹង ( **សុតមយបញ្ញា** ) ឬការគិតដឹងហៅថា

( ចិន្តាមយបញ្ញា ) ។

[ តាមគោលភាសា ពាក្យថា បដិសង្ខា សម្រេចរូបមកពី បតិបុព្វបទ+សំបុព្វបទ+ករធាតុ+ត្វាបច្ច័យផ្លាស់ត្វា> យ ហើយលុប យអក្សរចេញ] ។

អ្នកដែលសម្រេចនូវភង្គញ្ញាណហើយ រមែងឃើញច្បាស់ ថា រូបនាមក្នុងបច្ចុប្បន្នខណៈ ដូចជាសភាវៈប៉ោង ផត អង្គុយ ឈរ ដើរ បត់ លាត ឃើញ បានឮ នឹកគិត រលត់ទៅ មាន សភាពរលត់ទៅយ៉ាងឆាប់រហ័ស ក្នុងខណៈដែលកំពុងកំណត់ ដឹងនោះ ។ ក្នុងខណៈខ្លះ អាចឃើញច្បាស់ថា ចិត្តដែលច្បាស់ នូវការរលត់ទៅ បានរលត់យ៉ាងឆាប់រហ័ស វិបស្សនាញ្ញាណ ដែលដឹងច្បាស់ ការរលត់ទៅរបស់រូបនាម និងដឹងច្បាស់ការ រលត់ទៅរបស់ចិត្ត ដែលឃើញច្បាស់ ការរលត់ដូចពោលមក នេះ ឈ្មោះថា **ភង្គានុបស្សនា** ឬ **ភង្គញ្ញាណ** ដូចសេចក្តីពោល ថា :

**[១] រូបារម្មណតាចិត្តំ ឧប្បជ្ជិត្វា ភិជ្ជតិ ។ [២] តំ អារម្មណំ បដិសង្ខា តស្ស ចិត្តស្ស ភង្គំ អនុបស្សតិ ។បេ។ [៣]**

វេទនារម្មណតា, សញ្ញារម្មណតា, សង្ខារារម្មណតា, វិញ្ញាណារម្មណតា ចិត្តំ ឧប្បជ្ជិត្វា ភិជ្ជតិ ។ [៤] តំ អារម្មណំ បដិសង្ខា តស្ស ចិត្តស្ស ភង្គំ អនុបស្សតិ ។

"១. ចិត្តដែលទទួលរូបជាអារម្មណ៍ កើតឡើងហើយ រមែងរលត់ទៅវិញ ។

២. អ្នកបដិបត្តិធម៌ ឃើញច្បាស់នូវអារម្មណ៍នោះហើយ [ ជារលត់ទៅ] រមែងតាមដឹងការរលត់របស់វិបស្សនាចិត្តនោះ ។ល។

៣. ចិត្តដែលទទួលដឹងវេទនាជាអារម្មណ៍ ចិត្តដែលទទួលដឹងសញ្ញាជាអារម្មណ៍ ចិត្តដែលទទួលដឹងសង្ខារជាអារម្មណ៍ ចិត្តដែលទទួលដឹងវិញ្ញាណជាអារម្មណ៍ កើតឡើងហើយក៏រលត់ទៅវិញ ។

៤. អ្នកបដិបត្តិធម៌ ឃើញច្បាស់អារម្មណ៍នោះហើយ [ជារលត់ទៅ] រមែងតាមដឹងការរលត់របស់វិបស្សនាចិត្តនោះ" ។

អ្នកដែលកំណត់ដឹងសភាវៈរូប-នាម ជាដើមក្នុងបច្ចុប្បន្នខណៈហើយ ឃើញច្បាស់នូវការកើតរលត់បាន ការឃើញច្បាស់

ដូចពោលមកនេះ ជា**ភង្គញាណ** ទី ១ ដែលឃើញច្បាស់ការរលត់ទៅរបស់អារម្មណ៍ ដែលកំណត់ដឹង ( **ញាត** ) បន្ទាប់ពីនោះ អ្នកបដិបត្តិ អាចឃើញច្បាស់វិបស្សនាចិត្តនោះ (ញាណ) ថា រលត់ទៅ ការឃើញច្បាស់តមកនេះ ឈ្មោះថា **ភង្គញាណ** ទី ២ ដែលបន្ទាប់ពី**ភង្គញាណ**ទី ១ ការកើតបន្ទាប់ពី **ភង្គញាណ**, ញាណទី ២ នេះ ឈ្មោះដទៃទៀតថា **បដិវិបស្សនា** គឺការឃើញច្បាស់ មួយគ្រាទៀត ព្រោះជាការឃើញច្បាស់តមកពីវត្ថុដែលឃើញច្បាស់គ្រាដំបូង ។

[ គម្ពីរអដ្ឋកថារបស់បដិសម្ភិទាមគ្គពោលថា :

តេនាហុ បោរាណា ញាតញ្ច ញាណញ្ច ឧភោ បស្សតីតិ ។

“ ព្រោះហេតុនោះ បោរាណាចារ្យ ទើបពោលថា រមែងឃើញច្បាស់វត្ថុដែលញាណដឹងហើយ និងញាណទាំង ២ យ៉ាង”] ។

ដោយប្រការដូច្នេះ គ្រប់ៗ ខណៈដែលរូបប្រាកដ ការរលត់ភង្គញាណ រមែងកើតឡើង ២ ខណៈ គឺ ភង្គញាណទី ១ ឃើញច្បាស់នូវការរលត់ទៅរបស់រូប និងភង្គញាណទី ២ ឃើញនូវការរលត់ទៅរបស់វិបស្សនាចិត្តនោះ សូម្បីក្នុងខណៈដែល

វេទនាប្រាកដការរលត់ទៅ ភង្គញាណរមែងកើតឡើង ២ ខណៈ គឺ ភង្គញាណទី ១ ឃើញច្បាស់នូវការរលត់ទៅរបស់វេទនា និងភង្គញាណទី ២ ឃើញច្បាស់នូវការរលត់ទៅនៃវិបស្សនាចិត្ត ដូច្នេះ ជាដើម ។

ក្នុងខណៈដែលភង្គញាណប្រាកដឡើង អ្នកដែលចំរើនវិបស្សនាភាវនា រមែងឃើញច្បាស់រលត់ទៅថា សភាវធម៌បច្ចុប្បន្នដែលខ្លួនកំពុងកំណត់ដឹង និងចិត្តដែលឃើញច្បាស់នូវការរលត់ទៅ បានរលត់ជាគូៗ គ្នាទៅយ៉ាងឆាប់រហ័ស ។ ការឃើញច្បាស់នូវការរលត់ទៅរបស់អារម្មណ៍ និងចិត្តដែលដឹងច្បាស់ ដូចពោលជាភង្គញាណ ម្យ៉ាងទៀត ការរលត់ក្នុងរឿងនេះ មិនមែនជាការបែកធ្លាយ តែជាការរលត់សូន្យទៅ ដូចជាសេចក្តីក្នុងគម្ពីរអដ្ឋកថា ដែលអាងទុកក្នុងគ្រាដើមថា :

**ខយវយនិរោធេយេវ សតិ សន្តិដ្ឋតិ** ( សតិតាំងនៅមាំក្នុងនិរោធ គឺ ការអស់ទៅ ការសូន្យទៅ និងការវិនាសទៅវិញតែម្យ៉ាង ) **ខយតោ វយតោ ទិស្វា** ( ឃើញច្បាស់នូវការកើតឡើង ) ។

ក្នុងគម្ពីរបដិសម្ភិទាមគ្គនៅចែកការរលត់ទៅរបស់ទ្វារ ៦ អារម្មណ៍ ៦ វិញ្ញាណ ជាដើម ដោយពាក្យជាដើមថា :

**រូបារម្មណតា ចិត្តំ ឧបជ្ជិត្វា ភិជ្ជតិ ។ តំ អារម្មណំ បដិសង្ខា តស្ស ចិត្តស្ស ភង្គំ អនុបស្សតិ ។**

( ចិត្តដែលទទួលរូបជាអារម្មណ៍ កើតឡើងហើយរមែងរលត់ទៅ អ្នកបដិបត្តិធម៌ ឃើញអារម្មណ៍នោះហើយ [ ថាជាការរលត់ទៅ] រមែងដឹងតាមការរលត់របស់វិបស្សនាចិត្ត ) ហើយអធិប្បាយពាក្យថា **អនុបស្សតិ** ( តាមដឹង ) ដោយចែកជាអនុស្សនា ៧ ក្នុងទីនេះនឹងពោលដល់រឿងនោះទុកបរិច្ឆេទទី ៧ តទៅ ។

↳អត្ថប្រកបរបស់ភង្គញាណ ពោលទុកក្នុងគម្ពីរបដិសម្ភិ-ទាមគ្គថា :

**វត្ថុសង្កមនា ចេវ បញ្ញាយ ច វិវដ្ដនា**
**អាវជ្ជនាពលញ្ចេតិ បដិសង្ខាវិបស្សនា ។**

“ញាណដែលដល់ព្រមដោយអង្គ ៣ ពួកនេះ គឺ ការផ្លាស់អារម្មណ៍ [ ដោយផ្លាស់ពីការរលត់ទៅរបស់អារម្មណ៍ ទៅ

កាន់ការរលត់ទៅរបស់វិបស្សនាចិត្ត] ការផ្លាស់ទៅនៃបញ្ញា [ ដោយផ្លាស់ពីបញ្ញាដែលឃើញច្បាស់ការកើតរលត់ទៅកាន់ឃើញការរលត់] និងអាចពិចារណា [ ដែលអាចពិចារណាការរលត់ទៅរបស់វិបស្សនា បន្ទាប់ពីការរលត់ទៅរបស់អារម្មណ៍ ] ជា **ភង្គញាណ** ដែលឃើញច្បាស់នូវការរលត់ទៅរបស់វិបស្សនាចិត្ត កាលឃើញច្បាស់ការរលត់ទៅរបស់អារម្មណ៍ហើយ" ។

អង្គប្រកបរបស់ភង្គញាណខាងដើម គឺ :

១. ការឃើញច្បាស់នូវការរលត់ទៅរបស់វិបស្សនាចិត្ត បន្ទាប់ពីការឃើញច្បាស់នូវការរលត់ទៅរបស់អារម្មណ៍ហើយ ។

២. ការមិនឃើញច្បាស់នូវការរលត់ដូចជា ក្នុងខណៈកើតឧទយព្វយញាណ តែឃើញច្បាស់នូវការរលត់ទៅតែម្យ៉ាង ។

៣. ការពិចារណា ដែលឈ្មោះថា យោនិសោមនសិការ ដើម្បីឲ្យឃើញច្បាស់នូវការរលត់ទៅរបស់ វិបស្សនាចិត្ត បានទាន់ពេលកាលឃើញច្បាស់ការរលត់ទៅ របស់អារម្មណ៍ហើយ ។

អង្គប្រកបទី ១ និងទី ៣ កើតរួមគ្នាក្នុងខណៈតែមួយ

ព្រោះមានការពិចារណា ដូច្នោះ ហើយការឃើញច្បាស់នូវការរលត់ទៅរបស់វិបស្សនាចិត្ត រមែងកើតឡើងបានភ្លាម ដូចជាគម្ពីរអដ្ឋកថា បដិសម្ភិទាមគ្គអធិប្បាយថា :

[១] វត្ថុសង្កមនាតិ រូបាទីសុ ឯកេកស្ស ភង្គំ ទិស្វា បុន យេន ភង្គោ ទិដ្ឋោ, តស្សាបិ ភង្គទស្សនវសេន បុរិមវត្ថុតោ អញ្ញវត្ថុសង្កមនា ។[២] បញ្ញាយ ច វិវដ្ដនាតិ ឧទយំ បហាយ វយេ សន្តិដ្ឋនា ។ [៣] អាវជ្ជនាពលញ្ចេតិ រូបាទីសុ ឯកេកស្ស ភង្គំ ទិស្វា បុន ភង្គារម្មណស្ស ចិត្តស្ស ភង្គទស្សនត្ថំ អនន្តរមេវ អាវជ្ជនសមត្ថតា ។

"១. ពាក្យថា **វត្ថុសង្កមនា** ( ការផ្លាស់អារម្មណ៍ ) មានន័យថា ការឃើញច្បាស់ការរលត់ទៅរបស់រូបយ៉ាងណាទីមួយជាដើម ហើយផ្លាស់ទៅកាន់អារម្មណ៍ដទៃ ពីអារម្មណ៍ដើម ដោយការឃើញច្បាស់ការរលត់ទៅរបស់ចិត្ត ដែលដឹងច្បាស់ការរលត់នោះ ។

២. បាទគាថាថា **បញ្ញាយ ច វិវដ្ដនា** ( ការផ្លាស់ទៅនៃបញ្ញា ) មានន័យថា ការលះបង់នូវការកើតឡើង ហើយតាំង

ទៅក្នុងការរលត់ទៅ ។

៣. បាទគាថាថា **អាវជ្ជនាពលញ្ចេវ** ( កម្លាំងរបស់អាវជ្ជនចិត្ត ) មានន័យថា មានកម្លាំងក្នុងការពិចារណាយ៉ាងបន្តបន្ទាប់ ដើម្បីឲ្យឃើញការរលត់ទៅរបស់រូបយ៉ាងណានីមួយជាដើម ហើយឃើញខ្លាស់ការរលត់ទៅរបស់ចិត្ត ដែលមានការរលត់ទៅជាអារម្មណ៍ទៀត" ។

ម្យ៉ាងទៀត ការមានកម្លាំង ក្នុងការពិចារណាយ៉ាងបន្តបន្ទាប់ គឺការកើតវិថីចិត្តយ៉ាងបន្តបន្ទាប់មិនទទួលអារម្មណ៍ដទៃ ព្រោះការពិចារណា មិនអាចមានទៅបានដោយការមិនមាននូវកវន្តយាំងរវាងចន្លោះ ដូច្នោះ ពាក្យក្នុងព្រះបាលីថា **វត្ថុសង្កមនា** ( ការផ្លាស់អារម្មណ៍ ) និងពាក្យក្នុងគម្ពីរអដ្ឋកថាថា **អនន្តរមេវ អាវជ្ជនសមត្ថតា** ( មានប្រយោជន៍ក្នុងការពិចារណាយ៉ាងបន្តបន្ទាប់ ) ទើបសំដៅដល់ការកំណត់ដឹងអារម្មណ៍ម្តងមួយ មិនមែនសំដៅដល់ការកំណត់ដឹងអារម្មណ៍តែមួយ ច្រើនៗ ដងទេ ។

សរុបសេចក្តីថា អ្នកបដិបត្តិធម៌គួរឃើញច្បាស់ ការរលត់ទៅរបស់រូបនាមម្តងមួយៗ ដែលប្រាកដច្បាស់ មិនមែនឃើញ

ច្បាស់នូវការរលត់ទៅរបស់រូបនាមគ្រប់យ៉ាងទេ ទីងគួរឃើញច្បាស់ រហូតទាំងវិថីចិត្តមួយ មិនមែនជាការញែកកំណត់ចិត្តដួងមុខ និងដួងក្រោយ ក្នុងវិថីចិត្តមួយនោះទេ ក្រៅពីនោះគួរឃើញច្បាស់នូវការរលត់ទៅរបស់សភាវធម៌ ក្នុងបច្ចុប្បន្នតែម្យ៉ាង មិនគួរអនុមានដឹងនូវការរលត់ទៅរបស់សភាវធម៌អតីត និងអនាគត និងការរលត់ទៅរបស់សភាវធម៌ ដែលមិនប្រាកដច្បាស់ នៅក្នុងបច្ចុប្បន្នខណៈទេ ។

មានសេចក្ដីជាប់ទាក់ទងក្នុងរឿងនេះ ក្នុងគម្ពីរបដិសម្ភិទាមគ្គនិងវិសុទ្ធិមគ្គតាមលំដាប់ថា :

**អារម្មណអន្វយេន ឧភោ ឯកវវត្ថនា**
**និរោធេ អធិមុត្តតា វយលក្ខណាវិបស្សនា ។**

“ញាណដែលដល់ព្រមដោយអង្គ ២ ពួកនេះគឺ ការកំណត់ដឹងដោយសភាវៈតែម្យ៉ាង [ គឺការរលត់] ក្នុងអារម្មណ៍ទាំង ២ [ គឺអារម្មណ៍ដែលឃើញច្បាស់ដែលដល់បច្ចុប្បន្ន និងអារម្មណ៍ដែលមិនឃើញច្បាស់ ដែលបានដល់អតីត និងអនាគត]ដោយការអនុមានដឹង ដោយស្របតាមអារម្មណ៍ [ដែលជាបច្ចុប្បន្ន]

និងការបង្អោនចិត្តទៅក្នុងការរលត់ ជាភង្គញាណ ដែលឃើញ
លក្ខណៈរលត់ទៅ" ។

[១] **អារម្មណអន្វយេន ឧភោ ឯកវវត្ថនាតិ បច្ចក្ខតោ ទិដ្ឋស្ស អារម្មណស្ស អន្វយេន អនុគមនេន" យថា ឥទំ, តថា អតីតេបិ សង្ខារគតំ ភិជ្ជិត្ថ, អនាគតេបិ ភិជ្ជិស្សតី"តិ ឯវំ ឧភិន្នំ ឯកសភាវេន វវត្ថាបន្តិ អត្ថោ ។** [២] **វិមុត្តម្បិ ចេតំ បោរាណេហិ**

"សំវិជ្ជមានម្ហិ វិសុទ្ធទស្សនោ តទន្វយំ នេតិ អតីតានាគតេ សព្វេបិ សង្ខារគតា បលោកិនោ ឧស្សាវពិន្ទូ សូរិយេវ ឧគ្គតេ"តិ ។

"១. កន្ទះគាថាថា **អារម្មណអន្វយេវ ឧភោ ឯកវវត្ថនា** ( ការកំណត់ដឹងដោយសភាវៈតែម្យ៉ាងដូចគ្នា [ គឺការរលត់] ក្នុងអារម្មណ៍ទាំង ២ [ គឺអារម្មណ៍ដែលឃើញច្បាស់ ដែលបានដល់អារម្មណ៍បច្ចុប្បន្ន និងអារម្មណ៍ដែលមិនឃើញច្បាស់ ដែលបានដល់អតីត និងអនាគត] ដោយការអនុមានដឹងដែលស្របតាមអារម្មណ៍ [ ដែលជាបច្ចុប្បន្ន] មានន័យថា ការកំណត់ដឹងអារម្មណ៍ទាំង ២ ដោយសភាវៈតែម្យ៉ាងដូចគ្នានោះឯង យ៉ាងនេះថា កងសង្ខារដែលជាអតីតក៏វិនាសទៅ កងសង្ខារ

ដែលជាអនាគត ក៏វិនាសទៅវិញដែរ ដូចសង្ខារ [ ដែលរលត់ទៅក្នុងបច្ចុប្បន្ន] នេះជាការអនុមានដឹងដែលស្របតាមអារម្មណ៍ដែលខ្លួនដឹងដោយជាក់ច្បាស់ហើយ ។

២. សមពិតដូចបោរាណាចារ្យពោលថា :

ភិក្ខុជាអ្នកមានការឃើញដ៏បរិសុទ្ធ [ គឺភង្គញាណ] ក្នុងសង្ខារដែលមាននៅក្នុងបច្ចុប្បន្ន រមែងនាំយកអនុមានញាណ ដែលស្របតាមញាណ ឃើញប្រចក្សនូវការរលត់នោះទៅក្នុងកងសង្ខារដែលជាអតីត និងអនាគតថា សង្ខារទាំងពួងក៏មានប្រក្រតីបែកធ្លាយទៅដូចជាដំណក់ទឹកសន្សើម ដែលត្រូវពន្លឺព្រះអាទិត្យក៏បែកទៅ ដូច្នោះឯង" ។

តាមសាធកៈ ដែលនាំមកសម្តែងទុកក្នុងរឿងនេះ អ្នកបដិបត្តិធម៌មិនគួរកំណត់ដឹងសភាវធម៌ ដែលជាអតីត ឬអនាគតគួរកំណត់ដឹងសភាវធម៌បច្ចុប្បន្ន ដែលកំពុងប្រាកដការរលត់ប៉ុណ្ណោះ កាលគេបានឃើញច្បាស់នូវការរលត់ទៅ នៃសភាវធម៌បច្ចុប្បន្នហើយ ក៏នឹងអនុមានដឹងការរលត់ទៅរបស់អារម្មណ៍ដែលជាអតីត និងអនាគតបានក្នុងខណៈខ្លះ ការអនុមានដឹងដែល

ហៅថា អនុមានញាណនេះ ជាប់ទាក់ទងជាមួយការពិចារណាអារម្មណ៍ ដែលជាអតីត និងអនាគត ដែលបន្ទាប់ពីការឃើញច្បាស់ដែលហៅថា បច្ចក្ខញាណដូច្នោះ អ្នកចំរើនវិបស្សនា ទើបមិនចាំបាច់ត្រូវពិចារណាឲ្យឃើញការរលត់ទៅ ដោយការទឹកគិតរកហេតុ ផលនោះទេ ។

អ្នកដែលសម្រេចភង្គញាណលំដាប់ចាស់ ហើយរមែងឃើញច្បាស់នូវការរលត់របស់រូបនាម ដែលកំណត់ដឹងនិងការរលត់ របស់វិបស្សនាចិត្តផ្គួបជាគូរគ្នា ទៅយ៉ាងឆាប់រហ័ស ដូចជាគ្រាប់ល្ង បែកដែលត្រូវលីងក្នុងឆ្នាំង ដូចពពុះទឹកលើផ្ទៃទឹក ដែលកើតពី ភ្លៀងធ្លាក់ខ្លាំង និងដូចថ្ងៃចុះអ័ព្ទ ដូចព្រះពុទ្ធវចនៈ ដែលសំដៅដល់បុគ្គលដូចពោលថា:

យថា បុព្វុឡកំ បស្សេ យថា បស្សេ មរីចិកំ
ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ ។

“អ្នកដែលឃើញលោកថាមិនស្ថិតស្ថេរ និងរកសារៈមិនបាន ដូចជាមួយទឹងមនុស្សមើលពពុះទឹក និងថ្ងៃចុះអ័ព្ទ មនុស្សដូច្នេះ ស្តេចមច្ចុរាជ រមែងតាមរកមិនឃើញ” ។

បុគ្គលដែលសម្រេចកន្តញាណហើយរមែងមិនកើតអវិជ្ជា តណ្ហា ឧបាទាន កម្ម ភពថ្មី និងខន្ធក្នុងអារម្មណ៍គ្រប់យ៉ាង ដែលឃើញច្បាស់ថារលត់ទៅដោយកន្តញាណ ដូច្នោះ ព្រះពុទ្ធអង្គទើបត្រាស់ថា **មច្ចុរាជា ន បស្សតិ** ( ស្តេចមច្ចុរាជ រមែងតាមរកមិនឃើញទេ ) ដោយសំដៅដល់ ការប្រាសចាកសេចក្តីស្លាប់មួយខណៈព្រោះមិនមានភពថ្មី និងខន្ធទាំងសំដៅដល់ការប្រាសចាកសេចក្តីស្លាប់ ដោយមិនសេសសល់ក្នុងភពថ្មី កាលសម្រេចអរហត្តផលហើយ គឺកាលមិនមានការកើតក្នុងភពថ្មី ការស្លាប់ក្នុងភពថ្មីក៏មិនមាន ។

**តុំ បារមីចលនិធិ ចតុរិហពាហុសត្តិហិ សុត្តរិ**
**ចិរំ ជនកោវ សិន្ធុំ សម្បន្នវិក្កមផលោសិ**
**យថា ច សោវ ឯវំ ជនា វិរិយតប្ផល មេធយន្ត ៕**

“ព្រះអង្គទ្រង់កសាងបារមី ហើយឆ្លងសមុទ្រ គឺសាគរ អស់កាលដ៏យូរ ដោយកម្លាំងដៃគឺសេចក្តីព្យាយាម មានអង្គ ៤ [ គឺ សាច់ ស្បែក សរសៃ ឈាម ] ដូចព្រះមហាជនកឆ្លងនូវសមុទ្រគឺសាគរ ទីងពន្ធុះផលសម្រេចនូវសេចក្តីព្យាយាមនោះ

ដោយពិត យ៉ាងណា សូមឲ្យជនទាំងឡាយ ចូរជាអ្នកប្រកប ដោយសេចក្ដីព្យាយាម និងពន្លះផលនៃសេចក្ដីព្យាយាម នោះចុះ ។!៙៚

# "ញាណទី ៦_៧"

## _ភយញាណ
## _អាទីនវញ្ញាណ
## _និព្វិទាញាណ

ន សីលព្វតមត្តេន ពាហុសច្ចេន វា បន
អថ វា សមាធិលាភេន វិវិត្តសយនេន វា ។
ផុសាមិ នេក្ខម្មសុខំ អបុថុជ្ជនសេវិតំ
ភិក្ខុ វិស្សាសមាបាទិ អប្បត្តោ អាសវក្ខយំ ។

"ម្នាលភិក្ខុ បើភិក្ខុមិនទាន់ដល់ នូវការអស់អាសវៈទេ កុំអាលទុកចិត្ត ដោយគុណត្រឹមតែសីលនិងវត្ត ឬដោយភាពជាអ្នកចេះដឹងច្រើន មួយទៀត ដោយការបានសមាធិ ឬដោយការដេកក្នុងទីស្ងាត់ ឬក៏ដោយគុណមានប្រមាណប៉ុណ្ណោះថា អាត្មាអញ

ពាល់ត្រូវនូវនេក្ខម្មសុខ ដែលបុថុជ្ជនមិនដែលជួបប្រសព្វ ដូច្នេះឡើយ" ។

# ភយញ្ញាណ អាទីនវញ្ញាណ និព្វិទាញ្ញាណ និង បដិបទាញ្ញាណទស្សនវិសុទ្ធិ

អ្នកដែលសម្រេចមគ្គញាណដ៏ចាស់ក្លា ហើយរមែងយល់ចិត្តថា រូបនាមក្នុងអតីតរលត់ទៅហើយ រូបនាមក្នុងបច្ចុប្បន្នកំពុងតែនឹងរលត់ទៅ និងរូបនាមក្នុងអនាគត ក៏នឹងរលត់ទៅដូចគ្នា ទើបកើតបញ្ញា ដែលឃើញច្បាស់ថា ជាវត្ថុដែលគួរហៅថា ភយញ្ញាណ ដូចគម្ពីរវិសុទ្ធិមគ្គពោលថា :

តស្ស" អតីតា សង្ខារា និរុទ្ធា ។ បច្ចុប្បន្នា និរុជ្ឈន្តិ ។ អានគតេ និព្វត្តនកសង្ខារាបិ ឯវមេវ និរុជ្ឈន្តី"តិ បស្សតោ ឯតស្មឹ ឋានេ ភយតុបដ្ឋានញាណំ នាម ឧបជ្ជតិ ។

" កាលអ្នកបដិបត្តិធម៌នោះ ឃើញថា សង្ខារដែលជាអតីត

បានរលត់ទៅហើយ ដែលជាបច្ចុប្បន្ន ក៏កំពុងតែរលត់ទៅដែរ សូម្បីសង្ខារ ដែលនឹងកើតឡើង ក្នុងអនាគតក៏នឹងរលត់ទៅដូចគ្នា ញាណនោះ ឈ្មោះថា **ភយញាណ** ដែលឃើញប្រាកដថា គួរខ្លាច រមែងកើតឡើង ក្នុងពេលនោះ" ។

**ភយញាណ** ជាបញ្ញា ដែលប្រដោយសេចក្ដីដែលគួរឲ្យខ្លាចក្នុងរូបនាមដែលរលត់ទៅគ្រប់ៗ ខណៈ ដែលឃើញ នឹងជាបញ្ញា ដែលសម្គាល់ថា គួរឲ្យខ្លាចក្នុងអារម្មណ៍ដែលពិចារណាទៀតផង ក្នុងខណៈនោះ ចិត្តរបស់អ្នកបដិបត្តិធម៌ រមែងមិនផូរផង់ដូចជាក្នុងខណៈខ្លះ ឧទយព្វយញាណ និងភង្គញាណ តែមិនមែនជាអ្នកប្រទូសរាយ ឬបីសាចទេ ត្រឹមតែជាការផូរផង់ ព្រោះដឹងច្បាស់តាមសេចក្ដីពិតថា រូបនាមជារបស់គួរភ័យ ដូចគម្ពីរវិសុទ្ធិមគ្គពោលថា :

**[១] ភយតុបដ្ឋានញាណំ បន ភាយតិ ន ភាយតីតិ ។ [២] ន ភាយតីតិ ។ [៣] តញ្ហិ អតីតា សង្ខារា និរុទ្ធា ។ បច្ចុប្បន្នា និរុជ្ឈន្តិ ។ អនាគតា និរុជ្ឈិស្សន្តីតិ តីរណមត្តមេវ ហោតិ ។**

"១. សួរថា : ភយញាណដែលប្រាកដច្បាស់នូវការគួរខ្លាច

ថា គួរខ្លាច ឬមិនគួរខ្លាចហ្ន៎?

២. ឆ្លើយថា : មិនគួរខ្លាច ។

៣. ព្រោះញាណនោះ ត្រឹមតែជាការយល់ថា សង្ខារដែលជាអតីត ក៏រលត់ទៅហើយ ដែលជាបច្ចុប្បន្ន ក៏កំពុងតែរលត់ទៅដែរ សូម្បីសង្ខារដែលនឹងកើតឡើងក្នុងអនាគត ក៏នឹងរលត់ទៅដូចគ្នា" ។

កាលភយញាណចាស់ក្លាហើយ អាទីនវញ្ញាណ រមែងកើតឡើង លំដាប់នោះអ្នកបដិបត្តិ រមែងមិនឃើញរូបនាមដែលកំណត់ដឹងថាជាវត្ថុល្អ ម្យ៉ាងទៀតទាំងមិនឃើញរូបនាមដទៃទិងភពដែលខ្លួនអនុមានដឹង និងការពិចារណា ការកើតឡើងជាវត្ថុដែលល្អស្អាត គេជួបតែការគួររង្កាស់ របស់វត្ថុដែលកំណត់ដឹង និងពិចារណា ការកើតឡើងរបស់ភយញាណ និងអាទីនវញ្ញាណ នេះពោលទុកក្នុងគម្ពីរបដិសម្ភិទាមគ្គថា :

[១] ឧប្បាទោ ភយន្តិ ភយតុបដ្ឋានេ បញ្ញា អាទីនវេញ្ញាណំ ។ បវត្តំ ភយន្តិ, និមិត្តំ ភយន្តិ, អាយូហនា ភយន្តិ បដិសន្ធិ ភយន្តិ, គតិ, និព្វត្តិ, ឧប្បត្តិ, ជាតិ, ជរា, ព្យាធិ, មរណំ, សោកោ, បរិទេវោ, ឧបាយាសោ ភយន្តិ ភយតុ-

ដ្ឋានេ បញ្ញា អាទីនវេ ញាណំ ។ [២] ឧប្បាទោ ទុក្ខន្តិ ភយតុដ្ឋានេ បញ្ញា អាទីនវេ ញាណំ បវត្តំ [៣] ឧប្បាទោ សាមិសន្តិ ។បេ។ ឧប្បាយាសោ សាមិសន្តិ ភយតុដ្ឋានេ បញ្ញា អាទីនវេ ញាណំ [៤] ឧប្បាទោ សង្ខារាតិ ។បេ។ ឧប្បាយាសោ សង្ខារាតិ ភយតុដ្ឋានេ បញ្ញា អាទីនវេ ញាណំ ។

"១. បញ្ញាក្នុងសេចក្ដីប្រាកដដោយការគួរភយថា :

-ការកើតឡើង [របស់រូបនាម] គួរភ័យ ជាអាទីនវញ្ញាណ ។

-និម្មិត្ត [ គឺសង្ខាររូបនាម] គួរភ័យ ជាអាទីនវញ្ញាណ ។

-សេចក្តីខ្វល់[គឺកុសលនិងអកុសល]គួរភ័យជាអាទីនវញ្ញាណ

-កាកើតថ្មី គួរភ័យ ជាអាទីនវញ្ញាណ ។

-គតិ [ ភូមិដែលទៅកើត ដោយភាពជាសត្វនរក ប្រេត អសុរកាយ សត្វតិរច្ឆាន ការកើតជាមនុស្ស ឬទេវតា] គួរភ័យ ជាអាទីនវញ្ញាណ ។

-ការកពូន ( និព្វត្តិ )ឲ្យកើតឡើង ជាអាទីនវញ្ញាណ ។

-ជាតិ គួរភ័យ ជាអាទីនវញ្ញាណ ។

-ជរា គួរភ័យ ជាអាទីនវញ្ញាណ ។

-ព្យាធិ គួរភ័យ ជាអាទីនវញ្ញាណ ។

-មរណៈ គួរភ័យ ជាអាទីនវញ្ញាណ ។

-សេចក្តីសោយសោក ( សោក ) គួរភ័យ ជាអាទីនវញ្ញាណ ។

-ការយំរៀបរាប់ ( **បរិទេវ** ) គួរភ័យ ជាអាទីនវញ្ញាណ ។

-ការបន្តៀតបន្តល់ (ទុក្ខទោមនស្ស) គួរភ័យ ជាអាទីនវញ្ញាណ ។

**២. បញ្ញាក្នុងការប្រាកដដោយការឃើញថាគួរភ័យ :**

-ការកើតឡើង [របស់រូបនាម] ជាទុក្ខ ជាអាទីនវញ្ញាណ ។

-ការប្រព្រឹត្តទៅ [របស់រូបនាម] ជាទុក្ខ និងជាអាទីនវញ្ញាណ ។ល។

-ការបន្តៀតបន្តល់ចិត្ត ជាទុក្ខ ជាអាទីនវញ្ញាណ ។

៣. បញ្ញាក្នុងការប្រាកដ ដោយការគួរភ័យថា :

-ការកើតឡើង [របស់រូបនាម] ជាការលាយឡំដោយអាមិស ជាអាទិនវញ្ញាណ ។ល។

-ការបន្តៀតបន្តល់ចិត្តជាការលាយឡំដោយអាមិស ជាអាទីនវញ្ញាណ ។

៤. បញ្ញាក្នុងការការប្រាកដដោយការគួរភ័យថា:

-ការកើតឡើង [ របស់រូបនាម] ជាសង្ខារ [ ដែលមិនសុខស្ងប់] ជាអាទីនវញ្ញាណ ។ល។

-ការបង្ហៀតបង្អួលចិត្តជាសង្ខារ ជាអាទីនវញ្ញាណ ។

[ ក្នុងភាគៈទី ៣ សេចក្តីថា " ការកើតឡើង[របស់រូបនាម] ជាលាយឡំដោយអាមិស ជាអាទីនវញ្ញាណ" មានន័យថា ផ្ទះដែលមានអណ្តាតភ្លើង ក្នុងរដូវក្តៅ រមែងធ្វើឲ្យកន្វល់ថា ភ្លើងនឹងឆេះផ្ទះយ៉ាងណា រូបនាមដែលលាយឡំដោយកាមគុណ និងវដ្តទុក្ខ ដែលជាអាហាររបស់ភ្លើងកិលេស ក៏គួរកន្វល់ដូច្នោះ ដៃដែលប្រឡាក់អាហាររមែងគួរខ្ពើស យ៉ាងណា រូបនាមដែលលាយដោយអាហារគឺកិលេសដ៏ស្មោកគ្រោក ក្តៅអន្ទះអន្ទែង ក៏គួរខ្ពើស ដូច្នេះ] ។

អ្នកដែលឃើញច្បាស់នូវការកើតរលត់របស់រូបនាមក្នុងបច្ចុប្បន្ន និងវិបស្សនាចិត្ត ដោយភង្គញាណ ហើយក្នុងខណៈខ្លះ អាចពិចារណាដល់បដិសន្ធិ ដែលជាការកើតថ្មី របស់រូបនាមក្នុងភពនេះហើយ ដឹងច្បាស់ថា គួរភ័យ និងមិនមែនជាវត្ថុដែលល្អស្អាត ការឃើញច្បាស់យ៉ាងនេះជា និងអាទីនវញ្ញាណទៅព្រមគ្នា គប្បីជ្រាប់ការកើតឡើងរបស់ញាណទាំងពីរ ហើយក្នុងសេចក្តីដទៃតាមន័យ ដែលពោលនេះ មានសេចក្តីពិសេសក្នុងរឿងការប្រព្រឹត្តទៅរបស់រូបនាម ( **បវត្ត** ) និម្មិត្ត គឺសង្ខាររូប

នាម ( **និមិត្ត** ) ថាជាវត្ថុដឹងដោយជាក់ច្បាស់ ដូចការកើតឡើងរបស់រូបនាម មិនមែនជាវត្ថុ ដែលអនុមានដឹងដោយការពិចារណា ។

ក្នុងទាំង ១៤ បទ ផ្តើមពីការកើតឡើងរបស់រូបនាម ( ឧប្បាទ ) ទៅរហូតដល់ការចង្អៀតចង្អល់ចិត្ត ( **ឧបាយាស** ) ៥ បទដំបូង គឺការកើតឡើងរបស់រូបនាម ( **ឧប្បាទ** ) ការប្រព្រឹត្តទៅរបស់រូបនាម ( **បវត្ត** ) និមិត្តគឺសង្ខាររបស់រូបនាម ( **និមិត្ត** ) សេចក្តីខ្វល់ខ្វាយ គឺកុសលនិងអកុសល ( **អាយូហន** ) ការកើតថ្មី ( **បដិសន្ធិ** ) សម្តែងអារម្មណ៍ ដែលជាការកើតរបស់ភយញាណ និងអាទីនវញាណចំណែកបទ ដ៏សេស ១០ បទ មានភូមិ ដែលទៅកើត ( **គតិ** ) ជាដើម ពោលទុកដើម្បីសម្តែងពាក្យវេវចនៈដូចពោល ដោយមានបទ ដូចគ្នា គឺ ការបង្កើត ( **និព្វត្តិ** ) ការកើត ( **ជាតិ** )=ការកើតឡើងរបស់រូបនាម ( **ឧប្បាទ** ) និងការកើតថ្មី ( **បដិសន្ធិ** ) ។

ភូមិដែលទៅកើត ( **គតិ** ) និងការចូលដល់ ( **ឧប្បត្តិ** ) =ការប្រព្រឹត្តទៅរបស់រូបនាម ( **បវត្ត** ) ។

ការចាស់ ( ជរា ) ជាដើម **វេន** =និម្មិត្ត គឺសង្ខាររូបនាម ( **និម្មិត្ត** ) ។

ពីរភាគៈទាំង ៤ ភាគៈខាងដើម ភាគៈដំបូងសម្តែងការកើតឡើង របស់ភយញាណដោយពាក្យថា **ភយំ** ( គួរភ័យ ) ភាគៈក្រោយ សម្តែងការកើតឡើងរបស់អាទីនវញាណ ដោយពាក្យថា **ទុក្ខ** ( ជាទុក្ខ ) **សាមិសំ** ( លាយដោយអាមិស ) និងសង្ខារ ( **សង្ខារ** ) ដូចគម្ពីរមហាដីការបស់វិសុទ្ធិមគ្គពោលថា:

**[១]តត្ថ ភយាការេន បវត្តំ ញាណំ ភយតុបដ្ឋានញាណំ ។**

**[២] ឥតរាការេន បវត្តំ អាទីនវញាណន្តិ ទដ្ឋព្វំ ។**

"១. ក្នុងរឿងនោះ បញ្ញាដែលប្រព្រឹត្តទៅដោយអាការៈគួរភ័យ ឈ្មោះថា **ភយញាណ** ដែលឃើញច្បាស់ថាគួរភ័យ ។

២. ញាណ ដែលប្រព្រឹត្តទៅដោយជាប់ដោយអាការៈដទៃ គប្បីជ្រាប់ថា ជាអាទីនវញាណ" ។

អ្នកបដិបត្តិធម៌ ដែលឃើញច្បាស់ការកើតឡើងរបស់រូបនាមថា គួរភ័យ ជាទុក្ខលាយឡំដោយអាមិស និងជាសង្ខារ ដែលមិនសុខស្ងប់ រមែងកើតបញ្ញាអនុមានដឹងព្រះនិព្វានដោយ

លក្ខណៈផ្ទុយគ្នា ជាការមិនកើតឡើងរបស់រូបនាម ការប្រព្រឹត្ត ទៅរបស់រូបនាម ការមិនមាននិម្មិត្ត គឺសង្ខាររូបនាម ការមិន ខ្វល់ខ្វាយ គឺកុសល និងអកុសល និងការមិនកើតថ្មី ជាការ ក្សេម ជាសុខ ដែលរួចផុតពីអាមិស គឺវដ្តទុក្ខ កាមគុណ និង កិលេស ដូច្នោះ ក្នុងគម្ពីរបដិសម្ភិទាមគ្គ ទើបពោលដល់ការ ដឹងក្នុងផ្លូវនៃការសម្រេចនូវសន្តិបទ ៤ ការៈ ថា :

[១] អនុប្បាទោ ខេមន្តិ សន្តិបទេ ញាណំ ។បេ។ [២] អនុប្បាទោ សុខន្តិ សន្តិបទេ ញាណំ ។បេ។ [៣] អនុប្បាទោ និរាមិសន្តិ សន្តិបទេ ញាណំ ។បេ។ [៤] អនុប្បាទោ និព្វានន្តិ សន្តិបទេ ញាណំ ។បេ។

“១. សេចក្តីដឹងថា ការមិនកើតឡើងជាសុខក្សេម ជាការ ដឹងក្នុងផ្លូវសម្រេចនូវសន្តិបទ ។ល។

២. សេចក្តីដឹងថា ការមិនកើតឡើងជាសុខ ជាការដឹង ក្នុងផ្លូវសម្រេចនូវសន្តិបទ ។ល។

៣. សេចក្តីដឹងថា ការមិនកើតឡើងជាការមិនមានអាមិស ជាការដឹងក្នុងផ្លូវសម្រេចនូវសន្តិបទ ។ល។

៤. សេចក្តីដឹងថា ការមិនកើតឡើងជានិព្វាន ជាការដឹងក្នុងផ្លូវសម្រេចនូវសន្តិបទ ។ល។"

ម្យ៉ាងទៀត ការដឹងក្នុងផ្លូវសម្រេច នៃការសម្រេចសន្តិដែលសម្តែងទុកក្នុងភារៈទាំង ៤ នេះ មិនមែនជាភយញ្ញាណ ឬអាទីនវញ្ញាណ តែជាអានិសង្សដែលកើតឡើងពីញាណទាំង ២ ខាងដើម ។

កាលបើអាទីនវញ្ញាណចាស់ក្លាហើយ និព្វិទាញ្ញាណ គឺបញ្ញាដែលឃើញច្បាស់ការនឿយណាយ រមែងកើតឡើង ក្នុងខណៈនោះ អ្នកបដិបត្តិរមែងយល់ថា រូបនាមដែលកំណត់ដឹងគួរនឿយណាយ ព្រោះឃើញច្បាស់នូវទោសដោយអាទីនវញ្ញាណនោះឯង សូម្បីនឹងពិចារណាដល់វត្ថុណានីមួយ ក៏ដឹងច្បាស់ថាគួរនឿយណាយ សូម្បីសេចក្តីរីករាយ ក៏នៅតែគួរនឿយណាយ ការប្រាកដរបស់ញាណនេះ ត្រាស់ទុកក្នុងគម្ពីរធម្មបទថា :

សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។
សព្វេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ

អថ និព្វិន្ទតិ ទុក្ខេ ឯសស មគ្គោ វិសុទ្ធិយា ។
សព្វេ សង្ខារា អនត្តាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯសស មគ្គោ វិសុទ្ធិយា ។

" កាលណា បុគ្គលឃើញច្បាស់ដោយបញ្ញាថា សង្ខារទាំងពួងមិនទៀង កាលនោះ គេរមែងនឿយណាយក្នុងទុក្ខ [បញ្ចក្ខន្ធ]ការនឿយណាយក្នុងទុក្ខនោះ ជាផ្លូវនៃសេចក្តីបរិសុទ្ធ។

កាលណា បុគ្គលឃើញច្បាស់ដោយបញ្ញាថា សង្ខារទាំងពួងជាទុក្ខ កាលនោះ គេរមែងនឿយណាយក្នុងទុក្ខ [បញ្ចក្ខន្ធ] ការនឿយក្នុងទុក្ខនោះ ជាផ្លូវនៃសេចក្តីបរិសុទ្ធ ។

កាលណា បុគ្គលឃើញច្បាស់ដោយបញ្ញាថា សង្ខារទាំងពួងជាអនត្តា កាលនោះ គេរមែងនឿយណាយក្នុងទុក្ខ [បញ្ចក្ខន្ធ] ការនឿយក្នុងទុក្ខនោះ ជាផ្លូវនៃសេចក្តីបរិសុទ្ធ" ។

[ កន្ទះគាថាថា សព្វេសង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ ( កាលណា បុគ្គលឃើញច្បាស់ដោយបញ្ញាថា សង្ខារទាំងពួងមិនទៀង ) មានន័យថា ក្នុងខណៈដែលកន្ត្រាញាណចាស់ក្លា អ្នក

បដិបត្តិធម៌រមែងឃើញច្បាស់ដោយអនុមានញាណ ដែលស្រប តាមបច្ចក្ខញាណ ថា សង្ខារគឺរូបនាមទាំងពួងមិនទៀង ។

បាទគាថាថា **អថ និព្វិន្ទតិ ទុក្ខេ** ( កាលនោះ គេរមែងនឿយណាយក្នុងទុក្ខ ) មានន័យថា ក្នុងពេលនោះ គេរមែងនឿយណាយ ដោយនិព្វិទាញាណ ក្នុងទុក្ខគឺរូបនាមដែលខ្លួនឃើញថាគួរភ័យ និងជាទោសដោយភយញាណ និងអាទីនវញ្ញាណ ។

ក្នុងគម្ពីរមហាដីការបស់វិសុទ្ធិមគ្គ ( ភាគ ១ ទំព័រ ១៣ ) បានអធិប្បាយរឿងនេះ មួយន័យទៀតថា : កន្លះគាថាថា **សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ** ( កាលណា បុគ្គលឃើញច្បាស់ដោយបញ្ញាថា សង្ខារទាំងពួង មិនទៀង ) មានន័យថា កាលអ្នកបដិបត្តិធម៌ ឃើញច្បាស់ថា សង្ខារទាំងពួងមិនទៀង ដោយសម្មសនញាណ គេរមែងនឿយណាយក្នុងទុក្ខ ពេលខាងក្រោយដែលសម្រេចឧទយព្វយញាណ ជាដើមហើយ តាមន័យនេះ ពាក្យថា អថ ប្រែថា " ក្នុងពេលខាងក្រោយ" ន័យដំបូងប្រែថា " កាលនោះ"] ។

វិបស្សនាញាណទាំង ៣ គឺ **ភយញាណ អាទីនវញាណ**

និងនិព្វិទាញាណ មានលក្ខណៈឃើញទោសរបស់រូបនាមដូចគ្នា ដោយសេចក្ដីថាជា ញាណលំដាប់ទន់ខ្ចី កណ្ដាល នឹងចាស់ក្លាតាមលំដាប់ដូច្នោះ កាលបើភយញាណ កើតឡើងហើយ មិនយូរទើបមានអាទីនវញាណ និងនិព្វិទាញាណប្រាកដដល់បុគ្គលខ្លះ ក្រៅពីនោះ អ្នកខ្លះដែលមានលំដាប់ញាណឈានទៅមុខឆាប់ក៏អាចជួបលក្ខណៈភ័យខ្លាច ឃើញទោស ឬនឿយណាយត្រឹមយ៉ាងណា ឬទាំងយ៉ាង ដូចគម្ពីរវិសុទ្ធិមគ្គពោលថា :

[១] តេនាហុ បោរាណា "ភយតុដ្ឋានំ ឯកមេវ តីណិ នាមានិ លភតិ ។ សព្វសង្ខារេ ភយតោ អទ្ទសាតិ ភយតុដ្ឋានំ នាម ជាតំ ។ តេសុយេវ សង្ខារេសុ អាទីនវំ ឧប្បាទេតីតិ អាទីនវានុបស្សនា នាម ជាតំ ។ តេសុយេវ សង្ខារេសុ និព្វិន្ទមានំ ឧប្បន្នន្តិ និព្វិទានុបស្សនា នាម ជាតន្តិ" ។

[២] បាឡិយម្បិ វុត្តំ "យា ច ភយតុដ្ឋានេ បញ្ញា, យញ្ច អាទីនវេ ញាណំ, យា ច និព្វិទា, ឥមេ ធម្មា ឯកត្ថា, ព្យញ្ជនមេវ នានន្តិ" ។

"១. ដូច្នោះ បោរាណាចារ្យ ទើបពោលថា ភយញាណ

តែមួយនោះ មានឈ្មោះ ៣ យ៉ាង គឺ :

-ឈ្មោះថា ភយញ្ញាណ ព្រោះឃើញសង្ខារទាំងពួងគួរភ័យខ្លាច ។

-ឈ្មោះថា អាទីនវញ្ញាណ ព្រោះឲ្យឃើញទោសក្នុងសង្ខារ [ ដែលឃើញថា គួរភ័យ] ។

-ឈ្មោះថា និព្វិទាញ្ញាណ ព្រោះបង្កើតនូវការនឿយណាយក្នុងសង្ខារ [ ដែលឃើញទោសហើយ] នោះ ។

២. សូម្បីក្នុងព្រះបាលី [ បដិសម្ភិទាមគ្គ] ក៏ពោលថា បញ្ញាណា ក្នុងខណៈឃើញថា គួរភ័យ បញ្ញាណាក្នុង [ ការឃើញ]ទោស និងបញ្ញាណាដែល[ ឃើញសេចក្តី]នឿយណាយ បញ្ញា ទាំងនេះមានអត្ថធម៌ដូចគ្នា តែផ្សេងគ្នាដោយសព្ទ”។!០៚

ជលេន ភវតិ បង្កំ ជលេនេវ វិសុជ្ឈតិ
ចិត្តេន ភវតិ បាបំ ចិត្តេនេវ វិសុជ្ឈតិ ។

“ភក់កើតអំពីទឹក រមែងស្អាតដោយទឹកយ៉ាងណា បាបកើតអំពីចិត្ត រមែងផូរផង់ដោយចិត្តនោះ ដូច្នោះ” ។

**“ចប់ញាណទី ៨”**

# អានិសង្សនៃការចំរើនសតិប្បដ្ឋាន ៤

យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិប្បដ្ឋានេ ឯវំ ភាវេយ្យ សត្ត វស្សានិ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា ៚

"ម្នាលភិក្ខុទាំងឡាយ សូម្បីបុគ្គលណាមួយ បានចំរើនសតិប្បដ្ឋាន ទាំង ៤ អស់ ៧ ឆ្នាំ តាមលំដាប់នៃវិធីចំរើន ដែលតថាគតបានពោល ហើយយ៉ាងនេះ បណ្ដាផលទាំងឡាយ ២ ផលណាមួយ ក៏គង់នឹងបាន សម្រេចដល់បុគ្គលនោះ តាមសេចក្ដីប្រាថ្នាដោយពិត គឺថានឹងបាន សម្រេចនូវភាវៈជាព្រះអរហន្តក្នុងបច្ចុប្បន្នទាន់ភ្នែក ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេចនូវភាវៈជា ព្រះអនាគាមិបុគ្គលពុំខានឡើយ" ។

សម្រាប់ចែកជាធម្មទានក្នុងឱកាសពុទ្ធសករាជ ២៥៥២